# រឿង

# បំណុលជីវិត

ប្រលោមលោកមនោសញ្ចេតនា

ដោយ អ្នកស្រី កែវ ចន្ទ័បូរណ៍
P.O.Box 600279
Saint Paul, MN 55119
USA
khmervissal@yahoo.com
www.angkorwat.com

CHANBOKEO.COM

ខែមិនា ២០០០

រក្សាសិទ្ធិគ្រប់យ៉ាង

# ស្នាដៃខ្លះៗរបស់អ្នកស្រីកែវចន្ទ័បូរណ៌

១- រឿង សំនៀងស្នេហ៍កវី
២- រឿង និស្ស័យស្នេហ៍
៣- រឿង ផ្កាយវង្វេងមេឃ
៤- រឿង ស្នាមញញឹម
៥- រឿង កុលាបស្ទឹងខៀវ
៦- រឿង ក្លិនផ្កាមាលតី
៧- រឿង លិខិតមរតកសម្ងាត់
៨- រឿង បំណុលជីវិត
៩- រឿង ចរណៃដួងទ័យា
១០- រឿង អំបែងអណ្តែត
១១- រឿង ស្នេកចាកផុតទៅ
១២- រឿង តន្ត្រីបេះដូង
១៣- រឿង សារាណីយមាតា
១៤- រឿង ទារុណដួងចិត្ត
១៥- រឿង បើសិននៅមានថ្ងៃស្នេក
១៦- រឿង លំអងផ្កាស្នេហ៍
១៧- រឿង ត្រៃមិត្ររតននារី
១៨- រឿង ខ្មើយវាសនា
១៩- រឿង បើសិនអាចបង្វិលផែនដី
២០- រឿង សីវបុរេកាល
២១- រឿង មេឃដ៏សក្តិសិទ្ធិ
២២- រឿង មួយពាន់ទំព័រ
២៣- រឿង អាមេរិកដែនដីមាស
២៤- រឿង អាធ្រាតថ្ងៃរះ
២៥- រឿង បក្សីស្នួនសុបិន
២៦- រឿង ម្លប់អសោក
២៧- រឿង ពិជេដ្ឋភានុមា
២៨- រឿង ផ្ការីកក្រៅសួន
២៩- រឿង មន្តស្នេហ៍ស្រីខ្មៅ
៣០- រឿង អនង្គលាភា
៣១- រឿង ពណ្ណរាយពេជ្រ
៣២- រឿង សារិកា
៣៣- រឿង ផ្ការាជបឹងរាំង
៣៤- រឿង នភាមណី
៣៥- រឿង ស្រីនាថភ្លួងមាលា
៣៦- រឿង វាយោដួងចិត្ត

CHANBOKEO.COM

# សូមឧទ្ទិសចំពោះ

- លោក មេង សួង សុវណ្ណធី ជាស្វាមី
- កុមារី **សុវណ្ណធី ធម្មិកា បារមីបុណ្យ** ជាបុត្រីទោល
- លោកឪពុក ប៊ុនថង និងអ្នកម្តាយ កែវយឿង
- លោកឪពុកក្មេក មេងសួង និងអ្នកម្តាយក្មេក កូវសារ៉ាន់
- មិត្តសំលាញ់ ប៉ក់ដារិនី និង មិត្តសំលាញ់ លីតាយហុង ដែលជាមិត្តរួមថ្នាក់ចំនួន១២ឆ្នាំ។
- លោកឃីលឿង និងភរិយា   លោកម៉ក់សកលវរៈ និងភរិយា
- លោក តារា ហុងឃី ធារុណ សុភក្តិ ផល្លីន   ណារ៉ុង ផល្លី ជា-ស្រី និង វិរៈ ព្រម ទាំងបុគ្គលិកនៅសណ្ឋាគារសៀមរាបថោន ក្រុងសៀមរាប
- លោក ពៅសុគុណ និងមាតាបិតា ព្រមទាំងក្រុមគ្រួសារ អាហារដ្ឋានសែនមនោរម្យ សង្កាត់ព្រែកលាប ភ្នំពេញ។
- លោក អ៊ុម សុនាថ កាសែតកោះសន្តិភាព ផ្នែកទំនាក់ទំនងអន្តរជាតិ
- លោក ជិន សៅរិន កាសែតកោះសន្តិភាព ផ្នែកគ្រប់គ្រងគេហ៏ទំព័រអ៊ិនធឺណិត




អ្នកស្រី កែវ ចន្ទ័បូរណ៏

រដ្ឋមិនីសូតា សហរដ្ឋអាមេរិក

khmervissal@yahoo.com

www.angkorwat.com

## វាចាអ្នកនិពន្ធ

រឿង បំណុលជីវិត បានបកស្រាយនូវចំណងមនោសញ្ចេតនារវាងបុគ្គលពីររូប ដែលកំពុងធ្លាក់ក្នុងសភាពអស់សង្ឃឹមបំផុតក្នុងជីវិត ម្នាក់ជាបុត្រអភិជន ម្នាក់ ទៀតជាជនទុរគត ។ ប៉ុន្តែ ដោយសារចំណងសម្ពន្ធ័ដួងចិត្តដ៏មុតមាំរបស់គេ ចំពោះ គ្នាទៅវិញទៅមក គេក៏អាចស្វែងរកពន្លឺនៃសេចក្តីសង្ឃឹមរបស់គេជាថ្មីមួយទៀត យ៉ាងភ្លឺស្វាង ។

នាងខ្ញុំសង្ឃឹមថា ប្រិយមិត្តនឹងបានទទួលសេចក្តីសុខក្សេមក្សាន្តក្នុងអារម្មណ៏ ក្រោយពីបានអានសាច់រឿងប្រលោមលោកមួយនេះ ហើយសូមជួយប៉ះប៉ូវនូវ អក្ខរាវិរុទ្ធទាំងឡាយ ដែលកើតមានដោយអចេតនានៅក្នុងសំណៅរឿងមួយក្បាល នេះអោយបានប្រពៃផង ។ អ្នកនិពន្ធខ្ញុំសូមទទួលនូវ មតិយោបល់ពីប្រិយមិត្តអ្នក អាន តាមរយៈ អស័យដ្ឋានដូចខាងក្រោម :

អ្នកស្រីកែវចន្ទ័បូរណ៏
P.O.Box 600279
Saint Paul, MN 55119
USA
Khmervissal@yahoo.com
www.angkorwat.com

សូមប្រិយមិត្តបានជួបប្រទះតែវឌ្ឍនសុខ និងសុវត្ថិភាពរាល់ទិវារាត្រី ។

អ្នកនិពន្ធ
អ្នកស្រី កែវ ចន្ទ័បូរណ៏
ខែមិនាឆ្នាំ២០០៦

CHANBOKEO . COM

# កំណាព្យ

## ខ្លែង

ខ្លែងអើយខ្លែងហោះចោះវេហាស៍　　ត្រដែតកាយាខ្ពស់ពេកក្រៃ
ខ្លែងហោះអណ្តែតឆ្ងាយពីដី　　ខ្លែងជោរណាស់អីអំនួតអង្គ ។
គិតថាគ្មានគេណាសំណាង　　វាសនាបានឡើងឆ្ពោះតម្រង់
ខ្ពសកប់វេហាស៍ដូចខ្លែងអង្គ　　ឯមេឃនោះហោងស្មើរូបអ្នក ។
តែខ្លែងភ្លេចគិតថាខ្លួនខ្ពស់　　ត្រដែតកាយហោះថ្កើងប្រត្យក្ស
ពឹងកំលាំងខ្យល់ផ្លុំបណ្តាក់　　រុញច្រាណរូបអ្នកផុតពីដី ។
ភ្លេចថានៅខ្ពស់អ្នករងា　　លង់ភាពកំព្រាឯកាក្រៃ
ចាកភាពកក់ក្តៅនៅលើដី　　មានញាតិប្រុសស្រីចោមសាទរ ។
ខ្លែងហើរខ្ពស់ពិតត្បិតព្រោះខ្សែ　　ជាប់មាំជួយថែបានយ៉ាងល្អ
ភ្ជាប់ខ្លែងមកដីមានអ្នកឈរ　　ទប់ខ្លែងបវរមានលំនឹង ។
បើសិនខ្វះខ្យល់ខ្វះខ្សែមាំ　　ខ្វះអ្នកឈរចាំជួយតម្រង់
ម្ល៉េះសមខ្លែងដាច់រសាត់អង្គ　　អណ្តែតឆ្ងាយហោងធ្លាក់ដីវិញ ។
ច្នេះ ឱ! ខ្លែងអើយកុំភ្លេចខ្លួន　　ឡើងខ្ពស់គួរគន់គិតទន្ទេញ
យសអ្នកអណ្តែតព្រោះញាតិមិញ　　គ្រប់គ្នាបំពេញជាសាមគ្គី ។

CHANBOKEO.COM

## ទំនួញដើមបូព្រឹក្ស

បូព្រឹក្សនឹកគិតសង្វេគអង្គ        ថ្ងៃនេះបែរលង់ភាពឯកា
ត្បិតពួកចោរព្រៃក្រៃមហា        លួចកាប់ព្រឹក្សាជាញាតិមិត្ត។
ម្សិលមិញមានផ្តល់គគីរផ្អឹក        នាងនួនសន្ទឹកបេងប្រណិត
កកោះឈើទាលល្អវិចិត្រ        ខ្លុងត្បែងជាមិត្តកំដរគ្នា។
ផ្លូវព្រៃបាត់អស់ឈើល្អ        បូព្រឹក្សនៅឈរយំរងា
ពីដើមមានមិត្តដុះត្រៀបត្រា        ថ្ងៃនេះធិតាឯកាអង្គ។
បូព្រឹក្សទូញយំស្រណោះខ្លួន        វិយោគស្រពោនក្នុងអន្លង់
ព្រៃខ្មែរស្គុកស្គម្ភបែរក្លាយបង់        ពាយហើយបេងផ្តល់នាងនួនផ្អឹក។
ឈើខ្លឹមរយឆ្នាំដាំប្រវត្តិ        ជាតិខ្មែរបែរភ្លាត់ភ្លេចបូព្រឹក្ស
ដំណៃលឈើខ្មែរល្អពន្លឹក        គគីរបេងផ្អឹកថ្លៃប្រណិត។
បូព្រឹក្សប្រណម្យអង្វរខ្មែរ        អ្នកក្រុងអ្នកស្រែសូមប្រែចិត្ត
ឈប់បំផ្លាញព្រៃឈើប្រសិទ្ធ        ថែសម្បត្តិជាតិដែលកាន់តែស្ងួចទៅហើយ....

CHANBOKEO.COM

# ក្រមា

តំបន់ខ្លះហៅជាកន្សែង ជួនខុសកន្លែង ហៅក្រមា
យកមកជូតរុំជុំកេសា ចេញចរយាត្រាក្រោមថ្ងៃក្តៅ ។
ជួនកាលគេយកមកបង់ក រលាស់ចេញមកក៏បក់មូសទៅ
ជួនយកជូតញើសល្អពេកកូវ ជួនរុំខ្លួននៅជួសខោខ្លី ។
កាលខ្លះដូនចាស់យកចងពុង ជួនក្មេងគួចថង់ដាក់ចំណី
ជួនធ្វើសំពាយដើរកាត់ព្រៃ ជួនឆ្វាយរង្វេលទូលកញ្ជើ ។
មានកាលគេយកធ្វើអង្រឹង យោលកូនព្រលឹងលក់ប្រហើរ
ជួនកាលដណ្តប់កាយប្រសើរ ក្រមាបំរើអស់ខេមរា ។
សំខាន់បំផុតខែកក្តីក អាំងភ្លើងពេលព្រឹកខ្យល់រងា
តំកង់អាំងភ្លើងរុំក្រមា កក់ក្តៅកាយាសុខក្សេមក្សាន្ត ។
ពេលមានទុក្ខព្រួយស្រក់ទឹកភ្នែក ក្រមារំលែកទុក្ខពីប្រាណ
ជូតស្ងួតទឹកភ្នែកវិយោគស្រាន្ត ក្រមាកល្យាណប្រោសចិន្តា ។
មិត្តមួយយ៉ាងល្អកម្រក ក្រមានាំជោគដល់ខេមរា
អ្នកស្រុករស់ក្សាន្តជុំគ្រួសារ បានគុណក្រមាបំរើរៀងអើយ ។

ត្រិះរិះ ៖ កើតជាតិអ្នកក្រ តើនរណាមួយទៅដែលថាមិនស្គាល់ គុណក្រមា?

CHANBOKEO.COM

# ទឹកភ្នែកព្រះព្រហ្ម

(២០០៥)

ព្រះព្រហ្មយំសោកបោកអាត្មា ទួញថា ឱ កូនសំលាញ់ម្តាយ
ពេលអ្នកបានសុខគ្រប់ៗកាយ ម្តេចកូនភ្លេចម្តាយឈប់បួងសួង?
ប៉ុន្តែពេលកូនជួបទុក្ខសោក តាំងនាំគ្នាមករកម្តាយលួង
អង្វរបែបទ់មានផ្កាភ្លួង ធូបទៀនចេកដូងសព្វសារពើ។
ពេលបានជួបសុខ កូនក៏ស្វាត់ ពេលជួបវិបត្តិ ស្តី ម៉ែត្អើស៍
ថាម៉ែភ្លេចកូនមិនអើពើ កូនអើយ! ម៉ែស្ទើរខកចិន្តា។
ដឹងទេហ៏ណ៎កូន ម៉ែសោកសៅ បាត់រូបកូនទៅ ម៉ែទុក្ខា
ម្តាយនៅម្នាក់ឯងរែងសោកា រង់ចាំពេលណាកូនមករក។
អនិច្ចា! លុះគ្រាកូនមកដល់ អ្នកបែរនាំខ្វល់នាំទុក្ខសោក
ឱ្យម្តាយកកាយស្រាយជ័យជោគ ស្វះស្វែងភព្វមកអោយកូនវិញ។
ចំណែកសុខទុក្ខរបស់ម្តាយ កូនម៉ែបែរក្លាយភ្លេចគិតមិញ
ថាម៉ែរង់ចាំកូនបំពេញ បុណ្យកុសលវិញទើបធមិម្តាយសក្តិសិទ្ធិ...!

CHANBOKEO.COM

# បណ្ដាំកវី

(២០០៥)

បើចង់បានផ្លែត្រូវឆ្អែតពេជ្រ　　ពីថ្មគគ្រិចទៅភ្លឺថ្លា
ចង់បានកេរ្ដិ៍ឈ្មោះខ្ពស់សក្កា　　ចូលខ្លួនសិក្សាផុតល្ងង់ខ្លៅ ។
ដាវដែលមុតល្អត្បិតដុតដំ　　សំលៀងមុតមាំផ្សំភ្លើងក្ដៅ
ប្រាជ្ញត្បិតតម្រេះចេះជ្រាលជ្រៅ　　កោសល្យឆ្អិនឆ្អៅត្បិតឧស្សាហ៍ ។
រពីសដៃដាំបានផលបេះ　　បើដេកអាំងផេះផ្អៃឈឺផ្សា
ធ្វើស្រែមើលដីទឹកសព្វការ　　ពាក្យចាស់ថែងចារមានតម្លៃ ។
កុំសើចមុនគេ ប្រយត្ន័ជូន　　ត្រូវសើចខកខ្លួនមិនប្រពៃ
មុនញាក់ចិញ្ចើម ចូរឃ្នាតខ្ចី　　គិតមើលវែងខ្លីអស់ន័យអាថ៌ ។
កុំអាងអ្នកក្រៅជាដៃជើង　　ត្រូវពឹងខ្លួនយើងគ្រប់កិច្ចការ
បើសេពមិត្តពាលខូចជតា　　សេពប្រាជ្ញថ្កើងការឆ្លងដល់ត្រើយ ។
សាងអំពើល្អ ក៏មិនស្វាត់　　សាងទោសវិបត្តិ ក៏មិនស្បើយ
រន្ទឺកេរ្ដិ៍ឈ្មោះមិនស្វាត់ឡើយ　　ទុកអ្នកទៅហើយកំពង់នៅ ។
កវីជូនពាក្យបីបួនម៉ាត់　　ក្រែងលោបានស្ដាត់ប្រាប់កូនចៅ
សាងអំពើល្អយូរលង់ទៅ　　គង់ត្រាយនាំផ្លូវទៅរុងរឿង ។

CHANBOKEO.COM

# ល្អនិងអាក្រក់ (២០០២)

គ្រប់គ្នាចង់បានកេរ្តិ៍ឈ្មោះល្អ ល្បីល្បាញបវរកាត់ស្រែក្រុង
តែឈ្មោះអាក្រក់ល្អក់ខ្មៅយង់ ម្នាក់ៗគេចវង់ខ្លាចពារប៉ះ ។
អនិច្ចា! លុះដល់ពេលប្រព្រឹត្ត មារយាទចរិតបែរប្តូរផ្លាស់
ដើរចូលអាក្រក់មិនបំរះ ជួបល្អផាយណាស់ប្រាសរាប់យោជន៍ ។
បើពើបស្រីស្រាល្បែងស៊ីសង សប្បាយអឹងកងគ្មានអ្វីដូច
វែងត្រអាលត្រេកដេកច្រៀងហួច លុះកេរ្តិ៍ឈ្មោះខូចតាំងម៉្ងម៉ៅ ។
ពេលគេប្រទុស្ត យើងក៏ខឹង សញ្ជប់សញ្ជឹងគិតសែនក្តៅ
ដល់ពេលយើងវិញជាន់គេទៅ សប្បាយពេកក្រៃគ្មានគិតឡើយ ។
ពេលគេណែនាំ យើងប្រកែក មាត់ធំហារស្រែកតបខ្មើយៗ
សេរីភាពយើងកុំត្រួតរើយ ម៉ែឪតាអើយចេះមិនដល់ ។
ប៉ុន្តែដាំអ្វីបេះផ្លែហ្នឹង ចូរកុំទទឹងខុសភោគផល
ដាំក្រូចបេះស្វាយគ្មានឡើយយល់ បេះត្រឹមកុសលផលអ្នកដាំ!!!

# ចង់ចេះសំលាប់អាចារ្យចង់បានផ្លែផ្កាយកភ្លើងដុតគល់

(២០០៣)

ពាក្យចាស់លោកថា "សំលាប់អាចារ្យ បើសិនចង់ចេះ
យកភ្លើងដុតគល់ អោយដើមវាឆេះ ទើបអ្នកបានបេះ
ភោគផលថ្មីល្អ" ។

មានន័យយ៉ាងណា អស់បុត្រធិតា ឆោមឆើតបវរ
ដូចគុម្ពឫស្សី ដុតគល់ឆេះមក៏ លូតដើមថ្មីល្អ
ទំពាំងភ្លោះកូន ។

បើអ្នកមិនដុត ឫស្សីស្រកស្រុត គុម្ពក្លាយក្សំយសូន្យ
ដុតហើយត្រូវភ្លៀង ទំពាំងសាយកូន ចិញ្ចឹមបងប្អូន
ជាតិខ្មែរប្រុសស្រី ។

យកភ្លើងដុតវ៉ា សំលាប់អាចារ្យ បើចង់ចេះក្រៃ
មានន័យថាដេញ ប្រាជ្ញបាធ្យាយ សាកសួរអោយនាយ
អស់គ្រប់ជ្រុងជ្រោយ ។

សំនួរធ្ងន់ស្រាល សួរដេញអោយចាល់ បែកញើសខ្វរខ្វាយ
ចន្លោះត្រង់ណា វែកញែកដោះស្រាយ គ្រូស្វែងឱបាយ
ដោះស្រាយចំងល់ ។

សួរណាស់វៀនណាស់ កូនអើយចាំច្បាស់ ចំណេះនិមល
គ្រូមួយចាល់ចេះ គ្រូពីរគង់ស្គាល់ គ្រូបីគង់ផ្តល់
ចំលើយដល់អ្នក ។

ពាក្យស្លោកខេមរា ន័យជ្រៅលាក់អាថ តម្រាជ្រៅរាក់
បើសិនវែកញែក អត្ថន័យជំពាក់ "ស្តាប់មិនយល់ជាក់
កុំអាលញ្ញាក់ចិញ្ចឹម..."

CHANBOKEO.COM

# សាដៀវ

(២០០២)

សាដៀវផ្កាត់ព្ធ រន្ទឹឆ្លងភូមិ          កាត់ភាពជ្រងំភិរម្យឧត្តុង្គ
សូរសព្ទ័ពិរោះអន្ទងអារម្មណ៍     គ្រប់គ្នាសំងំស្តាប់សៀងសាដៀវ ។
ផ្លិកផ្លក់ភ្លិងភ្លង់លង់អស់ទ័យា       តន្ត្រីខេមរាផ្កាត់សារច្រៀងនាវ
ហាក់ចំរៀងទុំស្នូត្រផ្ញើនាងទាវ  សំនៀងសាដៀវនាវចិត្តលង់ស្នេហ៍ ។
សព្ទ័សៀងស្រទន់សណ្តំកាមា          ពិរោះសោតាឱភាល្ហើយល្ហែ
អនិច្ចាថ្ងៃនេះខេមរាប្រួលប្រែ       បោះសាដៀវបែរតន្ត្រីបរទេស ។
ជាតិគេរក្សាសម្បត្តិបុរាណ  ខ្មែរយើងគ្រប់ប្រាណបែរធ្វេសប្រហែស
ដៀលកេរ្តិ៍ដូនតាថាវាមិនផេះ         តន្ត្រីបរទេសទើបមានតម្លៃ ។
សាដៀវអាណិតធាតុពិតខេមរា      ធ្លាប់មានសក្តាខ្ពង់ខ្ពស់ស្ដឹមស្ដៃ
ឥលូវកូនខ្មែរបង្អាប់ដល់ដី      ហើយផ្តល់តម្លៃបរទេសដល់មេឃ ។
សាដៀវនាវចិត្តអស់បុត្រខេមរា       ឱ!បុត្រធិតាគប្បីត្រងត្រេក
រក្សាសម្បត្តិជាតិយើងល្អឯក            ទោះបរទេសប្លែក.....
ក៏កុំជាន់ខ្លួនឯងដើម្បីជាតិគេ!

អ្នកស្រីកែវចន្ទ័បូរណ៍

CHANBOKEO.COM

# វគ្គទីមួយ

# ភព្វ៍ឬអភព្វ៍?

នៅវាលយន្តហោះបុរីភ្នំពេញ...

យុវជនដ៏សង្ហារម្នាក់ក្នុងវ័យប្រមាណ២៤ឆ្នាំ កំពុងរុញរទេះដឹកវ៉ាលីស ដើរចេញមកក្រៅ... ភ្នែកគេវិញប្រដេញរំពៃមើលរកគ្នីគ្នា ដែលត្រូវមក ទទួលស្វាគមន៏ការវិលត្រលប់របស់នាយពីអាមេរិកថ្ងៃនេះ ។ មែនហើយ កំលោះយើងបានចេញទៅបន្តការសិក្សានៅអាមេរិក ចំនួន៦ឆ្នាំមកហើយ ទើបតែបញ្ចប់ការសិក្សាថ្មីៗនេះឯង ។ រំពេចនោះ មានសំលេងស្រែកហៅ ពីម្ខាងមកថា :

- វិរិន្ទសុគុណ!... ពួកយើងនៅខាងនេះ!

មាណពកំលោះបែរភ្លែតទៅរកម្ចាស់សម្លេង ស្រាប់តែប្រទះនឹងមិត្ត របស់ខ្លួនដែលកំពុងលើកដៃបក់បោយជាសញ្ញា ។ នាយយើងក៏ញញឹមឡើង យ៉ាងស្រស់ព្រមទាំងឧទានថា :

- ពិសិដ្ឋ!...

ទាំងពីរក៏ស្ទុះរត់ចាប់ដៃគ្នាយ៉ាងរីករាយ ។ នៅពីក្រោយខ្នងពិសិដ្ឋ នារី ដែលមានរូបឆោមយ៉ាងស្រស់មួយរូបឈរសំដែងអាការៈឃ្នាន់ខ្នាញ់ :

- បងសុគុណនឹកតែបងពិសិដ្ឋម្នាក់ទេ មែនទេ?

វិរិន្ទសុគុណបែរផាំងយ៉ាងលឿន ស្រាប់តែលាន់មាត់ថា :

- អូនដារិនី!

គ្រាន់តែឃើញភក្រ្តមាណវីភ្លាម សុគុណក៏ស្ទុះយ៉ាងលឿនទៅស្រវ៉ា អោបនាងដោយក្តីនឹករលឹក :

- បងនឹកអូនណាស់ ដារិនី... បែកគ្នាប្រាំមួយឆ្នាំ អូនស្រស់ប្លែកណាស់ ធ្វើ អោយបងមើលអូនស្ទើរតែមិនស្គាល់...

ឆវីញញឹមបំពាក់កំរងផ្កាម្លិះដល់នាយយើងហើយក៏ស្រដីឡើងថា :

- តែដារិនីចាំបងជានិច្ចណា៎... មិនថារូបបងផ្លាស់ប្តូរយ៉ាងណា!

ឮដូច្នោះ វិរិន្ទសុគុណរំភើបចិត្តណាស់ ក៏ស្រវ៉ាអោបនាងជាថ្មី :

- អរគុណអូនណាស់ ដារិនី! ៦ឆ្នាំដែលបងរង់ចាំជួបអូននោះ ពិតជាមាន ន័យសំរាប់បងធំធេងណាស់ ។

ស្រាប់តែពិសិដ្ឋយកដៃបេះអ្នកទាំងពីរចេញ ហើយឧទានកាត់ចង្វាក់ យ៉ាងលឿនតែម្តង :

CHANBOKEO.COM

- នែ៎! ទីនេះជាវាលចំណតយន្តហោះណា៎ មិនមែននៅផ្ទះទេ..មិនចេះខ្មាស គេទេហ៎? មើលហ្ន៎!
សាធារណជនគេសំលឹងមកយ៉ាងអ៊ូអរ... យ៉ាប់មែន!

វិរិទ្ធសុគុណបែរមើលជុំវិញខ្លួនឃើញកែវភ្នែករាប់រយសំលឹងមើលមក គេទាំងពីរមែន ក៏នឹករអៀសខ្លួនបន្តិចដែរ ។ នាយយើងក៏ប្រញាប់ទាញដៃ ស្រីស្រស់ម្ចាស់ដួងចិត្តរបស់គេចូលរថយន្តយ៉ាងលឿន ទុកអោយពិសិដ្ឋ សំលឹងតាមមើលពីក្រោយចំហមាត់តែម្នាក់ឯង :

- ពុទ្ធោអើយ! មើលគេ? បានជួបសង្សារភ្លាម ភ្លេចពួកម៉ាកអស់រលីង!

បន្តិចក្រោយមក គេទាំងបីក៏បានមកដល់វិឡាដ៏ស្កកស្កម្ភមួយ ។ គ្រាន់ តែក្រលេកឃើញវត្តមានអ្នកទាំងបីកាលណា មាណវីសោភាមួយរូបក៏ ចេញមកទទួល :

- ប្អូនប្រុសរបស់បង! ពុទ្ធោ! ខ្ពស់ហើយសង្ហាប្លែកតែម្តង!

វិរិទ្ធសុគុណក៏ស្ទុះទៅអោនសំពះមាណវីនោះភ្លាម :

- បងវរលក្ខណ៍! ជំរាបសួរ!

ការពិត នោះគឺជាវរលក្ខណ៍បងស្រីរបស់កំលោះសង្ហារយើងតើហ៎! នាងស្ទុះទៅអោបប្អូនដោយសេចក្តីត្រេកអររំភើបបំផុត :

- បងនឹកប្អូនណាស់ សុគុណ!

រួចហើយវរលក្ខណ៍ក៏បែរមកហៅពិសិដ្ឋនិងដារិនី :

- ម៉ោះ! ចូលទៅក្នុងផ្ទះ! លោកប៉ាកំពុងរង់ចាំទាំងអស់គ្នាហើយ ។

កំលោះយើងស្ទុះរឹងទៅមុនគេយ៉ាងរហ័សទៅក្រាបប្រណិបតន៍លោក វរៈជាឪពុកភ្លាម ។ នៅក្នុងសាលុង លោកវរៈដែលមានវ័យប្រហែលហា ប្អួយ កំពុងរង់ចាំមើលផ្លូវកូនប្រុសដោយចិត្តអន្ទះសា ។ កាលបើក្រលេក ឃើញវត្តមានរបស់កូនប្រុសនៅចំពោះមុខ លោកក៏លូកដៃអង្អែលក្បាល កូនដោយដួងចិត្តសែនរំភើបក្រៃលែង :

- សុគុណ! ប៉ារលឹកកូនអ្វីម្ល៉េះទេ... ៦ឆ្នាំដែលកូនចាកចេញទៅសិក្សានៅ
អាមេរិក វាយូរសែនយូរសំរាប់ប៉ាដែលចាំទន្ទឹងមើលផ្លូវកូនរាល់ថ្ងៃ...

រួចហើយលោកក៏បែរមុខទៅរកកញ្ញារូបស្រស់ដារិនី ដែលអង្គុយក្បែរ នោះ ទើបមានប្រសាសន៍បន្តថា :

- ហើយចំពោះគេម្នាក់នេះ ពេលវេលាប្រហែលជារត់យឺតជាងនោះទៅ ទៀតឆ្ងាយណាស់... !

ឮលោកវរៈមានប្រសាសន៍ដូច្នោះ ធិតាយើងអៀនឡើងថ្ពាល់ក្រហម តែម្តង ។ វរលក្ខណ៍ឃើញដូច្នោះ ក៏និយាយបន្ថែមថា :

- លោកប៉ា!..ប្អូនសុគុណគេក៏នឹកដារិនីដូចតែគ្នាហ្នឹង! ប៉ាមើលហ្ន៎! សុគុណ គេអង្គុយឆ្ងាយលោកប៉ា ឆ្ងាយបងស្រី ឆ្ងាយពិសិដ្ឋដែលជាពួកម៉ាក ប៉ុន្តែ ពេលនេះ គេមិនហ៊ានអង្គុយបែកឆ្ងាយសង្សារទេ សូម្បីតែកន្លះម៉ែត្រ...

ទាំងអស់គ្នាក៏ហោរគិលឡើង ។ សុគុណនិងដារិនីញញឹមទាំងអៀនអន់ ហើយចោលភ្នែកលួចសំលឹងមើលគ្នាភ្លៀកៗ ។

ការពិត គេទាំងពីរជាគូកំណាន់ចិត្តនឹងគ្នា តាំងពីមុនពេលសុគុណចេញ ទៅរៀននៅអាមេរិកម្ល៉េះ ។ សព្វថ្ងៃ ដារិនីបានរៀនបញ្ចប់ការសិក្សាផ្នែក គ្រប់គ្រងហើយ តែមិនទាន់បានចូលធ្វើការនៅឡើយ ត្បិតឪពុកម្តាយ របស់នាងជាមហាសេដ្ឋី

CHANDBOKEO.COM

មានប្រាក់ចាយមិនខ្វះ ម្លោះហើយធិតាយើងមិន នឹកភ័យព្រួយប្រញាប់ប្រញាល់រកការធ្វើអ្វីទេ ក៏ចេះតែបណ្ដែតបណ្ដោយអោយទៅតាមតែដំណើរទៅ ។ អ្វីដែលឆវីសោភារបស់យើងទន្ទឹងនៅពេល នេះ គឺការវិលត្រលប់របស់វិរិន្ទសុគុណតែប៉ុណ្ណោះ ព្រោះអីចាស់ៗបានជាប់ មាត់ជាប់កនឹងគ្នាមក តាំងពីគេនៅក្មេងៗមកម្ល៉េះ ថាលោកនឹងផ្សាភ្ជាប់ស្ពានមានមេត្រីនឹងគ្នានៅពេលណាដែលសុគុណគេបញ្ចប់ការសិក្សា ។

ដូចគេទាំងពីរបានគេងផ្សងទុកមែន ។ ពីរអាទិត្យក្រោយមក ពិធីភ្ជាប់ ពាក្យដ៏មហោឡារិកមួយបានឧប្បត្តិកឡើង ។ ស្នូរទះដៃប្រាវៗយ៉ាងខ្ទ័រខ្ទារ រំពងបានលាន់ឮឡើងចេញពីផ្ទះរបស់លោកតាភានិងភរិយា ។ កំលោះសង្ហា វិរិន្ទសុគុណលើកដៃនារីកំណាន់ចិត្តឡើង រួចហើយក៏បំពាក់ចិញ្ចៀនពេជ្រ មួយវង់ដល់នាង ព្រមទាំងស្រដីទៅកាន់នាងថា :
- ចិញ្ចៀននេះជាតំណាងដួងចិត្តរបស់បងដែលស្រលាញ់អូន ពេលនោះបង សូមផ្ញើចិត្តបងនៅក្នុងដៃអូនហើយ សូមអូនជួយថែរក្សាផងណាំអូនណាំ!

ចិញ្ចៀនបញ្ចាំចិត្ត

ចិញ្ចៀនមួយវង់ក្បង់យកចិត្ត  តំណាងស្នេហ៍ពិតចំពោះស្រី
សូមអូនទទួលដោយមេត្រី  តំណាងហឫទ័យបងប្រតិពទ្ធ័ ។
ចិញ្ចៀនស្រងាំដាំចិត្តស្នេហ៍  ចំពោះមាសមេស្មោះប្រាកដ
ស្នេគ្រ័ជូនចរណៃថ្លៃមរកត  ស្នេហ៍លុះថ្ងៃផុតជីវិតបង់ ។
ចិញ្ចៀនពេជ្រមួយបំពាក់ដៃ  ជូនស្រស់ពិសីកែវឆោមយង់
សូមអូនរក្សាកុំបោះបង់  ជីវិតបងលង់ក្នុងដៃនាង ។
ចិញ្ចៀនពេជ្រសល្អវរនាថ  សាងស្នេហ៍រយជាតិទៅវៀងៗ
ផ្ញើចិត្តលើស្រីមិនមានល្បៀង  បេះដូងផ្ញើនាងទ្យេងរៀងអើយ ។

លោកវរៈ កញ្ញាវរលក្ខណ៍ លោកតាភានិងភរិយា នាយពិសិដ្ឋជាមិត្ត និងភ្ញៀវសំខាន់ៗជាច្រើនទៀតនាំគ្នាសើចក្អាកក្អាយចំអកចំអន់អ្នកទាំងពីរ រហូតដល់ចប់ពិធីបុណ្យ ធ្វើអោយគូកំណាន់ទាំងទ្វេរិតតែអៀនអន់ដាក់គ្នា ឡើង តែគេក៏ពេញចិត្តនឹងការចំអន់របស់អ្នកទាំងឡាយមិនតិចដែរ ត្បិតពាក្យទាំងអស់នោះ បានតែធ្វើអោយគេមានអារម្មណ៍រំភើបចិត្តចំពោះគ្នា កាន់តែខ្លាំង ។

នៅខាងក្រៅ ចាស់ៗនិងភ្ញៀវទាំងឡាយនៅអង្គុយជជែកគ្នាពីនេះពី នោះ ។ ដារិនីនិងសុគុណអង្គុយកាន់ដៃគ្នាសាសងក្បែរកូនស្រះឈូកតូច មួយ ដែលមានទឹកបាញ់ព្រោងព្រាយយ៉ាងមនោរម្យ :
- បងសុគុណ! ជីវិតអាមេរិកយ៉ាងម៉េចដែរ? អូននឹកបងអើយសែននឹកតែ ម៉ាក់ប៉ាលោកមិនអនុញ្ញាតអោយអូនទៅសោះ កុំអីដារិនីទៅលេងបងរាល់ ឆ្នាំបាត់ទៅហើយ ។
- គ្មានអ្វីសប្បាយទេអូនអើយ! ស្រុកគេរវល់ណាស់ បើកភ្នែកឡើងឃើញ

CHANBOKEO.COM

តែធ្វើការ ទៅរៀនអោយរចល់ មិនទំនេរឡើយ ។ បើសិនកាលណោះ អូន បានទៅលេងបង ក៏បងគ្មានពេលជូនអូនដើរលេងដែរ ។ ជីវិតជានិស្សិត នៅសិក្សាមិនមានពេលដើរលេងទេ បើអាល័យតែយកពេលដើរ ច្បាស់ជា រៀនមិនចប់ដូចគំរោងទុកឡើយ... ប្រហែលជាអួសជើងដល់ចាស់សក់ស្កូវ ជាមិនខាន ។ ល្អហើយដែលអូនមិនបានទៅលេង.. កុំអីបងច្បាស់ជាបែក អារម្មណ៍រៀនលែងកើតស្រេច...

ឮនាយនិយាយកំប្លែងដូច្នោះ ដារិទីយកដៃបូតច្រមុះនាយភ្លាម :

- មិនចង់អោយដារិទីទៅលេងបង ព្រោះខ្លាចបែកអារម្មណ៍ ឬព្រោះខ្លាច ដារិទីចាប់ទាន់ថាបងលួចមានសង្សារនៅទីនោះ?

- អូយ! កុំចោទបងអញ្ចឹងអី.. ព្រះអើយ... បងមិនបានទាក់ទងនរណាទេ សូមស្បថណា៎...

- អត់ជឿទេ!

- ជឿមិនជឿ ក៏វិន្ទសុគុណបានមកដល់ចំពោះមុខអូនហើយ ហើយក៏បាន ប្រគល់បេះដូងរបស់បងទៅអូននៅចំពោះចាស់ទុំទៀតផង មិនដឹងថាអ្នក នៅស្រុកខ្មែរ គេជ្រះអារម្មណ៍សង្ស័យដែរទេហ្ន៎?

សុគុណសើចខឹកៗយ៉ាងសប្បាយ ដោយបានកំប្លែងលេងនឹងគូដណ្តឹង របស់នាយ អោយនាងបញ្ចេញកិរិយាខ្មិកខ្មាក់គួរអោយខ្មាញ់ ។ បន្តិចមក នាយយើងក៏ពោលបន្តថា :

- ដារិទី! គិតទៅយើងទាំងពីរមានសំណាងណាស់ មានកំណើតក្នុងត្រកូល អ្នកខ្ពង់ខ្ពស់ មានទ្រព្យ មានមុខមាត់ មានអ្វីៗសព្វយ៉ាង ហើយពេលនេះ ទៀត ក្តីស្រម័យរបស់យើងក៏កំពុងឈានទៅរកការពិតដ៏ត្រចះត្រចង់មួយ

- មែនហើយ... អូនក៏គិតដូច្នោះដែរ... អ្វីដែលអូនទន្ទឹងនៅពេលនេះគឺ អាពាហ៍ពិពាហ៍របស់យើងទាំងពីរណា៎បង ។

- មិនយូរទេ ពេលដែលបងចូលធ្វើការមានលំនឹងបន្តិច យើងនឹងរៀបការ នឹងគ្នាហើយ ។

អ្នកទាំងពីរក៏ញញឹមដាក់គ្នាយ៉ាងត្រចង់ ។

ពីរខែក្រោយមក...

ថ្ងៃនេះជាថ្ងៃចូលឆ្នាំខ្មែរគ្រប់ៗគ្នាតែងតែនាំគ្នាសំរាកការងារចេញដើរ កំសាន្តនៅក្រៅក្រុងអស់ ។ សុគុណក្រោកតាំងពីព្រឹកទៅទទួលដារិទីនារី កំពូលដួងចិត្តរបស់គេ ដើម្បីធ្វើដំណើរទៅរមណីយដ្ឋានទឹកធ្លាក់នៅក្បាល ឆាយចំងាយប្រហែលប្រាំពីរគីឡូម៉ែត្រពីក្រុងកំពង់សោម ។ ទៅដល់មាត់ របងវិឡាដ៏សែនស្រស់ស្អាតស្អែ សុគុណបានប្រទះឃើញដារិទីមកចេញឈរ ចាំដំណើររបស់នាយជាស្រេច :

- ដារិទី.. ថ្ងៃនេះស្លៀកខោខ្លី ពាក់វ៉ែនតាខ្មៅ ពាក់មួកកន្តិបយ៉ាងនេះ ដូច ក្រមុំអាមេរិកដល់ហើយហ្ន៎!

- យ៉ាងម៉េច... ឃើញលក្ខណៈយ៉ាងនេះ នឹកសង្សារនៅអាមេរិកមែនទេ បងសុគុណ?

- កុំនិយាយអញ្ចឹងមើល សំលាញ់ចិត្ត! យើងជិតរៀបការហើយណា៎! កុំ និយាយអ្វីដែលជាអពមង្គលដល់ចំណងសម្ពន្ធ័រវាងយើងទាំងពីរអីណា៎អូន!

ឮដូច្នោះ ដារិទីក៏ឆ្លើយឡើងថា :

CHANBOKEO.COM

- ចាំសៗ ឈប់ហើយ! គ្រាន់តែនិយាយលេងផងមិនបានដែរ ។

ឃើញធិតាធ្វើមុខក្រមូវ សុគុណក៏យកដៃបិចថ្ពាល់ :

- អឺ! ខឹងក៏ខឹងទៅ! បងចង់អោយអូនខឹងអញ្ចឹងណាស់ មើលចុះ! ថ្ពាល់ របស់អូនឡើងពណ៌ក្រហមទុំដូច្នោះ គួរអោយស្រលាញ់ដល់ហើយ ។

ពាក្យចំអន់របស់នាយធ្វើអោយដារិនីរឹងរិតខ្មាញ់ឡើង ។ នាងក៏លូក ដៃក្តិចបុរសយើង :

- នែះនែ៎... យកខ្លះទៅ... ក្រែងលោបែកអារម្មណ៍ ឈប់នឹករករឿងដារិនី តទៅទៀត ។

- អ៊ូយ! លែងឈឺម្លេះ? តិចបងឈប់ឡាន ចាប់អូនថើបអាលូវ..!

សុគុណមិចភ្នែកលលេងនឹងធិតា ។ តាមផ្លូវ ទាំងពីរនាក់ចំអកចំអន់គ្នា សើចផងយ៉ាងសប្បាយ ។ បីម៉ោងក្រោយមក គេក៏បានមកដល់រមណីយ ដ្ឋានក្បាលឆាយដែលមានទឹកធ្លាក់ឈូឆរយ៉ាងមនោរម្យ ។ នៅទីនោះ អ្នកទាំងពីរបានប្រទះនឹងទេសចរណ៍ជាច្រើន ខ្លះជាជាតិខ្មែរ ខ្លះជាជាតិបរទេស មកកំសាន្តនៅទីនោះដែរ ។ មិនតែប៉ុណ្ណោះ សុគុណនិងដារិនីបានទទួលការ ស្វាគមន៍ពីកុមារាកុមារីតូចៗជាច្រើន ដែលកំពុងដើរទូលនំលក់អោយភ្ញៀវ ដែលកំពុងដើរកំសាន្តទាំងឡាយនោះ ។ ក្មេងៗទាំងនោះនៅក្មេងៗណាស់ ខ្លះមិនទាន់គ្រប់បួនឆ្នាំផងក៏ចេះទូលនំលក់ដែរ ។ លុះគេទាំងពីរដាក់ខ្លួនចុះ ទទួលទានអាហារនៅរោងបាយមួយ ស្រាប់តែមានក្មេងមួយហ្វូងប្រហែល ជាង១០នាក់បានមកចោមរោមអ្នកទាំងពីរ :

- បងប្រុស បងស្រី!   ជួយទិញនំរបស់ពួកយើងខ្លះទៅ  ដើម្បីអោយយើង បានកំរៃនឹងទិញបាយញ៉ាំផង...

សុគុណឮដូច្នោះហាក់ដូចជានឹកអាណិតដល់ក្មេងទាំងនោះណាស់ ។ លុះ ឃើញនាយនៅរេរា ក្មេងស្រីម្នាក់ពោលឡើងថា :

- បងប្រុស បងស្រី.. បើបងទិញនំរបស់ប្អូនមួយកញ្ចប់ នោះប្អូននឹងច្រៀង កំដរបងទាំងពីរមួយបទ.. តើបងជួយទិញនំប្អូនទេ?

ទោះបីជាពេលនោះ កំលោះយើងមិនជានឹកចង់បរិភោគនំទាំងនោះក៏ ដោយក៏នាយយើងរកនឹកពាក្យប្រកែកថាមិនទិញមិនឃើញដែរ ។ មាណព យើងក៏សួរទៅក្មេងទាំងនោះថា :

- ប្អូនៗ ម៉េចមិននាំគ្នាទៅរៀន បែរជាមកដើរលក់នំទៅវិញ?

ស្រាប់តែកុមារីម្នាក់អាយុប្រហែល៩ឆ្នាំឆ្លើយឡើងថា :

- បងប្រុសអើយ... សាលារៀននៅឆ្ងាយ ដើរមិនដល់ទេ ហើយពួកយើង ក្រណាស់ មិនមានបាយបរិភោគគ្រប់ផង ធ្វើម៉េចនឹងទៅរៀនកើត? មាន តែជួយម៉ែពុកលក់នំទៅ ក្រែងមានភ្ញៀវគេមេត្តាជួយទិញ នឹងបានកំរៃ ទិញអង្ករ ។ ហោចណាស់ពួកយើងមិនបាច់ដើរសុំទានគេ អោយខូចមុខ មាត់ទឹកន្លែងល្អៗយ៉ាងនេះផង ។

សុគុណឮក្មេងឆ្លើយហើយក៏នឹកអាណិតក្មេងទាំងនោះរិតតែខ្លាំងឡើង នឹកភ្នកទៅដល់ជីវិតនៅអាមេរិក ដែលក្មេងៗក្រោម១៨ឆ្នាំត្រូវបានចូល រៀនគ្រប់ៗគ្នាមិនថាអ្នកក្រឬអ្នកមានទេ ។ នាយយើងគិតថា បើជាតិយើង ប្រឹងប្រែងបណ្តុះបណ្តាលក្មេងអោយបានរៀនសូត្រដូចស្រុកគេ មិនដឹងជា ប្រទេសខ្មែរនឹងសំបូរអ្នកចេះដឹង

CHANBOKEO.COM

ធ្វើការថ្កុំថ្កើងប្រទេសជាតិយ៉ាងណាទេ ។ ភ្លាមនោះ គេក៏លូកដៃយកប្រាក់ពីហោប៉ៅ មកទិញនំពីក្មេងទាំងនោះយក ទាំងអស់ ។ បន្តិចមក សុគុណក៏បបួលដារិនីនាំក្មេងទាំងនោះទះដៃច្រៀង បបួលក្មេងលេងល្បែងប្រណាំងគ្នាញ៉ាំនំ ដែលនាយទើបម៉ៅយកពីពួកគេ មក ធ្វើអោយបរិយាកាសទីនោះសប្បាយរីករាយក្រៃលែង ។

មួយសន្ទុះធំក្រោយមកសុគុណក៏ដឹកដៃដារិនីទៅអង្គុយលេងនៅក្បែរ មាត់ជ្រោះដែលទិដ្ឋភាពស្រស់បំព្រងគួរអោយចេតនា ។ នៅទីនោះ គេ ឃើញទឹកជ្រោះហូរធ្លាក់ឈូឆរលើផ្ទាំងថ្ម បង្កជាពពុះសខ្វាយព្រោងព្រាត ឡើង លាយឡំនិងស្នូរសន្ធឹកគ្រាំគ្រេងរបស់កំលាំងទឹកធ្លាក់ ស្តាប់យូរឡើង រិតតែយន់ស្មារតីឡើង មិនខុសពីតន្ត្រីរំងំបំពេរដួងចិត្តទេសចរណ៍គ្រប់ៗគ្នា ដែលមកកំសាន្តទីនោះឡើយ ។

### ស្ពានស្នេហ៍មនោរម្យ

ឱភាសពណ៌មាសនាគ្រាសាយណ្ហ៍ ហាក់ភក្ត្រស្រទន់មុំស្នេហាបង
ព្រឹក្សាតូចធំខៀវស្រស់បំព្រង គីរីជ្រោះជ្រងកំដរគូស្នេហ៍ ។
ឮដំរៃហាស៍ពពករសាត់ ជំនោរផាយផាត់ផ្ការីកហូរហែ
រៀមបីត្រកងនោមកែវមាសមេ ច្រៀងលោមបំពេរសំនៀងភិសម័យ ។
ទឹកជ្រោះបែកផ្សែងប្រលែងថ្មដា ខ្ចីវជាសញ្ញាពរជ័យសប្បាយ
ពីព្រហ្មទេវតាដល់យើងពីរកាយ បងនិងនោមឆាយគូនិត្យភក្តិ ។
ឱ! ទឹកជ្រោះអើយជួយចាំស្នេហ៍យើង ឱ! ព្រៃរុងរឿងសូមជាសាក្សី
មេឃអើយសូមចាំពាក្យពេចន៍សំដី គូគាប់ថ្មោងថ្មីសច្ចាស្នេហ៍ពិត ។
ជាតិនេះជាតិណាប្រាថ្នាជាគូ យើងពិតហ៊ានប្តូរស្មគ្រស្មោះនៃបនិត្យ
សូមយល់សុភមង្គលអម្រឹត ស្នេហ៍យើងសុក្រឹតអង្វែងរៀងអើយ ។

រសៀលបន្តិច មាណពកំលោះក៏កាន់ដៃគូកំណាន់ចិត្តដើរឡើងតាមដង ជ្រោះសំដៅទៅរថយន្តវិញ ។ មិនទាន់ដើរដល់រថយន្តផង ស្រាប់តែសុគុណ មានអារម្មណ៍ថាញ័រដៃញ័រជើងយ៉ាងណាមិនដឹង ស្រាប់តែងងិតមុខឈឹង ដោយឯកឯង ។ នាយក៏ឧទានឡើងយ៉ាងប្រញាប់ថា :

- អូនដារិនី... ជួយបងផង!

រួចហើយនាយយើងធ្វើមុខស្លេក ដួលប្រូសទៅដីបាត់មាត់ឈឹងតែម្តង ធ្វើអោយឆវីយើងតក់ស្លុតយ៉ាងខ្លាំង :

- បងសុគុណ... បង! បងយ៉ាងម៉េចហ្នឹង?

CHANBOKEO.COM

ដារិទីយកដៃអង្រួនតែនាយនៅតែមិនឆ្លើយដដែល ។ ធិតាភ័យណាស់
ក៏ស្រែកឆោឡោឡើងហៅអោយគេឯងជួយយ៉ាងប្រញាប់ ។

នៅមន្ទីរពេទ្យមួយនៅកំពង់សោម...

សុគុណបើកភ្នែកឡើងឃើញឃើញខ្លួននាយនៅក្នុងបន្ទប់មួយ :

- ដារិទី... បងនៅឯណាហ្នឹង?

- ប្អូនសុគុណ! នេះបងណា បងវរលក្ខណ៏... ប្អូនបានដឹងខ្លួនវិញដូច្នេះ បង ត្រេកអរណាស់... ឃើញប្អូនសន្លប់បាត់មាត់ច្រើនម៉ោង ប៉ានឹងបងភ័យស្លុត ទឹកមាត់អស់ហើយណាសុគុណ.

- បងវរលក្ខណ៏... លោកប៉ា!

លោកវរៈដែលនៅឈរក្បែរកូនស្រីរបស់លោកនោះ ក៏ញញឹមឡើងៈ

- កូនមានអារម្មណ៏យ៉ាងម៉េចដែរ សុគុណ? ធូរស្រាលក្នុងខ្លួនខ្លះទេ?

- បាទ! នៅញ័រក្នុងទ្រូងនៅឡើយ លោកប៉ា! ហើយចុះឯណាអូនដារិទី?

- នាងអង្គុយកំដរឯងមួយយប់ហើយ ទំរាំតែប៉ានិងបងស្រីឯងបើកឡានពី ភ្នំពេញមកដល់ ។ ឥលូវនេះ ដារិទីបានចេញទៅផ្ទះជាមួយឪពុកម្តាយរបស់ គេអំបាញមិញនេះឯង ព្រោះគេគិតភ័យបារម្ភនឹងកូនឯងពេក រហូតចង់ឈឺ ខ្លួនឯង ទើបប៉ាឱ្យនាងទៅរកសំរាកសិនក្រែងមិនស្រួលខ្លួនម្នាក់ទៀត ។

ភ្លាមនោះ លោកគ្រូពេទ្យក៏ចូលមកដល់ មានប្រសាសន៏ជំរាបទៅ
លោកវរៈថា :

- កូនប្រុសរបស់លោកកំពុងរើជំងឺចាស់ ។ ឈាមរបស់គេចុះខ្សោយដោយ
សារ ជំងឺរលាកក្រលៀនរបស់គេដែលស្ថិតនៅក្នុងដំណាក់ចុងក្រោយហើយ ពេលនេះ ថ្នាំអ្វីក៏លែងមានប្រសិទ្ធភាពតទៅទៀតដែរ ។ សេចក្តីសង្ឃឹមគឺ មានតែមួយទេដែលអាចជួយជីវិតរបស់កូនប្រុសរបស់លោកបាន នោះគឺវះ កាត់ដាក់ក្រលៀនថ្មីជំនួសក្រលៀនចាស់ ដែលមានជំងឺមិនអាចព្យាបាលបាន តទៅទៀត ។ ចំពោះបញ្ហានេះ កូនប្រុសរបស់លោកមិនត្រូវការក្រលៀន ពីរយកមកដាំទេ ដាំបានតែមួយក៏គេអាចមានជីវិតរស់នៅធម្មតាវិញបាន ដែរ ។ ដូច្នោះ បើលោកអាចរកនរណាម្នាក់ដែលអាចអោយក្រលៀនល្អ របស់គេ មកដាំបានទាន់ពេលវេលា នោះកូនប្រុសរបស់លោកក៏អាចមាន ឱកាសរស់នៅធម្មតា ដូចគេឯងជាប្រក្រតីវិញហើយ ។

បន្ទាប់ពីពិគ្រោះអំពីគំរោងព្យាបាលជាមួយលោកវរៈរួចហើយ លោក
គ្រូពេទ្យក៏ចេញទៅវិញ ។ កាលបើសុគុណឃើញឪពុករបស់ខ្លួនមានទឹកមុខ បង្កប់ដោយសេចក្តីព្រួយបារម្ភ
គេក៏ញញឹមហើយពោលបន្លប់ថា :

- លោកប៉ា! ទៅគិតច្រើនធ្វើអី? លោកគ្រូពេទ្យនិយាយបែបនេះតាំងពី យូរមកហើយតែក៏មិនឃើញសុគុណទៅណាមកសោះ ។ ដូច្នេះ លោកប៉ា ឈប់ព្រួយទៅ ។ ម្យ៉ាងទៀត បើស្រុកខ្មែរគ្មានពេទ្យល្អព្យាបាលទេ ចាំខ្ញុំ ទៅអាមេរិករកពេទ្យល្អព្យាបាលវិញ ។ សុគុណស្បែកស្វិតណាស់ មិនទៅ ណាចោលប៉ានិងបងវរលក្ខណ៏ងាយៗឡើយ ។

CHANBOKEO.COM

តែសំដីទាំងនោះ មិនបានធ្វើអោយលោកវរៈនិងបងស្រីរបស់នាយ មានអារម្មណ៍ប្រសើរវិញទេ។ អ្នកទាំងពីរសំលឹងមុខសុគុណ ដោយដួងចិត្ត ក្រៀមក្រំបំផុត។ លោកវរៈគ្រវីក្បាលដកដង្ហើមធំៗ អាណិតកូនប្រុស ដែលកំពុងពេញវ័យ ដែលគួរណាស់តែបានទទួលនូវសុខភាពល្អនិងជីវិត ភ្លឺថ្លា តែបែរជាមកប្រទះនូវជំងឺរ៉ាំរ៉ៃទៅវិញ។ ថ្ងៃស្អែកឡើង កំលោះវិរិន្ទ សុគុណ ក៏ត្រូវឪពុកនាំខ្លួនត្រលប់មករក្សាជំងឺឯទីក្រុងភ្នំពេញវិញ។

បីបួនថ្ងៃក្រោយមក មាណពយើងក៏បានទទួលដំណឹងពីក្រុមគ្រួសារ របស់លោកតារាមកថា ដារិទ្ធីនារីរូបស្រស់ក៏មិនស្រួលខ្លួនដែរ ចាប់តាំងពី ថ្ងៃដែលសុគុណដួលសន្លប់ឯមាត់ជ្រោះក្បាលឆាយមកម្ល៉េះ ម្ល៉ោះហើយនារី ក៏មិនអាចមកសួរសុខទុក្ខនាយបានដោយផ្ទាល់ ឃើញតែលោកតារានិង ភរិយាប៉ុណ្ណោះមកមើលនាយម្តង កាលពីថ្ងៃដំបូងដែលនាយត្រូវពេទ្យនាំ ខ្លួនមកដល់ភ្នំពេញភ្លាម។ គេនឹកព្រួយបារម្ភពីធិតាណាស់ ចង់ទៅសួរសុខ ទុក្ខនាងនៅឯផ្ទះ តែក៏មិនអាចធ្វើបានដោយសុខភាពរបស់នាយមិនព្រម អនុញ្ញាត្តអោយដើរចោលមន្ទីរពេទ្យឡើយ។ លុះគិតយូរៗទៅ កំលោះ យើង ក៏ហាក់ដូចជានឹកឆ្ងល់បន្តិចដែរថា ហេតុអីក៏ដារិទ្ធីក្លាយជានារីមាន អារម្មណ៍ទន់ខ្សោយដូច្នេះតាំងពីអង្កាល់? កាលដើមឡើយ... នាងជានារី កីឡាមួយរូបយ៉ាងក្លាហាន ហើយជាមនុស្សមានប្រាជ្ញាស្មារតីរឹងប៉ឹងមិន ចាញ់បុរសឡើយ។ ចុះហេតុដូចម្តេចពេលនេះ នាងក្លាយទៅជាទប់ចិត្ត មិនបានចំពោះរឿងនាយទៅវិញ។ គិតទៅគិតមក សុគុណក៏ពោលលួង ចិត្តខ្លួនឯងថា :

- ៦ឆ្នាំដែលយើងបែកពីនាង ដើម្បីទៅរៀននៅអាមេរិក ប្រហែលជាមាន អ្វីកើតឡើងក្នុងជីវិតរបស់នាងហើយ បានជាដារិទ្ធីផ្លាស់ប្តូរទៅជាបែបនេះ! តែល្អើយចុះ...ថ្ងៃណាដែលយើងបានគ្រាន់បើ ចាំយើងទៅសួរសុខទុក្ខនាង ឯផ្ទះចុះ បើសិនជានាងមិនអាចមកជួបយើងនៅឯមន្ទីរពេទ្យនេះបាន។

មួយអាទិត្យក្រោយមក...

ពិសិដ្ឋបរឡានមកដល់ផ្ទះវរលក្ខណ៍ :

- ជំរាបសួរបងលក្ខណ៍! ឮថា សុគុណគេចេញពីមន្ទីរពេទ្យ ថ្ងៃនេះហើយ មែនទេបង?

- មែនហើយ! ហ្នឹ! គេមកដល់ហើយ នៅអង្គុយខាងក្នុង កំពុងរង់ចាំពិសិដ្ឋ ផ្លូវឯងមកលេងហ្នឹងណាំ។

ឮដូច្នោះ ពិសិដ្ឋស្ទុះរឹងទៅជួបសុគុណភ្លាម :

- សូមទោសណាំសំលាញ់! គ្នាអាល័យចេញទៅធ្វើការនៅសៀមរាប ទើប មិនបានមកមើលឯងទាន់ពេល។ ឯងយ៉ាងម៉េចទៅហើយឥលូវនេះ?

សុគុណនៅអង្គុយក្នុងសាលុង មានទឹកមុខស្លេកស្លាំងនៅឡើយ។ លុះ ក្រលេកឃើញវត្តមានរបស់មិត្តកាលណា គេក៏លាន់មាត់ឡើង :

- គ្មានឹកឯងណាស់ពិសិដ្ឋ! ឯងជាមិត្តតែមួយដែលគ្នានឹកជាងគេ។

ពិសិដ្ឋក៏នៅអង្គុយសំណេះសំណាលលេងជាមួយនឹងសុគុណយ៉ាងយូរ។ ការពិតអ្នកទាំងពីរក៏ជាមិត្តនឹងគ្នាតាំងពីនៅបឋមសិក្សាម្ល៉េះ ហើយក៏ធ្លាប់ បានរួមដំណើរទៅរៀននៅអាមេរិកជុំគ្នាផង

CHANBOKEO.COM

តែពិសិដ្ឋគេរៀនតែបួនឆ្នាំក៏ ត្រលប់មកប្រទេសខ្មែរមុន ចំណែកសុគុណវិញនៅបន្តពីរឆ្នាំទៀតទើបបាន ជាគេមកដល់ស្រុកខ្មែរក្រោយពិសិដ្ឋ ។ គេទាំងពីរទៅមកនឹងគ្នាយ៉ាងស្និទ្ធ ស្មាលស្មើរតែជាសមាជិកគ្រួសារតែមួយទៅហើយ ។ ភ្លាមនោះ ពិសិដ្ឋសួរ ទៅសុគុណថា :

- ហើយចុះដារិនី មានមកលេងនឹងឯងញឹកញាប់ទេ សុគុណ?

ស្រាប់តែសុគុណប្រែទឹកមុខភ្លាម :

- គ្នាមិនបានឃើញនាង តាំងពីថ្ងៃដែលខ្ញុំមិនស្រួលខ្លួនចូលមន្ទីរពេទ្យម្ល៉េះ!

- អូហ៎... ម៉េចអញ្ចឹង? នាងមានរវល់អីមែនទេហ៎?

- ខ្ញុំគិតថាដារិនីកំពុងតែរន្ធត់នឹងដំណឹងដ៏អាក្រក់នេះ ហើយប្រហែលជា មិន ទាន់សំរួលចិត្តបាន... ទើបគេមិនមកមើលខ្ញុំ....

- កុំសំកុកធ្វើមុខជូរដូចក្រសាំងអី ឯងចង់ទៅលេងគេទេ? គ្នាជូនឯងទៅ...

- តើគួរសមដែរទេ បើយើងទៅដោយមិនបានណាត់គេជាមុននោះ?

- យី! ទៅខ្លាចចិត្តធ្វើអី? ក្រែងឯងទាំងពីរជាគូដណ្តឹងត្រឹមត្រូវហើយ តើហ៎ មិនមែនទេហ៎?

- តែក៏គ្នា...ចេះតែខ្លាចចិត្តគេណា៎!

- ម៉ោះ! កុំសួញសាញច្រើន ឡើងឡានទៅ!

ភ្លាមនោះ ពិសិដ្ឋក៏បែរក្រោយ កួកហៅបងស្រីរបស់សុគុណ :

- បងលក្ខណ៍! ខ្ញុំនាំសុគុណទៅក្រៅម៉ាភ្លែត បន្តិចមកវិញហើយ!

ថាហើយ គេបរឡានវូចេញទៅ រកតែវរលក្ខណ៍ស្រែកឃាត់មិនទាន់ ។ នាងក៏លាន់មាត់ថា :

- ហើយចុះពីរនាក់នេះ គេទៅណាគេ អីក៏ប្រញាប់ប្រញាល់ម្ល៉េះ? សុគុណ អើយសុគុណ មិនដឹងថាខ្លួនមានជំងឺទេហ្អី បានជាចេញពីពេទ្យមិនទាន់បាន ប៉ុន្មាននាទីផងក៏ចេញដើរលេងភ្លាម... ចំមែនក្មេងកំលោះៗ!!

ថាហើយនាងក៏ត្រលប់ចូលផ្ទះវិញទៅ ។ រីឯពិសិដ្ឋវិញក៏បាននាំសុគុណ មកដល់វិឡារបស់លោកតារា ។ រ៉ឹង!ៗ ស្នូរកណ្តឹងទ្វាររោទិ៍ឡើង ស្រាប់តែ មានក្មេងស្រីបំរើមួយរូបមកបើកទ្វាររបងអោយ :

- នាង! ដារិនីនៅផ្ទះទេហ៎? (សុគុណសួរ)

- ចាស នៅ! សូមអញ្ជើញចូល...!

សុគុណបែរសំលឹងមកពិសិដ្ឋហើយញញឹម ត្បិតដឹងថាមាណវីនៅផ្ទះ ។ គេទាំងពីរក៏បានមកអង្គុយរង់ចាំនៅតុកំសាន្ត ឯសួនច្បារក្រោមម្លប់ឈើដ៏ ត្រឈៃមួយខាងមុខផ្ទះ ។ មួយស្របក់មក ដារិនីក៏លេចធ្លោមកដល់ ប្រកប ដោយទឹកមុខស្ងួតៗ ដាក់សុគុណនិងពិសិដ្ឋ ខុសធម្មតា:

- បងពិសិដ្ឋ! បងសុគុណ! សុខសប្បាយទេ?

ឃើញនាងសួរដូចធម្មតាៗ ហាក់ដូចគ្មានព្រួយបារម្ភអីពីសុគុណសោះ

CHANBOKEO.COM

ពិសិដ្ឋក៏លួចចងចិញ្ចើមដៀងភ្នែកទៅសុគុណ ដែលកំពុងតែញញឹមតបទៅ ធិតាវិញថា ៖

- បងស្រួលបួលគ្រាន់បើវិញហើយ... តែបងបារម្ភពីអូន ទើបមកសួរសុខទុក្ខអូនហ្នឹងណា! អូនសុខសប្បាយទេហ៎ ដារិនី?

ដារិនីឈ្ងោកមុខមួយស្របក់ទើបឆ្លើយមកវិញថា ៖

- សុខ តែមិនសប្បាយទេ...

- ហេតុអីទៅ? (សុគុណសួរ)

ដារិនីសំលឹងទៅពិសិដ្ឋហើយក៏ពោលឡើងថា ៖

- បងពិសិដ្ឋ! អោយខ្ញុំសុំពេលនិយាយជាមួយបងសុគុណពីរបីនាទីបានទេ?

ឮដូច្នោះ ពិសិដ្ឋងក់ក្បាល ហើយដើរទៅអង្គុយរង់ចាំសុគុណនៅក្នុងឡានបាត់ទៅ ។ ដារិនីក៏បែរមកសុគុណហើយក៏និយាយបន្តថា ៖

- បងសុគុណ! ជំងឺបងមើលមិនជាទេ មែនទេហ៎?

- គឺ.. ពេទ្យថា.. ប្រហែលមិនអីទេ...!

- បានន័យថាយ៉ាងម៉េច? បងប្រាប់ខ្ញុំអោយត្រង់បានទេហ៎?

- បានន័យថា... បើបងអាចរកក្រលៀនថ្មីមកដាំជំនួសរបស់បងដែលកំពុង តែមានជំងឺនោះបាន នោះបងនឹងអាចជាសះស្បើយរស់នៅប្រក្រតីដូចគេ ដូចឯងបានហើយ...

- ហើយចុះបើ... បងរកមិនបាន...វិញនោះ?

- បងគិតថានឹងទៅអាមេរិក ក្រែងមានពេទ្យជំនាញគេអាចព្យាបាលបង បានណាអូន!

- តើធ្វើម៉េចនឹងដឹងថា ពេទ្យអាមេរិកពិតជាអាចជួយបងបាន?

- បងមិនដឹងទេ គ្រាន់តែមិនព្រមលះបង់ក្ដីសង្ឃឹមរបស់បងតែប៉ុណ្ណោះ

- បានន័យថា.. បងកំពុងតែលួងលោមអារម្មណ៍ដោយបណ្ដុះក្ដីសង្ឃឹមក្លែងក្លាយមួយហើយ... តែចំពោះ ដារិនី... អូនមិនអាចទន្ទឹងរង់ចាំចំលើយពី សេចក្ដីសង្ឃឹមក្លែងក្លាយនោះបានទេណាបង!

- ដារិនី... អូនចង់មានន័យថាយ៉ាងម៉េចហ្នឹង? បងមិនយល់ទេ...

- គឺ... មានន័យថា អូននៅក្មេង មានសុខភាពល្អ គួរណាស់តែរស់នៅមានជីវិតសុខដុមរមនាយូរអង្វែង មិនមែនមួយភ្លែតទេ ។ បងសុគុណ! ថ្វីបើ យើងបានភ្ជាប់ពាក្យរួចមែន តែក៏មិនយឺតពេលដែរបើយើងដកពាក្យពីគ្នា វិញ ។ បើអូនបន្តទំនាក់ទំនងជាមួយបង តើអូនមានសង្ឃឹមអ្វីទៅ? អូនពិតជាមិនចង់រៀបការជាមួយបង រួចហើយក៏ក្លាយជាស្រីមេម៉ាយទាំងក្មេង យ៉ាងនោះទេ... ត្បិតពាក្យសន្យាដែលបងថានឹងថែរូបអូនដល់ចាស់ស្លាប់ នោះ វាមិនអាចកើតឡើងតាមសន្យារបស់បងបាននោះឡើយ ។

CHANBOKEO.COM

ដារិទីឈ្ងោកមុខ ធ្វើមុខស្លូតស្រពោន ។ កាលបើឮធិតាវាចាដូច្នោះ បុរសយើងស្រាប់តែកកអណ្ដាតរឹងស្ទូកនិយាយលែងរួចតែម្ដង ។ បន្តិចមក ដារិទីក៏ពោលបន្តទៅទៀតថា :

- អូននៅតែស្រលាញ់បងដដែល... គ្រាន់តែអូនមិនចង់យកជីវិតដ៏រីករាយរបស់ខ្លួនមកបូជាចំពោះស្នេហាមួយដែលគ្មានដំណើរទៀងទាត់បែបនេះទេ អូនបានគេងគិតច្រើនថ្ងៃហើយថាអូនត្រូវជំរាបបងយ៉ាងណា ប៉ុន្តែបើអូន ខ្វះសេចក្តីក្លាហាននឹងជំរាបបង នោះបានន័យថាអូននឹងទាញខ្លួនអោយលង់ក្នុងសេចក្តីទុក្ខកាន់តែខ្លាំងថែមទៀត...

ភ្លាមនោះ ដារិទីងើបមុខឡើង ហើយនិយាយជាមួយសុគុណយ៉ាងម៉ឺងម៉ាត់ចំលែកថា :

- ដារិទីសូមជូនពាក្យបងវិញត្រឹមនេះចុះ...ណាំបង! ហើយ សូមបងអភ័យ ទោសអោយអូនផង ។

ថាហើយនាងក៏ដោះចិញ្ចៀនពេជ្រភ្ជាប់ពាក្យ ដាក់លើតុអោយសុគុណវិញ រួចលើកដៃជូតទឹកភ្នែក ដែលកំពុងតែស្រក់មកលើថ្ពាល់របស់នាង ។ ធិតាក៏ស្រដីជាចុងក្រោយបន្ថែមទៀតថា :

- យើងសូមរាប់គ្នាត្រឹមតែជាមិត្តទៅចុះណាំ បងសុគុណ!!

ភ្លាមនោះ មាណវីក៏បង្វិលខ្លួនថយក្រោយដើរចូលទៅផ្ទះវិញទាំងចិត្តសោកសៅ ។ សុគុណធ្វើមុខស្រលាំងកាំង ដោយភ្ញាក់ផ្អើលនឹងកិរិយាផ្លាស់ ប្ដូរដ៏លឿនចំលែករបស់នារីយើងខ្លាំងពេក ។ មាណពក៏ស្រវាយកចិញ្ចៀន ពេជ្រដ៏ភ្លឺចិញ្ចាចនោះលើកយកមកកាន់មើលមួយស្របក់ ទើបងើបឡើងដើរចេញសំដៅទៅរថយន្តដែលមានពិសិដ្ឋកំពុងតែអង្គុយរង់ចាំ ។ ដោយ ឃើញទឹកមុខមិត្តរបស់ខ្លួនមិនសូវស្រួល ពិសិដ្ឋក៏បរឡានានាំគេមកផ្ទះវិញ យ៉ាងប្រញាប់តែម្ដង :

- សុគុណ!... ទោះជាយ៉ាងណា ចូរឯងចងចាំថា ឯងនៅមានរូបខ្ញុំ មានបង លក្ខណ៍ និងលោកប៉ាផងដែរ ដែលស្រលាញ់ឯងជានិច្ច មិនថាឯងឈឺឬឯង ជាទេ... កុំគិតផ្ដេសផ្ដាសណាំ... ឮហើយនៅ?

សុគុណញញឹមស្ងួតមិនតបអ្វីវិញទេ ។ គេនៅស្ងាត់ស្ងៀមរហូតទាល់តែដល់ផ្ទះវិញ ។ លុះឃើញសុគុណរត់ចូលបន្ទប់ពួនសំងំ វិរលក្ខណ៍ក៏ចាប់ពិសិដ្ឋ មកឈ្លេចសួរហេតុការណ៍ ។ បន្តិចក្រោយមក ពិសិដ្ឋក៏ជំរាបលាបងស្រី របស់សុគុណត្រលប់ទៅផ្ទះវិញទៅ ។

រាត្រីនោះ...

កំលោះវិទ្ធសុគុណយើងអង្គុយសំកុកនៅលើពូក សំលឹងមើលរូបថត របស់គេទាំងឡាយដែលធ្លាប់បានដើរលេងថតជុំគ្នាជាមួយនិងដារិទីតែ ពីរនាក់.. រួចហើយក៏អាននៅគ្រប់សំបុត្រទាំងឡាយដែលនាងធ្លាប់ផ្ញើអោយនាយកាលពីនៅសហរដ្ឋ ។ គេអានទៅអានមក ដដែលជាដដែល រហូតដល់ជិតភ្លឺ នៅតែគិតមិនអស់ចិត្តថាហេតុអ្វីខ្លួននាយ

CHANBOKEO.COM

ដែលធ្លាប់តែនឹក ថាខ្លួនជាមនុស្សមានសំណាងបំផុត ប្រែក្លាយជាមនុស្សអស់សង្ឃឹមតែក្នុង មួយប៉ប្រិចភ្នែកដូច្នេះ? គេក្ដុកក្ដួលក្នុងចិត្តក្រៃលែង ទីមួយតូចចិត្តនឹងជំងឺ ទីពីរឈឺចិត្តនឹងគូដណ្ដឹងគេជូនពាក្យជូនសំដីវិញ ទីបីចុកចាប់ព្រោះក្ដីសង្ឃឹមមិនបានដូចបំណង ។ ពេលនេះ សុគុណមានទឹកមុខកាន់តែស្លេកស្លាំងកាន់ តែខ្លាំងឡើងៗ សឹងតែបន់ឱ្យខ្លួនដាច់ខ្យល់ស្លាប់ភ្លាមៗឥលូវនេះ ។

## លាហើយស្នេហ៍

ហេតុអ្វីសុរិយានៅរឿងរះ ហេតុអ្វីឱភាសនៅចាំងចែង
ខុសអ្វីរូបខ្ញុំបែរចំបែង ម្នាក់ឯងគ្មានស្បើយល្ហើយឱរា ។
ហេតុអ្វីពពេជហើរមានគូ មេឃខ្មៅយប់យូរនៅតារា
ប្លែកតែទ្រូងខ្ញុំធំខ្លោចផ្សា គេងស្ដាយពាក្យថា "ស្នេហ៍លាហើយ" ។
ស្ដាយពេលកន្លងយូរខែឆ្នាំ ខ្ញុំគេងរង់ចាំគ្មានប្រែឡើយ
ទឹកគូនៃបនិត្យឥតមានស្បើយ បេះដូងព្រាត់ហើយពីឱរា ។
ផ្ការលាន់ក្នុងទ្រូងលាន់គគ្រឹក ទឹកភ្លៀងក៏ស្រក់ចាកនេត្រា
ស្ដាយស្នេហ៍ដែលស្មោះប្រែអាសារ សល់ត្រឹមពាក្យថា "លាហើយស្នេហ៍!"

រ៉ឹង! រ៉ឹង! ទូរសព្ទ័លាន់ឮឡើង... ពិសិដ្ឋប្រែខ្លួនបើកភ្លើងមើល នាឡិកា ឃើញម៉ោងបួនភ្លឺ :
- អាឡូ មានការអ្វីទៅសុគុណ បានជាដាស់គ្នាទាំងព្រហាម?
- គឺគ្នាគេងមិនលក់... គិតថា ចង់ចេញទៅលេងក្រៅក្រុងមួយគ្រា
- បើចង់ទៅ ម៉េចក៏មិនទៅទៅ... ចាំប្រាប់គ្នាធ្វើអី?
- ព្រោះតែចង់អោយឯងជូនទៅណា៎
- ចង់ទៅអង្កាល់ដែរ? កុំប្រាប់ណា៎ថា ឯងចង់ទៅឥលូវនេះ...
- មែនហើយ... ធ្វើដំណើរព្រលឹមអញ្ចឹងទើបត្រជាក់ស្រួលខ្លួន
- អូហ៎មិនកើតទេ សំលាញ់! គ្នាត្រូវទៅធ្វើការណា៎!
- អញ្ចឹងសុំគេឈប់មួយថ្ងៃទៅ...
- ហើយឯងចង់ទៅណា៎?
- ទៅចំការរបស់ឯងនៅឯបាត់ដំបង...

CHANBOKEO .COM

- ពុទ្ធោទៅដើរលេងអីបានឆ្ងាយម្ល៉េះ?

- ម៉េច? ជូនឬមិនជូន?

- អឺ... អឺ... ទៅឥលូវហើយ ហើយឯងមិនជំរាបលោកប៉ានិងបងវរលក្ខណ៍ ទេឬអី?

- ចាំគ្នាសរសេរចំណារជំរាបគាត់ចុះ ព្រោះមិនចង់ដាស់គាត់ទាំងព្រហាម ។

៩៩៩៩៩៩៩៩៩៩៩៩៩៩៩៩៩៩៩៩៩

៩៩៩៩៩

៩

CHANBOKEO . COM

# វគ្គទី២
# និស្ស័យថ្មី

ជាងបួនម៉ោងក្រោយមក អ្នកទាំងពីរក៏បានមកដល់ក្រុងបាត់ដំបង ហើយគេក៏បន្តដំណើរតាមផ្លូវដងស្ទឹង សំដៅទៅរកចំការក្រូចមួយនៅម្តុំ ភូមិវត្តគរខាងត្បូងទីក្រុង ។ កំពុងតែបើករថយន្តភ្លេចខ្លួន នៅម្តុំផ្សារលើ ស្រាប់តែមានមាណវីមួយរូបរត់កាត់ផ្លូវពីខាងលិចសំដៅទៅមាត់ស្ទឹងយ៉ាង លឿនតែម្តង ។ ពិសិដ្ឋភ្ញាក់ព្រើតចាប់ហ្វ្រាំងស្ទើរមិនទាន់ ។ រថយន្តក៏ស្ទុះ ទៅប៉ះនារីនោះភឹងដួលរមៀលពីរជុំ ។ សំណាងល្អដែរ ដែលផ្លូវវាមានកន្ទុកច្រើន មិនអាចបើកបរលឿនបាន កុំអីពេលនេះ ជីវិតរបស់នារីយើងសូន្យ បាត់ទៅហើយ ។ កំលោះទាំងពីរក៏ស្ទុះចេញយ៉ាងលឿនពីរថយន្ត រត់សំដៅ ទៅរកមើលមាណវី ស្រាប់តែដាក់ភ្នែកក្រលេកទៅម្ខាង ឃើញបុរសម្នាក់ក្នុងវ័យប្រហែលជាងសាមសិបឆ្នាំ កំពុងតែកាន់ពូថៅរត់ដេញស្រីក្មេងនោះ ហើយទាំងស្រែកវ៉ាង១ឡើងថា :

- ឯណា? មីខ្មៅវ្យងវាស្លាប់ហើយនៅ? បើមិនទាន់ទេ.. យើងនឹងកាប់វាឱ្យងាប់ពេលនេះតែម្តង...

នារីនោះឮហើយក៏ប្រែខ្លួនងើបអង្គុយឡើងហើយស្រែកទាំងរន្ធត់ថា :

- អូយ! ... ជួយខ្ញុំផង...!

ការឃើញបុរសនោះលើពូថៅយាយីស្រីក្មេងនោះដូច្នោះ សុគុណទ្រាំមិនបានក៏យកជើងគៀងបុរសនោះដួលប្រួសធ្លាក់ពូថៅទៅម្ខាង ។ គាត់ក៏ងើបឡើងវិញទាំងទទ្រេតទទ្រោតទំនងស្រវឹងស្រាស្រែកគំហកទៅសុគុណ ទាំងកំហឹងថា :

- នែ៎អាស្វាពីរនាក់! ឯងចេះមកហែហៃអីដែរ?

ថាហើយ គាត់ក៏ស្រវាពូថៅរកដេញកាប់អ្នកទាំងពីរសាជាថ្មី ។ ពិសិដ្ឋឃើញហើយក៏ស្ទុះទាញដៃនារីអោយក្រោកឡើងជាប្រញាប់ ហើយក៏រុញ នាងចូលទៅក្នុងឡានទើបបែរខ្លួនទៅរកជួយសុគុណដែលកំពុងតដៃ រង កំលាំងពូថៅ ដែលហោះឆិត១ រហើយសក់ក្បាល ។ ទំរាំតែពិសិដ្ឋមកដល់ សុគុណបានប៉ែងជើងបុរសនោះឱ្យដួលរបូតពូថៅពីដៃទៅហើយ ។ ពិសិដ្ឋ

CHANBOKEO.COM

ក៏ស្ទុះទៅជួយចាប់ក្រៀកដៃបុរសកំណាចក្រពាត់ទៅក្រោយ ហើយក៏ដោះ អាវបុរសនោះពីខ្លួនចងដៃគាត់ភ្លាម ។ បន្តិចមក អ្នកស្រុកជិតខាងក៏មក ដល់ព្រមគ្នាឈូឆរព្រមទាំងមានក្រុមសមត្ថកិច្ចមកដល់ដែរ ។ បុរសនោះក៏ ត្រូវប៉ូលីសនាំខ្លួនចេញបាត់ទៅ ។

ពិសិដ្ឋនិងសុគុណក៏ដើរចូលឡានវិញ ស្រាប់តែប្រទះឃើញស្រីក្មេង មួយរូបនោះ មានធ្លាក់ឈាមពីច្រមុះព្រមទាំងមានរបួសច្រើនកន្លែង ។ គេ ទាំងពីរសំលឹងមុខគ្នា ហើយក៏សំរេចចិត្តនាំធិតាទៅមន្ទីរពេទ្យធំ នៅឯក្រុង បាត់ដំបង ។

នៅក្នុងមន្ទីរពេទ្យ...

- សង្ឃឹមថានាងមិនអីទេ... (ពិសិដ្ឋពោលទាំងចិត្តនឹកព្រួយបារម្ភគ្បិតខ្លួន បានធ្វើអោយនាងរងគ្រោះ )

សុគុណយកដៃទះស្មាមិត្ត :

- កុំពិបាកចិត្តពេកអី... តាមមើលនាងមិនជាមានរបួសធ្ងន់អីប៉ុន្មានទេគ្បិត ពេលនោះ ខ្ញុំឃើញនាងងើបដើរបាន...

ពិសិដ្ឋញញឹមតបវិញ ។ រំពេចនោះ លោកគ្រូពេទ្យមួយរូបចេញមក ហៅអ្នកទាំងពីរទៅពិភាក្សា :

- សូមជំរាបអ្នកទាំងពីរថា នារីម្នាក់នេះ បានទទួលការរងគ្រោះខាងផ្លូវ ភេទយ៉ាងធ្ងន់ធ្ងរ ថែមទាំងត្រូវសន្ទុះរថយន្តបុកចំត្រូវឆ្អឹងជំនីរខាងឆ្វេង ថែមទៀត តែមិនមានបាក់ឆ្អឹងឆ្អែងទេ គ្រាន់តែមានស្នាមជាំយ៉ាងធំ ប៉ុណ្ណោះ ប្រហែលជានាងត្រូវរក្សាខ្លួនយូរថ្ងៃហើយទើបជាសះស្បើយ ។ សូមលោកមេត្តាជួយផ្តល់ដំណឹងទៅក្រុមគ្រួសាររបស់នាងផង ។

សុគុណនិងពិសិដ្ឋ មើលមុខគ្នាទៅវិញទៅមក គ្បិតគេទាំងពីរគ្មាន នរណាស្គាល់ក្រុមគ្រួសាររបស់ធិតាម្នាក់នោះសោះ ។ តើអោយគេត្រូវធ្វើ ដូចម្តេចទៅ? អ្នកទាំងពីរក៏ត្រលប់ទៅកន្លែងអ្នកជំងឺវិញ ដើម្បីសាកសួរ ដំណឹងពីធិតារងគ្រោះ ។

- ប្អូនស្រីឈ្មោះអីដែរ? (ពិសិដ្ឋសួរ)

ធិតានោះមានមុខមាត់នៅក្មេងច្រឡឹង ប្រហែលជា១៨ឬ១៩ឆ្នាំ ប៉ុន ហ្នឹង ។ កាលបើឮពិសិដ្ឋសួរដូច្នោះនាងក៏ឆ្លើយថា :

- ចាស ឈ្មោះសំនៀង...! អរគុណបងៗទាំងពីរណាស់ ដែលបានជួយខ្ញុំឱ្យ រួចគ្រោះថ្នាក់... (មាណវីលើកដៃសំពះឡើង)

- ខុសហើយ... យើងក៏បានបង្កគ្រោះភ័យដល់នាងដែរ.. មិនបាច់អរគុណ ទេ នាំតែខ្ញុំរឹតតែមានអារម្មណ៍ថាខុសរិតតែច្រើន (ពិសិដ្ឋឆ្លើយវិញ)

រំពេចនោះ សុគុណក៏សួរនាងថា :

- ហើយចុះឪពុកម្តាយនឹងក្រុមគ្រួសាររបស់ប្អូននៅឯណាដែរ? យើងនឹង ជួយនាំដំណឹងទៅជំរាបគាត់ អោយបានដឹងថានាងនៅឯណា ។

ស្រាប់តែ តរុណីយើងរលីងរលោងទឹកភ្នែកមួយរំពេច ។ បន្តិចមកនាង ក៏ជូតទឹកភ្នែកហើយស្រដីថា :

- ខ្ញុំគ្មានឪពុកម្តាយទេ... គឺពុកខ្ញុំស្លាប់យូរហើយ.. តែម៉ែទើបតែស្លាប់កាល ពីប៉ុន្មានអាទិត្យមុននេះឯង...

ស្រដីបានតែប៉ុណ្ណេះ មាណវិក៏យំហ៊ូតែម្តង ។ សុគុណនិងពិសិដ្ឋសំលឹង មុខគ្នាធ្វើឡឹងឡង់ មិនដឹងថាត្រូវសួរនាងយ៉ាងម៉េចទៀត ។ មើលទៅនារី ដូចជាបានប្រទះនូវឆាកជីវិតយ៉ាងខ្លោចផ្សាណាស់ហើយបានជាទ្រហោរយំ ដោយឥតខ្មាសអៀនយ៉ាងនេះ ។ បន្តិចមក សុគុណក៏លួងលោមថា :

CHANDOKEO.COM

- ប្អូនស្រី! ពិតមែនតែយើងមិនដែលស្គាល់គ្នាពិតមែន... ប៉ុន្តែកាលបើបង ប្រុសទាំងពីរនាក់នេះ ប្រទះឃើញប្អូនស្ថិតនៅក្នុងសភាពធ្ងន់ធ្ងរ បងក៏មិន អាចទ្រាំបញ្ឈរភ្នែកមើលបានដែរ ។ បើមានអ្វីដែលអាចអោយបងជួយ បាន នាងនិយាយប្រាប់មកចុះណាំ ក្រែងបងអាចជួយជាដៃជើងភ្នែកច្រមុះ ខ្លះ១.... ហើយក៏ឈប់គិតទៀតទៅថា នាងជាមនុស្សដែលអភព្វជាងគេ ក្នុងលោកនេះ...

ឮសំដីលួងលោមដ៏ពិរោះនេះកាលណា ធិតាក៏ងើបមុខឡើង ជូតទឹក ភ្នែកភ្លាម ហើយក៏ពោលឡើងដោយកំហឹងថា :

- អ្វីដែលខ្ញុំប្រាថ្នាធំជាងគេបង្អស់ពេលឥលូវនេះ គឺធ្វើយ៉ាងណាដែលបុរស ប្រព្រឹត្តអំពើបាបលើស្រី១ ត្រូវបានទទួលនូវការដាក់ទោសដោយយុត្តិធម៌ ដើម្បីជាគំរូដល់អ្នកដទៃទាំងអស់គ្រប់គ្នាថា ថ្វីបើខ្លួនជាប្រុសក៏ពិតមែន ក៏ប៉ុន្តែត្រូវរក្សាតម្លៃសីលធម៌ផង ទើបគេហៅថាប្រុស... មិនមែនអាងខ្លួន ប្រុសហើយ ចង់ធ្វើអ្វីស្រេចតែចិត្តនោះទេ ។

សុគុណនិងពិសិដ្ឋមើលមុខគ្នាសាជាថ្មី ។ បន្តិចមក សុគុណក៏ពោលបន្ត ទៅទៀតថា :

- មើលទៅប្អូនស្រី ហាក់ដូចជាកំពុងមានអារម្មណ៍ល្អក់កករណាស់ ។ បង ថាប្អូនគួរធ្វេចសំរាកយកកំលាំងសិនទៅ ។ ចាំស្អែក ពេលបងមកលេងប្អូន សាជាថ្មី ចាំយើងជជែកគ្នាបន្តទៀត...

ស្រាប់តែសំនៀងឆ្លើយថា :

- ប៉ុន្តែ... ខ្ញុំមិនអាចទ្រាំសំរាកទីនេះបានទេ..

- ម៉េចអញ្ចឹង? (ពិសិដ្ឋសួរ) លោកគ្រូពេទ្យបានប្រាប់ខ្ញុំថានាងត្រូវនៅថែ រក្សាជំងឺពីរបីថ្ងៃទៀតទើបអាចចេញទៅផ្ទះបាន ។

- ប៉ុន្តែ...ខ្ញុំគ្មានប្រាក់សោះសំរាប់បង់ថ្លៃព្យាបាល...

សុគុណឮដូច្នោះក៏ញញឹមឡើង ហើយឆ្លើយវិញថា :

- រឿងនេះបងទាំងពីរចាត់ចែងអោយហើយ ប្អូនស្រីគេងទៅ ចាំស្អែកបង មកមើលប្អូនទៀតណាំ

សំនៀងឮហើយក៏លើកដៃសំពះ :

- អរគុណបងប្រុសទាំងពីរណាស់ចំពោះសន្ដានចិត្តដ៏ថ្លៃថ្លានេះ ។

សុគុណនិងពិសិដ្ឋញញឹមដាក់នាង បញ្ចេញនូវសមានចិត្តអាណិតអាសូរ ចំពោះនាងហើយក៏បបួលគ្នាចេញទៅ ។ សំនៀងសំលឹងមើលតាមអ្នកទាំង ពីររហូតផុតមាត់ទ្វារទើបប្រែខ្លួនទាញភួយដណ្តប់ធ្វេចសំងំយកកំលាំង ។ វេលានោះ នាងគេងគិតមមៃតែម្នាក់ឯងថា :

- តើបុរសក្មេង១ពីររូបនេះជានរណា? ហេតុអ្វីក៏គេមានសមានចិត្តម្ល៉េះ? ហេតុអ្វីក៏បុរសខ្លះទៀត ដែលមានវ័យចំណាស់ជាង ហើយធ្វើរហូតទៅដល់ ជាឪពុកគេ តែបែរជាមានចិត្តឧត្បាត ខ្វះសីលធម៌ចំពោះមនុស្សទន់ខ្សោយ ទៅវិញ តួយ៉ាងដូចជាបុរសកំណាច ដែលលីពូថៅរត់ដេញកាប់យើងមួយ ស្របក់មុននេះជាដើម ។ តើបុរសទាំងពីររូបនោះ បានទទួលការអប់រំយ៉ាង ណា ទើបគេសំដែងមានគុណធម៌ និងសីលធម៌យ៉ាងខ្ពង់ខ្ពស់បែបនេះ? នៅក្នុងស្រុកភូមិយើង បើបុរសគ្រប់គ្នាមានសន្ដានចិត្តចំពោះញាតិហើយ ចេះជួយគ្នាពេលមានធុរៈតូចធំដូចបុរសពីររូបនេះ ជីវិតក្នុងសង្គមខ្មែរមិន ដឹងជាសុខដុមរមនាយ៉ាងណាទេ...

CHANBOKEO.COM

ស្ដីពីសុគុណនិងពិសិដ្ឋម្ដង...

ពិសិដ្ឋបាននាំសុគុណមកដល់ដីចំការមួយ ដែលមាន ដើមឈើស៊ីផ្លែដុះយ៉ាងត្រឈឹងត្រឈៃ មានផ្ទះធំមួយខ្ពង់ប្រក់ក្បឿងយ៉ាងស្អាត សង់នៅចំ កណ្ដាលដីភូមិ ។ ភ្លាមនោះតាចាស់យាយចាស់ពីរនាក់ចេញមកទទួល អ្នកទាំងពីរដល់មាត់របងចំការ :

- អូហ៎! ចៅសិដ្ឋអើយ សុខសប្បាយជាទេហ៎ចៅ? (តាចាស់ឧទានឡើង)

នោះគឺតាក្រូច យាយប្រាង ជាអ្នកចាំចំការអោយគ្រួសាររបស់ពិសិដ្ឋ ។ គ្រាន់តែក្រលេកឃើញគាត់ទាំងពីរភ្លាម ពិសិដ្ឋក៏អោនសំពះសួរ :

- ជំរាបសួរ តា! យាយ! ខ្ញុំសុខសប្បាយទេ ។ នេះពួកម៉ាកខ្ញុំឈ្មោះ វិរិទ្ធសុគុណ តាយាយនៅចាំគេទេ? គេធ្លាប់មកលេងទីនេះកាលពីនៅ ពួកយើងនៅក្មេងៗនោះអី ។

- ចឹក៏មិនចាំហាក់! អានាងនេះចូលចិត្តបរិភោគស្វាយឱក់រ៉ងណាស់! មកទី នេះពេលណា សួររកតែស្វាយនេះទេ (ដូនចាស់ឆ្លើយ)

ភ្លាមនោះសុគុណគេអោនសំពះតាយាយភ្លាម :

- ជំរាបសួរបាទ!

- អឺ...ចៅអើយ! ហេតុអ្វីទឹកមុខហាក់ដូចជាស្លេកស្លាំងម្ល៉េះ? មិនស្រួល ខ្លួនព្រោះធ្វើដំណើរឆ្ងាយមែនទេ? (តាក្រូចសួរ)

សុគុណញញឹមមិនទាន់ឆ្លើយអ្វីផង ពិសិដ្ឋក៏អោនខ្សិបប្រាប់គាត់តិចៗ:

- ចូលទៅក្នុងផ្ទះសិនទៅតា! ចាំខ្ញុំនិយាយរឿងប្រាប់ ។

តាក្រូចយាយប្រាងឮដូច្នោះក៏ប្រញាប់ប្រញាល់ជួយរើយកឥវ៉ាន់ពីខាង ក្រោយគូថឡានឡើងយកទៅលើផ្ទះភ្លាម ។ គ្រាន់តែមកដល់ខាងលើផ្ទះ មិនទាន់ សុគុណក៏លូនទៅលើគ្រែសន្ទូកជើងភ្លាម ទំនងអស់កំលាំង ។ ពិសិដ្ឋឃើញហើយក៏ដើរទៅជិតនាយសួរថា :

- សុគុណ! ឯងមានលេបថ្នាំហើយនៅ?

- លេបហើយ! គ្រាន់តែរាងដូចជានៅធីងធោងបន្តិច ត្បិតអីថ្ងៃនេះ ខ្ញុំយក ខ្លួនទៅតតាំងនឹងបុរសកំណាចនោះការពារស្រីក្មេងម្នាក់នោះខ្លាំងបន្តិច ទើប ឥលូវបែបចង់រើបជំងឺហើយ!

ថាហើយសុគុណក៏ធ្មេចសំងំយកកំលាំង ។ ពិសិដ្ឋលូកដៃទៅស្ទាបថ្ងាស របស់មិត្តស្រាប់តែភ្ញាក់ព្រើតឡើង :

- យ! ឯងកំពុងគ្រុនក្ដៅតើហ៎ សុគុណ? ហេតុអ្វីនៅពេទ្យអំបាញមិញ ម៉េច បានជាឯងមិនមាត់? តោះ! ងើបឡើងខ្ញុំនាំឯងទៅពេទ្យវិញ បើមានការ អ្វីទៅ ពេទ្យអាចជួយឯងបានទាន់ពេលវេលាណ៎ ។

តែសុគុណប្រកែក :

- មិនអីទេ ក្នាគ្រាន់តែអស់កំលាំងប៉ុណ្ណឹងឯង សំរាកបន្តិចទៅ លែងអី ហើយ កុំបារម្ភអីច្រើនពេក ។

តែពិសិដ្ឋនៅតែមិនទុកចិត្តដដែល ។ គេក៏បង្ខំអោយសុគុណឡើងឡាន ត្រលប់ទៅពេទ្យវិញយ៉ាងប្រញាប់ ។ លុះមកដល់ពេទ្យធំបាត់ដំបងពិនិត្យ រោគកាលណា លោកគ្រូពេទ្យក៏លែងអោយសុគុណត្រលប់ទៅផ្ទះ ព្រោះ

CHANBOKEO.COM

មាណពក្តៅខ្លួនខ្លាំងពេក ។ សុគុណក៏ត្រូវនៅសំរាកនៅទីនោះសិនទំរាំកំដៅ ខ្លួនចុះថមថយអនុភាព ។ ពិសិដ្ឋក៏ត្រលប់ទៅស្នាក់ងផ្ទះក្នុងចំការងណោះ វិញទាំងបារម្ភ ។ នាយគិតថានឹងទូរសព្ទ័ទៅជំរាបលោកវរៈជាឪពុកសុគុណ ដែរ តែសុគុណបានហាមឃាត់ ។ ការពិត គេមិនចង់អោយឪពុកដឹងថា នាយមិនស្រួលខ្លួនទេ នាំតែលោកពិបាកចិត្តដោយសាររឿងនេះ ។ ម្យ៉ាង ទៀត នាយក៏មិនចង់អោយដំណឹងរបស់នាយដែលត្រូវចូលពេទ្យសាថ្មីនេះ បានឮទៅដល់ក្រមុំដារិនីផង ត្បិតកំពុងតែតូចចិត្តនឹងនារីដែលច្រានចោល រូបគេចេញទៅ នៅពេលគេកំពុងតែត្រូវការកំលាំងចិត្តបំផុត ។

ស្អែកឡើង...

សុគុណអផ្សុកពេក ក៏ចេញដើរមករំហើយលេងខាងក្រៅអាគារ ស្រាប់តែប្រទះអ្នកជំងឺស្រីម្នាក់អង្គុយសំកុកនៅកៅអីសួនច្បារក្នុងបរិវេណ មន្ទីរពេទ្យ ។ គ្រាន់តែក្រលេកឃើញនាងភ្លាម គេក៏ស្ទុះដើរទៅជិតហើយ ហៅនាងថា :

- សំនៀង?...

ស្រាប់តែធិតាងើបមុខឡើង :

- អូហ៎... បងប្រុស?... មកសំរាន្តពេទ្យទីនេះដែរ?

- គឺ...ខ្ញុំគ្រុនក្តៅខ្លាំងពេក តែឥលូវបានធូរស្រាលបន្តិចហើយ ។ ចុះប្អូនស្រី វិញនោះយ៉ាងណាដែរ?

សំនៀងយកដៃជូតទឹកភ្នែក ហើយឈ្ងោកមុខនៅស្ងៀមមួយស្របក់ ទើបឆ្លើយថា :

- របួសផ្លូវកាយប្រហែលជាធូរស្រាលហើយ ប៉ុន្តែរបួសផ្លូវចិត្តវិញ... មិន ដឹងថាមានថ្ងៃជាសះស្បើយឬក៏អត់ទេ...

សុគុណឮដូច្នោះក៏នៅស្ងៀម មិនហ៊ានសួរតទៅទៀត ក៏បង្វែររឿង ផ្សេងវិញ :

- សំនៀងចូលចិត្តអានសៀវភៅទេ?

- ចូលចិត្ត... គ្រាន់តែគ្មានសមត្ថភាពទិញសៀវភៅអានប៉ុណ្ណោះ ។

- គឺ... ខ្ញុំមានសៀវភៅប្រលោមលោកពីរបីក្បាល ដែលខ្ញុំយកមកជាប់ មកតាមខ្លួន រឿងខ្លះជារឿងថ្មីទើបនឹងបោះពុម្ព ចង់អានលេងទេ? គ្រាន់ នឹងកែអផ្សុក ឬប្តូរអារម្មណ៍ក្នុងខ្លួនខ្លះៗ?

- អានយ៉ាងម៉េចនឹងចូលទៅ បើអារម្មណ៍ខ្ញុំស្មុគស្មាញយ៉ាងនេះ?

- បើអញ្ចឹង... យើងគូររូបលេងវិញ... យ៉ាងម៉េចដែរ?

- បងប្រុសចូលចិត្តគូររូបណាស់មែនទេ?

- ចេះតិចៗដែរ ល្មមអាចផាត់ពណ៌អោយយក្សតាមក្លោងទ្វារវត្តបានយ៉ាង ស្រស់អស់ទាស់តែម្តង ។

ឮមាណពនិយាយបែបកំប្លែង ធិតាក៏ញញឹមឡើង :

- ប៉ុន្តែ... តើយើងបានអ្វីមកគូរទៅ?

ស្រាប់តែសុគុណស្ទុះទៅយកសំពៀតផ្ទាល់ខ្លួនរបស់គេ ពីបន្ទប់អ្នកជំងឺ

CHANBOKEO.COM

មកភ្លាមហើយក៏ស្រវាលូកយកសៀវភៅធំមួយដែលមានក្រដាសផ្ទាំងរឹងៗ
សំរាប់គូរគំនូរព្រមទាំងខ្មៅដៃពណ៌ប្អូនដប់ដើមទៀតផង :

- ឃើញទេហ៏? នេះនែ៎... ប្រដាប់ប្រដា... ប្អូនស្រីគូរជាមួយបងទេ?

សុគុណក៏ហែកក្រដាសមួយសន្លឹកហុចអោយទៅតរុណីយើង :

- ប្អូនសាកល្បងគូរមើលទៅ... គូរអ្វីក៏បានដែរ មិនចាំបាច់ស្អាតទេ តែសូម គូរតាមសមត្ថភាពដែលអាចធ្វើទៅបាន ។

ធិតាសំលឹងមុខសុគុណ ហើយចាប់ញញឹមតិចៗមកវិញហើយ ។ នាងក៏
លូកដៃឈោងទទួលយកក្រដាសនិងខ្មៅដៃពណ៌ ពីសុគុណមកគូរភ្លាម ។ នាយយើងឃើញដូច្នោះក៏ញញឹមឡើងដែរ ។
គេក៏ចាប់ខ្មៅដៃគូសវាស យ៉ាងសប្បាយ ហើយក៏និយាយលេងពីនេះពីនោះជាមួយសំនៀង ទោះបី ជាពេលខ្លះ
នាងគ្រាន់តែញញឹមមិនស្តីតបអ្វីមកនាយក៏ដោយ ។ បន្តិចមក គេក៏គូសបានរូបទេសភាពស្ពានថ្មមុខសាលាខេត្តបាត់ដំបង
ដោយមានសត្វ តោធំៗមួយគូអង្គុយហាមាត់ចាំយាមស្ពានទៀតផង ។ ភ្លាមនោះ នាយ យើងក៏ងើបមុខឡើងសួរមាណវីថា :

- ប្អូនស្រី! គូរបានរូបស្អីមួយហើយឬនៅ?

សំនៀងឮសំនួររបស់សុគុណ ក៏នៅស្ងៀមធ្វើអឹមអៀន លាក់រូបមិនឱ្យ នាយឃើញ ។
សុគុណឃើញកិរិយានាងរបៀបលាក់លៀម ក៏ញញឹមហើយ សួរឡើងបន្តថា :

- កុំខ្មាសកុំអៀនអីណា៎! គូរស្អាតឬមិនស្អាតក៏ចេះតែគូរទៅ ធ្វើម៉េចអោយ
តែចេញពីអារម្មណ៍នឹងស្នាដៃរបស់ខ្លួនផ្ទាល់ ។

សំនៀងលួចញញឹមតិចៗ ហើយក៏គូរតទៅទៀត ។ សុគុណក៏ចាប់បើក ទំព័រថ្មីគូររូបមួយទៀតដែរ ។ យូរៗម្តង
គេលួចចោលកន្ទុយភ្នែកមើលធិតា ដែលអង្គុយឈ្ងោកមុខផ្ទៀងផ្ទងគូររូបដោយផ្ចិតផ្ចង់ ។ ពិតមែនតែនាងជា នារីធម្មតាៗ
ស្លៀកពាក់សាមញ្ញៗ តែសម្រស់សោភ័ណរបស់នាងបានលេច អណ្តែតមកគួរអោយចាប់ចិត្តចេតនាពេកក្រៃ ។
ក្រោមផ្ទៃមេឃពណ៌មាស ដ៏ស្រទន់នាពេលព្រលប់ វង់ភក្ត្រ៍ធិតាស្រស់ស្អាតមិនខុសពីតួរបាំទេវី អប្សរានៅក្នុងរាជវាំងនោះឡើយ ។
សុគុណលួចគយគន់ស្ទើរតែភ្លឹកស្មារតី ម្តងៗទៅហើយ ។ គេលួចញញឹមម្នាក់ឯង សរសើរសំណាងខ្លួនឯងដែល
កាលៈទេសៈបាននាំរូបនាយអោយមកប្រទះទេពធិតាដ៏ស្រស់ស្អាតមួយរូប នៅពេលនេះ ។
គេលួចសំលឹងគយគន់រូបនាងយ៉ាងពិនិត្យពិច័យ ទំនងដូច ជាមានបំណងគូររូបនាងផ្តិតនៅក្នុងបេះដូងរបស់គេហើយ ។

ទេវីកំពូលដួងចិត្ត

១. ឱ ស្រីល្អល្វតល្វន់ ទន់ភ្លន់ សមជានារីខ្មែរ
រូបអូនល្អម្ល៉េះទេ អោយបងគួចស្នេហ៍ បេតីវរមិត្រ ។

២. ម្រាមដៃតូចស្រលូន ដងខ្លួនកិន្នរវិចិត្រ
ដំណើរសមសួនពិត វង់ភក្ត្រ៍វរមិត្រ ញញឹមមានន័យ ។

៣. ឱ ទេវីខេមរា សោភាស្រស់លើសអស់ស្រី

CHANBOKEO.COM

ក្រោមមេឃលើផែនដី  មានតែពិសីដែលបងលង់ស្នេហ៍ ។

៤.	ឆ្លើយមកថាអូនស្មគ្រ័ វរលក្ខណ៍ បងចាំមាសមេ

ហត្ថារៀមទាំងទ្វេ  ទទួលក្តីស្នេហ៍ តែទេវីអូនមួយ ។

មួយស្របក់ក្រោយមក នាយយើងសង្កេតឃើញថាមាណវីយើងហាក់ ដូចជាមានកិរិយាល្ងិតល្ងៃទៅក្នុងខ្លួន ក៏បែរបបួលនារីចូលទៅសំរាកវិញ :

- មើលទៅមួសនាំគ្នាចេញធ្វើការហើយ ។ សំនៀង! យើងគិតសំរាកសិន ទៅ! ចាំស្អែកចាំយើងគូរបន្តទៀតណាំ!

- ចាំស!

ធិតាក៏ងើបឡើងជួយរៀបទុកដាក់ឥវ៉ាន់គំនូរទុកវិញ តែនាងលួចបត់ទុកនូវគំនូររបស់នាងមិនអោយសុគុណឃើញទេ ។  ចៃដន្យ កិរិយាលិបលរបស់នាងបែរជាធ្វើឱ្យបុរសយើងចាប់ភ្លឹកទៅវិញ :

- ប្អូនគូររូបអ្វីដែរ អោយបងសុំមើលផងបានទេ?

- រូបមិនស្អាត មិនហ៊ានអោយមើលទេ...

- ណ្ហើយ! មិនអោយក៏បានដែរ ។ អោយតែប្អូនសប្បាយចិត្ត ធ្វើយ៉ាងម៉េច ស្រួល ក៏ធ្វើទៅ ។

ភ្លាមនោះ នាយលូកយកសៀវភៅមួយក្បាលចេញមក :

- នេះជារឿងប្រលោមលោកទើបតែនឹងចេញថ្មី ឈ្មោះផ្កាយរង្វែងមេឃ ប្អូនស្រីយកទៅអានលេងទៅក្រែងអាចលាងអារម្មណ៍ហ្មួហ្មងបានខ្លះ ។

គ្រាន់តែក្រលេកឃើញរូបលើក្របខាងក្រៅ ធិតាហាក់ដូចជាចាប់ចិត្ត នឹងរូបនោះណាស់ ក៏លូកដៃទទួលយកភ្លាម :

- ចាំស! អរគុណ!

បន្ទាប់មក គេក៏បំបែកផ្លូវគ្នាត្រលប់ទៅរកបន្ទប់សំរាករៀង២ខ្លួន ។

ស្អែកឡើង...

ពិសិដ្ឋមកលេងនឹងសុគុណ ឃើញនាយមានអាការៈប្រក្រតីវិញ ក៏សុំ អនុញ្ញាតគ្រូពេទ្យអោយនាយទៅសំរាកទៅផ្ទះ ។ សុគុណរៀបចំឥវ៉ាន់រួច ហើយក៏ដើរចេញមកក្រៅ ។ បានពីរបីជំហាន ស្រាប់តែនាយទុចង៉ក់ បែរ មើលទៅក្រោយធ្វើរេរា២ ។ ពិសិដ្ឋឃើញកិរិយារបស់មិត្តដូច្នោះក៏សួរថា:

- ឯងភ្លេចអីឬសំលាញ់?

- មែនហើយ! គឺភ្លេចរឿងមួយ..មែន!

- រឿងអ្វីទៅ?

CHANBOKEO.COM

- ឯងមិនចាំទេ? គឺរឿងក្មេងស្រីដែលយើងនាំមកមន្ទីរពេទ្យនេះ កាលពី ម្សិលម៉្ងៃនោះ? ថ្ងៃនេះ យើងមិនទាន់បានទៅសួរសុខទុក្ខគេនៅឡើយទេ ។

- យី! ឯងចាប់អារម្មណ៍ពីគេដល់ប៉ុណ្ណឹងផងឬសំលាញ់?

ពិសិដ្ឋចំអន់លេង តែសុគុណមិនឮទេ ។ គេបែរជាដើរសំដៅទៅរក អាគារដែលសំនៀងស្នាក់នៅថែជំងឺ ស្រាប់តែប្រទះនឹងស្រ្តីចំណាស់ម្នាក់ ដើរមកដល់ចំពោះមុខនាយ :

- លោក! មានស្រីក្មេងម្នាក់ ផ្ញើសៀវភៅនេះសងជូនលោកវិញ ហើយផ្តាំ អរគុណលោកផងដែលលោកបានជួយសង្គ្រោះនាងកាលពីម្សិលម៉្ងៃ ។

- អូហ៎! ហើយចុះនាងទៅណាហើយ?

- ចេញពីមន្ទីរពេទ្យតាំងពីព្រហាមម្ល៉េះ? ប្រហែលជានាងស្រួលបួលហើយ ទេដឹង ព្រោះយប់មិញ  មីងឃើញនាងដេកមើលសៀវភៅរឿងមួយក្បាល នេះម៉ាយប់ទើសភ្លឺតែម្តង ។

- អញ្ចឹងមីងដឹងដែរទេ ថាផ្ទះគេនៅឯណា?

- មីងអត់ស្គាល់នាងទេ ។ ឮនាងថាទៅមើលប្អូននៅឯផ្ទះ ខ្លាចឪចុងធ្វើបាប ប៉ុន្តែនាងមិនបាននិយាយប្រាប់ថានាងរស់នៅឯណាឡើយ ។

ពិសិដ្ឋនិងសុគុណឮដូច្នោះ សម្លឹងមុខគ្នាសំដែងការព្រួយបារម្ភ រួចក៏ លាស្រ្តីចំណាស់នោះចេញមកវិញ ។ តាមផ្លូវ សុគុណមានអារម្មណ៍នឹកបារម្ភ ពីសំនៀងចំលែកយ៉ាងណាក្នុងចិត្តមិនដឹង ។ គេនៅអង្គុយស្ងៀម១មិនស្រដី រហូតទាល់តែដល់ផ្ទះ ។ ថ្ងៃដន្ទ្យពិសិដ្ឋបានទទួលទូរសព្ទ័មួយមកពីភ្នំពេញថា ក្រសួងមានការប្រញាប់អោយនាយយើងបង្ហាញវត្តមានភ្លាម១ ។ គេក៏ផ្ទុក ផ្តាក់សុគុណ ជាមួយនឹងតាក្រូចយាយប្រាងអោយនៅជួយមើលថែរក្សា រួច ក៏ប្រញាប់ប្រញាល់បររថយន្តត្រលប់មកភ្នំពេញវិញយ៉ាងលឿន ។

សុគុណផ្តេកខ្លួននៅលើគ្រែមួយក្បែរបង្អួច ដែលមានខ្យល់បក់ រសៀក១ពីក្រៅមក ធ្វើអោយបរិយាកាសក្នុងបន្ទប់មានភាពមនោរម្យក្រៃ លែង ។ គេយកដៃគងថ្ងាស គិតដល់នារីម្នាក់ដែលមានឈ្មោះថា សំនៀង មិនអស់ មិនហើយ មិនដឹងជាហេតុអ្វីទេ.. គ្រាន់តែជួបមុខនាងភ្លាម ស្រាប់តែចាប់ អារម្មណ៍ភ្លែតតែម្តង ។ ថ្ងៃដន្ទ្យ គេមិនស្គាល់នាងសោះ ថានាងជានរណា រស់នៅឯណា ។ អ្វីដែលនាយស្គាល់គឺឈ្មោះរបស់នាង តែម្យ៉ាង :

- សំនៀង! ឈ្មោះនេះពិរោះណាស់!

សុគុណលាន់មាត់ខ្សិប១  ហៅនាងតែម្នាក់ឯង ។  បន្តិចមក គេក៏ស្រវា ទាញសៀវភៅប្រលោមលោក ដែលសំនៀងផ្ញើតាមស្រ្តីចាស់មកសងនាយ វិញនោះ យកឡើងមកបើកបំរុងនឹងអាន ស្រាប់តែប្រទះនឹងកូនក្រដាស មួយសន្លឹក ដែលមានរូបគំនូរបុរសម្នាក់ខ្សៀសសដោយខ្មៅដៃយ៉ាងក្រវែម ក្រវ៉ាម ។

CHANBOKEO.COM

ពិតមែនតែរូបនោះជាគំនូរវាសដៃក៏មែនពិត តែគេគូរបានស្អាត ណាស់ ដូចរូបនាយបេះបិតតែម្ដង
ដូចសូម្បីតែប្រជ្រុយរបស់នាយនៅ កន្ទុយចិញ្ចើមស្ដាំ។ សុគុណខុទានទាំងភ្ញាក់ផ្អើលឡើងថា :

- នេះជាស្នាដៃរបស់នាងមែនទេ សំនៀង? ពិតជាមិនធម្មតាទេ... នាងពិត
ជាមានទេព្យកោសល្យគួរអោយកោតសរសើរក្រៃលែង!

លុះនាយក្រឡាប់រូបនោះឡើង ក៏ប្រទះឃើញសំនៀងសរសេរចារលើ
ខ្នងរូបនោះថា :

- សំនៀងសូមអរគុណចំពោះសន្ដានចិត្តថ្លៃថ្លារបស់បងប្រុសនិងមិត្ត។ ខ្ញុំ មិនដឹងជាបានអ្វីមកសងគុណចំពោះលោកវិញទេ
ព្រោះខ្ញុំមានជីវិតទីទាល់ ក្រណាស់។ ពេលនេះ ខ្ញុំត្រូវត្រលប់ទៅផ្ទះវិញហើយត្បិតខ្ញុំបារម្ភចំពោះប្អូន
ស្រីម្នាក់ដែលនៅតូចមិនទាន់គ្រប់១០ឆ្នាំនៅឡើយ។ ណាមួយ ឪពុកចុង របស់ខ្ញុំត្រូវប៉ូលីសចាប់ទៅ
ប្រហែលជាលែងវិលត្រលប់មកធ្វើបាបរូប យើងបានទៀតហើយ។ ដូច្នេះ ខ្ញុំសូមខ្លួនត្រលប់ទៅថែរក្សាប្អូនរបស់ខ្ញុំវិញ
កុំឱ្យនាងភិតភ័យដោយសារការបាត់រូបខ្ញុំពីផ្ទះដោយឥតដំណឹង។ បើមាន ឱកាស ខ្ញុំនឹងវិលមកសងគុណលោកវិញមិនខាន...
សំនៀង!

សុគុណគេងអានលិខិតដ៏ខ្លីមួយច្បាប់នេះម្ដងហើយម្ដងទៀត ហើយក៏ នឹកស្រម័យដល់សំដីលោកគ្រូពេទ្យគ្រប់៧ម៉ាត់ ដែលថា
ធិតាបានទទួលរង
គ្រោះផ្លូវភេទយ៉ាងធ្ងន់ធ្ងរ។ គេនឹកមមៃនៅក្នុងចិត្តតែម្នាក់ឯងថា :

- ឬមួយក៏នាងត្រូវឪពុកចុងធ្វើបាប?... ហើយដែលនាងថា ម្ដាយនាងទើប តែបាត់បង់ជីវិតទៅថ្មី១នេះ.. តើដោយប្រការអ្វីទៅ?
ដោយសារតែគាត់ ទទួលទារុណកម្មពីឪពុកចុងរបស់នាងមែនទេ? ហើយចុះនាងតូចដែលជា ប្អូននោះ
មានទទួលរងគ្រោះដូចនាងដែរឬទេ?... គិតទៅ! គួរអោយខ្ពើម រអើមផង អាសូរផង
ចំពោះបុរសដែលប្រព្រឹត្តអសីលធម៌លើភេទទន់ ខ្សោយ... ខ្ពើម ចំពោះការប្រព្រឹត្តរបស់គេ.. អាសូរ ព្រោះគេកំពុងងងិត
ផ្លូវដើររកពន្លឺនៃសេចក្ដីល្អនិងការកសាងល្អមិនឃើញ.. តើធ្វើម៉េចទៅនឹង អាចណែនាំបុរសយង់ឃ្នងបែបនេះ
អោយស្គាល់នូវកំហុសរបស់ខ្លួនហើយ កែប្រែមកល្អវិញបាន? គិតទៅភាពក្រីក្រអវិជ្ជាគួរអោយខ្លាចមែន ត្បិតព្រោះ
តែវានេះហើយដែលបណ្ដាលអោយមនុស្សងងិត... ងងិត... លែងដឹងថា អ្វីល្អ អ្វីអាក្រក់ អ្វីត្រូវ អ្វីខុសអស់ហើយ...! សំនៀង!
ខ្ញុំពិតជាអាណិត នាងណាស់... តើធ្វើម្ដេចទៅទើបខ្ញុំអាចជួយនាងបាន ដើម្បីកុំអោយនាង
និងប្អូនរបស់នាងត្រូវទទួលរងគ្រោះតទៅទៀត?

សុគុណគិតទៅគិតមក នៅតែមិនចេញដដែល មិនដឹងថាទៅតាមរក សំនៀងនៅឯណា។ រំពេចនោះ
នាយក៏នឹកភ្ញាកទៅដល់កន្លែងដែលសំនៀង រត់ចេញមកដល់នឹងឡានរបស់ពិសិដ្ឋ ក៏ស្ទុះរឹងងើបទៅរកតាក្រូច :

- តា! ខ្ញុំសុំពឹងមួយបានទេ?

- មានការអី ចៅ?

CHANBOKEO.COM

- គឺ ខ្ញុំចង់ទៅមើលកន្លែងដែលយើងមានជួបគ្រោះថ្នាក់កាលពីម្សិលនោះ

សាជាថ្មី ។

- អូហ៎... ទៅធ្វើអី?

សុគុណាក៏អូសដៃតាក្រូចឡើងម៉ូតូចេញទៅ ។ តាមផ្លូវនាយរៀបរាប់ រឿងទាំងឡាយអោយតាស្តាប់ផង សួរផង ក្រែងគាត់បានស្គាល់សំនៀង ដែរ តែគាត់បែរជាគ្រវីក្បាលហើយឆ្លើយថា :

- តាយាយចាស់ៗហើយនៅយាមតែដីចំការមិនសូវបានទៅណាមកណាទេ ទើបមិនសូវជាស្គាល់គេ ជាពិសេសគឺក្មេងៗស្រុករក្រោយនោះតែម្តង ។

បន្តិចមក មាណពកំលោះក៏នាំតាក្រូចមកដល់ផ្សារលើហើយក៏ចុះដើរ សួរមនុស្សជាច្រើននាក់ តែក៏ពុំបានលទ្ធផលអ្វីសោះ ។ សុគុណាក៏វិលត្រលប់ ទៅផ្ទះវិញទាំងអស់កំលាំងល្ហិតល្ហៃ ។ រាត្រីនោះ គេគេងសំលឹងមើលតែរូប គំនូរដែលធិតាបានគូរអោយនាយ... គេងគិតមិនអស់មិនហើយថា ហេតុអ្វី ក៏នាយបែរមកចាប់អារម្មណ៍ចំពោះនារីសាមញ្ញមួយរូបនេះម្ល៉េះ? មួយថ្ងៃ កន្លងមកហើយ គេមមៃឃើញតែរូបនាងនៅនឹងភ្នែកដដែល ហាក់ដូចជា នាងមិនបានបែកពីនាយទៅណាសោះឡើយ ។ បន្តិចមក គេក៏ចាប់ខ្មៅដៃ ចាប់ក្រដាសគូសវាសឡើងជាគំនូរមួយ បន្ទប់អារម្មណ៍ដ៏សែនធុញថប់ របស់គេ ។

ជំនោរមេសា

១. ជំនោររាត្រីមេសា ក្នុងឱរា រៀមរែងនឹកចរណៃ
ថ្ងៃនេះគេងហើយឫនៅពិសី ដឹងទេណាំចរណៃ ថាបងនឹករូបអូន?

២. អាធ្រាតសន្សើមត្រជាក់ កាយញ័រញាក់ក្រៀមក្រំស្រពោន
កណ្តាលរាត្រីស្ងាត់សូន្យ មមៃឃើញរូបអូន
ញញឹមដាក់បងគ្មានស្រាន្ត ។

បន្ទរ.នៅក្នុងដួងចិត្តបង មានតែរូបស្រី រៀមអាល័យនឹកតែកល្យាណ
ឱ! ជំនោរក្សេមក្សាន្ត សូមនាំពាក្យប្រុសប្រាណ ប្រាប់កល្យាណ
ថាបងនឹកអូនណាស់ ។

៣. ហត្ថាទាំងទ្វេប្រណម្យ ថ្វាយបង្គំ ដល់ព្រះពុទ្ធជាម្ចាស់
ថារៀមបងស្នេហ៍ពៅណាស់ សូមជួបស្រីកុំបីនិរាស
ជាគូលុះសូន្យអើយ ។

ពីរថ្ងៃកន្លងទៅ...

សុគុណាដើរពីក្រោយតាក្រូចចូលក្នុងចំការ ត្បិតឮគាត់ថានឹងរកមើល បេះផ្លែឈើមកបរិភោគ ។ លុះដើរមកដល់ជាយដីចំការ នាយយើងក៏ប្រទះ នឹងរោងស្បូវមួយដែលគេសង់ឡើងទំនងសំរាប់អង្គុយលេង ។ សុគុណាក៏ ដើរទៅអង្គុយលេងនៅទីនោះ ក្នុងពេលដែលតាក្រូចលើកកន្ទ្រងបេះ ស្វាយ ។ ភ្លាមនោះ នាយយើងចោលភ្នែកទៅខាងក្រោយគុម្ពោតឫស្សី មួយឯជាយដីចំការ ស្រាប់តែឃើញស្រមោលមនុស្សដេកដួលកំរើកតិចៗ ។ សុគុណាក៏ ស្រែកលាន់មាត់ឡើងថា :

CHANBOKEO . COM

- តាៗ! មើលហ្នុ៎! នរណាគេមកដេកដួលនៅក្នុងដីចំការយើងហ្នុ៎ក!

តាក្រូចឮដូច្នោះក៏ដាក់កំប្រោងស្វាយចុះ ហើយរត់តាមក្រោយសុគុណ ទៅរកមើលដែរ ។ នៅទីនោះ អ្នកទាំងពីរក៏បានប្រទះស្រីក្មេងម្នាក់មានមុខ មាត់ប្រលាក់សុទ្ធតែឈាមថ្មីៗ កំពុងដួលត្របោមជង្គង់ភិតភ័យញ័រខ្លួន ចំប្រប់ដូចកូនកណ្តុរធ្លាក់ទឹក ។ សុគុណក៏ស្ទុះទៅជួយលើកនាងឡើង :

- នាង! មានរឿងអីហ្នឹង?

ស្រាប់តែ សុគុណធ្វើមុខភាំងស្រលាំងកាំងចំហមាត់ ព្រោះអីនារីនោះ ក៏គ្មាននរណាជាសំនៀងដែលគេកំពុងតែគេងនឹកពីរថ្ងៃមកហើយនោះទេ ។

- ជួយខ្ញុំផង...!

ធិតាពោលបានតែប៉ុណ្ណេះក៏យកដៃត្របោមជង្គង់វិញ ហើយញ័រចង្កា ចំប្រប់សាជាថ្មី ។ លុះឃើញនាងមានឈាមប្រលាក់ពេញខ្លួន ហើយឃើញ នាងភិតភ័យរហូតនិយាយមិនរួច បុរសយើងក៏លើកគ្រាហ៍នាងឡើងសំដៅទៅផ្ទះភ្លាម ។

យាយប្រាងក៏យកទឹកក្តៅមកជូតឈាមអោយ ហើយផ្លាស់សំលៀក បំពាក់ថ្មីអោយធិតាយើង ។ បន្តិចមក តាក្រូចនិងសុគុណក៏ចូលមកដល់ :

- យ៉ាងម៉េចហើយយាយ...? (តាក្រូចសួរ)

- នាងគ្មានរបួសទេ មានតែស្នាមជាំច្រើនកន្លែង (យាយប្រាងឆ្លើយវិញ)

- ហើយចុះហេតុអ្វីក៏ខ្លួននាងប្រលាក់ឈាមអីច្រើនម្ល៉េះ?

- មើលទៅ មានតែនាងទេដែលអាចឆ្លើយសំនួរនេះបាន ។ ប៉ុន្តែ... នាង ហាក់ដូចជាកំពុងតក់ស្លុតនឹងរឿងអ្វីម្យ៉ាងហើយ ។ មើលចុះ! ញ័រចំប្រប់ដូច កូនចាបធ្លាក់ទឹកអញ្ចឹង ។ យើងកុំអាលទាន់បង្ខំសាកសួរនាងធ្វើអី អោយ នាងគេងសំរាកអោយស្ងប់អារម្មណ៍សិនទៅ សឹមសួរនាងពេលនាងមាន កំលាំងស្មារតីប្រក្រតី ។

យាយប្រាងនិយាយផង លើកភួយដណ្តប់អោយនាងផង ។ បន្ទាប់មក ក៏លើកក្លាំទឹកក្តៅនាំតាក្រូចចេញទៅ ។ សុគុណឈរសំលឹងធិតាដោយដួង ចិត្តញាប់ញ័រ ។ មើលទៅនាងចុះ! បែកគ្នាតែពីរថ្ងៃសោះ... ធិតាបានប្រែ ទៅជាមនុស្សផ្សេងចំលែកម្នាក់ទៅហើយ ។ ថ្ងៃមុន ពិតមែនតែនាងយំ យែកមានទឹកភ្នែក តែក៏នៅអាចញញឹមដាក់នាយយើងយ៉ាងស្រស់ស្រាយ តែពេលនេះ... នាងមានកិរិយាធ្ងន់ធ្ងរចំលែកណាស់ ប្រហែលជានាងពើប ប្រទះហេតុការណ៍អ្វីគួរអោយតក់ស្លុតស្មារតីខ្លាំងហើយ ។ ថ្វីត្បិតតែពេល នេះ ធិតាយើងបានប្រទះក្រសែភ្នែកនឹងសុគុណច្រើនដង តែកិរិយារបស់ នាងបែរជាសំដែងថា នាងភ័យខ្លាចចំពោះវត្តមានបុរសយើង ដល់កំរិត ហើយ ។ ពេលនោះ មាណពនឹកគិតក្នុងចិត្តតែម្នាក់ឯងថា :

- សំនៀង... តើនាងត្រូវបុរសគំរាមកំហែងរូបនាងយ៉ាងណាខ្លះ បានជា នាងមានប្រតិកម្មចំពោះវត្តមានរបស់ខ្ញុំយ៉ាងចំលែកបែបនេះ?

CHANBOKEO.COM

បន្តិចមក ធិតាក៏ធ្មេចភ្នែកសំងំ។ ឃើញនាងរក្សាភាពស្ងប់ស្ងៀមបាន បុរសយើងក៏ដកដង្ហើមយូបន្ធូរទ្រូងឡើង។ គេក៏ដាក់ខ្លួនអង្គុយចុះក្បែរនាង រួចសំលឹងមុខធិតា នឹកគិតសង្វេគក្នុងចិត្តតែម្នាក់ឯង :

- ហ៊ឹ! មិនគួរណាឡើយស្រីដែលនៅក្មេងហើយស្រស់ស្អាតដូចជានាង បែរ ជាមករងគ្រោះអាក្រក់ៗ ក្នុងជីវិតដូច្នោះទេ... គួរអោយអាសូរណាស់!

ភ្លាមនោះ គេក៏យកដៃទៅអង្អែលកេសានាងបន្ថើរៗដោយក្តីអាណិត អាសូរពេញបេះដូងរបស់នាយ :

- សូមអោយនាងបានគេងលក់ក្សេមក្សាន្ត ហើយស្ងប់សុខក្នុងអារម្មណ៏ លែងភិតភ័យអ្វីទាំងអស់ ចាប់ពីពេលនេះតទៅ...!!

បំពេរក្សេមក្សាន្ត

គេងទៅពៅអើយយ៉ាងសុខសាន្ត សំរាកចិត្តប្រាណអោយធូរស្បើយ
គេងទៅមាសម៉ុំកែវត្រាណត្រើយ បងនៅក្បែរហើយបំពេរស្រី។
គេងទៅណាំស្ងួនព្រលឹងចិត្ត លក់ចាកភ័យភិតរឿងអប្រិយ
គេងអោយអារម្មណ៏សុខជាថ្មី ភ្ញាក់ឃើញសិរីថ្ងៃថ្មីទៀត។
គេងទៅទួនល្អងបងបំពេរ ថ្នមថែមមាសមេស្រស់វរនាថ
គេងអោយក្សេមក្សាន្តមិនរវាត ភ្ញាក់ឡើងថ្មីទៀតជួបមង្គល។
គេងលក់ស្កប់ស្កល់ណាំមុំណាំ កុំបីសង្ការណាំនិមល
គេងទៅឆវីបងសូមផ្តល់ ចំរៀងមង្គលថ្នមចិត្តអូន...

CHANBOKEO.COM

# វគ្គទី៣

# បង្គោលជីវិត

សំនៀងបើកភ្នែកឡើងមើលជុំវិញខ្លួនសាជាថ្មី ស្រាប់តែប្រទះនឹងកែវ ភ្នែកសុគុណដ៏ភ្លឺថ្លាកំពុងតែសំលឹងមករកនាង :

- សំនៀង! បានធូរស្រាលក្នុងខ្លួនខ្លះហើយនៅ? (សុគុណសួរ)

ធិតាយកដៃខ្ទប់ថ្ងាសទំនងដូចជាឈឺក្បាល ។ ភ្លាមនោះ ទឹកភ្នែកពីរ តំណក់បានហូរស្រក់ចេញមកពីកែវភ្នែកនារីយើង ។ កាលបើឃើញដូច្នោះ សុគុណក៏ស្ទុះមកអង្គុយជិតមាណវីហើយសួរថា :

- ប្អូនស្រីមិនស្រួលខ្លួនខ្លាំងមែនទេ? ទៅពេទ្យទេ?... ខ្ញុំជូននាងទៅ...

សំនៀងគ្រវីក្បាលហើយក៏ប្រែខ្លួនទៅម្ខាងយំសសឹកសាជាថ្មី ។សុគុណ ក៏មិនមាត់មិនកអ្វីដែរ ។ គេនៅតែស្ងៀមៗមិនស្រដីអ្វីអោយរំខានចិត្តនាង ទេ ។ បន្តិចមក យាយប្រាងក៏លើកថាសបបរមកដល់ :

- នាងអើយ! ក្រោកឡើង ញ៉ាំបបរបន្តិចទៅចៅ ក្រែងលោបានស្រួលខ្លួន គ្រាន់បើជាងមុនណា៎!

តាក្រូចក៏កាន់ផ្លែក្រូចមួយកញ្ច្រែងមកដល់ដែរ :

- ហើយនេះ ក្រូចពីចំការថ្មីៗ ផ្អែមណាស់ ទទួលទានបន្តិចទៅនឹងមាន កំលាំងវិញណា៎ចៅ ។

កាលបើយល់សន្តានចិត្តសប្បុរសមនុស្សធម៌ និងការយកចិត្តទុកដាក់ របស់តាយាយព្រមទាំងមាណពកំលោះយើង ធិតាក៏ស្ទុះក្រោកចុះពីលើគ្រែ ហើយក៏ក្រាបសំពះអ្នកទាំងបីៈ

- តា! យាយ! ជួយខ្ញុំផង... ខ្ញុំមិនមែនជាឃាតករទេ... គឺគាត់បានធ្វើ បាបរូបខ្ញុំនិងប្អូនស្រីរបស់ខ្ញុំ... ទើបយើងចាំបាច់ត្រូវតែការពារខ្លួន...

នាងស្រដីឡើងដោយសំលេងញ័រលាយឡំនឹងទឹកភ្នែកយ៉ាងជោគជាំ ។ ទាំងកំលោះវិរិន្ទសុគុណ ទាំងតាក្រូច ទាំងយាយប្រាង នាំគ្នាបើកភ្នែកធំៗ សំលឹងគ្នាទៅវិញទៅមកដោយការភ្ញាក់ផ្អើលជាខ្លាំង ។ យាយប្រាងក៏ចាប់ ធិតាអោយងើបមុខឡើងសួរថា :

- មើល៍... ចៅស្រី! និយាយរឿងអោយយាយស្តាប់បន្តិចមើល ថាចៅមាន រឿងអ្វីខ្លះទៅ ដែលនាំអោយរូបចៅក្លាយជាតក់ស្លុតស្មារតីយ៉ាងនេះ?

CHANBOKEO.COM

ភ្លាមនោះ សំនៀងស្រវាអោយយាយប្រាងយំហ៊ូតែម្តង ។ សុគុណលួច
ជ្រួញចិញ្ចើមតែម្នាក់ឯងត្បិតអីក្នុងចិត្តកំពុងតែអន្ទះសាចង់ដឹងហេតុការណ៍ ទាំងឡាយ
ដែលនាំអោយនារីយើងមានអាកប្បកិរិយាចំលែកយ៉ាងនោះ ។ មួយភ្លែតក្រោយមក ធិតាក៏អោនឈ្ងោកមុខជូតទឹកភ្នែកមកវិញ
តែមិន ឃើញស្រដីអ្វីទេក្រៅពីអង្គុយញ៉ូរចង្កាចំប្រប់ធ្វើមុខស្វាយល្អូក ។ យាយ
ប្រាងឃើញដូច្នោះក៏យកដៃស្ទាបថ្ងាសស្ទាបខ្លួននាងហើយក៏មានប្រសាសន៍
ឡើងថា :

- ទៅពេទ្យទេហ៎ចៅ?

សំនៀងគ្រវីក្បាល ហើយឆ្លើយឡើងទាំងតក់ស្លុតថា :

- មិនទេ យាយ... ខ្ញុំខ្លាច... ខ្ញុំមិនទៅទេ...
- ឯងខ្លាចទៅ មីនាង? ពេទ្យជាកន្លែងព្យាបាលអោយឯងធូរស្រាលណា៎

តែសំនៀងមិនឆ្លើយទេ គ្រាន់តែលួចសំលឹងមើលតាគ្រូចនិងសុគុណ ភ្លែកៗ
សំដែងអាការៈហាក់ដូចជាខ្លាចអ្នកទាំងពីរណាស់ ។ យាយប្រាង យល់ចិត្តក៏ពោលទៅកាន់តាគ្រូចថា :

- នែ៎ តា! នាំសុគុណទៅក្រៅម៉ាភ្លែតសិនទៅ! មើលទៅចៅស្រីប្រហែល ជាគេចង់និយាយរឿងស្រីៗតែពីរនាក់ខ្ញុំហើយ !

តាគ្រូចឮដូច្នោះក៏សំលឹងមុខសុគុណហើយក៏ញាក់មុខអោយសញ្ញាទៅ នាយយើងភ្លាម ។
មាណពយល់សភាពការណ៍ក៏ងើបថយចេញទៅដោយ ឥតប្រកែកមួយម៉ាត់ឡើយ ។ បន្ទាប់មក យាយប្រាងក៏សួរទៅមាណវី យើង
ភ្លាមថា :

- ចៅស្រី! មានរឿងអីនិយាយចេញមក៏ ក្រែងលោយាយតាអាចជួយអ្វី បានណា៎ចៅ ។

ធិតាឈ្ងោកមុខយំមួយស្របក់ទើបជូតទឹកភ្នែកសាជាថ្មីរួចហើយក៏ផ្ចង់
ស្មារតីតាំងចិត្តក្លាហាននិយាយរឿងជំរាបជូនចាស់តាមដំណើរ :

- ឪពុកចុង...របស់ខ្ញុំយង់ឃ្នងណាស់ ។ គាត់ផឹកស្រា ស្រវឹងគ្រឿងញៀន
វាយធ្វើបាបម៉ែរបស់ខ្ញុំ រហូតឈឺស្លាប់កាលពីប៉ុន្មានអាទិត្យមុននេះ ។ មិន
ត្រឹមតែប៉ុណ្ណោះទេ... ក្រោយពីម៉ែខ្ញុំចែកឋានទៅ គាត់ក៏ចាប់ផ្តើមធ្វើបាប ខ្ញុំជំនួស ។ កាលម៉ែនៅរស់
ម៉ែតែងតែយកខ្លួនការពារខ្ញុំជានិច្ច រហូតដល់ គាត់ត្រូវទទួលរងគ្រោះយ៉ាងធ្ងន់ធ្ងរជាច្រើនដង ។ លុះអត់ពីម៉ែទៅ ខ្ញុំក៏ពុំ
មាននរណាជាបង្អែកទៀតដែរ ក្រៅពីការតស៊ូដោយកំលាំងរបស់ខ្លួនឯង ផ្ទាល់ ។ កាលប៉ុន្មានថ្ងៃមុននេះ
ឪពុកចុងរបស់ខ្ញុំនោះបានជក់ថ្នាំញៀនវង្វេង វង្វាន់ស្មារតីហើយបានចូលមកចាប់រូបខ្ញុំធ្វើបាបផ្លូវភេទយ៉ាងព្រៃផ្សៃបំផុត
ក្នុងខណៈដែលខ្ញុំកំពុងគេងសំរាកអស់កំលាំង ដោយធ្វើការច្រើនពេក ។ ពេលដែលរើបំរះរត់រួចខ្លួនមកនោះ
ខ្ញុំក៏បានជួបប្រទះបងប្រុសម្នាក់នេះ ព្រមទាំងមិត្តរបស់គាត់ម្នាក់ទៀតមកជួយធ្វើអន្តរាគមន៍ចាប់ឪពុករបស់ខ្ញុំ
អោយទៅប៉ូលីសហើយក៏យករូបខ្ញុំទៅព្យាបាលនៅមន្ទីរពេទ្យ ។ ប៉ុន្តែ... ដោយក្តីបារម្ភពីសុខទុក្ខប្អូនស្រីពេក

CHANBOKEO.COM

ទើបខ្ញុំសំរេចចិត្តលួចរត់ចេញពីពេទ្យ ទៅមើលប្អូន មានដឹងអីថា ឪពុកចុងរបស់ខ្ញុំបានត្រូវដងត្រូវផ្លែជាមួយ ប៉ូលីសខ្មោចឆៅម្នាក់ដែលជាពួកម៉ាករបស់គាត់ ហើយគេក៏ដោះលែង អោយគាត់មានសេរីភាពត្រលប់មកផ្ទះវិញធ្វើមិនដឹង។ គ្រានោះ កំរោល ដែលនៅគ្របដណ្តប់ខ្លួនរបស់គាត់មិនទាន់អស់ចំហាយនៅឡើយទេ។ គាត់ ក៏កើតមានគំនិតអាក្រក់ចង់បំពានរូបខ្ញុំសាជាថ្មីទៀត។ ចៃដន្យប្អូនស្រីខ្ញុំ វាបានប្រទះឃើញហើយក៏ស្រែកឆោឡោហៅអោយគេជួយ។ ឪពុកចុង របស់ខ្ញុំខឹងណាស់ក៏ស្រវាច្របាច់កប្អូនស្រីខ្ញុំ ដែលជាកូនស្រីរបស់គាត់បង្កើត នោះ រហូតដល់នាងដាច់ខ្យល់ស្លាប់នៅក្នុងដៃរបស់គាត់ទៅ។ ឃើញហេតុ ការណ៍រន្ធត់ពេក ទ្រាំមិនបាន ខ្ញុំក៏ងើបប្រវេប្រវាជួយសង្គ្រោះប្អូន តែត្រូវ បុរសចិត្តនរកនោះវាវាយដំយ៉ាងខ្លាំង រហូតខ្ញុំមិនអាចទ្រាំទ្របាន ទើបខ្ញុំ ចាប់ផ្តាក់ឡើងគ្រវីតដៃវិញទៅគាត់វិញទៅ។ ពេលនោះ.. ខ្ញុំមើលអ្វីមិន ឃើញទេក្រៅពីដឹង ថាមានឈាមបាញ់ស្រោចពាសពេញខ្លួនរបស់ខ្ញុំតែ ប៉ុណ្ណោះ។ ដោយការភិតភ័យខ្លាំងពេក.. ខ្ញុំក៏ទំលាក់ផ្តាក់នោះចោល ហើយក៏រត់គេចខ្លួនមក... ព្រោះខ្លាចប៉ូលីសតាមចាប់យកខ្ញុំទៅផ្តន្ទាទោស ណាំយាយ...

ធិតានិយាយរៀបរាប់រឿងរបស់នាងផង យំសសឹកផង យ៉ាងអណោច អធម្ម។ យាយប្រាងស្តាប់ឮហើយ ក៏កើតមានចិត្តអាណិតអាសូរនារីយើង នៅក្នុងជំរៅចិត្តណាស់។ គាត់ក៏យកដៃអង្អែលក្បាលនាងឡើង ហើយមាន ប្រសាសន៍ថា :

- ចៅអើយ! យាយពិតអាណិតចៅឯងណាស់។ ណ្ហើយ... ឈប់ភ័យទៀត ទៅ។ នៅទីនេះ ចៅបានសុខហើយ គ្មាននរណាគេមករំខានចៅទៀតទេ។ រឹងប៉ឹងឡើងណាំចៅ! យាយតាក៏គ្មានកូនគ្មានចៅឯណាដែរ។ ចៅឯងស្នាក់ នៅជាមួយយាយតាទីនេះហើយ មិនបាច់រត់គេចចរ រកទីសំណាក់ជ្រក កោនឯណាទៀតឡើយ ឮហើយនៅ?

ឮប្រយោគនេះភ្លាម ធិតាក៏ញញឹមឡើងទាំងទឹកភ្នែកហើយស្ទុះក្រាប សំពះយាយប្រាងភ្លាម :

- ចៅសូមផ្ញើខ្លួនជាមួយយាយផង... !! ហើយចៅសូមអរគុណចំពោះទឹក ចិត្តសប្បុរសធមិរបស់យាយណាស់ ដែលបានជួយសង្គ្រោះជីវិតតូចដូចកូន ស្រមោចរបស់ចៅអោយមានពន្លឺរស្មីម្តងទៀត។

ថ្ងៃនោះ សំនៀងមានអារម្មណ៍ធូរស្រាលមកវិញយ៉ាងច្រើន បន្ទាប់ពី បាននិយាយគ្នាជាមួយយាយប្រាង ទំលាយរឿងស្នេហ៍ស្មោគ្រស្នាញទាំងឡាយអស់ ពីក្នុងដើមទ្រូងមកថែមទាំងងើបចេញមកបរិភោគបាយជុំគ្នាជាមួយយាយ តាព្រមទាំងកំលោះភ្នំពេញទៀតផង។ នៅវាងពេលកំពុងបរិភោគបាយ តាយាយទាំងពីរនាក់បានលួចសង្កេតឃើញមាណពកំលោះយើងលួចចោល កន្ទុយភ្នែកលួចគយគន់សំនៀងមិនឈប់ឈរឡើយ។ ថ្វីបើធិតាមិនចាប់ ភ្លឹកក៏ដោយ ក៏តាយាយចាប់បានគ្រប់កាយវិការរបស់នាយទាំងអស់ដែរ។ កាលបើឃើញសុគុណយកចិត្តទុកដាក់ចំពោះមាណវី មិនមានឱ្យគ្នើសចិត្ត គាត់ទាំងពីរក៏កេះគ្នា គេចឈប់បរិភោគបាយទៅ ដើម្បីអោយក្មេងៗគេ ជជែកអ្វីរឿងគេតែពីរនាក់ កុំអោយគេមានចិត្តរអៀសខ្លួនទើសទាល់នឹង វត្តមានរបស់គាត់នៅចំពោះមុខ។

ព្រលប់ថ្ងៃដដែល...

CHANBOKEO.COM

នៅលើរានហាលចំហៀងផ្ទះ ក្បែរម្លប់ដើមម៉ាក់ប្រាងដែលកំពុង បញ្ចេញផ្លែពណ៌បៃតងពណ៌លឿងរយោងគ្រប់មែក សំនៀងដាក់ខ្លួនអង្គុយ នៅក្នុងកៅអីផ្តៅមួយ សំលឹងមើលទៅមេឃ ហាក់កំពុងផ្ញើអារម្មណ៍នឹក រលឹករបស់នាងទៅម្តាយនិងប្អូនជាទីស្រលាញ់របស់នាង។ ភ្លាមនោះ ទឹក ភ្នែកពីរតំណក់ក៏ហូរចុះមកប្រលែងថ្ពាល់ទាំងគូរបស់នាងសាជាថ្មី។ សុគុណ ក៏ដើរមកជិតយកក្រមាមួយមកហុចអោយនាងជណ្តប់ព្រមទាំងស្រដីថា :

- សំនៀង... កាត់ចិត្តខ្លះទៅណា៎!... នៅទីនេះ នាងមានសុវត្ថិភាពហើយ មិនបាច់ព្រួយបារម្ភពីរឿងអ្វីទេ។

សំនៀងងាកមុខមកឃើញកំលោះយើង ក៏យកដៃជូតទឹកភ្នែកយ៉ាង រហ័សហើយក៏ឆ្លើយវិញថា :

- ខ្ញុំកំពុងតែខំកាត់ចិត្តហើយ... ប្រហែលមិនយូរទេ ខ្ញុំនឹងតាំងចិត្តបានរឹង មាំជាងនេះមិនខាន..!

សុគុណក៏ដាក់ខ្លួនអង្គុយចុះនៅលើកៅអីផ្តៅមួយទៀតដែលក្បែរនោះ សំលឹងមើលទៅផ្ទៃមេឃដែរ។ មួយស្របក់ក្រោយមក គេក៏បែរសំលឹង មកនារីហើយក៏ពោលឡើងថា :

- សំនៀង.. ប្អូនដឹងទេ...? ជួនកាលយើងអាចកាច់ចង្កូតជីវិតយើងបានថា យើងនឹងឈោងចាប់យកអនាគតបែបនេះ ឬក៏បែបនោះ... ប៉ុន្តែជួនកាល យើងក៏មិនអាចធ្វើអ្វីបាន កែអ្វីបានឡើយ ក្រៅតែពីបណ្តោយអោយជីវិត រសាត់ទៅមុខតាមតែដំណើរ... ទោះបីជាយ៉ាងណាក៏ដោយ មានតែ បច្ចុប្បន្នទេដែលជាអ្នកកាត់ក្តីអោយជីវិតរបស់យើង ថាតើយើងគួររស់ នៅអោយបានល្អបំផុត ឬក៏យើងគួររស់នៅក្នុងអន្លង់ទុក្ខសោករហូតថ្ងៃចុង ក្រោយនៃជីវិត! ចំពោះរូបបងវិញ កាលបើខ្លួនស្ថិតនៅក្នុងចំណុចទាល់ ច្រកស្រោយមិនចេញ បងប្រហែលជាសំរេចចិត្ត រើសយកផ្លូវជីវិតមួយណា ដែលល្អជាងគេសំរាប់បងហើយ ប្រឹងរស់អោយបានល្អប្រសើរបំផុតមុននឹង ខ្លួនយើងលាចាកពីលោកនេះទៅ...

សំនៀងឮវាចារបស់មាណពយើងដូច្នោះ ក៏ភ្ញាក់ព្រើត បើកភ្នែកបែរ មើលមកនាយ បន្ទាប់មកក៏វាចាសួរទៅវិញថា :

- បងប្រុសមានវាចា ហាក់ដូចជាកំពុងស្ថិតនៅក្នុងសភាពធ្ងន់ធ្ងរមួយ ក្នុង ជីវិតដែលមិនអាចកែឆ្នៃអ្វីបានអោយប្រសើរឡើងបានអញ្ចឹង ធ្វើជាបុរស ចេះមានរឿងធ្ងន់ធ្ងរក្នុងជីវិតដែរហ៎ ?

- មិនថាប្រុសឬស្រីទេ សំនៀង... យើងអាចប្រទះនូវឧបសគ្គក្នុងជីវិតបាន គ្រប់ទីកន្លែង... ខុសគ្នាត្រង់តែថា តើយើងមានទឹកចិត្តនឹងច្បាំងពុះពារឱ្យ ផុតឧបសគ្គនោះដែរឬទេ? ឬក៏ត្រូវរស់បណ្តែតបណ្តោយតាមវាសនាកម្ម តែប៉ុណ្ណោះ?

- ខ្ញុំប្រហែលកំពុងក្លាយជាមនុស្សយ៉ាប់ម្នាក់ទេដឹង?... គឺមនុស្សដែលលង់ ក្នុងក្តីអស់សង្ឃឹមហើយបណ្តែតបណ្តោយជីវិតតាមតែវាសនា.. ពេលនេះ... ខ្ញុំសំលឹងមើលអនាគតរបស់ខ្ញុំលែងឃើញកោះត្រើយហើយ ក្រៅតែពីភាព អាប់អួរងងឹតតែម្យ៉ាង...

- នរណាថា? សំនៀងមិនដឹងខ្លួនទេហ៎? បើប្អូនមិនព្យាយាមពុះពារដើម្បី ការពារខ្លួនរបស់នាង ធ្វើម៉េចយើងនឹងបានជួបគ្នានៅថ្ងៃមុននោះកើត? ហើយបើនាងមិនពុះពារ ធ្វើម៉េចនឹងរក្សាជីវិតរបស់ខ្លួនរហូតមកដល់ពេល

CHANBOKEO.COM

នេះបានទៅ? ប៉ុន្តែ..ឥលូវ...សំនៀងបានផុតគ្រោះភ័យទៅហើយ ហេតុអ្វី បានជាប្អូនស្រីប្រែជាបាក់ស្មារតីមិនព្រមតាំងចិត្តរឹងមាំ ដើម្បីជួយខ្លួនឯង តទៅទៀតដូច្នេះ?

កាលបើឮសុគុណវាចាដូច្នោះ សំនៀងហាក់ដូចជាមានអារម្មណ៍ប្លែក ក្នុងចិត្តតែម្តង។ បន្ទាប់មកនាងក៏ឆ្លើយវិញថា :

- ចំពោះផ្កាដែលរោយទៅហើយ តើគេនៅមានសល់សង្ឃឹមអ្វីទៀតទៅ សំរាប់អនាគតរបស់ខ្លួន?

- ប៉ុន្តែ ជីវិតមនុស្ស មិនមែនជាផ្កាទេ ដែលរោយទៅហើយលែងរីកស្រស់ វិញនោះ។ មនុស្សយើងគ្រប់រូបតែងតែមានឱកាសសាងខ្លួនឱ្យល្អឡើងវិញ បានជានិច្ច បើប្រសិនជាគេមានចិត្តកសាងជីវិតសាថ្មីម្តងទៀតពិតមែន។ រីឯតម្លៃមនុស្សទៀតសោត គឺមិនមែនស្ថិតនៅលើសំដីចចាមអារាមរបស់ អ្នកស្រុកដែលរង់ចាំតែសើចយំចំអកអោយ ឬក៏ស្ថិតនៅលើភាពក្រពុំតែម្យ៉ាងនោះដែរ ប៉ុន្តែ...គឺស្ថិតនៅលើរូបគេផ្ទាល់នោះទេតើហ៎ ថាតើគេមាន លក្ខណៈសម្បត្តិអ្វីខ្លះដែលល្អប្រពៃ ហើយតើគេនឹងសាងអ្វីខ្លះទៀត នៅ ក្នុងជីវិតដែលគួរឱ្យកត់សំគាល់ រួមទាំងចិត្តគំនិតមារយាទនិងការប្រព្រឹត្ត របស់គេនោះផង។

ឮប្រយោគនេះកាលណា សំនៀងឈ្ងោកមុខចុះគិតមួយស្របក់ ទើប ងើបមុខមកវិញហើយពោលថា :

- ប្រហែលបងប្រុសជាមនុស្សទីមួយហើយ ដែលធ្វើបដិវត្តន៍ថ្មី ដើម្បីផ្លាស់ ប្តូរទស្សនិងឆន្ទៈបុរាណរបស់ខ្មែរយើង ដែលទំលាប់ផ្តល់តម្លៃទៅស្ត្រីលើភាព ក្រពុំបរិសុទ្ធតែម្យ៉ាង។ បើសិនសង្គមយើងគ្រប់គ្នា គិតដូចជាបងប្រុស ប្រហែលជានារីរងគ្រោះទាំងឡាយមានអារម្មណ៍ស្ងប់សុខ មិនធ្វើបាបខ្លួន មិនធ្វើអត្តឃាត មិនរត់ចោលគ្រួសារ... មិនតែប៉ុណ្ណោះ គេច្បាស់ជាហ៊ាន ចេញមុខមកថ្កោលទោសបុរសយង់ឃ្នងទាំងអស់ ដែលប្រព្រឹត្តអំពើបាប លើនារីៗនោះជាមិនខាន ដើម្បីឱ្យជនឧក្រិដ្ឋបានទទួលនូវការផ្តន្ទាទោស យ៉ាងសក្តិសម ចំពោះអំពើអសីលធម៌របស់គេ...

- ប្រហែលមិនមែនមានតែបងម្នាក់ទេ សំនៀង! បងគិតថា ប្រហែលជា មានខ្មែរយើងជាច្រើនទៀតរាប់មិនអស់ទេ ដែលមានឆន្ទៈយ៉ាងនេះដែរ។ ស្រុកទេសយើងកំពុងមានដំណើរវិវត្តន៍ទៅមុខ។ ពលរដ្ឋក៏បានចូលរៀន សូត្រចេះដឹងកាន់តែច្រើន មិនយូរទេ សង្គមយើងនឹងប្រាសចាកការថ្កោល ទោសចំពោះនារីតែមួយចំហៀងនោះហើយ ជាពិសេសនៅក្នុងករណី និង បុព្វហេតុអាក្រក់ទាំងឡាយដែលកើតឡើងស្រដៀងៗ នឹងរឿងរ៉ាវរបស់ សំនៀងពេលនេះ...

សំនៀងឮដូច្នោះក៏ញញឹមឡើងយ៉ាងបំព្រង :

- សំនៀងពិតជាសំណាងណាស់ ដែលបានមកជួបបងថ្ងៃនេះ។ ពាក្យសំដី របស់បងប្រុសទាំងអំបាលម៉ាន ពិតជាកំលាំងចិត្តដ៏មានប្រសិទ្ធភាពបំផុត ចំពោះសំនៀង... ជាពិសេស ពេលនេះ ខ្ញុំមានអារម្មណ៍ថា ពិភពលោកនេះ មិនចង្អៀតចង្អល់ពេកទេ សំរាប់មនុស្សទាល់ច្រកដូចជារូបសំនៀងខ្ញុំនេះ...

CHANBOKEO.COM

សំនៀងដួងចិត្ត

ស្តាប់សៀងសត្វយំលាន់រងើយ ទឹកហូរទៅហើយជ្រែកបព្វតា
ខ្យល់សែនត្រជាក់ថ្នមចិន្តា ត្បូងគាប់ទេវហាថ្នាបរិសុទ្ធ ។
ក្លិនផ្កាក្រអូបជិតនាសា សុរិយ៍យាត្រាអស្តង្គត
អោយស្បែអន្ធការយាងដណ្តប់ ពិភពលោកផុតដែនរស្មី ។
ជំនោរត្រជាក់ធ្លាក់ពីជើង ថ្នមដួងចិត្តយើងត្រកាលក្រៃ
ព្រះចន្ទ័យាងចរភក្ត្រ័ប្រិមប្រិយ បញ្ចេញរស្មីថ្មីម្តងទៀត ។
ដូចចិត្តស្រពោនយើងពីរអង្គ គង់នៅសង្ឃឹមជួបវរនាថ
ថ្ងៃនេះចាកភ្លឺ ស្អែកលែងឃ្លាត ថ្ងៃរះម្តងទៀតភ្លឺជាថ្មី ។

អ្នកទាំងពីរក៏ញញឹមដាក់គ្នាឡើង ជាលើកដំបូងដែលគេបានយល់ចិត្ត គ្នាទៅវិញទៅមកកាន់តែប្រសើរជាងមុន ។ពេលនោះសុគុណមានអារម្មណ៍ ថា ដួងចិត្តរបស់គេកំពុងតែទទួលនូវពន្លឺសេចក្តីសុខមួយយ៉ាងចំលែក នឹង រកពាក្យមកបរិយាយអោយសមមិនបានឡើយ ។ គេនៅដដែកជាមួយ ធិតាយើងពីនេះពីនោះយ៉ាងយូរ រហូតទាល់តែយាយប្រាងមកអូសបំបែក អ្នកទាំងពីរឱ្យចូលដំណេកទើបគេបំបែកជួរទៅកុំអីម្លេះសមគេនាំគ្នាជជែក ភ្លេចខ្លួនទាល់ភ្លឺផងក៏មិនដឹង ។ យប់នោះ សំនៀងមានអារម្មណ៍ល្អប្រសើរ ឡើងវិញយ៉ាងច្រើន រីឯភាពចុកចាប់ផ្លូវកាយក៏ថមថយអនុភាពទៅតាម នោះដែរ ។ ខុសអ្វីតែកំលោះយើង... ថ្វីបើនាយមានអារម្មណ៍ថា ខ្លួនកំពុង មានការរំភើបចិត្ត ដោយបានមកជួបមាណវីជនបទដ៏សោភាមួយរូប ដែលមានឫកពានិងសំដីសំដៅសមរម្យគួរជាទីពេញចិត្តក៏ដោយ ក៏រឿង រ៉ាវចាស់ៗរវាងនាយនិងដារិនីតែងតែចេញរូបមករំខានអារម្មណ៍នាយយើង មិនឱ្យមាណពច្ឆេចបានមួយស្រលេតឡើយរហូតទល់ភ្លឺ ។

ច្រើនថ្ងៃកន្លងទៅ...

សំនៀងមានសុខភាពរឹងប៉ឹងធម្មតាវិញហើយ ហើយក៏បានតាំងចិត្តនៅ ជួយធ្វើការក្នុងចំការ បំរើតាយាយនិងបំរើសុគុណវិញជាការតបស្នងចំពោះ ទឹកចិត្តរបស់អ្នកទាំងបី ដែលបានជួយសង្គ្រោះយកចិត្តទុកដាក់មើលថែ រក្សារូបនាងហាក់ដូចជាញាតិសន្តានម្នាក់ដូច្នោះឯង ។ ថ្ងៃនេះ នាងចូល ចង្ក្រាន ជាមួយយាយប្រាង ដើម្បីជួយដៃជើងដាំស្ល :

- យាយ! សំនៀងស្រួលខ្លួនហើយ! អោយចៅសុំផ្ទេរដំណែងពីយាយបាន ទេហ៎? ចៅគិតថា ចង់ទុកអោយយាយសំរាកមួយថ្ងៃ ហើយចង់បង្ហាញស្នា ដៃក្មេងជាន់ក្រោយម្តង...
- អឺ...! យាយមានទៅថាអី បានមកជួយ យាយរិតតែអរ... ហើយចេះធ្វើ អាហារអ្វីខ្លះដែរទៅចៅ?
- ចេះច្រើនណាស់ ត្បិតខ្ញុំធ្លាប់ជួយម៉ែធ្វើបាយសម្លលក់រាល់ថ្ងៃណាំយាយ!
- អីយ៉ាមានអន់ឯណា! ថ្ងៃនេះ យាយតាប្រហែលជាបានឆ្ងាញ់មាត់ហើយ

CHANBOKEO.COM

មានប្រសាសន៍ចប់ យាយប្រាងក៏ងើបដើរចេញទៅ។ បន្តិចក្រោយ មក សុគុណក៏ដើរចូលមកដល់ :

- សំនៀងស្រួលខ្លួនហើយហ្អែស ថ្ងៃនេះ?

ធិតាងាកមុខឃើញនាយយើងក៏ញញឹមឡើងថែមទាំងស្រដីថា :

- ចាស! ជាស្រួលបួល លែងអីហើយបង!

- ហើយចុះបំរុងធ្វើម្ហូបអ្វីហ្នឹង? មើលទៅគួរអោយឆ្ងាញ់ណាស់។

- មិនដឹងទេ... ធ្វើតាមដែលខ្លួនចេះ មិនដឹងថាបងចូលចិត្តដែរឬក៏អត់ទេ...

- បងមិនមែនជាមនុស្សរើសអាហារទេ.. ស្អីក៏បរិភោគបានទាំងអស់ហ្នឹង អោយតែដួសដាក់ចាន។

- អញ្ចឹង ខ្ញុំច្បាស់ជាបបរស ដាក់ទឹកស៊ីអ៊ីវជូនហើយ (សំនៀងលលេង)

- ហ៊ានសាក... ហ៊ានពួយអស់ពីចានឱ្យមើលអាលូវហ្នឹង!

សុគុណស្រដីផងសើចកខឹកផង រួចក៏កាន់សៀវភៅមួយដើរហួសចូលទៅចំការបាត់ទៅទុកអោយសំនៀងរៀបចំអាហារតែម្នាក់ឯង។ បន្ទាប់ពី ដណ្តាំអាហារឆ្អិន នាងក៏ដួសជូនតាយាយពិសារ រួចហើយក៏ដើរទៅតាមរក សុគុណនៅឯក្នុងដីចំការក្រោយផ្ទះអោយមកបរិភោគបាយ។ តាមការពិត ទៅ ប៉ុន្មានថ្ងៃនេះ តាយាយមិនសូវបាននៅបរិភោគជុំគ្នាជាមួយអ្នកទាំង ពីរ ព្រោះគាត់ហាក់ដូចជាមិនចង់រំខានទឹកចិត្តសុគុណដែលកំពុងផ្តោតភ្នែក ផ្តោតអារម្មណ៍លើធិតាយើង។ ណាមួយ វណ្ណៈគាត់ត្រឹមតែជាអ្នកចាំចំការ គាត់មិនហ៊ានវាយកំពស់ឋានៈអោយស្មើនឹងភ្ញៀវដែលជាមិត្តរបស់ម្ចាស់ ចំការដែរ ទើបគាត់ចេះតែនាំគ្នាគេចៗបាត់តែអញ្ចឹងទៅ។

លុះសំនៀងដើរមកដល់ខ្ទមស្បូវចាំចំការស្រាប់តែប្រទះឃើញសុគុណ អង្គុយផ្អែកលើប៉ៅអ៊ីយ៉ាងស្ងៀមស្ងាត់តែម្នាក់ឯង នៅដៃមានកាន់ចិញ្ចៀន ពេជ្រមួយមានរន្ទះភ្លឺផ្លេកៗយ៉ាងរន្ទាល។ គេលើកចិញ្ចៀននោះយកមក សំលឹងមើលចុះឡើងយ៉ាងយូរ សំដែងទឹកមុខស្រងូតស្រងាត់ រួចហើយ ស្រាប់តែលើកចិញ្ចៀនគប់ចោល ទៅក្រោយខ្ទងរូចូលក្នុងព្រៃ។ ចៃដន្យចិញ្ចៀននោះរមៀលច្រលោតតោត មកជ្រុះនៅក្បែរជើងសំនៀងដែល កំពុងដើរចូលពីក្រោយខ្ទងទៅជិតនាយ បំរុងនឹងហៅមកបរិភោគបាយ។ មាណវីភ្ញាក់ព្រើត ស្ទុះអោនឈ្ងោកយកដៃរើសចិញ្ចៀននេះឡើងមកវិញ :

- បងប្រុស.. មានរឿងអ្វីហ្នឹងបានជាបោះចិញ្ចៀននេះចោលដូច្នេះ?

សុគុណភ្ញាក់ព្រើតបែរក្រោយភ្លែតយ៉ាងរហ័ស :

- អុះ សំនៀងទេ?... មកអីស្ងាត់ៗឥចឹង?

- ចាស! គឺមកតាមបងទៅពិសារបាយនោះអី!

ភ្លាមនោះ នាងក៏លើកចិញ្ចៀនហុចទៅអោយនាងហើយសួរថា :

- នេះជារបស់ក្លែងក្លាយមែនទេ បានជាបងបោះចោលងាយៗយ៉ាងហ្នឹង?

CHANBOKEO.COM

សុគុណដាក់ភ្នែកក្រលេកមើលចិញ្ចៀនសាជាថ្មី ហើយសំលឹងទៅរក ធិតាយើង បន្ទាប់មកក៏ស្រដីថា :

- ចិញ្ចៀនពេជ្រនោះជារបស់សុទ្ធ តែម្ចាស់វាទេតើ ដែលមានដួងចិត្តក្លែង ក្លាយ មិនគួរអោយរាប់ជាគ្នាបាន...
- មានន័យថាម៉េចទៅ? សំនៀងស្តាប់មិនយល់ទេ...

សុគុណធ្វើមុខស្ងួត ហើយនិយាយដោយសំដីធុញថប់ថា :

- នាងមិនបាច់យល់ទេ... គ្រាន់តែដឹងថា ខ្ញុំលែងចង់ទុកវាទៀតហើយ...
- ពុទ្ធោ របស់នេះមានតម្លៃណាស់ ម៉េចក៏បោះចោលងាយៗម្ល៉េះ? អ្នកក្រ ដូចសំនៀងនេះ សន្សំមួយជាតិក៏រកលុយទិញមិនបានដែរ បើសិនជាលោក បោះចោលពិតមែននោះ សំនៀងពិតជាស្តាយណាស់... ប៉ុន្តែ...

ស្រាប់តែនាងដាក់ខ្លួនចុះអង្គុយផ្ទាល់ដី ក្បែរសុគុណហើយស្រដីតទៅទៀតថា :

- បើបងបោះចោលមែន សំនៀងសុំរើសយកបានទេ? ក្រែងថ្ងៃណាមួយ សំនៀងប្រទះនឹងជីវិតទាល់ច្រក នឹងអាចយកទៅលក់ដោះទាល់..
- ទៅចង់បានវាធ្វើអ្វីសំនៀង... នេះជារបស់ដែលមនុស្សម្នាក់គេគ្រវាត់ ទៅហើយ... វាជារបស់អពមង្គលណាស់ ដឹងទេ?
- មិនអីទេ របស់មិនមានមង្គល វាសមនឹងរូបខ្ញុំហើយដែលកំពុងបាក់មែក បាក់ធាង...

សុគុណឮដូច្នោះហាក់ដូចជាអាណិតនាងណាស់ គេក៏ស្រដីទៅវិញថា :

- កុំនិយាយប្រមាថខ្លួនអីសំនៀង! បើនាងចង់បានពិតមែន ចាំបងទិញថ្មីអោយវិញណា៎ បងមិនចង់អោយនាងពាក់របស់ដែលគេទេ...
- ប៉ុន្តែ.. សំនៀងមិនចង់បានអ្វីពីបងទេ.. សេចក្តីល្អរបស់បងដែលផ្តល់មកអោយសំនៀងនៅពេលនេះ វាមានតម្លៃលើសពីអ្វីទាំងអស់ កុំថាឡើយ ត្រឹមតម្លៃចិញ្ចៀនមួយនេះ មួយរយដង មួយពាន់ដងទៀតក៏មិនស្មើដែរ ។ បងមិនពិបាកទិញអ្វីអោយទេ.. អោយតែបងអាណិតស្រលាញ់សំនៀង ដូច្នេះរហូតទៅ នោះសំនៀងនឹងនឹកគុណបងអស់មួយជីវិត ។

សុគុណឮដូច្នោះ ក៏លែងមាត់តទៅទៀត ហើយក៏បែរសំលឹងកែវភ្នែករបស់នាងដែលកំពុងសំលឹងមកនាយហាក់ដូចជាកំពុងរង់ចាំសេចក្តីសន្តោស ប្រណីពីនាយអញ្ចឹង ។ ភ្លាមនោះ គេក៏លើកដៃអង្អែលកេសានាងថ្នមៗរួច ហើយស្រដីវាចាយ៉ាងស្រទន់ថា :

- សំនៀងកុំភ័យអី... បងពិតជាអាណិតស្រលាញ់រូបប្អូនហើយបងនឹងគ្រប់គ្រងរូបប្អូនអោយបានសុខរៀងទៅ ចាកផុតអស់នូវទុក្ខភ័យទាំងឡាយ... ឮហើយនៅ?

ឮប្រយោគនេះកាលណា សំនៀងក៏ញញឹមឡើងទាំងរលីងរលោងទឹកភ្នែក ហើយក៏លើកដៃប្រណម្យសំពះនាយយើងភ្លាម:

CHANDBOKEO.COM

- អរគុណបងណាស់! បើគ្មានបងទេ... ខ្ញុំក៏ប្រហែលជាមិនបានឃើញថ្ងៃរះ
សាជាថ្មីនៅពេលនេះដែរ...

សុគុណក៏លូកចាប់ទ្រដៃទទួលនូវពាក្យអំណរគុណរបស់នាង រួចហើយ ក៏ពោលថា :

- ណ្ហើយចុះ! បើប្អូនចង់បានចិញ្ចៀននេះពិតមែន ប្អូនយកទៅចុះណាំ! បង
 មិនថាអីទេ។

សំនៀងឮដូច្នោះក៏ញញឹមឡើងទាំងត្រេកអរ :

- អរគុណបង!

នាងក៏ឈ្ងោកចុះយកចិញ្ចៀនមកពាក់ ស្រាប់តែល្មមនឹងម្រាមដៃប៉ិច ដូចគេវាស់អញ្ចឹង។ នាងក៏លូចយកដៃអង្អែលចិញ្ចៀន ដោយក្ដីរំភើបក្នុង ចិត្ត ត្បិតនាងមិនដែលនឹកស្មាន ថាខ្លួននឹងមានសំណាងមកពាក់របស់មាន តម្លៃដូច្នេះម្ដងណាឡើយ។ ឃើញនារីសប្បាយចិត្ត សុគុណក៏ញញឹមឡើង ដាក់នាង :

- ចុះឯណា ក្រែងថា សំនៀងមកតាមបងទៅញុំាបាយហ្អី? ហើយហេតុអី អង្គុយញញឹមញញែម ភ្លេចបាយទឹកបងអស់អញ្ចឹង?

សំនៀងភ្ញាក់ស្មារតីព្រើត ញញឹមឡើងទាំងអឹមអៀនឆ្លើយថា :

- អូហ៎ សូមទោស... សំនៀងអាល័យតែអរភ្លេចខ្លួន... បានជា...

- អញ្ចឹង ម៉ោះ ងើបឡើង... ទៅញុំាបាយ! បងឃ្លានហើយណាំ!

ថាហើយសុគុណក៏ស្ទុះទាញដៃសំនៀងអោយងើបឡើង ហើយដើរដឹក
ដៃនាងត្រលប់ទៅផ្ទះវិញ។ ទាំងពីរនាក់ក៏ញញឹមដាក់គ្នាយ៉ាងបំព្រងមើល ទៅហាក់បីដូចជាបក្សាបក្សីមួយគូ
ដែលកំពុងចាប់ផ្ដើមយល់ចិត្តគ្នាទៅវិញ
ទៅមកមិនខុសឡើយ។

ចាប់តាំងពីថ្ងៃនោះមកគេទាំងពីរហាក់ដូចជាមានចំណងផ្លូវចិត្តស្និទ្ធស្នាល ។ លាក់ក្នុងអារម្មណ៍តែរៀងៗខ្លួនមិនហ៊ានស្រដី តែក៏ពុំអាចលាក់ជិតពីក្រសែ ភ្នែកចាស់ៗពីរនាក់របស់យើងឡើយ។ តាប្រាងចូលចិត្តលលេងនឹងកំលោះ យើងណាស់ ខុសតែយាយប្រាងដែលយកពេលវេលាមកអប់រំសំនៀងរាល់ ថ្ងៃអោយកាន់តែប្រពៃឡើងទៅវិញ។ គាត់ស្រលាញ់ហើយមើលការខុស ត្រូវសំនៀងដូចជាកូនចៅម្នាក់របស់គាត់ដែរ។ ដោយហេតុថាគាត់ទាំងពីរ មិនដែលមានកូនមានចៅផងនោះ សំនៀងក៏បានក្លាយជាបេះដូងប្រមាត់ ថ្លើមរបស់តាយាយទាំងពីរនាក់តែម្ដង។ នេះជាលើកដំបូងក្នុងជីវិតហើយ ដែលសំនៀងមានអារម្មណ៍ថា ជីវិតរបស់នាងបានប្រទះនូវសេចក្ដីសុខមួយ យ៉ាងកក់ក្ដៅក្រៃលែង។

CHANBOKEO.COM

## សុភមង្គល

យើងស្រលាញ់គ្នាឥតជិនណាយ ពីរកាយយល់ចិត្តត្បិតនិស្ស័យ
ថ្វីបើអតិតកាលសែនអប្រិយ គង់យើងចាប់ដៃសាងផ្លូវល្អ ។
មិនអោយអតិតវិលវិញឡើយ ព្រាត់ហើយសូមឃ្លាតចាកចេញចរ
ស្វែងជីវិតថ្មីយ៉ាងបវរ ក្រោកឈររឹងប៉ឹងប្រឹងតស៊ូ ។
នេះដោយកំលាំងថាមពលចិត្ត ស្មោះស្មគ្រ័ជិតស្និទ្ធហ៊ានផ្តាច់ប្តូរ
ពលីដើម្បីភ្ជាប់ជាគូ និស្ស័យពេញពោរដោយមង្គល ។
យើងស្រលាញ់គ្នាតរៀងទៅ បងនិងពាលពៅថ្លៃនិមល
សូមចាប់ដៃគ្នាសាងមង្គល យល់តែក្បេមក្សាន្តឥតប្រែឡើយ ។

CHANBOKEO . COM

# វគ្គទី៤
# ចំណងដួងចិត្ត

ថ្ងៃនេះ សុគុណអផ្សុកពេកក៏ដើរចុះទៅមាត់ស្ទឹងអង្គុយមើលគេដងត្រី ស្រាប់តែប្រទះនឹងសំនៀងនៅអង្គុយនៅលើកាំជណ្ដើរស្ពាន ចុះទៅក្នុងស្ទឹង ធ្វើមុខស្រងូតស្រងាត់។ នាយយើងក៏ដើរទៅជិតហើយសំរុតខ្លួនអង្គុយចុះ ក្បែរនាង រួចក៏ពោលថា :

- នឹកផ្ទះមែនទេ?...

សំនៀងភ្ញាក់ព្រើតពីការភ្លន់ភ្លឹកអារម្មណ៍ បែរមើលមកមាណពដែល មកអង្គុយជិតនាងពីកាលណាមិនដឹង។ នាងក៏ប្រញាប់ឆ្លើយវិញថា :

- មិនមែនទេ! គឺខ្ញុំនឹកម៉ែនិងប្អូន ត្បិតអីតាំងពីថ្ងៃចាកចេញពីផ្ទះមក ខ្ញុំមិន ដែលបានធ្វើបុណ្យបញ្ជូនកុសលអ្វីដល់អ្នកទាំងពីរម្ដងណានៅឡើយទេ។

សុគុណឮដូច្នោះក៏វាចាតបវិញថា :

- នាងចង់ទៅវត្តទេ? ចាំបងជូនទៅ! វត្តយើងមានឆ្ងាយឯណា... ដើរបន្តិច ក៏ដល់ស្រេច។

- ប៉ុន្តែ.. ខ្ញុំមិនហ៊ានចេញមុខទៅណាទេ ខ្លាចអ្នកស្រុកគេស្គាល់

- ទៅខ្លាចធ្វើស្អី? សំនៀងមានធ្វើអ្វីខុសទៅទើបខ្លាចគេ? នែ៎! នៅជាមួយ បងហើយ មិនត្រូវខ្លាចនរណាទេ... បើមានគេមកហៃហៃ ចាំបងចាត់ការ ឮហើយនៅ?

ឃើញសុគុណនិយាយទ្រង់កំប្លែង សំនៀងញញឹមតិច១ :

- ឃើញបងស្លេក១ស្លាំង១ ពិសារថ្នាំព្រឹកល្ងាចយ៉ាងនេះ សំនៀងមិនហ៊ាន រំខានបងទេ។

សុគុណឮដូច្នោះ ក៏ដាក់ទឹកមុខជ្រប់ភ្លាម :

- គិតទៅមនុស្សយើង.. រាប់គ្នា តែពេលណាសប្បាយហើយមានកំលាំងជា មនុស្សពេញប្រយោជន៍ទេ មែនទេ? ហើយមនុស្សជំងឺដូចបងនេះប្រហែល គ្មានវាសនានឹងមានញាតិមិត្តណាគេមករាប់រកទេ...

ឃើញសុគុណសំដែងទឹកមុខស្រពាប់ស្រពោនដូច្នោះ សំនៀងភ្ញាក់ខ្លួន នឹកស្ដាយក្រោយដែលខ្លួននាងបាននិយាយបំបាក់ទឹកចិត្តបុរសយើង :

CHANBOKEO.COM

- អោយសំនៀងសូមទោសបងផង អំបាញមិញខ្ញុំនិយាយលេងទេ។ ចាំ
ស្អែកយើងទៅវត្តទាំងអស់គ្នាហើយខ្ញុំនឹងសុំអោយលោកគ្រូស្រោចទឹកមន្ត អោយបងឆាប់ជាវិញផងណាំ...

តែពេលនេះ សុគុណលែងសប្បាយចិត្តទៀតហើយ។ គេនៅតែដាក់ មុខជ្រប់ដដែល បន្តិចមកក៏ដកដង្ហើមធំ រួចងើបមុខមើលទៅខ្សែទឹកក្នុង ស្ទឹងសង្កែដែលកំពុងតែហូរខ្ចួលខ្ចាញ់។ កិរិយារបស់នាយដែលធ្លាប់តែញញឹមញញែមដាក់សំនៀងជានិច្ច មិនថាស្រួលខ្លួនឬមិនស្រួលទេ ពេល នេះបែរជាផ្លាស់ប្តូរយ៉ាងចំលែកតែម្តង ធ្វើអោយសំនៀងលួចបន្ទោសខ្លួន ឯង តែក្នុងចិត្តដែលនិយាយលេងមិនបានគិតដល់អារម្មណ៍អ្នកជំងឺ។ នាងក៏ឈ្ងោកទៅជិតសុគុណហើយវាចាលួងលោមដោយស្រទន់ថា :

- កុំយល់ច្រលំអីណាំបង! មិនថាបងជាឬបងឈឺទេ.. សំនៀងនឹងស្រលាញ់ បងដូចជាបងប្រុសដ៏ល្អម្នាក់របស់សំនៀងរហូតទៅ...!!

ពូវាចារបស់ធិតាយើងដូច្នោះ នាយក៏ងាកមុខមកនាង ហើយក៏ឆ្លើយ ឡើងថា :

- តែ បងមានជំងឺ...ដែលពេទ្យអស់មានសមត្ថភាពនឹងព្យាបាលបាន.. បង
មានជីវិតនៅសល់តែត្រឹមតែប្រាំឬប្រាំមួយខែទៀតប៉ុណ្ណោះ...

- ពុទ្ធោ! បងសុគុណ!... ជាការពិតឬបង?

សុគុណងក់ក្បាលទាំងទឹកមុខស្រងូត ស្រាប់តែសំនៀងរលីងរលោង ទឹកភ្នែកឡើង :

- បងមិនលលេងនឹងប្អូនទេ មែនទេ?

- រឿងយ៉ាងនេះ គេមិនមែនយកមកលលេងសើចចោលទេ សំនៀង។ បង ពិតជាមានជំងឺដូច្នោះពិតមែន...

- ពេទ្យសព្វថ្ងៃជំនាញៗណាស់ ថែមទាំងមានបច្ចេកទេសខ្ពស់ទៀតផង ហេតុអ្វីបានជាគេពុំអាចជួយបងបានដូច្នេះ? ហេតុអី?

សុគុណឃើញកិរិយាសំនៀងហាក់ដូចជាបារម្ភផងរន្ធត់ផង គេក៏នៅ ស្ងៀមហើយពោលដូរសាច់រឿងបន្តិចវិញ :

- សំនៀង! ក្រែងអូនថាចង់ទៅវត្តនាំបងទៅស្រោចទឹកនោះអី បងចង់
ទៅឥលូវនេះ.. អូនទៅជាមួយបងទេ?

- ឥលូវនេះ? ហេតុអ្វីក៏ប្រញាប់ម្ល៉េះ ពេលនេះ ហួសម៉ោងប្រគេនចង្ហាន់ ព្រះសង្ឃហើយណាំ!

- អោយតែនឹកចង់ធ្វើបុណ្យ ទៅវត្តថ្មើរណាក៏បានដែរ ព្រះលោកមិន ប្រកាន់ពេលវេលាទេ។

ភ្លាមនោះ សំនៀងយកដៃផ្តិតទឹកភ្នែក ហើយស្ទុះងើបឡើង :

- អញ្ចឹង បងនៅចាំត្រង់នេះហើយ។ សំនៀងទៅយកកង់មកឌុបបងទៅ។

ថាហើយនាងក៏ស្ទុះទៅយ៉ាងលឿន រកតែសុគុណឃាត់ក៏មិនទាន់ផង។ បន្តិចមក នាងក៏ដឹកកង់មកដល់វិញ :

- បងសុគុណ! ឡើងជិះពីក្រោយមកណាំ!

ស្រាប់តែសុគុណងើបឡើងយកដៃចាប់ចង្កូតកង់ :

- ម៉ោះ! ទុកអោយបងឌុបអូនវិញ។

- បងមិនស្រួលខ្លួន ត្រូវថ្នមសុខភាពខ្លះ ទុកអោយសំនៀងឌុបបងចុះ។

CHANBOKEO . COM

- កុំអាល័យប្រកែកអ្វី... អូនទុកអោយបងឱបចុះ ចាំដល់ពេលណាបងមិន អាចទៅរួច ចាំបងអោយអូនដឹកបងម្តង ។

និយាយមិនឈ្នះ សំនៀងក៏នៅស្ងៀមហើយក៏ហុចកង់អោយសុគុណ ឡើងជិះ ។ នាងក៏ហក់អង្គុយលើរានខាងក្រោយ យកដៃកាន់ចង្កេះមាណព ចេញដំណើរទៅ ។ តាមផ្លូវគេទាំងពីរហាក់ដូចជាមានអារម្មណ៍ភ្លឺថ្លាមកវិញ ជាពិសេសគឺសុគុណតែម្តង ។ ម្រាមដៃដែលសំនៀងកាន់ចង្កេះរបស់នាយ នោះ ហាក់ដូចជាកំពុងបញ្ជូនថាមពលវេទមន្តម្យ៉ាង ដល់បេះដូងនាយឱ្យ រំភើបញាប់ញ័ររកថាមិនត្រូវសោះឡើយ ។

រំភើប

រំភើបដួងចៃស្តីមិនរួច ត្បិតចិត្តគិតគួចលួចស្នេហ៍ស្រី
មិនហ៊ានវាចាប្រាប់ចរណៃ សំដែងចិត្តថ្លៃថាបងស្មគ្រ័ ។
រំភើបអ្វីម្ល៉េះព្រះអង្គអើយ ហឫទ័យមិនស្បើយចិត្តជំពាក់
លួចគិតប្រាថ្នានោមវរលក្ខណ៍ ជាគូអមតៈស្នេហ៍យូរលង់ ។
រំភើបទ័យាហារមិនបាន លួចស្នេហ៍កល្យាណស្រស់នោមយង់
មេត្តាបងទេណាំនួនល្អង ខ្សិបប្រាប់បងផងអោយបានដឹង ។
រំភើបចិត្តពេកគ្មានពាក្យថ្លែង ក្នុងចិត្តគិតក្រែងស្រស់ព្រលឹង
អូននាងមិនស្មគ្រ័បែរជាខឹង ត្បិតរូបបងហ្នឹងមិនសមអូន..?
ថ្វីបើបានជួបត្រឹមពេលខ្លី តែដួងហឫទ័យស្មោះលុះសូន្យ
សច្ចាថ្នមស្នេហ៍ចាកស្រពោន អូនអើយឆ្លើយផង គិតយ៉ាងណា?

បន្តិចមក គេក៏កាន់ចង្កូតកង់នៅដៃម្ខាងរួចហើយក៏ដកដៃម្ខាងមកបន្លំ កាន់ម្រាមដៃរបស់សំនៀង ដែលកំពុងកាន់ចង្កេះនាយ ដោយមិនបានចាប់ ភ្លឹក ។ លុះឃើញនាយស្រវាចាប់ម្រាមដៃនាងភ្លាម តរុណីយើងភ្ញាក់ព្រើត ខំស្ទុះដកដៃយ៉ាងរហ័ស តែក៏ដកមិនរួចសោះ ត្បិតកំលោះយើងបានចាប់ ដៃនាងក្តាប់យ៉ាងជាប់ណែនទៅហើយ ។ ម្យ៉ាងទៀត កាលបើឃើញ សុគុណកំពុងមានទឹកមុខរីករាយមកវិញថ្មីៗ ធិតាក៏មិនហ៊ានធ្វើអ្វីអោយ បាក់ទឹកចិត្តនាយដែរ ម្ល៉ោះហើយក៏បណ្តោយអោយនាយឱបកង់កាន់ដៃ នាងរហូតទៅដល់ខ្លោងទ្វារវត្តគរទើបគេព្រលែងវិញ ។ លុះនាងស្ទុះចុះពី រានកង់ដើរពីក្រោយសុគុណ មាណពលួចងាកក្រោយចោលកន្ទុយភ្នែក អោយនាងហើយលួចញញឹមតែម្នាក់ឯង ។ បន្ទាប់មកគេក៏ដើរដឹកកង់ធ្វើ មិនដឹងសំដៅទៅកុដិដ៏ស្អាតវិចិត្រមួយ ។

នៅចំពោះមុខព្រះសង្ឃមួយព្រះអង្គ អ្នកទាំងពីរអោនក្រាបបង្គំទទួល នូវទឹកមន្តពីព្រះអង្គនិងពរសាធុការដ៏ល្អប្រសើរជាច្រើន ធ្វើអោយគេមាន ចិត្តមានអារម្មណ៍ធូរស្រាលសប្បាយរីករាយតែម្តង ។ មិនតែប៉ុណ្ណោះ អ្នក ទាំងពីរក៏បានបង្សុកូលជូនម្តាយនិងប្អូនស្រីរបស់នាងទៀតផង ។

បន្តិចមក គេក៏នាំគ្នាដើរដឹកកង់ចេញពីវត្តរកត្រលប់ទៅផ្ទះវិញ ស្រាប់ តែសុគុណបបួលឡើងថា :

CHANBOKEO.COM

- សំនៀងចង់ទៅដើរលេងនៅផ្សារទេ?

- ទៅផ្សារ? បងចង់ទៅធ្វើអី?

- បងគិតថា ចង់ទៅរកទិញអ្វីបន្តិច...

- តែសំនៀងមិនចង់ទៅទេ...

- ហេតុអីទៅ?

- នៅផ្សារលើមានគេស្គាល់ឪពុកចុងរបស់ខ្ញុំគ្រប់គ្នា បើគេឃើញមុខនោះគឺ ខ្ញុំចៀសមិនរួចពីការនិន្ទា... ឬក៏...

វំពេចនោះ ស្រាប់តែមានស្រីម្នាក់ស្រែកវ៉ាង១ឡើងយ៉ាងខ្លាំង១ថា :

- នែ៎មីឃាតករ! យើងរកមុខនាងយូរហើយ ទៅពួនឯណាបានទើបតែ ចេញមុខមកថ្ងៃហ្នឹ៎ស?

ស្រីនោះជំទាលផងរត់ផង ស្ទុះមករកទះតប់សំនៀង តែត្រូវសុគុណ យកដៃរងជាប់ ថែមទាំងស្រដីសួរយ៉ាងប្រញាប់ទៅវិញថា :

- បងស្រីមានរឿងអីហ្នឹង? ហេតុអ្វីចាំប្រើកំលាំងបាយផង?

- គឺវា... គឺវាបានសំលាប់បងប្រុសរបស់យើង... គឺវាហ្នឹងហើយ...

សំនៀងរត់គេចទៅពួនពីក្រោយខ្នងសុគុណ ហើយឆ្លើយទាំងភ័យរន្ធត់ ទៅវិញថា :

- អត់ទេ... ខ្ញុំមិនបានសំលាប់នរណាទេ...

- យើ! នៅប្រកែកទៀត.. បើមិនមែនជាឯង តើនរណាទៅវិញ?

ដោយស្នូរសំលេងជំទាលរបស់ស្ត្រីម្នាក់នោះពូខ្លាំង១ពេក អ្នកស្រុកក៏ ផ្អើលឈូឆរត់មកមើល ធ្វើអោយមាណវីយើងស្លុតស្មារតីរឹតតែខ្លាំង ។ លុះ ឃើញនាងភិតភ័យយ៉ាងនោះ សុគុណក៏យកដៃត្រកងការពារនាងភ្លាម ព្រមទាំងលួចខ្សិបថា :

- នែ៎ ឈប់ភ័យទៅ! នៅទីនេះជាបរិវេណវត្តណា៎ គ្មាននរណាហ៊ានធ្វើអី អូនទេ ដឹងទេ?

វំពេចនោះ លោកតាអាចារ្យនិងមេភូមិក៏មកដល់ :

- មានការអ្វីដែរទៅចៅ១អើយ ឈ្លោះគ្នារឿងអីហ្នឹង?

សុគុណបែរក្រោយឃើញមនុស្សចាស់ចូលធ្វើអន្តរាគមន៏ ក៏លើកដៃ សំពះឡើង :

- ជំរាបសួរបាទ! គឺមានរឿងច្រលំបន្តិចបន្តួចទេបាទ!

- មិនច្រលំទេ! យើងស្គាល់នាងនេះច្បាស់ណាស់! វាជាមនុស្សដែលបាន សំលាប់បងប្រុសរបស់ខ្ញុំ ( ស្រីនោះស្រដីផង ចង្អុលមុខទៅសំនៀងផង)

ស្រាប់តែតាមេភូមិស្រដីឡើង :

- គេជាស្រីរាងតូច១ស្គម១យ៉ាងនេះ ទៅសំលាប់មនុស្សប្រុសឯណាកើត ទៅ? នាងអើយ! ឯងស្រវឹងកញ្ឆាឬស្រវឹងស្រា បានជានិយាយរកខុសរក ត្រូវអ្វីមិនឃើញយ៉ាងនេះ? ឬក៏ដើរជាន់ពៃរ៨ទិសទើប...

CHANBOKEO . COM

ឮដូច្នោះស្រីម្នាក់នោះក៏បែរជាខឹងនឹងតាមេភូមិភ្លាម ហើយនិយាយ កាត់ប្រសាសន៍គាត់ថា :

- នែ៎តាចាស់! បើមិនដឹងខ្យល់អីទេ.. បិទមាត់ទៅ តិចដាល់បាក់ធ្មេញអស់ អាលូវហ្នឹង?

- ពុទ្ធោ! (តាមេភូមិឆ្លើយ) សំដីក៏យង់ឃ្នង កិរិយាក៏យង់ឃ្នងបែបនេះ ធ្វើឱ្យតាគិតថា អ្នកដែលសាហាវហ៊ានធ្វើបាបឬសំលាប់មនុស្សដូចគ្នា គឺ ប្រហែលជាចៅស្រីឯងហ្នឹងតែម្តងហើយ...

លើកនេះ ស្រីម្នាក់នោះលែងទ្រាំបានហើយ ក៏ជះកំហឹងលើតាមេភូមិ ម្តងវិញ :

- នែ៎តាចាស់! បើមិនបិទមាត់ទេ យើងបិទជួសក៏បានដែរ ។

ថាហើយ នាងក៏លើកដៃយាររកប្រវាយធ្វើបាបតាមេភូមិ ស្រាប់តែ អ្នកស្រុកស្ទុះរត់ប្រញាប់ចាប់យកចេញភ្លាមមិនអោយតាមេភូមិមានរបួស ទាន់ទេ ។ បន្តិចមក អ្នកស្រុកក៏រត់ទៅតាមលោកគ្រូអធិការវត្តមកដល់ ។ ព្រះអង្គក៏មានដីការឡើងថា :

- នរណាគេមានកំហឹងពុះពោរម្ល៉េះហ្ន៎? ហេតុអ្វីក៏កំរោលចូលរហូតដល់ បាត់ស្មារតីនិងភាពថ្លៃថ្នូរអស់រលីងយ៉ាងនេះ? ទីនេះជាវត្តអារាម ជាទីស្ងប់ សុខនិង ជាម្លប់ត្រជាក់ដល់មនុស្សលោកគ្រប់គ្នា ។ បើសិនចង់ពន្លត់ភ្លើង កំរោលនោះ វត្តយើងអាចទទួលញោមគ្រប់ពេលវេលា មានញោមអង្គណា ស្មគ្រ័ចិត្តទេ?

គ្រាន់តែក្រលេកឃើញព្រះសង្ឃនិមន្តមក ស្រីម្នាក់នោះក៏ដកដៃទៅ វិញ ហើយក៏ស្រដីតាមសំរួល :

- សូមទោសព្រះតេជគុណ! ខ្ញុំព្រះករុណាទ្រាំមិនច្រលោតមិនបានដោយ សារតែបានជួបឃាតករដែលសំលាប់បងប្រុសរបស់ខ្ញុំព្រះករុណានៅទីនេះ

- ញៀររមែងរំងាប់ដោយការមិនចងញៀរ... ការដែលញោមខឹងច្រលោត រហូតដល់បាត់បង់នូវសុគតិនិងភាពថ្លៃថ្នូរហើយ អ្វីៗមិនអាចស្រាយរួចដូច បំណងរបស់ញោមឡើយ ។ ថ្ងៃនេះ អាត្មាសូមបិណ្ឌបាត្រនូវកំហឹងនិងគំនុំ គុំគួន ដែលមាននៅក្នុងចិត្តរបស់ញោមទាំងអស់បានដែរទេ?

ឮដូច្នោះ ស្រីម្នាក់នោះមិនឆ្លើយនឹងព្រះអង្គវិញទេ បែរជាយកដៃ ចង្អុលមុខសំនៀងហើយសំលក់នាងស្ទើរជ្រុះគ្រាប់ភ្នែក :

- យើងផ្ញើទុកសិនចុះ! ចាំស៊ីសងថ្ងៃក្រោយក៏បានដែរ ។

ថាហើយ នាងក៏ដើរចេញទៅ ។ ព្រះគ្រូចៅអធិការឃើញដូច្នោះក៏ និមន្តត្រលប់ទៅកុដិវិញដែរ ។ តាមេភូមិក៏សួរអ្នកទាំងពីរឡើងថា :

- តាមិនដែលឃើញចៅទាំងពីរពីមុនមកទេ ។ ឯងជាមនុស្សចំណូលថ្មីមែន ទេ? ចង់អោយតាចុះស្ថិតិប្រជាជនបន្ថែមក្នុងភូមិយើងនេះទេ?

តាអាចារ្យឮដូច្នោះក៏បន្ទរឡើង :

- ប្រហែលជាទើបនឹងរៀបការថ្មីហើយមើលទៅ បានដូចជានៅអឹមអៀន ដាក់គ្នាយ៉ាងនេះ? មើលទៅ ទាំងគូស្រស់ស្អាតសមគ្នាដល់ហើយហ្ន៎!

សុគុណលួចដៀងកន្ទុយភ្នែកដាក់សំនៀង ឃើញនាងឈ្ងោកមុខទ្រង់ អៀនប្រៀន ក៏ឆ្លើយវិញថា :

CHANBOKEO.COM

- គឺប្រពន្ធខ្ញុំជាមនុស្សអៀនលាក់មុខដូច្នោះឯង មិនសូវហ៊ានងើបមើល មុខនរណាទេ លោកតា!

ឮដូច្នោះ សំនៀងលួចយកដៃទៅមួលចង្កេះសុគុណពីក្រោយខ្លាច់ទាំង ឃ្នាន់ខ្នាញ់ ធ្វើអោយសុគុណរិតតែបានចិត្ត ចង់តែលលេងបន្ថែមទៀត ជា ពិសេស ពេលនាយយើងឃើញធិតាអៀនឡើងក្រហមថ្ពាល់គួរអោយចង់បបោសលួងលោមយ៉ាងនោះ មាណពរិតតែចង់ចំអន់នាងថែមមិនចង់ឈប់ សោះ ។ បន្តិចមកគេទាំងពីរក៏សំពះលាលោកតាទាំងពីរត្រលប់មកផ្ទះ វិញ ។ កំពុងតែធាក់កង់សុខៗ ស្រាប់តែសុគុណមានអារម្មណ៍ថាងងិតមុខ ឈឺងតែម្តង ។ ធិតា យើងក៏លោតចុះទប់កង់មិនអោយដួល :

- បងសុគុណ!.. មិនស្រួលខ្លួនទៀតហើយមែនទេ?

មាណពងក់ក្បាល ។ សំនៀងភ័យភើតពោះឡើងធាក់កង់ជាប្រញាប់ ហើយដាក់បុរសយើងអោយអង្គុយអោបចង្កេះផ្តេកក្បាលលើខ្នងរបស់ នាង រួចហើយនាងក៏ប្រឹងធាក់កង់ឌុបនាយយើងរហូតទាល់តែដល់ផ្ទះ ទើបគ្រាហ៊ីរូបនាយទៅដាក់នៅលើគ្រែ ។ ភ្លាមនោះ តាក្រូចរត់មកដល់ :

- សុគុណយ៉ាងម៉េចហ្នឹង? ជំងឺចាស់រើឡើងវិញទេដឹង?

- តា.. យើងគួរយកគាត់ទៅពេទ្យឬយ៉ាងណា (សំនៀងសួរ)

ស្រាប់តែសុគុណស្រវាចាប់ដៃនាងហើយគ្រវីក្បាល :

- មិនបាច់ទេ!    បងលេបថ្នាំ ហើយគេងសំងំមួយភ្លែតទៅ អស់អីហើយ ។ ពេលនេះ អោយបងសុំទឹកឆ្អិនមួយកែវមក...

សំនៀងស្ទុះទៅយកថ្នាំរបស់នាយព្រមទាំងទឹកក្តៅមកផង ។ មួយ ស្របក់មក សុគុណក៏ធ្ងេចសំងំស្ងាត់ស្ងៀម ។ សំនៀងក៏សួរខ្សិបៗទៅតា ក្រូចថា :

- តា! តើយើងគួរជំរាបដំណឹងដល់ក្រុមគ្រួសាររបស់គាត់ទេ?

- តាមិនស្គាល់លេខទូរសព្ទ័អ្នកភ្នំពេញទេ ចៅអើយ ។

ស្រាប់តែយាយប្រាងដើរចូលមកដល់ :

- តែពិសិដ្ឋគេបានសរសេរលេខទុកអោយខ្ញុំឯនេះនែ៎ ។ បើសិនទៅផ្សារ ទូរសព្ទ័ហៅគេ ប្រហែលជាជួបហើយ ។

ស្រាប់តែសុគុណបើកភ្នែកមកវិញ :

- ខ្ញុំមិនអីទេ! មិនបាច់ប្រាប់ទៅអ្នកផ្ទះរបស់ខ្ញុំក៏បានដែរ ចាំស្អែកស្រួលខ្លួន ចាំខ្ញុំទៅផ្សារណាត់ ទូរសព្ទ័ទៅលោកប៉ាជំរាបគាត់ ។

រួចហើយនាយក៏បែរមកគោះដៃសំនៀង :

- សំនៀង អូនមិនបាច់ចេញទៅក្រៅផ្ទះទេ ។ នៅទីនេះ អូនមានសុវត្ថិភាព គ្រប់គ្រាន់ហើយ ។ បងមិនចង់អោយនាងទៅក្រៅទេព្រោះបារម្ភក្រែង មានមនុស្សគេមកយាយីរូបអូនដូចថ្ងៃនេះទៀត ។

ឮសុគុណស្រដីដូច្នោះ តាយាយទាំងពីរនាក់មើលមុខគ្នាភ្លាម ។ បន្តិច

CHANBOKEO.COM

មក គាត់ក៏នាំគ្នាចេញទៅ នៅតែសំនៀងដែលនៅអង្គុយកំដរនាយ:

- បងសំរាន្តទៅណា៎!

សុគុណញញឹមសំលឹងមកសំនៀងដោយក្រសែភ្នែកដ៏ផ្អែមល្ហែមមួយ :

- ហើយពេលបងភ្ញាក់មកវិញ សូមឱ្យបងឃើញរូបអូនមុនគេ ព្រមទេ?

សំនៀងងក់ក្បាលហើយញញឹមតបវិញ :

- អញ្ចឹង ឆាប់សំរាន្តទៅ នឹងអាលមានកំលាំងមកអង្គុយមើលមុខសំនៀង ជាថ្មីទៀត។ អោយតែជាពេលណា ចាំខ្ញុំអង្គុយឱ្យបងមើលអោយឆ្អែតតែ ម្តង សុខចិត្តទេ?

ឮនាងនិយាយលេងបែបនោះ មាណពលួចញញឹមភ្លាមហើយក៏ប្រែ ខ្លួនទៅម្ខាងបិទភ្នែកសំងំគេង។ មិនដឹងជាអស់យូរប៉ុនណាទេ លុះសុគុណ ភ្ញាក់ឡើងក៏ស្ទុះងើបហៅរកនារីយើងភ្លាម :

- សំនៀង... សំនៀង...

- យ៉ាងម៉េចសុគុណប្អូនសំលាញ់បង? សុខទុក្ខយ៉ាងណាហើយ?

សុគុណឮពាក្យនេះកាលណាក៏ញីភ្នែកឡើងអោយស្វាងពីដំណេក រួច ហើយក៏លាន់មាត់ថា :

- បងវរលក្ខណ៏!

គេក៏ស្ទុះងើបមកស្រវាអោបបងស្រីភ្លាម :

- ប្អូនកំពុងតែនឹកបង បងក៏មកដល់ល្មម។

- កូននឹកតែបងស្រី ចុះមាននឹកប៉ាខ្លះដែរឬទេកូន?

- លោកប៉ា...!

សុគុណលាន់មាត់ឡើងហើយស្ទុះទៅសំពះលោក ដែលមកអង្គុយរង់ ចាំតាំងពីអង្កាល់មិនដឹង :

- លោកប៉ា! ម៉េចបានអញ្ជើញមកដល់ទីនេះដែរ?

- គឺចៅស្រីយាយផាត់ឈ្មោះសំនៀងគេទូរសព្ទ័ទៅពិសិដ្ឋពីម្សិលមិញ

- ពីម្សិលមិញ? (សុគុណយកដៃអេះក្បាល) ហើយខ្ញុំគេងលក់យូរដល់ ម្លឹងផងឬលោកប៉ា?

រំពេចនោះ នាយក៏ក្រលេកមើលជុំវិញខ្លួន ស្រាប់តែឃើញនាយនៅ ក្នុងបន្ទប់ចំលែមួយ :

- កូននៅកន្លែងណាហ្នឹងលោកប៉ា?

- នៅពេទ្យធំណា៎! តាយាយនិងចៅស្រីគាត់ដឹកឯងយកមកពេទ្យកាលពី ព្រលប់ថ្ងៃម្សិលត្បិតកូនមិនស្រួលខ្លាំងមមើមមាយផ្តេសផ្តាស។ លុះដឹង ដំណឹងដូច្នេះ ទើបពិសិដ្ឋគេជូនប៉ានិងបងវរលក្ខណ៏មកនេះអី។

CHANBOKEO.COM

តែសុគុណមិនបានស្តាប់ប្រសាសន៍របស់លោកវរៈចប់ចុងចប់ដើមទេ។ គេបែរជាអើតអើមដកកសំលឹងទៅក្រៅទៅវិញ។ ឃើញកិរិយារបស់ប្អូន ដូច្នោះ វរលក្ខណ៏ក៏សួរឡើង :

- រកនរណាគេ សុគុណ? រកពិសិដ្ឋមែនទេ? មិនបាច់រកទេ គេជូនចៅស្រី យាយប្រាងទៅផ្ទះហើយ ព្រោះគេឃើញនាងអត់ងងុយកំដរឯងម៉ាយប់ ទាល់ភ្លឺ ខ្លាចឈឺម្នាក់ទៀតទើបដេញអោយទៅសំរាក។

- បងវរលក្ខណ៏! លោកប៉ា! ខ្ញុំចង់ចេញទៅផ្ទះ (សុគុណពោលឡើង)

- ប៉ាអរណាស់កាលបើកូនចង់ទៅផ្ទះយើងវិញ។

- គឺ... កូនមិនបានសំដៅថាទៅផ្ទះនៅភ្នំពេញទេ តែកូនចង់ទៅផ្ទះនាយ សិដ្ឋដែលនៅឯវត្តគរទេតើហ៎!!

លោកវរៈព្វហើយក៏សំលឹងមុខវរលក្ខណ៏ តែលោកក៏មិនហ៊ានជំទាស់ ចិត្តកូនដែរ។ មួយស្របក់ក្រោយមក អ្នកទាំងបីក៏បានមកដល់ផ្ទះពិសិដ្ឋឯ ចំការនៅវត្តគរវិញ។ គ្រាន់តែចុះពីឡានមិនទាន់ សុគុណក៏ហក់ឡើងលើ ផ្ទះយ៉ាងលឿន ទុកអោយលោកវរៈនិងវរលក្ខណ៏សំលឹងមើលតាមក្រោយ ទាំងទឹកមុខងឿងឆ្ងល់។ លុះមកដល់មាត់ទ្វារបន្ទប់របស់សំនៀង គេក៏ទុច ង៉ក់ បំរុងនឹងរកគោះទ្វារ ស្រាប់តែដកដៃទៅវិញ បន្តិចមកក៏យកដៃច្រាន ទ្វារថ្នម១លួចសំលឹងទៅក្នុងបន្ទប់ ឃើញចិតាគេងសំងំលង់លក់លើគ្រែ តែម្នាក់ឯងស្ងៀមស្ងាត់។ គេក៏លួចបើកទ្វារលប១ ដើរចូលទៅជិត ហើយ ដាក់ខ្លួនចុះក្បែរនាងថ្នម១ ហាក់មិនចង់រំខានអោយភ្ញាក់ដំណេករបស់នាង ឡើយ។ គេលួចគយគន់សំលឹងមុខនាងយ៉ាងយូរ ដោយក្តីរំភើបក្នុងចិត្ត។ នៅដៃឆ្វេងដែលនាងដាក់ទ្រក្រោមថ្ពាល់គេង មាណពយើងឃើញចិញ្ចៀន ចាំងភ្លេក១ពីម្រាមដៃរបស់នាង។ គេក៏លូកដៃទៅអង្អែលម្រាមរបស់នាង យ៉ាងថ្នម១ ដោយដួងចិត្តញាប់ញ័រចំលែកថែមទាំងលួចនឹកគិតក្នុងចិត្តថា :

- ឱ! ចិញ្ចៀនអើយ! តើអ្នកកំពុងស្ថិតនៅក្នុងដៃម្ចាស់ពិតរបស់អ្នក ឬក៏ យ៉ាងណា? ឬក៏គេ...ជាមនុស្សដែលមានចិត្តក្លែងក្លាយ ដូចម្ចាស់ដំបូង របស់អ្នកដែរ?... ឱសុគុណអើយ... ហេតុអ្វីក៏គិតវែងឆ្ងាយម្ល៉េះ? តើនរណា ទៅដែលគេនឹងមកស្មគ្រ័ចងចិត្តចងបេះដូងជាមួយអ្នក កាលបើអ្នកមាន ជីវិតនៅសល់មិនបានប៉ុន្មានខែទៀតផងនោះ?

រំពេចនោះ ស្រាប់តែបេះដូងនាយរណ្តំកាន់តែខ្លាំងឡើង...ដៃនាយក៏ ញ័រស្ទើរតែទប់មិនបាន គេក៏ដកដៃចេញមកវិញធ្វើទឹកមុខស្រងូតស្រងាត់ ហើយគិតក្នុងចិត្តបន្តទៀតថា :

- សុគុណអើយ! សូមអ្នកកុំសាងក្តីសង្ឃឹមឬក្តីស្រម័យថ្មីអី... ទោះជាយ៉ាង ណាក៏វាមិនអាចទៅរួចដែរ ព្រោះអីនៅពេលមិនយូរមិនឆាប់ អ្នកនឹងលា គេទាំងឡាយទៅឆ្ងាយហើយ...

សុគុណក៏ងាកបែរដើរចេញទាំងទឹកភ្នែករលីងរលោង ស្រាប់តែ :

- បងសុគុណ!

មាណពភ្ញាក់ព្រើត បែរក្រោយ ឃើញមាណវីយើងភ្ញាក់ឡើង ក្រោក អង្គុយ ព្រមទាំងសួរមកនាយទាំងទឹកមុខត្រេកអរថា :

CHANDBOKEO.COM

- បងស្រួលខ្លួនហើយឬ ទើបមកផ្ទះវិញ? យប់មិញខ្ញុំព្រួយពីបងណាស់ បងដឹងទេ? ខ្ញុំបានទាំងទូរសព្ទ័ទៅជំរាបបងពិសិដ្ឋអោយជំរាបលោកប៉ា របស់បងទៀតផង ។

- បងស្រួលបួលហើយសំនៀង ។ បងអរគុណអូនណាស់ដែលយកចិត្តទុក ដាក់ចំពោះបង ។

ថាហើយ គេក៏បែរមើលមុខនាង ហើយក៏ស្រដីថែមទៀតថា :

- គ្រាន់តែបង... ខកចិត្តបន្តិច...

- ខកចិត្ត? រឿងអ្វីទៅបង?

- គឺខកចិត្តនៅពេលបើកភ្នែកឡើង មិនបានឃើញសំនៀងមុនគេនោះអី..

ឮដូច្នោះ សំនៀងឈ្ងោកមុខចុះ :

- អោយសំនៀងសូមទោសណាំបង... ដែលគេចខ្លួនមកសំងំគេង មិនបាន នៅមើលថែរូបបងដូចដែលខ្ញុំបានសន្យា...

ឃើញសំនៀងឈ្ងោកមុខទទួលកំហុសដូច្នោះ បុរសយើងក៏យកដៃ ទៅភ្ញើយចង្កានាងឡើង ហើយវាចាយ៉ាងស្រទន់ទៅកាន់នាងថា :

- តែឥលូវនេះ បងឈប់ខកចិត្តវិញហើយ ព្រោះបងបានឃើញអូនសាជា ថ្មី! មើល៏ ឯណា..? ញញឹមដាក់បងបន្តិចមក បានទេហ៎?

សំនៀងក៏ងើបមុខសំលឹងនាយវិញ ដោយក្រសែភ្នែកភ្លឺថ្លាពណ្ណរាយ ។ គ្រាន់តែក្រសែភ្នែកអ្នកទាំងពីរប្រទាក់គ្នាភ្លាម គេក៏ញញឹមដាក់គ្នាឡើង ដោយឯកឯង លាយឡំនឹងអារម្មណ៏រីករាយរំភើបចំពោះគ្នាទៅវិញទៅ មកតែរៀងៗខ្លួន ។

ក្លិនស្នេហ៍

ក្លិនស្នេហ៍ក្រអូបស្រូបមិនណាយ ពិដោរសុះសាយអប់ដួងចិត្ត
ក្លិនមានទេពមន្តហាក់អម្រឹត ប្រស់ព្រំជីវិតអោយបំព្រង ។
ក្លិនស្នេហ៍សាយគន្ធអង្រួនចិត្ត ខាបសណ្ដំពិតពេញបេះដូង
ក្លិនអប់ស្មារតីអោយធ្លាក់លង់ រសស្នេហ៍ផូផង់យ៉ាងត្រកាល ។
ក្លិនស្នេហ៍សណ្ដំដួងទ័យា ផ្ទាក់ផ្ទមចិន្ដាអោយស្រើបស្រាល
ក្លិនស្នេហ៍បរិសុទ្ធពិតវិសាល ពន្លឺត្រកាលក្នុងអារម្មណ៏ ។
ក្លិនស្នេហ៍ភក្ដីស្រីនិងបង ក្រអូបកន្លងយ៉ាងភិរម្យ
ក្លិនស្នេហ៍មង្គលថ្កាលឧត្ដម ជីវិតសុខដុមរៀងទៅអើយ ។

សុគុណយកដៃទៅអង្អែលថ្ពាល់ធិតាថ្នមៗដោយដួងចិត្តញាប់ញ័របំផុត រួចក៏បន្ទន់ខ្លួនសំយុងនាសា បំរុងនឹងថែថើបថ្ពាល់ដ៏ក្រហមរលោងរបស់ កល្យាណីយើងនោះទៅហើយ ស្រាប់តែ :

- អាហ៊្មែម! សុំចូលលេងផងបានទេ?

CHANBOKEO .COM

សុគុណានិងសំនៀងភ្ញាក់ព្រើត គេចមុខចេញរៀងៗខ្លួនភ្លាម ត្បិតនឹក អៀនខ្មាស់ក្នុងចិត្តទាំងសងខាង ។ ពេលនោះមាណពយើងឧទានបន្ទប់ថា :

- បងវរលក្ខណ៍... មានការអីមែនទេ?
- អត់មានអីទេ... គ្រាន់តែបងចង់ស្គាល់មិត្តស្រីរបស់ប្អូនតើហ៎

សុគុណាឮហើយក៏អេះអុញក្រហមស្លឹកត្រចៀកងាំងមិនហ៊ានឆ្លើយ ។ រី ឯសំនៀងវិញក៏ឈ្ងោកមុខគេចទៅម្ខាងដែរ មិនហ៊ានស្រដីអ្វីទេ ត្បិតនាង កំពុងភិតភ័យមិនដឹងថានឹងត្រូវធ្វើយ៉ាងណាអោយសមឡើយ ។ ភ្លាមនោះ វរលក្ខណ៍ក៏ស្រដីទៅកាន់អ្នកទាំងពីរថា :

- បងភរទេ.. ការពិតគឺ លោកប៉ាចង់ជួបនិយាយជាមួយប្អូនណា៎

សុគុណាឮហើយក៏ងាកមើលសំនៀង ញញឹមដាក់នាងបន្តិចរួចដើរចេញ ទៅ ។ ចំណែកវរលក្ខណ៍ក៏ដាក់ខ្លួនចុះក្បែរ ធិតាយើងហើយសួរនាងថា :

- ស្រួលខ្លួនគ្រាន់បើហើយឬនៅ? បងមកនេះ...គឺដើម្បីអរគុណនាងដែល បានជួយមើលថែប្អូនប្រុសរបស់បងយ៉ាងល្អ ។
- ចាំស មិនអីទេ! មិនជាភារៈធ្ងន់ស្រាលអីទេ បងស្រី!
- មើលទៅនាងក៏ដូចជាទើបតែជាពីឈឺដែរ
- ចាំស! ខ្ញុំជាស្រួលបួលវិញហើយ មិនអីទេ ។
- ហើយចុះពេលនាងឈឺដូច្នេះ មិនខាតសាលាអស់ហើយទេហ៎?
- គឺ... ខ្ញុំឈប់រៀនពីរឆ្នាំហើយ មិនបានប្រលងឌីប្លូមអ្វីនឹងគេទេ ត្បិតម៉ែ ឈឺធ្ងន់ អត់មាននរណាមើលថែគាត់...
- អូហ៎ព្រះអើយ.. ហើយចុះម្ដាយរបស់ប្អូនយ៉ាងណាហើយ?

សំនៀងឈ្ងោកមុខនៅស្ងៀមលែងឆ្លើយ ទុកអោយទឹកភ្នែកឆ្លើយតប ជំនួសវិញ ។ វរលក្ខណ៍ឃើញដូច្នោះក៏លួងលោម :

- អឺៗ កាត់ចិត្តទៅណា៎អូន!... កុំគិតច្រើនអី នាំតែមិនស្រួលខ្លួន!! ម៉ោះ! យើងចេញទៅជជែកគ្នានៅខាងក្រៅវិញ ក្រែងលោបានធូរស្បើយក្នុងដួង ចិត្តខ្លះៗ ។

ថាហើយ វរលក្ខណ៍ក៏ស្រវាកាន់ដៃសំនៀងដើរចេញពីបន្ទប់ទៅ ។

៩៩៩៩៩៩៩៩៩៩៩៩៩៩

៩៩៩៩៩

៩

CHANBOKEO.COM

# វគ្គទី៥

# អនុស្សាវរីយ៍ចុងក្រោយ

លោកវរៈបានទទួច សូមអោយសុគុណត្រលប់ទៅរក្សាជំងឺនិង ចំណាយពេលវេលាចុងក្រោយរបស់នាយជុំជាមួយគ្រួសារនៅឯភ្នំពេញ តែ សុគុណបែរជាប្រកែកយ៉ាងដាច់អហង្ការថាមិនទៅជាដាច់ខាតម្យ៉ាងដោយ នាយយើងមិនចង់ជួបមុខដារ៉ានីផង ម្យ៉ាងគេកំពុងតែជំពាក់ចិត្តលើធិតាថ្មី ម្នាក់នៅភូមិវត្តគរនេះផង។ មួយវិញទៀត ខ្យល់អាកាសក្នុងចំការមាត់ស្ទឹងសង្កែបានផ្តល់នូវបរិយាកាសយ៉ាងមនោរម្យក្រៃលែង សំរាប់បុរស យើងដែលកំពុងតែអស់ពេលវេលាបន្តិចម្តងៗ...។

វីសំនៀងយើងវិញ កាលបើបានដឹងរឿងរបស់សុគុណពេលណាមក នាងក៏លែងមានអារម្មណ៍នឹងនដែរ។ មួយថ្ងៃៗ នាងបំរើផ្គាប់ផ្គុនបុរស យើងមិនអោយគ្នើសចិត្តឡើយ គឺឆវីខឹតខំធ្វើអ្វីៗសព្វយ៉ាងដើម្បីនាយ មិនថាជាអ្វីទេ... អោយតែនាងអាចធ្វើបាន មាណវីរត់ធ្វើតាមទាំងអស់ ថ្នមចិត្តសុគុណមិនអោយខ្ទក់ចិត្តសូម្បីបន្តិច។ នាងនឹកអាណិតរូបគេណាស់ ដែលនាយមានពេលវេលាកាន់តែខើចទៅៗជាលំដាប់...

នៅរសៀលថ្ងៃមួយ....

ពិសិដ្ឋក៏ធ្វើដំណើរមកលេងមិត្តនៅបាត់ដំបង កាលបើបានដំណឹងថា មិត្តរបស់ខ្លួនកាន់តែមិនស្រួលខ្លួនខ្លាំងហើយ។ លុះពេលនាយមកដល់ផ្ទះ នៅចំការ ក៏ប្រទះនឹងសុគុណកំពុងគេងលក់ដោយអាការៈល្ហិតល្ហៃ។ គេក៏ដើរចេញមកជជែកគ្នាលេងជាមួយលោកវរៈ និងកូនស្រីរបស់លោកវិញ។ បន្តិចមកគេឆ្មៀងទៅជួបសំនៀង ដែលឈរអើតអើមនៅក្រោយផ្ទះ បក់ ដៃ មកនាយជាសញ្ញាហាក់ដូចជាចង់និយាយអ្វីមួយជាមួយនាយយើង។ ពិសិដ្ឋក៏ដើរចេញមកជួបនាង និយាយគ្នាមួយស្របក់ ក៏បញ្ឆោះឡាននាំ សំនៀងចេញទៅក្រៅ តែមិនឮគេនិយាយប្រាប់នរណាក្នុងផ្ទះថាគេនាំនាង ទៅណា ឡើយ សូម្បីតែតាក្រូចយាយប្រាង។

ប្រហែលមួយម៉ោងក្រោយមក សុគុណក៏ភ្ញារភ្ញាក់ពីដំណេកដើរចេញ ពីបន្ទប់មក ឈរនៅរានហាលមុខផ្ទះ ស្រាប់តែប្រទះឃើញពិសិដ្ឋបរឡាន នាំសំនៀងមកដល់ផ្ទះវិញ ហើយឃើញកិរិយារបស់សំនៀងហាក់ដូចជារីករាយញញឹមញញែមខុសប្រក្រតីទៀតផង។ រីឯពិសិដ្ឋវិញ ក៏ញញឹមដាក់ សំនៀងយ៉ាងរីករាយយ៉ាងត្រកាលដែរ

CHANBOKEO.COM

មើលទៅទាំងគួហាក់ដូចជាកំពុង មានសុភមង្គលក្នុងចិត្តណាស់ ធ្វើអោយសុគុណនឹកខ្ទក់ ល្អក់ក្នុងអារម្មណ៍ ភ្លាមមួយរំពេច។ គេលាន់មាត់ខ្សិបៗតែម្នាក់ឯងថា :

- ពុទ្ធោអើយ! គ្រាន់តែឃើញសុគុណមានជំងឺរាំរ៉ៃពេលណា នាងបែរជាខំស្កាត់ទាក់ទងណាត់គ្នាសាងស្ពានទុកអោយហើយ... នេះឬចិត្តនារី? មួយ ណាក៏ដូចមួយណាដែរ គឺដូចគ្នាទាំងអស់ហ្នឹង មិនថាដារិទីឬក៏សំនៀងទេ.. គេសំលឹងមើលយើងតែពេល ណាដែលគេអាចបូតផលប្រយោជន៍ពីយើង បានតែប៉ុណ្ណោះ.. លុះគេដឹងថាយើងជាមនុស្សអស់សង្ឃឹម គេក៏នាំគ្នាបែរ មុខចេញ ហើយស្រវេស្រវារកកន្លែងតោងថ្មីទៀត...

ល្ងាចនោះ សុគុណមិនបរិភោគបាយទេ ហើយក៏មិនទទួលថ្នាំអ្វីទាំងអស់ក្រៅពីគេងសំងំដោយអាការៈល្ងិតល្ងៃនិងអស់សង្ឃឹម។ គេមិនព្រម និយាយរកនរណាទាំងអស់ សូម្បីតែលោកវរៈជាឪពុក ឬក៏វរលក្ខណ៍ជា បងស្រីដែរ។ អាកប្បកិរិយាដ៏ចំលែករបស់គេ ធ្វើអោយគ្រប់គ្នាចាប់ភ្លឹក ថាខុសប្រក្រតីដែរ។ មិនអស់ចិត្តសោះ វរលក្ខណ៍ក៏ចុះជណ្តើរទៅតាមរក សំនៀង ដែលកំពុងលាងសំអាតចានក្បានងផ្ទះបាយ :

- សំនៀង! អោយបងសុំពឹងអ្វីបន្តិចពីប្អូនបានទេ?
- ចាស! មានការអ្វីសំខាន់ឬបង?
- គឺរឿងសុគុណណា៎!

បន្ទាប់មក គេក៏សំណេះសំណាលគ្នាមួយស្របក់ រហូតដល់សំនៀងទុក ដាក់ចានក្បានអស់ ទើបនាងលាងដៃលាងជើងទៅរកមើលសុគុណនៅឯ បន្ទប់របស់នាយ។ ស្រាប់តែ អ្នកទាំងពីរមិនបានប្រទះឃើញរូបនាយនៅក្នុងបន្ទប់ទេ។ គេក៏នាំគ្នាភ័យឆោឡោហៅគ្នាដើររកពេញចំការ។ សំនៀង ភ័យណាស់មិនដឹងថាទៅរកនាយនៅឯណាទេ។ នាងរត់ត្រេចុះត្រេឡើង ក៏បានមកដល់មាត់ស្ទឹងសង្កែ ស្រាប់តែប្រទះឃើញនាយយើងអង្គុយច្រងុក លើកាំជណ្តើរស្ពានតែម្នាក់ឯង។ នាងក៏ឧទានហៅ :

- បងសុគុណ...!

សុគុណឮហើយក៏បែរក្រោយ។ កាលបើក្រលេកមកឃើញសំនៀង ភ្លាម នាយយើងក៏បែរមុខចេញទៅវិញ :

- មកតាមបងមានការអីដែរសំនៀង?
- គឺចាស់ៗគាត់បារម្ភពីបងណាស់ កាលបើបងដើរចេញមក ដោយមិនមាន ប្រាប់នរណាដូច្នេះ...
- មនុស្សដូចបងនេះ តើមានតម្លៃអ្វីអោយនរណាគេបារម្ភខ្វះទៅ?
- ម៉េចក៏បងមានប្រសាសន៍ដូច្នោះ? គ្រប់គ្នាស្រលាញ់បងហើយបារម្ភពី បងណាស់ ហេតុអ្វីក៏បងបែរជា...
- ហើយចុះសំនៀងមានបារម្ភពីបងខ្លះដែរទេហ៎?
- បើសំនៀងមិនបារម្ភពីបងទេ តើសំនៀងចេញតាមរកបងពេកនេះធ្វើអ្វី?

សុគុណឈ្ងោកមុខសំលឹងដីមួយស្របក់ក៏សួរថែមទៀតថា :

- សំនៀងចាំបាច់អីត្រូវបារម្ភពីបងដែរ បើយើងជាមនុស្សដែលគ្មានចំណង នឹងគ្នាផងនោះ?

CHANBOKEO.COM

- ម៉េចក៏បងថាគ្មាន?

ស្រាប់តែសុគុណបែរសំលឹងមុខនាងយ៉ាងរហ័ស :

- អញ្ចឹងអូនប្រាប់បងមក៏ ថាអូនបារម្ភខ្វាយខ្វល់ពីបងក្នុងឋានៈខ្លួនជាអ្វី ដែរទៅ?

- បងសុគុណ... គឺជាបងប្រុសដ៏ល្អបំផុតរបស់សំនៀង ហើយនៅក្នុងលោក

នេះ ក៏គ្មាននរណាម្នាក់ដែលល្អចំពោះសំនៀងស្មើនឹងរូបបងដែរ ។

- គឺបងទទួលឋានៈត្រឹមតែជាបងប្រុសដ៏ល្អរបស់សំនៀងទេហ៏?...

- ចាំស មែនហើយ!

- ប៉ុន្តែ.. បងមិនដែលគិតចំពោះសំនៀងមួយនាទីណាទេ ថាអូនជាប្អូនស្រី របស់បង!! គឺបងមិនដែលគិតសូម្បីបន្តិច...!!

ព្ញសំដីសុគុណគំហកធ្ងន់ៗដូច្នោះ សំនៀងនឹកតួចចិត្តភ្លាមមួយរំពេច ។ នាងក៏តបទៅវិញទាំងខ្ទក់ខ្ទាញ់ ក្នុងចិត្តថា:

- មែនហើយ... ព្រោះអូនជាអ្នកក្រៅ... ជាអ្នកក្រ... ជាមនុស្សខ្វាត់ព្រាត់ ជាមនុស្សមានប្រវត្តិមិនស្អាត ទើបបងទទួលអូនមិនបាន

មែនទេ? ស្តាយ ណាស់ដែលសំនៀងគិតខុស ចំពោះបងពីមុនៗមក...!!

ថាហើយសំនៀងក៏យកដៃខ្ទប់ទឹកភ្នែកដែលកំពុងតែស្រក់មកលើរង្វង់ ភក្ត្ររបស់នាង

ហើយបែរខ្នងដើរចេញទៅវិញយ៉ាងរហ័ស ស្រាប់តែ សុគុណ ងើបឈរឡើងហើយស្រែកពីក្រោយមកយ៉ាងខ្លាំងៗថា :

- មែនហើយ! មកពីអូនជាអ្នកក្រៅ ទើបបងមិនអាចទទួលអូនជាប្អូនស្រី របស់បងបាន ប៉ុន្តែតាមការពិតវិញនោះ... គឺបង...

បងអាចទទួលអូនបាន ត្រឹមតែជាគូជីវិតរបស់បងតែម្យ៉ាងប៉ុណ្ណោះ គ្មានអ្វីក្រៅពីហ្នឹងទៀតទេ..!!

ព្ញប្រយោគនេះភ្លាម ធិតាទុចង៉ក់ ហើយងាកបែរក្រោយយ៉ាងរហ័ស :

- បង... មានប្រសាសន៍ថាម៉េចហ្នឹង?

- អូនស្តាប់មិនច្រលំទេ សំនៀង! គឺបងមានន័យថា បងស្រលាញ់សំនៀង

ស្រលាញ់អូនជាគូជីវិតរបស់បងណាំអូន...

សុគុណវាចាដោយសំលេងញ័រៗទំនងជារន្ធត់ក្នុងចិត្តណាស់ ។ គេក៏ លើកដៃទាំងទ្វេរបស់គេឡើង ហើយស្រដីបន្ថែមទៀតថា :

- រង្វង់ដៃរបស់បងនេះ តែងតែទន្ទឹងរង់ចាំ ទទួលរូបអូនឱ្យមករស់នៅ នៃបនិត្យ ក្បែរបេះដូងរបស់បងជានិច្ចរហូតតទៅដែរ...

ស្រាប់តែនាយដាក់ដៃចុះវិញហើយឈ្ងោកមុខបែរចេញ រួចហើយក៏ ដូរប្រយោគជាថ្មីយ៉ាងសោកសៅថា :

- ប៉ុន្តែ មនុស្សដែលអស់ពេលវេលាដូចរូបបង ប្រហែលជាគ្មានសំណាង នឹងបានស្គាល់នូវសុភមង្គលដ៏កក់ក្តៅបែបនោះឡើយ ។

តើនរណាមួយ ដែលហ៊ានប្រថុយនឹងយកជីវិតរបស់គេ មកលិចលង់ជាមួយនឹងបុរសដែល

មានជីវិតត្រឹមតែប៉ុន្មានខែទៀតដូចជារូបបងនេះទៅ?

សុគុណពោលឡើងដោយសំលេងញ័រៗ ហាក់ដូចជាគេកំពុងតែរន្ធត់ ចិត្តអាណិតខ្លួនរបស់គេណាស់ ។

ទឹកភ្នែកពីរតំណក់ក៏ហូរចេញមកប្រលែង កែវភ្នែករបស់បុរសយើងភ្លាមមួយរំពេច ។

CHANBOKEO.COM

ស្តាយ

ស្តាយណាស់ដែលបងមានពេលខ្លី　　　មិនអាចថ្នមស្រីម្ចាស់ស្នេហា
ជាគូជីវិតរស់យូរយារ　　　សុខដុមរមនាតរៀងទៅ ។
ស្តាយដែលបុណ្យបងមានសែនតិច　　　មិនអាចប្រកែកច្បាំងស៊ូនៅ
ដើម្បីថ្នមស្នេហ៍ស្រស់ពាលពៅ　　　អោយភ្លឺគង់នៅអង្វែងបាន ។
ស្តាយដៃអភ័ព្វផុតបំណង　　　នឹងបីត្រកងថ្នមកល្យាណ
បានត្រឹមតែព្រួយញ័រអង្គប្រាណ　　　លួចស្នេហ៍ភ្ញុំផាន់តែម្នាក់ឯង ។
ស្តាយណាស់ស្តាយស្នេហ៍ដ៏ឧត្តម　　　បងផ្ញើជូនមុំយ៉ាងធំធេង
ពេលនេះរូបបងសែនចំបែង　　　កណ្តោចកណ្តែងក្នុងភពកម្ម....

កាលបើឃើញកិរិយារបស់សុគុណដូច្នេះ ធិតាញាប់ញ័រក្នុងចិត្តយ៉ាង ណាមិនដឹងទេ ។ នាងទ្រាំឈរមើលនឹងភ្នែកទៀតលែងបានទៀតហើយ ។ ទីបំផុត ធិតាក៏បែរខ្លួនដើរតម្រង់ទៅដល់ជិតមាណព ហើយលើកដៃផ្តិតទឹកភ្នែករបស់នាយ មិនអោយស្រក់មកលើផ្ទៃមុខ រួចក៏ស្រដីថា :

- នរណាគេសុខចិត្តអោយបងស្រក់ទឹកភ្នែករបៀបនេះ? បើបេះដូងរបស់ បងស្រោបដោយទុក្ខ ជីវិតរបស់សំនៀងក៏មិនអាចរីកស្រស់បំព្រងទៅរួច ដែរ ។ បងដឹងទេថា ភាពញញឹមនៅលើផ្ទៃមុខរបស់បងជាសន្សើមដែលប្រស់ជីវិតរបស់សំនៀងអោយមានភាពត្រកាលជានិច្ច..! ញញឹមឡើងវិញ បានទេហ៍បង? ហើយសំនៀងសន្យាថានឹងនៅក្បែរបងរហូតតទៅ... !

មាណពយើងឮដូច្នោះក៏ញញឹមឡើងភ្លាម :

- ពិតមែនឬសំនៀង?　អូនពិតជានៅក្បែរបងរហូតដល់វេលាចុងក្រោយ របស់បង មែនទេអូន?

- ចាស! មែនហើយ! អូនសន្យា...! ថ្វីបើពេលវេលារបស់បងមានតិចក៏ ពិតមែន តែក៏ជាពេលវេលាដ៏មានតម្លៃបំផុតសំរាប់ជីវិតរបស់អូនដែរ...

សុគុណឮដូច្នោះ ក៏ស្រវាក្រសោបកាយរបស់ធិតាយើងយ៉ាងណែនផ្អិប នឹងដើមទ្រូងរបស់នាយ ព្រមទាំងវាចាទាំងរំភើបក្នុងចិត្តថា :

- អរគុណណាស់...សំនៀងបណ្តូលចិត្តបង! អូនគឺជាអ្វីៗទាំងអស់របស់បង ក្នុងជាតិនេះ ។

មាណពឧទានឡើង ទាំងដួងចិត្តរំជើបរំជួលញាប់ញ័រក្រៃលែង ត្បិត គេមិនបាននឹកស្មានជាមុនថា ធិតានឹងផ្តល់ចំលើយវិជ្ជមានមកនាយឡើយ ។ នាយត្រេកអររំជើបរំជួលរហូតដល់ទៅរលីងរលោងទឹកភ្នែក ។ គេនៅឈរអោបក្រសោបធិតាយើងយ៉ាងយូរហាក់បីដូចចង់អោយនាងបានស្តាប់ឮនូវ វាចាបេះដូងរបស់នាយ

CHANBOKEO.COM

ដែលកំពុងរណ្តំសារភាពប្រាប់នូវអារម្មណ៍ប្រតិពទ្ធ័ របស់នាយចំពោះធិតា ថាតើសេចក្តីស្នេហារបស់នាយចំពោះរូបនាង មានកំរិតអត្ថន័យធំធេងយ៉ាងណា។

ទំហំស្នេហ៍

ស្នេហ៍យើងធំធេងជាងផ្ទៃមេឃ ពន្លឺភ្លឺផ្លេកជាងសុរិយ៍
ស្នេហ៍យើងសែនធ្ងន់លើសផែនដី សែនជ្រាលជ្រៅក្រៃលើសមុទ្ទ។
ស្នេហ៍សែនត្រជាក់ហាក់អម្រឹត ស្នេហ៍មានជីវិតយូរប្រាកដ
ទោះបីសង្ខារកាយរលត់ ស្នេហ៍បរិសុទ្ធស្ពេរក្បេមក្សាន្ត។
ស្នេហ៍យើងពីរប្រាណសុខសាន្តក្រៃ គ្មានឧបសគ្គអ្វីបំបែកបាន
ស្នេហ៍ចិត្តនិងចិត្តយ៉ាងកល្យាណ រលាយរូបប្រាណក៏នៅស្នេហ៍។
ស្នេហ៍អើយស្នេហ៍ធំលើសអ្វីៗ ស៊ូប្តូរសង្ខ័យមិនបែកបែរ
ស្មគ្រ័ស្មោះភក្តីចំពោះស្នេហ៍ សច្ចាថ្នមថែស្នេហ៍តែមួយរៀងទៅ...

ពេលវេលាក៏ឈានទៅមុខយ៉ាងយឺតៗ ក្រោមជំនោររំភើយៗនាមាត់ ស្ទឹងសង្កែ គូស្នេហ៍ទាំងទ្វេហាក់ដូចជាមិនបានចាប់ភ្លឹកទេថាគេនៅឈរទី នោះ សំដែងការសាសងតាមស្នូរចង្វាក់បេះដូង អស់រយៈយូរប៉ុណ្ណាឡើយ រហូតទាល់តែគេឮសំលេងពិសិដ្ឋក្ងុកហៅទើបភ្ញាក់ស្មារតី រួចហើយក៏ស្រវា កាន់ដៃគ្នាត្រលប់ឡើងច្រាំងសំដៅទៅលំនៅវិញ ទាំងដួងចិត្តរំភើបរីករាយ ឥតព្រំដែន។

នៅក្នុងបន្ទប់គេង...

សំនៀងរៀបចំចងមុងរៀបខ្នើយរៀបគ្រែ បំរុងចូលគេងទៅហើយ ស្រាប់តែឮស្នូរគោះទ្វារ។
នាងក៏ស្ទុះទៅបើកទ្វារបន្ទប់ឡើងស្រាប់តែប្រទះ
ឃើញសុគុណនៅឈរញញឹមទីនោះ :
- បងសុគុណ? មានការអ្វីទាំងយប់ហ្នឹង?
- គឺ... អោយបងសុំគេងទីនេះជាមួយអូនផងបានទេ?
- ថាម៉េច? បងកុំមកលលេងដូច្នេះអី មិនល្អស្តាប់ទេបង...
- បងមិនបានលលេងទេ... គឺបងនិយាយពាក្យពិត!
- មិនបានទេ... បងសុគុណ! បើចាស់ៗដឹង... ខ្ញុំច្បាស់ជាមានរឿងធំហើយ បងឆាប់ចេញទៅ ចាំស្អែកយើងនិយាយគ្នាទៀតណា៎!

ថាហើយ នាងក៏យកដៃច្រានទ្រូងសុគុណអោយថយចេញពីបន្ទប់រួច ហើយក៏ទាញទ្វារផ្ទិបយ៉ាងរហ័ស ក្នុងចិត្តភ័យអរតក់ស្លុតយ៉ាងណាមិនដឹង ទេចំពោះឥរិយាបថយ៉ាងចំលែករបស់សុគុណថ្ងៃនេះ។ នាងអង្គុយគិតមួយ ស្របក់ក៏នឹកភ្ញាកចង់ដឹងថាតើសុគុណគេទៅវិញបាត់ហើយឬនៅ។ នាងស្ទុះ ងើបឡើងបើកទ្វាររកមើលស្រាប់តែឃើញនាយនៅឈរច្រងុកនៅកន្លែង ដដែលធ្វើមុខស្ងួត។ មាណវីឃើញដូច្នោះ ក៏ស្ទុះបិទទ្វារយ៉ាងរហ័សហើយនឹកគិតរំជើបរំជួលក្នុងចិត្តបែកញើសជោគខ្លួនតែម្នាក់ឯង :

CHANBOKEO.COM

- សំនៀងអើយ! តើនាងត្រូវគិតយ៉ាងណាពេលនេះ? ត្រូវបដិសេធដើម្បី ភាពត្រឹមត្រូវក្នុងរង្វង់សីលធម៌ប្រពៃណី ឬក៏ត្រូវធ្វើតាមគេដើម្បីសេចក្តី ស្នេហាដ៏ស្មោះស្ម័គ្រមួយ?...

គិតទៅគិតមក សំនៀងនៅតែគិតមិនចេញដដែល ។ នាងគេងប្រែ ប្រួលចុះឡើងៗយ៉ាងយូរ ត្បិតមិនដឹងថានឹងត្រូវធ្វើយ៉ាងណាអោយសម សោះឡើយ ណាមួយនាងគ្រាន់តែជាបញ្ចើក្អែកធ្វើម៉េចនឹងហ៊ានលូកថ្លើម ម្ចាស់ផ្ទះទៅ? ណាមួយខ្លាចសុគុណអាក់អន់ចិត្តចំពោះនាងដែលមិនព្រម ធ្វើតាមពាក្យសន្យារបស់នាងចំពោះរូបគេ ណាមួយសុគុណកំពុងមានជំងឺទៀត ប្រហែលជាគំនិតស្មារតីរបស់នាយមិនប្រក្រតី ដោយសារថ្នាំសង្កិន អារម្មណ៍ក៏មិនដឹង ។ សំនៀងគិតអ្វីមិនចេញសោះ ក្រៅពីនៅគេងប្រែខ្លួន ត្រេះត្រុះម្នាក់ឯងយ៉ាងយូរ...

មិនដឹងជាអស់ពេលយូរប៉ុនណាទៀតទេ ស្រាប់តែនាងឮសំលេងគោះ ទ្វារជាថ្មី ។ ធិតាងើបឡើង ទៅឈរជិតមាត់ទ្វារ តែមិនហ៊ានបើកគន្លឹះទេ ត្បិតពុំដឹងថាសុគុណគេមានគំនិតយ៉ាងណាទៀត ។ រំពេចនោះ ធិតាបែរជា ឮសំលេងហៅនាងឡើងថា :

- អូនសំនៀង! គេងហើយនៅ? នេះបងវរលក្ខណ៍ណា៎... ឆាប់បើកទ្វារ ឡើង! បងមានការពឹងអូនបន្តិច...

កាលបើឮដូច្នោះ នាងក៏បើកទ្វារឡើងឃើញវរលក្ខណ៍ឈរនៅមាត់ ទ្វារតែមិនឃើញវត្តមានរបស់សុគុណទេ ។ នាងក៏សួរទៅវរលក្ខណ៍ថា :

- បងស្រីមានការអ្វីទាំងយប់ហ្នឹង?

- បងមកសុំពឹងប្អូនរឿងមួយ គឺ... អំបាញ់មិញនេះសុគុណគេមានអារម្មណ៍ ហាក់ដូចជាមិនសូវស្រួលខ្លួនទៀតហើយ ហើយគេមមើមមាយហៅរកតែ សំនៀងមិនឈប់ទើបបងមកនេះដើម្បីសុំអោយប្អូនទៅកំដរគេម៉ាភ្លែត តើ បានដែរឬទេ?

សំនៀងមិនស្រដីឆ្លើយថាម៉េចទេ គ្រាន់តែដើរតាមពីក្រោយវរលក្ខណ៍ រហូតដល់បន្ទប់របស់នាយ ។ នៅលើគ្រែ ធិតាឃើញសុគុណគេងធ្មេចភ្នែក ធ្វើមុខក្រៀមក្រំហើយស្លេកស្លាំងចំលែកណាស់ ។ គេយកដៃគងថ្ងាសហាក់ ដូចជាមិនចង់អោយនរណាឃើញចិញ្ចើមចងរបស់នាយនោះឡើយ ។ នៅ ក្បែរនោះ លោកវរៈនៅអង្គុយស្ងៀម សង្កេតមើលអាការៈរបស់កូនហើយ គ្រវីក្បាល ។ លុះក្រលេកឃើញវត្តមានរបស់នារីយើងភ្លាម លោកក៏ឧទាន ឡើងថា :

- អូហ៍ សំនៀង? មកហើយឬកូន? នេះ៎ មកជួយប៉ាមើលសុគុណបន្តិចទៅ ប៉ាឃើញគេក្តៅខ្លួនរសាប់រសល់រវើរវាយនិយាយអ្វីទេ ស្តាប់មិនបានសោះ ឮតែហៅឈ្មោះសំនៀងមិនឈប់...

សំនៀងក៏ដើរចូលទៅជិតសុគុណនៅជាយគ្រែម្ខាងទៀត ហើយស្រដី ហៅមាណពតិច ១ :

- បងសុគុណ..! នេះ សំនៀងណា៎... ! បង!

រំពេចនោះស្រាប់តែសុគុណបើកភ្នែកឡើងហើយឧទានទាំងត្រេកអរ:

- សំនៀង! អូនមកហើយហ្ន៎ស?

ហើយនាយក៏លើកដៃបោះឡើងស្រវាចាប់ដៃសំនៀងយ៉ាងណែន :

CHANBOKEO.COM

- បងត្រេកអរណាស់ដែលអូនមក៏... ! គឺ...យប់នេះ អូនមកគេងកំដរបង មែនទេ?... មែនទេ?

មាណពស្រដីដោយសំលេងខ្សិប១តែក៏ល្មមអោយអ្នកទាំងអស់ឮគ្រប់ គ្នាដែរ ។ សំនៀងមិនហ៊ានឆ្លើយថាយ៉ាងណាទេ នាងងើបមុខឡើងសំលឹង ទៅលោកវរៈ ហើយបន្ទាប់មកក៏សំលឹងទៅវរលក្ខណ៍ទៀតហាក់ដូចជា កំពុងចង់សុំច្បាប់អនុញ្ញាត្តិដូច្នោះដែរ ។ ភ្លាមនោះ លោកវរៈក៏មាន ប្រសាសន៍ឡើងថា :

- មែនហើយ! សំនៀងនៅកំដរមើលថែរក្សាសុគុណបានទេ? ប៉ានិងបង វរលក្ខណ៍អត់ងងុយច្រើនយប់ហើយដែលនៅកំដរគេ គិតថារកសុំសំរាក មួយពេលសិន សង្ឃឹមថាកូនមិនទើសទាល់ក្នុងចិត្តពេកទេ ណា៎សំនៀង...!

សំនៀងនៅអេះអុញមិនហ៊ានឆ្លើយថាយ៉ាងណាទេ ។ បន្តិចមក លោក វរៈក៏កេះហៅកូនស្រីហើយនាំគ្នាចាកចេញពីបន្ទប់សុគុណទៅ ។ នៅលើគ្រែ សុគុណស្រវាកាន់ដៃសំនៀងជាប់យ៉ាងណែន ហាក់បីដូចជាភ័យខ្លាចនាងដូរ ចិត្តលែងនៅកំដរនាយដូច្នោះឯង ។ មើលទៅទឹកមុខគេហាក់ដូចជារីករាយ រំភើបចិត្តណាស់កាលបើគេបានយល់រូបនាងនៅចំពោះមុខ :

- សំនៀង... គេងក្បែរបងមក៏!

- អត់ទេ... សំនៀងនៅអង្គុយទីនេះបានហើយ

- អូនខ្លាចឆ្លងជំងឺពីបងមែនទេហ៎ បានជាមិនហ៊ានគេងក្បែរបង?

- សំនៀងមិនខ្លាចទេ ព្រោះជំងឺរបស់បងមិនមែនជាជំងឺឆ្លងឯណា!

- អញ្ចឹងអូនគេងលើខ្នើយក្បែរបងមក៏.. ដើម្បីអោយបងមានឳកាសបាន ថ្នាក់ថ្នមអូនផង... បានទេអូន?

ថាហើយនាយក៏ទាញខ្នើយខិតទុកកន្លែងអោយធិតាគេងក្បែរខ្លួន :

- មិនដឹងថាបងមានជីវិតរស់នៅប៉ុន្មានថ្ងៃទៀតទេ... ប៉ុន្តែ មុននឹងបងចាក ចេញទៅ បងចង់សាងនូវអនុស្សាវរីយ៍ល្អ១ រវាងយើងទាំងពីរ... មិនដឹងថា អូនអនុញ្ញាត្តអោយបងមានឳកាសបែបនោះដែរឬទេ?

មាណពស្រដីផង យកដៃទៅបបោសថ្ពាល់ធិតា យ៉ាងថ្នម១ផង ។ បន្តិចមក នាយក៏ពោលបន្តទៅទៀតថា :

- អោយបងសូមទោសផង... ដែលសុខភាពបងមិនអនុញ្ញាត្តអោយបង រស់នៅថ្នាក់ថ្នមរូបអូនយូរអង្វែងបាន... សំនៀង... បងស្រលាញ់អូន.. បងចង់មានជីវិតរស់នៅដើម្បីរូបអូន... ថ្វីបើពេលនេះ បងដឹងហើយថា ជីវិតរបស់បងកាន់តែខិតទៅរាល់ថ្ងៃ តែបងមិនបានសោកស្តាយទេ ព្រោះបងបាន ចំណាយពេលចុងក្រោយជាមួយនារីដែលបងស្រលាញ់ ហើយដែលបងដឹង ថានាងក៏ស្រលាញ់បងដូចគ្នាដែរ ។

សំនៀងឮវាចានេះកាលណា ក៏ស្រក់ទឹកភ្នែកច្រោក ហើយស្រវាចាប់ ដៃបុរសយើងយកមកដាក់ផ្ទាប់នឹងថ្ពាល់របស់នាង ព្រមទាំងស្រដីទាំងអួល អាក់ថា :

CHANBOKEO.COM

- មិនថាពេលវេលារបស់បងកាន់តែថយតិចយ៉ាងណាទេ សំនៀងសន្យាថា នឹងនៅក្បែរបងហើយផ្តល់សេចក្តីសុខជូនបងជានិច្ច! បងសុគុណ! អូនក៏ ស្រលាញ់បងដូចគ្នា ។ អ្វីដែលអូនអាចធ្វើបាន អូននឹងបូជាជូនបងទាំងអស់ សូម្បីតែជីវិតរបស់អូន អូនក៏អាចបូជាជូនបងបានដែរ បើសិនជាអាចធ្វើឱ្យ
បងចាកផុតពីសេចក្តីស្លាប់បាន... អូននិយាយពិតមែនណា!!

សុគុណរំភើបចិត្តណាស់ កាលបើបានឮប្រយោគនេះចេញពីមាត់របស់ នារីបណ្តូលចិត្តរបស់គេ ។ សំនៀងក៏ផ្អែកកេសាលើដើមទ្រូងរបស់សុគុណ ហើយស្រដីតទៅទៀតថា :

- បងសំរាន្តទៅ... សំរាន្តដោយដួងចិត្តយ៉ាងស្ងប់សុខបំផុត ។ សំនៀងនឹង
នៅក្បែរបងរហូតវិនាទីចុងក្រោយ...

- សំនៀងកំពូលដួងចិត្តបង...!

បើសិនជាមានថ្ងៃស្អែក

បើសិនបងមានសល់ថ្ងៃស្អែក  រៀមសូមរំលែកជូនស្រស់ស្រី
នូវការថ្នាក់ថ្នមពីហប្ញទ័យ  សមចិត្តបើតីស្រស់ពំងា ។
បើសិនបងមានសល់ថ្ងៃស្អែក  សូមកុំអោយបែកមុំសោភា
សូមយើងបានរស់នៅក្បែរគ្នា  ជាគូទ័យាសុខក្សេមក្សាន្ត ។
បើសិនបងមានសល់ថ្ងៃស្អែក  រៀមបងសូមស្រែកប្រកាសថ្កាន
ថាបងស្នេហ៍អូនលុះអវសាន  គ្មានថ្ងៃប្រែប្រួនពីពៅឡើយ ។
បើសិនបងមានសល់ថ្ងៃស្អែក  បងសូមរំលែកចិត្តបងហើយ
បេះដូងបងកាត់ជូនត្រាណត្រើយ ជាតិនេះជាតិក្រោយស្នេហ៍តែអូន...

សុគុណក៏ស្រវាត្រកងអោបកាយធិតាក្នុងរង្វង់ដៃយ៉ាងណែន ដោយ
ដួងចិត្តរំភើបញាប់ញ័ររណ្តំនឹងរកពាក្យថ្លែងអោយសមមិនបានឡើយ ។ គេ គិតអ្វីមិនឃើញសោះឡើយ ក្រៅតែពីកំលាំងកំសួលនៃសេចក្តីស្នេហារបស់ គេចំពោះនាងយ៉ាងខ្លាំងក្លាតែម្យ៉ាងប៉ុណ្ណោះ ។ ធិតាយើងក៏ដូចគ្នាដែរ មិនបានគិតអ្វីឡើយក្រៅតែពីបណ្តោយអោយគូស្នេហ៍ស្រវាអោបថ្នាក់ថ្នមទៅ តាមកំសួលមន្តស្នេហ៍
ដែលកំពុងដុតរោលចិត្តរបស់គេយ៉ាងមហិមានោះ ឡើយ ។ ទាំងទ្វេកាយាញញឹមដាក់គ្នាយ៉ាងបំព្រង ទទួលយកសុភមង្គល មួយដែលគេគិតថា ជាចំណងអនុស្សាវរីយ៍ដ៏មានតម្លៃបំផុតរវាងរូបគេ ទាំងពីរនាក់ ។ យប់នោះ
សំនៀងបាននៅបំរើថ្នាក់ថ្នមបុរសយើងពេញមួយ រាត្រីតាមដែលបុរសយើងត្រូវការ...

មាន់រងាវខ្ញៀវៗ... ថ្ងៃរះឡើងហើយឯបូព៌ាទិស...

សំនៀងភ្ញាក់ភ្ញាក់ស្មារតីឡើង ក៏ស្ទុះងើបឡើង ស្រាប់តែសុគុណស្រវា ចាប់ដៃនាងជាប់ :

- អូនបំរុងទៅណាហ្នឹង សំនៀង?

CHANBOKEO.COM

- គឺ.. ទៅបន្ទប់អូនវិញនោះអី... នេះភ្លឺហើយណាំបង!

- តែបងមិនចង់អោយអូនទៅទេ... នៅកំដរបងបន្តិចទៀតសិនបានទេ?

- មិនបានទេ... តែចាស់ៗគាត់មកឃើញមិនល្អមើលទេណាំបង!

- ចាស់ៗគាត់ជ្រាបពីរឿងយើងគ្រប់គ្នាហើយអូន... ទៅខ្មាស់គាត់ធ្វើអី?

តែសំនៀងមិនស្តាប់ទេ ។ នាងក៏ស្ទុះងើបឡើងហើយខ្សិបដាក់ត្រចៀក

នាយថា :

- គឺអូនទៅដណ្តាំអាហារមកជូនបងពិសារ បន្តិចអូនមកវិញហើយ ។

តែសុគុណនៅតែចាប់ដៃនាងដដែលមិនព្រមលែងសោះ ។ ភ្លាមនោះ

នាយយើងដាក់ភ្នែកទៅឃើញចិញ្ចៀន ដែលសំនៀងពាក់នៅលើម្រាមដៃ

កំពុងចាំងរស្មីផ្លេកៗ ។ គេក៏ងើបសំលឹងមុខសំនៀងហើយសួរនាងថា :

- អូនពាក់ចិញ្ចៀននេះមិនដែលដោះទេ មែនទេ?

សំនៀងគ្រវីក្បាល ។ សុគុណពោលបន្តទៀតថា :

- បើអូនស្រលាញ់ចិញ្ចៀននេះពិតមែន អូនកុំដោះវាអីណាំ បងសូមអោយ អូនពាក់វារហូតទៅ...!

សំនៀងញញឹមហើយអោនខ្សឹបដាក់ត្រចៀកនាយយើងវិញថា :

- មិនដោះទេ លុះណាតែម្ចាស់គេមកទារទៅវិញ! យ៉ាងម៉េច? បងស្តាយ មែនទេ? មិនបាច់ស្តាយទេ!

សំនៀងមិនអោយបងវិញឡើយ ។

ថាហើយនាងក៏ងើបដើរចេញទៅទាំងសើចញញឹម ទុកឱ្យសុគុណ សំលឹងមើលពីក្រោយ

ដោយក្រសែភ្នែកប្រកបដោយសេចក្តីស្នេហាយ៉ាង ធំធេងឥតព្រំដែន ។

ពីរថ្ងៃកន្លងទៅ...

នៅចំហៀងផ្ទះ សំនៀងកំពុងតែពូតខោអាវរលាស់ហាល ស្រាប់តែ នាងឃើញពិសិដ្ឋថយឡានយ៉ាងបន្ទាន់ ។

នាងឃើញដូច្នោះនឹកឆ្ងល់ណាស់ក៏

ស្រែកសួរឡើងថា :

- បងពិសិដ្ឋមានការអ្វីហ្នឹងដូចជាបន្ទីរបន្ទាន់ម្ល៉េះ?

- គឺនាយគុណវាដើរទៅដួលសន្លប់នៅមុខបន្ទប់ទឹក បងវរលក្ខណ៍ថាអោយ នាំគេទៅមន្ទីរពេទ្យឥលូវនេះ ។

ពិសិដ្ឋស្រដីមិនទាន់ចប់ផង ស្រាប់តែវរលក្ខណ៍និងលោកវរៈគ្រាហ៍ សុគុណចេញពីបន្ទប់ចុះតាមជណ្តើរមកដល់ ។

សំនៀងឃើញហើយស្ទុះទៅ

យ៉ាងលឿន ។ លោកវរៈក៏បក់ដៃហៅ :

- អឺ បាននាងមកដល់ល្អហើយកូន! ម៉ោះឡើងឡានមក៏ ទៅជុំគ្នាតែម្តង ទៅ។ មើលទៅសុគុណ គេប្រហែលជាត្រូវការកំលាំងចិត្តពីកូនហើយណា៎ សំនៀង!

សំនៀងក៏ហក់ទៅជួយគ្រាហ៍សុគុណឡើង ជំនួសលោកវរៈហើយក៏ ដាក់នាយទៅក្នុងឡាន បន្តិចមកក៏នាំគ្នាចេញដំណើរទៅមន្ទីរពេទ្យធំឯក្រុង បាត់ដំបង។ ចៃដន្យ អាការរោគរបស់សុគុណហាក់ដូចជាធ្ងន់ធ្ងរបន្តិច ហើយ។ លោកគ្រូពេទ្យបានសំរេចអោយគេត្រលប់ទៅរក្សាជំងឺ ឯមន្ទីរ ពេទ្យជំនាញនៅក្រុងភ្នំពេញវិញ។ ដោយមិនអាចបង្អង់បាន លោកវរៈក៏ សំរេចចិត្តធ្វើដំណើរចេញទៅភ្លាមៗ។ ប៉ុន្តែដោយសារអាការៈរបស់សុគុណ ហាក់ដូចជាយ៉ាប់យ៉ឺនខ្លាំង លោកគ្រូពេទ្យម្នាក់ក៏ត្រូវរួមដំណើរជូនអ្នកជំងឺ ទៅជាមួយដែរដើម្បីជួយរក្សាមើលថែតាមផ្លូវ។ ពេលនោះ លោកវរៈក៏ សំរេចអោយសំនៀងនៅចាំឯបាត់ដំបងសិន ហើយចាំអោយពិសិដ្ឋត្រលប់ មកទទួលនាងតាមក្រោយវិញនៅថ្ងៃស្អែក។ ពេលនោះ លោកនឹងកូនស្រី ក៏កំដរសុគុណធ្វើដំណើរចេញទៅ ដោយមានពិសិដ្ឋជាអ្នកបើកបរ ព្រមជា មួយលោកគ្រូពេទ្យម្នាក់ជាអ្នកតាមថែរក្សាជំងឺរបស់សុគុណ ដែលកំពុង តែមមើមមាយលែងដឹងខុសត្រូវអ្វីទាំងអស់។

សំនៀងឈរសំលឹងតាមមើលស្រមោលរថយន្តដែលបរចេញទៅយ៉ាង លឿនរហូតដល់ដាច់ពីក្រសែភ្នែក។ ទឹកភ្នែកជាច្រើនដំណក់បានហូរចាក នេត្រាធិតាយើងមកប្រលែងនឹងរង្វង់ភក្រ្តដ៏សែនក្រៀមក្រំរបស់នាងហាក់ បីដូចជាកំពុងស្រែកប្រាប់ពិភពលោកថា បេះដូងរបស់នាងបានរសាត់ចាក ឆ្ងាយឱវានាងហើយ.. តើនាងគួរមានសង្ឃឹមដែរទេថានាងនឹងមានឱកាស បានទៅទាន់ដង្ហើមម្ចាស់ដួងចិត្តជាចុងក្រោយ? តើថ្ងៃស្អែកពិសិដ្ឋនឹងវិល មកទទួលនាងឬទេ? ឬក៏វាសនារបស់នាងបានត្រឹមតែឈរសំលឹងពីមាត់ ស្ទឹងសង្កែបែរមុខសំលឹងទៅកើតរង់ចាំដំណឹងពីភ្នំពេញតែម្យ៉ាង? តើពេល នេះ សុគុណគេកំពុងមានអាការៈយ៉ាងណា? តើគេមានអារម្មណ៍យ៉ាងណា កាលបើនាងមិនបាននៅក្បែររូបគេដូចដែលនាងធ្លាប់បានសន្យាចំពោះគេ? សំនៀងដើរឈ្ងោកៗម្នាក់ឯង យំអស់ចិត្តអស់ចង់ទើបធ្វើដំណើរត្រលប់មក ផ្ទះវិញ។

ឱវាព្រាត់បេះដូង

បងចាកចេញទៅស្រីនៅសោកា　　　រន្ធត់ឱវាខ្លោចផ្សាសង្រែង
ព្រាត់គ្នាគ្រានេះចិត្តមុំរង្វេង　　　ស្មារតីចំបែងក្រែងឃ្លាតលែងវិល។
សម្លឹងស្រមោលរថយន្តបរទៅ　　　នាំរូបពាលពៅទាំងក្តីមន្ទិល
សុខទុក្ខយ៉ាងណា ឱ!ប្រុសនិមល　　　សូមមេត្តាផ្តល់ដំណឹងអូនផង។
ទឹកភ្លៀងហូរស្រក់ចាកកែវនេត្រា　　　ដាស់ដួងចិន្តាប្រណម្យបន់ផ្សង
សូមស្នេហ៍ចាកផុតទុក្ខសោកសៅហ្មង　ព្រះអើយជួយផងកូនសត្វរងគ្រោះ។
ផ្គរលាន់ពេញទ្រូងដូចអន្លូងដី　　　ឱវាក្រៀមក្រំនឹកដល់បុរស
ស្នេហាដំបូងម្តេចប្រែអសុរស　　　មេឃអើយស្រណោះស្តាប់អង្វរខ្ញុំផង!

CHANBOKEO.COM

តាក្រួចយាយប្រាងឃើញមាណវីហាក់ដូចជា អោបទុក្ខក្រៀមក្រំខ្លាំង ពេក ក៏ចេះតែនាំគ្នាមកនិយាយលួងលោម អោយនាងបានល្ហែល្ហើយ ។ ប៉ុន្តែមួយថ្ងៃកន្លងផុតទៅ មួយថ្ងៃទៀតចូលមកដល់... បន្តវេនបីដងជាប់ៗ គ្នាហើយ ពិសិដ្ឋមិនដែលវិលត្រលប់មកទទួលនាង ដូចដែលលោកវរៈបាន សន្យានោះឡើយ ។

ចិតាយើងក៏កាន់តែមានអារម្មណ៍ធុញថប់ឡើងៗ ជា

រៀងរាល់ថ្ងៃ ។ ទីបំផុត នាងក៏សំរេចចិត្ត ទទូចសុំអនុញ្ញាត្តិពីយាយប្រាង

និងតាក្រួចទាំងពីរនាក់ :

- តា! យាយ! ចៅសុំអនុញ្ញាត្តទៅតាមបងសុគុណឯភ្នំពេញបានទេ?

- ហើយចុះមីនាងឯងស្គាល់ភ្នំពេញដែរទេ ចៅ? (តាក្រួចសួរ)

- ចាំស!មិនស្គាល់ទេ... តែចៅមានលេខទូរសព្ទ័បងពិសិដ្ឋ គិតថានឹងអាច ទាក់ទងតាមរកគាត់ឃើញ ។

- ដូចជាប្រថុយប្រថានទេដឹងចៅ? (យាយប្រាងនឹកបារម្ភ) យើងជាស្រី ហើយនៅក្មេងទៀត..

ទៅប្រថុយប្រថានជាមួយជីវិតទីក្រុងដ៏អ្វូអែដូច្នោះ យាយដូចជាបារម្ភពីសុវត្ថិភាពរបស់ចៅដល់ហើយនេះ!!

- ហើយចុះឯងមានសោហ៊ុយអីដែរទេចៅ? (តាក្រួចសួរ)

សំឡេងឈ្ងោកមុខហើយគ្រវីក្បាល ។ យាយប្រាងក៏ពោលបន្តថា :

- ហើយបើគ្មានសោហ៊ុយ តើចៅនឹងធ្វើដំណើរទៅយ៉ាងណា?

សំឡេងឈ្ងោកមុខសំលឹងចិញ្ចៀនមួយវង់ ដែលសុគុណបានគ្រវែង ចោលថ្ងៃមុន នឹកគិតថានឹងប្រថុយយកវាទៅលក់ដើម្បីជាសោហ៊ុយទៅចុះ បន្តិចមកនាងក៏ឆ្លើយជំរាបទៅតាយាយថា :

- គឺខ្ញុំមានមធ្យោបាយអាចទៅដល់ភ្នំពេញតាមរកបងសុគុណឃើញ...

ឃើញភាពកន្ទះរាតប់ប្រមល់របស់ចៅស្រីខ្លាំងពេក តាយាយទាំងពីរ

ក៏បណ្តោយអោយនារីយើងចាកចេញទៅ តាមបំណងប្រាថ្នារបស់នាង ។

បន្តិចមក... តាក្រួចក៏យកលេខទូរសព្ទ័របស់ពិសិដ្ឋមកហុចអោយនាង :

- នេះ លេខទូរសព្ទ័របស់ពិសិដ្ឋ ។ សូមចៅទន្ទេញអោយចាំមាត់ទៅណា៎ ។ ពេលនេះ

តាក៏សោកស្តាយដែរដែលភ្លេចសុំលេខទូរសព្ទ័ពីលោកវរៈនិងកូន ស្រីរបស់លោក ។ ប៉ុន្តែ ចូរចៅកុំព្រួយអី ព្រោះពិសិដ្ឋគេជាមិត្តជិតដិតនឹង សុគុណណាស់ បើរកពិសិដ្ឋឃើញ ចៅក៏រកសុគុណឃើញដែរ..

មាណវីក៏លូកដៃទទួលលេខទូរសព្ទ័ពីតាក្រួច ហើយក៏អោនប្រណម្យ សំពះលាតាយាយទាំងពីរធ្វើដំណើរចេញទៅ...

៩៩៩៩៩៩៩៩៩៩៩៩៩៩៩៩

៩៩៩៩៩

៩

# វគ្គទី៦
# ពិរោធ

លោកវរៈបាននាំសុគុណមកដល់មន្ទីរពេទ្យជំនាញ ឯភ្នំពេញដោយ សុវត្ថិភាព។ មាណពក៏បានទទួលការថែទាំរក្សាយ៉ាងហ្មត់ចត់បំផុត ប៉ុន្តែ ទោះជាយ៉ាងណាក្តី សុខភាពរបស់នាយកាន់តែទ្រុឌទ្រោមបន្តិចម្តងៗ។ លុះព្រលឹមស្អែកឡើង លោកវរៈបានពឹងអោយពិសិដ្ឋត្រលប់មកទទួល សំនៀងដូចដែលលោកបានសន្យា ទទួលថៃដន្យ ពិសិដ្ឋត្រូវក្រសួងហៅ ចេញទៅបំពេញភារៈនៅក្រៅក្រុងជាប្រញាប់ ក៏ពន្យារពេលទៅទទួលនារី យើងមួយថ្ងៃ។ នៅថ្ងៃបន្ទាប់មក សុគុណបានដឹងខ្លួនមកវិញ។ គេក៏ទទូច ឱ្យលោកវរៈចាត់មនុស្សអោយទៅតាមសំនៀង។ ដោយក្តីអាណិតចំពោះ កូនប្រុសដែលមានជីវិតកាន់តែថយទៅម៉្ងៃបន្តិចៗ លោកវរៈទ្រាំមិនបានក៏ ដេញវរលក្ខណ៏ កូនស្រីរបស់លោក ឱ្យបើកឡានជាមួយអ្នកបំរើស្រីម្នាក់ ត្រលប់ទៅបាត់ដំបង ដើម្បីនាំយកសំនៀងមកភ្នំពេញតាមដែលកូនប្រុស របស់លោកទាមទារ។ ប៉ុន្តែថៃដន្យសំណាងមិនល្អ រថយន្តរបស់អ្នកទាំងពីរ ក៏ត្រូវឡានទ្រុងកៀវធ្លាក់ស្ពាមភ្លោះរបួសទាំងពីរនាក់ហើយត្រូវដឹកត្រលប់ មកព្យាបាលខ្លួនឯភ្នំពេញវិញដដែល។ ពិតជាគ្រោះជាន់លើគ្រោះមែន! ពេលនោះ លោកវរៈស្ទើរតែវិលវល់វង្វេងស្មារតីអស់ទៅហើយព្រោះកូន របស់លោកទាំងពីររូបស្ថិតនៅក្នុងពេទ្យព្យាបាលទាំងអស់គ្នា។ សំណាងល្អ ដែរដែលវរលក្ខណ៏មិនមានរបួសអ្វីដល់ថ្នាក់ពិការ តែក៏ត្រូវនៅគេងឈឺលើ គ្រែអស់ជាយូរខែថ្ងៃ មុននឹងអាចជាសះស្បើយឡើងវិញបាន។

នៅក្នុងមន្ទីរពេទ្យ...

សុគុណគេងលើគ្រែធ្វើមុខស្អុយប៉ែ ណាមួយសុខភាពរបស់នាយក៏កាន់ តែថមថយទៅ ណាមួយគេមិនបានជួបមុខសំនៀងម្ចាស់ដួងចិត្តរបស់គេ ណាបងស្រីក៏មានរបួសគេងពេទ្យ មានតែលោកវរៈតែម្នាក់ឯងប៉ុណ្ណោះ ដែលរត់ចុះរត់ឡើងរវាងកូនទាំងពីររហូតលែងបានទៅធ្វើការធ្វើងារអ្វីអស់ ហើយ។ នេះជាថ្ងៃទីបួនហើយដែលនាយបានបែកពីសំនៀងមក តែបួនថ្ងៃ នោះវាមានភាពវែងអន្លាយលើសបួនឆ្នាំទៅទៀតសំរាប់រូបនាយដែលគេង ដង្ហោយរកតែសំនៀងបណ្តូលចិត្ត នៅមុនគេលាចាកលោកទៅតែម្យ៉ាង ប៉ុណ្ណោះ។ នៅលើគ្រែ សុគុណគេងធ្មេចភ្នែកស្រដីតែម្នាក់ឯងខ្សិបៗថា :

CHANBOKEO.COM

- សំនៀង..តើអោយបងធ្វើយ៉ាងណាទៅ? ពេលនេះ បងនឹកអូនក្រៃលែង នឹងរកពាក្យមកថ្លែងអោយសមស្មើមិនបានឡើយ... តើ.. បងមានវាសនា ..នឹងបានឃើញមុខអូននៅវេលាចុងក្រោយ... នៃជីវិតរបស់បងដែរឬទេ? សំនៀងអូនអើយ.. បងនឹកអូនណាស់... កំពូលដួងចិត្តរបស់បង!

នឹក

| | |
|---|---|
| នឹកណាស់នឹកណាស់ម្ចាស់ចិន្តា | នឹកថ្លៃស្នេហាគ្មានល្ហែល្ហើយ |
| នឹកពៅទងវង់កែវត្រាណត្រើយ | ពៅអើយពេលណាអូនមកដល់? |
| នឹកព្រឹកនឹកថ្ងៃនឹករាត្រី | បេះដូងមមៃឆោមនិមល |
| នឹកយន់ឱរាវែងខ្វាយខ្វល់ | បន់ព្រះមង្គលសូមជួបអូន។ |
| នឹកអើយសែននឹករលឹកមុំ | ទ្រូងស្មើរស្រែកយំនឹកមាសស្ងួន |
| នឹកគ្មានពេលស្រាន្តទេនឹមនួន | ហឫទ័យស្រពោននឹកតែស្រី។ |
| នឹកឥតរសាយណាយចិន្តា | បន់អស់ទេវតាសូមប្រណី |
| ជួយបំភ្លឺផ្លូវនាំចរណៃ | មកជួបប្រុសថ្លៃដូចបំណន់។ |

វំពេចនោះ ស្រាប់តែសុគុណព្ធសួរសិរិបជើងដើរចូលមកក្នុងបន្ទប់របស់ នាយ តែនាយមិនខ្វល់ទេ ក្រៅតែពីនិយាយរអ៊ូមិនចេះឈប់ហៅរកតែ ឈ្មោះសំនៀងតែម្យ៉ាងមិនដាច់សោះ។ វំពេចនោះ ស្រាប់តែមាណពព្ធ សំលេងខ្សិបដាក់ត្រចៀកនាយថា :

- នែ៎ សំលាញ់! គ្នាមានដំណឹងល្អមកប្រាប់ណា៎ ឯងចង់ដឹងទេហ៎?

ព្ធដូច្នោះ សុគុណបើកភ្នែកយ៉ាងរហ័សហើយស្រដីឡើងខ្សាវៗថា :

- ពិសិដ្ឋ? ឯងនាំសំនៀងមកដល់ហើយមែនទេហ៎?

- អត់ទេ...

- បើអញ្ចឹង... ម៉េចថាជាដំណឹងល្អទៅកើត?

- ឯងស្តាប់សិនទៅមើល៎! គ្នាទើបទទួលដំណឹងថាមាន សប្បុរសជនម្នាក់ គេស្មគ្រ័ជួយផ្តល់គ្រលៀនមួយគ្រាប់ដល់ឯង...តើនេះមិនមែនជាដំណឹងល្អ សំរាប់ឯងទេ?

ស្រាប់តែសុគុណបើកភ្នែកធំៗតែម្តង ហើយលាន់មាត់ខ្សិបៗថា :

- បានន័យថា ខ្ញុំមានសង្ឃឹមថ្មីហើយមែនទេ?

- មែនហើយ...

- ជយោសំលាញ់!

ទាំងពីរនាក់អោបគ្នាដោយក្តីត្រេកអរឥតឧបមា។ បន្តិចមក សុគុណក៏ និយាយទៅកាន់ពិសិដ្ឋថា :

CHANBOKEO.COM

- ចុះសប្បុរសជននេះជានរណា ហើយ...តើខ្ញុំត្រូវធ្វើដំណើរទៅប្រទេស ណាទៅ ទើបអាចទទួលការដាំគ្រលៀនថ្មីនេះបាន?

- ឯងមិនបានទៅណាទាំងអស់ ។ ឯងដឹងទេ នៅមន្ទីរពេទ្យយើងនោះមាន ពេទ្យជំនាញមកពីបរទេសច្រើនណាស់ គេអាចវះកាត់នៅភ្នំពេញយើងនេះ ដោយមិនបាច់ទៅណាឆ្ងាយឡើយ ។

សុគុណញដូច្នោះក៏នឹកត្រេកអររំភើប រហូតទាល់តែរលីងរលោងទឹក ភ្នែកតែម្តង ។ គេក៏នឹកបន់ស្រន់ក្នុងចិត្តថា :

- សំនៀង! មិនយូរមិនឆាប់ បងនឹងបានវិលវិលទៅជួបអូនវិញហើយ ។

ស្អែកឡើង ពិសិដ្ឋចេញទៅកំដរវរលក្ខណ៍ ទុកអោយលោកវរៈមកចាំ ទទួលរត់មើលការខុសត្រូវការវះកាត់របស់សុគុណយើង ។ លោកអង្គុយ សំកុកនៅចាំខាងក្រៅបន្ទប់វះកាត់លើកដៃប្រណម្យបន់ស្រន់ក្នុងចិត្ត :

- សូមអោយកូនប៉ាបានសុខសប្បាយណាំកូនណាំ! សូមអោយការវះកាត់ បានប្រកបដោយជោគជ័យបំផុត ។

ពេលវេលាធ្វើដំណើរទៅយ៉ាងយឺតបំផុតសំរាប់លោកវរៈ ដែលអង្គុយ រង់ចាំស្តាប់ដំណឹងពីសុខទុក្ខរបស់កូនប្រុសរបស់លោក ។

៨ម៉ោងបានកន្លងផុតទៅ...

លោកវេជ្ជបណ្ឌិតជាតិអាឡឺម៉ង់មួយរូបដើរចេញមក ដោយមានអ្នក បកប្រែមកតាមផង ។ លោកក៏មានប្រសាសន៍ជំរាបទៅឪពុករបស់សុគុណ ដោយវាចាយ៉ាងសុភាពថា :

- អ្នកជំងឺមានសុខភាពទន់ខ្សោយបន្តិច បានជាការវះកាត់នេះមានកំឡុង យូរជាងធម្មតា ប៉ុន្តែសំណាងល្អណាស់ដែលអ្នកបរិច្ចាគនោះមានសុខភាព បរិបូណ៌ ហើយមានឈាមក្រុមដូចគ្នានឹងកូនប្រុសរបស់លោកដែរ ទើប ការវះកាត់ដាំក្រលៀនថ្មីនេះឈានដល់កំរិតជោគជ័យយ៉ាងប្រសើរជាងការ គិតទុកជាមុន គ្រាន់តែកូនប្រុសរបស់លោកត្រូវការការរក្សាជំងឺជិតដល់ បំផុតពីពេទ្យរបស់យើង ។ បើមិនដូច្នោះទេ ខ្លាចប្រពន្ធ័អ្វីៗក្នុងខ្លួនគេមាន ប្រតិកម្មប្រឆាំងនឹងរបស់ដាំថ្មីនោះ នឹងនាំអោយពិបាកមិនខាន ។ ទោះជា យ៉ាងណាក្តី ខ្ញុំគិតថាការវះកាត់នេះបានសំរេច៩០ភាគរយហើយ នៅសល់ កំរិត១០ភាគរយទៀតគឺការថែទាំរង់ចាំមើល ថាតើខ្លួនអ្នកជំងឺអាចទទួល របស់ដាំនេះដោយជោគជ័យឬយ៉ាងណា ។ បើសិនអ្វីៗធ្វើដំណើរតាមសំរួល ហើយហើយបើអ្នកជំងឺមិនមានប្រតិកម្មអ្វីទេ បានន័យថាកិច្ចការសំរេចដូច បំណងគ្រប់ប្រការ ។

លោកវរៈស្តាប់ពាក្យពន្យល់របស់លោកគ្រូពេទ្យយ៉ាងក្បោះក្បាយធ្វើ អោយលោកស្រលះអារម្មណ៍ ហើយមានក្តីសង្ឃឹមកាន់តែមុតមាំជាងមុន ។ ជាយូរមកហើយដែលលោកភ្លេចញញឹម ទើបតែវេលានេះ ភាពញញឹមបាន វិលមករកផ្ទៃមុខរបស់លោកសាជាថ្មីម្តងទៀតយ៉ាងបំព្រង ។

មួយអាទិត្យកន្លងទៅ...

CHANBOKEO.COM

សុគុណបើកភ្នែកដឹងខ្លួនមកវិញហើយ ដឹងថាក្នុងខ្លួនរសេះរសោះអស់ កំលាំងណាស់ រកថាមិនត្រូវសោះថាតើនាយគួរសង្ឃឹមឬមិនគួរសង្ឃឹមលើ ការវះកាត់នោះដែរឬទេ ត្បិតអី នាយមិនឃើញខ្លួននាយប្លែកអ្វីសោះក្រៅ តែពីការអស់កំលាំង និយាយរកនរណាក៏មិនកើត ។ ក្នុងជំរៅចិត្តរបស់គេ គេនឹកតែសំនៀងម្នាក់ប៉ុណ្ណោះ ។ គេស្តាយដោយនាងមិនបាននៅជិតនឹង ជួយស្តាប់លទ្ធផលនៃការវះកាត់ ស្តាយដោយនាងមិនបាននៅញញឹមលើក ទឹកចិត្តនាយ ក្នុងឱកាសដែលនាយកំពុងឆ្លងកាត់ពីជីវិតអស់សង្ឃឹមមករក ការមានសង្ឃឹមជាថ្មី ស្តាយដោយនាយមិនមានមនុស្សមកជួយរំលែកទឹក ចិត្តរំភើបរបស់នាយដែលដឹងថា នាយនៅមានឱកាសរស់នៅម្តងទៀតដូច គេដូចឯងមិនយូរមិនឆាប់ ។ ប៉ុន្តែការនឹករលឹករបស់គេចំពោះសំនៀងវាធំ ធេងហួសប្រមាណ រហូតដល់អ្វីៗក៏ក្លាយជាឥតន័យឥតខ្លឹមសារដដែល ។
គេបានទទូចសុំអោយពិសិដ្ឋជាទទួលនាងមកនៅកំដរនាយឯភ្នំពេញ ប៉ុន្តែ
ពិសិដ្ឋចេះតែមានការជាប់រវល់រហូតមិនអាចដកឃ្លាបានសោះ ម្ល៉ោះហើយ មាណពយើងត្រូវតែរង់ចាំទាំងត្រដរតទៅទៀត គឺរង់ចាំដល់ថ្ងៃណាមួយ ដែលសុខភាពនាយបានគ្រាន់បើ នឹងអាលហក់ទៅបាត់ដំបងរកម្ចាស់ បេះដូងរបស់គេវិញសាជាថ្មី ។

១០ថ្ងៃក្រោយមកទៀត...

ថ្ងៃនេះ សុគុណមានអារម្មណ៍ថាបានគ្រាន់បើជាងមុនច្រើន អាចងើប អង្គុយបាន ហើយដើរទប់ៗបានតិចៗទៀតផង ។ គេសប្បាយចិត្តអ្វីម្ល៉េះ កាលបើបានដឹងថា សុខភាពគេកំពុងមានដំណើរត្រលប់មកភាពប្រក្រតី វិញដូចបំណង ។ កំពុងតែសំរុតខ្លួន បំរុងថានឹងងើបដើរត្រិបៗ ទៅរកអើត មើលទេសភាពនៅខាងក្រៅបង្អួច ស្រាប់តែសុគុណឮសំលេងគោះទ្វារព្រម ទាំងសូរសំណើចរអ៊ីកមកផង :

- យ៉ាងម៉េចហើយ សុគុណប្អូនរបស់បង? ជាហើយមែនទេ?
- បងវរលក្ខណ៍..!

មែនហើយនោះគឺជាវរលក្ខណ៍បងស្រីរបស់នាយដែលទើបតែនឹងចេញ ពីមន្ទីរពេទ្យព្រឹកនេះ ។ មើលទៅនាងឃើញមាននៅសល់ស្លាកស្នាមថ្មេរ ដេររបួសនៅដៃនៅជើងខ្លះដែរ ដូចជាមិនទាន់ជាសះស្បើយនៅឡើយទេ តែភាពរីករាយរបស់នាង បានលុបបំបាត់ស្នាមរបួសទាំងឡាយនោះអស់ រលីងតែម្តង ។
នាងរត់មកស្រវាអោបប្អូនប្រុសហើយស្រដីបន្តថា :

- តាំងពីបងបានដឹងដំណឹងល្អថាប្អូនរបស់បងផុតគ្រោះថ្នាក់ ស្រាប់តែបង នេះជាឯងៗ មិនបាច់ថ្នាំពេទ្យហើយថែមទាំងបានចេញមកផ្ទះ លឿនជាង ពេទ្យស្មានមុនទៅទៀត ។ សុគុណ! បងសប្បាយចិត្តអ្វីម្ល៉េះ កាលបើបង មកឃើញអូនស្រួលបួលឡើងវិញដូច្នេះ ។

សុគុណវិញក៏ដូចគ្នាដែរ ។ គេគេងអផ្សុកលើគ្រែយូរហើយ ។ ក្រៅពី លោកវរៈនិងពិសិដ្ឋ មាណពមិនដែលបានឃើញមុខនរណាទៀតទេ ។ កាល បើឃើញបងស្រីរីករាយគ្រេកអរកខិបកខុបពន់ពេក នាយក៏ញញឹមឡើង ដោយក្តីរំភើបចិត្ត :

CHANBOKEO.COM

- ខ្ញុំនឹកបងណាស់បងលក្ខណ៍! ហើយចុះរបួសបងសះអស់ហើយហ្អែស៎?

- នៅទេ តែបងបារម្ភពីឯងជាងណាំ! អូហ៎នែ៎ ពិសិដ្ឋគេទូរស័ព្ទមកបងមុន

នេះបន្តិចថាគេមានរង្វាន់មួយនាំអោយឯងភ្ញាក់ផ្អើលអស្ចារ្យ ដែលប្អូនបាន ឆ្លងកាត់គ្រោះរួចផុតមកនេះ ។

- រឿងអ្វីទៅបង ដែលគួរអោយភ្ញាក់ផ្អើលនោះ?

- មិនដឹងទេ.. ទាល់តែប្អូនចាំជួបនឹងពិសិដ្ឋដោយផ្ទាល់ហើយ...

វំពេចនោះស្រាប់តែ :

- សួស្តីបងសុគុណ! ជំរាបសួរបងវរលក្ខណ៍!

សំលេងនារីម្នាក់ស្រួយស្រែស ពោលពីក្រោយខ្នងអ្នកទាំងពីរកាត់ការ សន្ទនាអោយអាក់ខាន ។

សុគុណងាករឹងបែរមើលនារីម្ចាស់សំលេង យ៉ាងរហ័សសឹងបាក់កហើយលាន់មាត់ថា :

- សំនៀង!....

ស្រាប់តែនាយធ្វើមុខភ្ញាក់ស្រលាំងកាំងតែម្តង ត្បិតនារីនោះមិនមែន ជាសំនៀងដែលគេកំពុងទន្ទឹងរង់ចាំនោះឡើយ ។

ការពិតជាក្រមុំដ៏ស្រស់ ស្អាតម្នាក់ ដែលបេះដូងរបស់គេបានភ្លេចស្រមោលនាងទៅយូរណាស់មក ហើយ ។

នារីសោភាយើងដើរមកជិតអ្នកទាំងពីរ ដោយមានកាន់ផ្កាមួយ

បាច់មកយ៉ាងប្រណិតមកជាមួយផង :

- នេះគឺ ជាដារិទីណាំបងសុគុណ! មិនទាន់អីផងធ្វើជាហៅខុសឈ្មោះទៅ ហើយ? ឬ ក៏នៅខឹងអន់ចិត្តនឹងអូនទៀតឬព្រលឹង?

ម៉េចហើយ ជិតជា

ហើយឬនៅបងសំលាញ់?

ថាហើយ នាងក៏ញញឹមយ៉ាងស្រស់ដាក់កំលោះយើង ហើយឈ្ងោក បំរុងនឹងស្រវាអោបរូបនាយយើងសំដែងក្តីត្រេកអរ

ស្រាប់តែសុគុណងាក គេចចេញផុង ធ្វើអោយនាងភ្ញាក់ក្រញាំងឡើង ។ វរលក្ខណ៍ឃើញដូច្នោះ ក៏បែរមុខធ្វើជាមិនឃើញ

ត្បិតនឹកខ្លាចនារីយើងអាមាស ។ ភ្លាមនោះ សុគុណក៏វាចាថា :

- ដារិទីសុខសប្បាយជាទេហ៎?

ឮវាចានាយដូច្នោះ នារីយើងក៏ញញឹមសាជាថ្មី :

- សុខតែមិនសប្បាយទេ ព្រោះដារិទីនឹកបង...

ពេលនោះ សុគុណនឹកក្នុងចិត្តថា "ហេតុអីក៏ដារិទីទើបតែនឹកបងថ្ងៃ នេះទៅវិញ? ចុះពីមុន១មកនោះ

មានដែលនឹកខ្លះទេហ៎?..."

ភ្លាមនោះដារិទីក៏យកដៃទៅទះថ្ពាល់បុរសយើងបន្ថើរ១ :

CHANBOKEO.COM

- កុំធ្វើមុខអញ្ចឹងមើល៏! នៅខឹងនឹងដារិនីទៀតហ្អឹងហ្ន៎ស? នេះអូនមកសុំ ទោសបងណា៎
ដែលអូនមានកិរិយាឆ្គាំឆ្គងគិតមិនល្អស្រដីមិនល្អដាក់បង..! អូនសូមទោសណា៎! ឈប់ខឹងបានទេសំលាញ់ចិត្ត?
យើងជាគ្នាវិញទៅណា៎ បង? បានទេ?

ដារិនីឈ្ងោកមុខទៅជិតសុគុណ សំលឹងមុខនាយយើងយ៉ាងយូរតែគេ
នៅតែឈ្ងោកមុខនៅស្ងៀមមិនមានស្រដីតបអ្វីទេ មិនដឹងថាគេកំពុងគិតពី អ្វីឡើយ ។ លុះឃើញដារិនីម្ចិកម្ចក់ដាក់ប្អូនប្រុសដូច្នោះ
វិរលក្ខណ៏ក៏គេចខ្លួន ចេញមកក្រៅស្រាប់តែប្រទះនឹងពិសិដ្ឋដែលឈរអែបមាត់ទ្វារនៅស្ងៀមៈ
- យី! ពិសិដ្ឋ! មកដល់ពីអង្កាល់ ម៉េចក៏មិនមាត់មិនកយ៉ាងនេះ?
- បាទ! គឺមកពីឃើញសុគុណគេមានភ្ញៀវពិសេសនៅខាងក្នុង ទើបពិសិដ្ឋ មិនហ៊ានចូលទៅរំខាន...

គ្រាន់តែឮសំលេងពិសិដ្ឋ សុគុណក៏បែរមើលភ្លាម ស្រាប់តែនាយប្រទះ ស្រមោលមនុស្សស្រីមួយរូបសក់វែងខ្មៅរលើប
បែរខ្នងយកដៃខ្ទប់មុខរួច ហើយដើរចេញទៅយ៉ាងរហ័សពីមាត់ទ្វារបន្ទប់របស់នាយ មើលទំនងរាង
រៅគឺជាសំនៀងបេះបិតតែម្តង ។ សុគុណ ភ្ញាក់ព្រើតស្រែកហៅឡើង :
- សំនៀង! សំនៀង!... ឈប់សិនអូន! អូនទៅណាហ្នឹង?

បុរសយើងត្រដេវត្រដរប្រឹងស្ទុះចុះពីលើគ្រែ ប្រវេប្រវរត់ទៅតាម :
- សំនៀង! មកវិញសិនអូន... សំនៀង!

ទាំងអស់គ្នានៅទីនោះសំលឹងមើលគ្នាធ្វើស្រលាំងកាំង ។ កាលបើគេ
ដើបតាមនាងមិនទាន់ សុគុណក៏បែរមកពិសិដ្ឋវិញនិយាយទាំងដង្ហក់ថា :
- ពិសិដ្ឋទៅជួយឃាត់សំនៀងអោយយើងផង...
- គឺ... គឺ.. ឯងនៅទីនេះហើយ ចាំយើងទៅតាមអោយឮហើយនៅ?

កាលបើឮចំលើយរបស់ពិសិដ្ឋដូច្នោះ សុគុណក៏យល់ជាក់ច្បាស់ភ្លាមថា នារីមួយរូបនោះជាសំនៀងច្បាស់ណាស់ ។ ភ្លាមនោះ
នាយក៏ហាក់ដូចជា មានអារម្មណ៏ថាធីងធោងមួយរំពេចតែម្តង ។ វិរលក្ខណ៏ឃើញហើយក៏ស្ទុះ
មកជួយគ្រាហ៏ប្អូនត្រលប់ទៅគ្រែវិញ ។ ដារិនីឃើញហេតុការណ៏ដូច្នោះក៏ សួរអ្នកទាំងពីរថា :
- មានរឿងអ្វីហ្នឹងបងលក្ខណ៏? បងសុគុណ?

វិរលក្ខណ៏សំលឹងមុខសុគុណ ទុកអោយនាយឆ្លើយដោយខ្លួនឯង ។ ជួន ពេលនោះ សុគុណមានអារម្មណ៏មិនសូវល្អសោះ ។
គេក៏មិនបានឆ្លើយតប ទៅដារិនីវិញដែរ ក្រៅតែពីជ្រួញចិញ្ចើមបិទភ្នែកធ្វើមុខហាក់ដូចជាអន់ចិត្ត តែប៉ុណ្ណោះ ។
កាលបើឃើញសុគុណលែងមានអារម្មណ៏ល្អដូច្នោះ ដារិនីក៏ លាអ្នកទាំងពីរត្រលប់ទៅវិញបាត់ទៅ ។

ថ្ងៃនោះ សុគុណរង់ចាំអោយពិសិដ្ឋវិលនាំសំនៀងមកវិញសាជាថ្មី ប៉ុន្តែ ចាំបាត់ៗ
នៅតែមិនឃើញអ្នកទាំងពីរវិលមកវិញសោះ ។ គេក៏បង្ខំអោយ បងស្រីទូរសព្ទ័តាមរកពិសិដ្ឋ តែទូរសព្ទ័យ៉ាងណាក៏មិនចូល ។
ដោយសារ ខ្លួនទើបតែចេញពីមន្ទីរពេទ្យដែរ វិរលក្ខណ៏ក៏អស់កំលាំងល្វិតល្វៃដូចគ្នា ។ នាងបានផ្ទុកផ្តាក់ប្អូនប្រុសជា

CHANBOKEO.COM

មួយហ្នឹងគិលានុបដ្ឋាកយិកាប្រចាំការហើយ ក៏ត្រលប់ចេញទៅផ្ទះវិញ ដោយបានសន្យាជាមួយប្អូនថា នឹងទៅតាមនាំសំនៀងមកឱ្យវិញយ៉ាងឆាប់បំផុត ។ គ្រានោះ សុគុណក៏ក្លាយជាមនុស្ស កណ្តោចកណ្តែងដួងចិត្តសាជាថ្មីម្តងទៀត ។

វិលវិញណាំអូន

| | |
|---|---|
| ឃើញមុខគ្នាហើយម្តេចតោះតើយវិញ | ឱ្យបងទោម្នេញគេងគិតមិនយល់ |
| បងនឹកស្រីថ្លៃរាល់ថ្ងៃសែនខ្វល់ | បន់ជួបនិមលឆាប់ៗកុំខាន ។ |
| គ្រាន់តែយល់ភក្រ្តវិរលក្ខណ៍បែរខ្នង | ឱ្យរៀមសៅហ្មងពេញអស់អង្គប្រាណ |
| មានរឿងហេតុអ្វីបានស្រស់កល្យាណ | បែរខ្នងរុញច្រានឱ្យឃ្លាតម្តងទៀត? |
| អូនអើយវិលវិញបងគេងរង់ចាំ | ឱ!ស្រស់ស្រងាំ វិលណាវរនាថ |
| បងរង់ចាំអូនឥតមានរវាត | ចាំជួបម្តងទៀតសូមវិលជាថ្មី ។ |
| ខឹងបងរឿងអ្វីស្រដីណាំអូន | បងនឹងឆ្លើយស្ងួនអោយសមភក្តិ |
| សូមវិលកុំខានបងចាំរូបស្រី | ចាំតែពិសីម្ចាស់ស្នេហ៍តែមួយ ។ |

មួយរាត្រីកន្លងទៅ...

សុគុណរង់ចាំមើលផ្លូវសំនៀងត្រលប់មកវិញ ឡើងផ្សាភ្នែកមួយយប់ ទៅហើយនៅតែមិនឃើញនរណានាំនាងមកសោះ ។ ដោយក្តីអន្ទះសាពេក នាយក៏ត្រដេវត្រដរប្រឹងក្រោកដើរទាំងកំលាំងចិត្តអន្ទះសាស្ទុះទៅលួចយកអាវផាយរបស់គិលានុបដ្ឋាកម្នាក់មកពាក់ ហើយក៏លបដើរចេញទៅតាម ទ្វារចំហៀងនៃមន្ទីរពេទ្យយ៉ាងរហ័ស ។ ជួនពេលនោះនៅព្រហាមផង មិន ទាន់មានអ្នកជំងឺក្រោកនៅឡើយទេ ទើបគ្មាននរណាគេឃើញនាយ ឡើយ ។ បន្តិចមក សុគុណក៏ហៅម៉ូតូឌុបមួយចេញដំណើរសំដៅផ្ទះរបស់ ពិសិដ្ឋភ្លាម ។ មកដល់មាត់ទ្វាររបងគេហដ្ឋានដ៏ស្តុកស្តម្ភមួយ សុគុណចុះពីម៉ូតូហើយប្រាប់អ្នកម្ចាស់ម៉ូតូថា :

- ប្អូននៅចាំបងទីនេះសិនហើយ បន្តិចបងមកវិញ!

- បាទ!

នៅធ្លាមុខផ្ទះ សុគុណប្រទះឃើញក្មេងស្រីបំរើម្នាក់កំពុងបោសសំអាត ក៏បក់ដៃហៅ :

- នាង! ពិសិដ្ឋនៅផ្ទះទេ?

ស្រីបំរើនោះក៏ឆ្លើយវិញថា :

- ចាស នៅ! អញ្ជើញចូល!

រួចហើយ នាងក៏ស្ទុះមកបើកទ្វាររបងអោយនាយភ្លាម ។ រំពេចនោះ សុគុណក៏សួរបន្ថែម :

- ចុះសាច់ញាតិស្រីដែលមកពីបាត់ដំបងនោះ គេនៅទីនេះដែរទេ នាង?

CHANBOKEO.COM

- បងស្រីដែលថាឈ្មោះសំនៀងនោះ មែនទេ? គាត់ក៏នៅផ្ទះដែរ ។

ឮដូច្នោះ សុគុណអរភើត ស្រាប់តែនាយរពឹសមាត់សួរទៀតថា :

- ហើយចុះនាងដឹងទេ ថាសំនៀងគេមកដល់ភ្នំពេញនេះ ប៉ុន្មានថ្ងៃហើយ?

- គាត់មកយូរហើយតើហ៎ ប្រហែលជាងពីរអាទិត្យហើយទេដឹង តែគាត់...

ក្មេងស្រីនោះនិយាយមិនទាន់ចប់ផង ស្រាប់តែសុគុណក្រលេកទៅ មាត់ទ្វារផ្ទះឃើញពិសិដ្ឋដើរទប់ខ្លួនសំនៀងចេញពីក្នុងផ្ទះមកត្រិប១ សំដៅ ទៅរករថយន្ត តែគេមិនបានចាប់ភ្លឹកនឹងវត្តមានរបស់សុគុណទាំងព្រហាម នោះឡើយ ។ គ្រាន់តែក្រលេកឃើញអាការៈជិតដិតស្និទ្ធស្នាលរវាងពិសិដ្ឋ នឹងសំនៀងភ្លាម ស្រាប់តែសុគុណនឹកអន់ចិត្តស្រលេតហើយកើតក្តីធុញថប់ ច្រណែនប្រចណ្ឌយ៉ាងណាមិនដឹងទេ ។ ទ្រាំមិនបាន នាយយើងក៏ស្ទុះរឹង ទាំងតក្កហលទៅប្រច្រានអ្នកទាំងពីរបំបែកគ្នាភ្លាម ធ្វើអោយសំនៀងដួល ប្រូសទៅម្ខាង ហើយពិសិដ្ឋក៏ច្រឡើតតើតថយក្រោយពីរបីជំហាន ។ដោយ ការនឹករលឹកខ្លាំង ធ្វើអោយនាយយើងខកចិត្តខ្លាំង រួចប្រចណ្ឌក៏ខ្លាំងណាស់ ដែរ ។ ពេលនោះ សុគុណប្រែជាលែងមានឥរិយាបថទន់ភ្លន់អស់រលីង ។ មាណពក៏ស្រែកគំហកទៅសំនៀងភ្លាមឡើងថា :

- បងមិននឹកស្មានសោះថាអូនចិត្តរាយមាយដល់ម្លឹងទេសំនៀង? បងគេង ចាំមើលផ្លូវអូនផ្សាភ្នែករាប់អាទិត្យមកហើយ ប៉ុន្តែអូនបែរជាមកមាន សេចក្តីសុខជាមួយនឹងគេដទៃ រួចទុកបងចោលឱ្យនៅកណ្តោចកណ្តែង ដូច្នេះទៅវិញ? ហេតុអី?... ហេតុអីអូន បែរក្លាយជាមនុស្សចិត្តងាយ ផ្លាស់ប្តូរលឿនយ៉ាងនេះ????

ភ្លាមនោះ មាណពសំលឹងទៅម្រាមដៃសំនៀងដែលធ្លាប់ពាក់ចិញ្ចៀន ពេជ្រភ្លឺចិញ្ចច ស្រាប់តែបាត់ចិញ្ចៀននោះពីដៃនាងទៅ ។ សុគុណហាក់ដូច ជារន្ធត់ចិត្តណាស់ ក៏បន្លឺវាចាបន្តថា :

- សំនៀង... តើអូនដោះចិញ្ចៀនរបស់បងចោលទៅណា? ឬក៏មកពីអូន ឃើញជីវិតបងកំពុងតែរលត់ទៅ ទើបអូនខំត្រដរប្រវេប្រវាស្វែងរកច្រាំង ថ្មី សំរាប់តោង...?

សំនៀងប្រឹងងើបឡើងតតេះតតះ ទឹកមុខសំដែងនូវការឈឺចាប់យ៉ាង ចំលែកបំផុត ។ កាលបើឮសំដីទ្រគោះបោះបោករបស់បុរសយើងចំពោះរូប នាងភ្លាម ទឹកភ្នែកជាច្រើនដំណក់ក៏ប្រជ្រៀតគ្នាហូរចេញមកលើផ្ទៃមុខដ៏ សែនស្លាំងរបស់នាងយ៉ាងសស្រាក់ ។ ធិតាបែរសំលឹងសុគុណវិញដោយការ ខកចិត្តយ៉ាងធំធេងឥតឧបមា :

- មែនហើយ! បងមានប្រសាសន៍ត្រូវណាស់! សំនៀងជាស្រីចិត្តងាយពិត មែន... ហ៊ានលះបង់សព្វយ៉ាងដើម្បីមនុស្សដែលខ្លួនស្រលាញ់... ហ៊ានកាត់ បន្ថយសូម្បីតែជីវិតរបស់ខ្លួនឯងដើម្បីរូបគេម្នាក់នោះ... នេះហើយឬចិត្ត បុរស? កាលបើបានដល់ត្រើយហើយ គេក៏បញ្ចេញភាពយង់ឃ្នងរបស់ខ្លួន សងវិញភ្លាម១ដែរ! ល្មើយចុះ! មនុស្សបាក់មែកបាក់ធាង ចិត្តងាយដូចជា សំនៀងមិនមានកត្តិយសអី នឹងនៅទើសមុខទើសមាត់បងតទៅទៀតដែរ! សូមបងរស់នៅសាងសុខបន្តជីវិតដោយសប្បាយចុះ... សំនៀង...សូមលា

CHANBOKEO.COM

បងហើយ...

ថាហើយ សំនៀងស្រក់ទឹកភ្នែកច្រោក១ រួចហើយក៏ប្រវេប្រវាងើប រត់ទាំងតតេះតតះចេញទៅក្រៅតាមទ្វាររបងយ៉ាងលឿន រកតែនរណា ឃាត់ក៏មិនទាន់ដែរ ។ កាលបើឃើញដូច្នោះ សុគុណហាក់ដូចជារន្ធត់ក្នុងចិត្ត ពន់ពេកណាស់ ។ ពិតមែនតែពេលនេះគេកំពុងតែខឹងច្រលោតនឹងសំនៀង ក៏ពិតមែន តែគេក៏មិនចង់អោយនាងចាកចេញពីរូបនាយទៅវិញងាយ១ ដូច្នោះដែរ ។ សុគុណក៏ស្រែកឃាត់នាងឡើងថា :

- សំនៀង! ឈប់សិន! អូនទៅណា?... សំនៀង... ឈប់សិនអូន!

ថាហើយ សុគុណយកដៃអោបពោះរត់តាមពីក្រោយនាងយ៉ាងរហ័ស បានតែពីរបីជំហានក៏ងងឹតមុខដួលប្រួសទៅដីតែម្តង ។ ពិសិដ្ឋឃើញដូច្នោះ ក៏ស្ទុះទៅជួយលើកនាយឡើង ព្រមទាំងស្រដីទាំងមុខក្រញូវថា :

- នែ៎សុគុណ! បើឯងមានសុខភាពជានាដូចប្រក្រតីវិញនោះ យើងនឹងដាល់ឯងបែកមាត់មិនខានដែលឯងស្រដីដាក់សំនៀងធ្ងន់១យ៉ាងនេះ?

- យ៉ាងម៉េច? កាន់ជើងគ្នាផងហ្អែស? ផ្អែមណាស់ឬដែលឯងលបឆ្មក់នៅ ក្រោយខ្នងយើង?

- តែផ្តាស! នាយសុគុណឯងកាន់តែផ្តាសហើយ ។ ឯងដឹងទេ? ដែលឯង និយាយទាំងប៉ុន្មាននេះមិនត្រឹមតែឯងមាក់ងាយយើងដែលជាមិត្តសំលាញ់ របស់ឯងទេ ប៉ុន្តែឯងកំពុងតែប្រមាថទឹកចិត្តនិងកិត្តិយសសំនៀងច្រើន ណាស់ ។ ការពិត សំនៀងគេងពេទ្យជិតបីអាទិត្យហើយ ហើយក៏ទើបតែ ចេញពីមន្ទីរពេទ្យម្សិលមិញនេះឯង ។ នាងមិនទាន់ជាស្រួលបួលនៅឡើយ ទេ... ឯងល្មមរៀនទទួលស្គាល់សុខទុក្ខរបស់អ្នកដទៃខ្លះផងទៅ!

- ហ្អាស? ពិសិដ្ឋ ឯងថាម៉េចហ្នឹង?....

សុគុណលាន់មាត់បើកភ្នែកធំ១ រួចហើយក៏ពោលបន្តថា :

- តើនាងមានរឿងអីទៅ ពិសិដ្ឋបានជាត្រូវចូលមន្ទីរពេទ្យផង?

- បើចង់ដឹងច្បាស់ ឯងរត់ទៅតាមសួរនាងដោយផ្ទាល់ទៅ...!!

សុគុណឮហើយក៏បែរក្រោយរកមើលសំនៀង តែនាងបានគេចបាត់ ស្រមោលទៅហើយ ។ ពេលនោះ វិរិទ្ធសុគុណក៏ខំគិតលួងលោមដួងចិត្តគេ តែម្នាក់ឯងថា ប្រហែលជាសំនៀងមិនទាន់ទៅណាឆ្ងាយនៅឡើយទេគ្រាន់តែខ្នក់ចិត្តហើយគេចមុខមួយពេល ព្រោះតែខឹងនឹងពាក្យដ៏អសុរសរបស់ នាយតែប៉ុណ្ណោះ ។ សុគុណក៏ដើរចេញមកក្រៅរបងរកមើលសំនៀង ប៉ុន្តែ គេមិនបានឃើញស្រមោលនាងតទៅទៀតឡើយ ។ លុះពិសិដ្ឋនាំនាយដើរសាកសួរអ្នកដែលរស់នៅម្តុំ១នោះ គេក៏ប្រាប់ថាបានឃើញនាងបានឡើង ជិះម៉ូតូឌុបចេញទៅហើយ មិនដឹងជាទៅខាងណាទេ ។ រំពេចនោះ សុគុណ មានអារម្មណ៍ថាងងិតមុខឈឺងតែម្តង ហើយក៏ធីងធោងរករលំដួលសាជា ថ្មី ។ ពិសិដ្ឋក្រលេកឃើញទាន់ក៏លាន់មាត់ឡើងយ៉ាងប្រញាប់ថា :

- សុគុណ! ឯងមិនស្រួលខ្លួនទៀតហើយ ត្រូវតែប្រញាប់ទៅមន្ទីរពេទ្យវិញ ទើបបាន...

- ប៉ុន្តែ... ខ្ញុំចង់ទៅតាមរកសំនៀងសិន... (សុគុណប្រកែក)

CHANBOKEO.COM

- មិនបានទេ! ឯងត្រូវទៅពេទ្យសិនទើបបាន។

ទោះបីជាសុគុណប្រកែក ចង់ចេញទៅតាមរកសំនៀងបែបណាក៏ ដោយក៏ពិសិដ្ឋលែងស្តាប់នាយយើងដែរត្បិតពេលនេះ មាណពមានអាការៈ កាន់តែមិនស្រួលខ្លាំងហើយ ហើយទឹកមុខរបស់នាយកាន់តែស្លេកខៀវ ទៅៗយ៉ាងចំលែករហូតដល់ទៅទន់ខ្លួនល្វក់ដើរលែងរួចតែម្តង។ ដោយក្តី បារម្ភចំពោះមិត្តជាអនេក ពិសិដ្ឋក៏បរឡាននាំសុគុណត្រលប់ទៅមន្ទីរពេទ្យ យ៉ាងបន្ទីរបន្ទាន់បំផុត។

មកដល់មន្ទីរពេទ្យកាលណា ពិសិដ្ឋប្រទះឃើញបុគ្គលិកពេទ្យជាច្រើន រួមទាំងលោកវរៈនិងកូនស្រីផង កំពុងតែចលាចលតាមរកវិន្ទសុគុណខ្វែង ខ្វាត់ដោយរូបនាយបានបាត់ខ្លួនពីមន្ទីរពេទ្យទៅដោយអាថិកំបាំង។ កាល បើប្រទះឃើញពិសិដ្ឋនាំខ្លួនមាណពយើងមកដល់ ទាំងអស់គ្នាក៏ស្ទុះស្ទារ មកទទួលយ៉ាងប្រញាប់ប្រញាល់ លើកនាយដាក់លើគ្រែរុញចូលបន្ទប់ អាសន្នភ្លាមមួយរំពេច។ គ្រានេះ សុខភាពរបស់សុគុណទាំងផ្លូវកាយផ្លូវ ចិត្តហាក់ដូចជាមានដំណើរទ្រុឌទ្រោមយ៉ាងរហ័សចំលែកណាស់ ធ្វើអោយ គ្រប់ៗគ្នារឹងរិតតែបារម្ភ ចំពោះនាយកាន់តែខ្លាំងឡើងៗ។

ក្នុងឱកាសដែលនៅអង្គុយរង់ចាំដំណឹងពីលោកវេជ្ជបណ្ឌិតចំពោះស្ថាន ភាពរបស់អ្នកជំងឺ លោកវរៈក៏ហៅពិសិដ្ឋមកសួរខ្សិបៗថា ៖

- តើមានរឿងអ្វីដែរទៅពិសិដ្ឋ ដែលធ្វើឱ្យសុគុណបែរក្លាយជាធ្ងន់ធ្ងរខុស ប្រក្រតីយ៉ាងនេះ?

ពិសិដ្ឋក៏រៀបរាប់ដំណើររឿង ជំរាបលោកវរៈនិងវរលក្ខណ៍ដែលនៅ អង្គុយស្តាប់យ៉ាងស្ងប់ស្ងៀមក្បែរនោះ នូវអ្វីដែលនាយយើងបានប្រទះនៅ
ថ្ងៃនេះ។ ភ្លាមនោះ លោកវរៈក៏លាន់មាត់ឡើងថា ៖

- សុគុណអើយ! កូនជាក្មេងល្អយូរហើយ ហើយយ៉ាងម៉េចយ៉ាងម៉ាបានជា កូនក្លាយជាមនុស្សកំរោល មានពិរោធ ហើយឆាប់ច្រលោតដោយឥតហេតុ ផលយ៉ាងនេះ? តើនេះមកពីកូនកំពុងទទួលប្រតិកម្មពីថ្នាំព្យាបាល ឬក៏មក ពីសេចក្តីស្នេហារបស់កូនដែលមានចំពោះសំនៀងនោះវាខ្លាំងហួសហេតុ?..

ពិសិដ្ឋនិងវរលក្ខណ៍លួចសំលឹងមុខគ្នានៅស្ងៀម មិនហ៊ានឆ្លើយទៅ លោកថាយ៉ាងណាឡើយ។ មួយស្របក់ក្រោយមក ពិសិដ្ឋក៏ជំរាបលាអ្នក ទាំងពីរត្រលប់ទៅវិញ ដោយសន្យាថានឹងទៅជួយតាមរកសំនៀងមកឱ្យ សុគុណយ៉ាងឆាប់រហ័សបំផុត។

លុះនាយមកដល់ផ្ទះវិញ ស្រាប់តែក្មេងស្រីបំរើរត់មកប្រាប់នាយទាំង ត្រហេបត្រហបថា ៖

- លោកពិសិដ្ឋ! មុននេះបន្តិច មានគេនាំបងសំនៀងមកទទួលយកឥវ៉ាន់ ផ្ទាល់ខ្លួនរបស់គាត់ទៅអស់ហើយ។

- អូហ៎... ហើយចុះពីណាគេទៅដែលនាំសំនៀងមក? នាងស្គាល់គេទេ?

- ចាំស! មិនស្គាល់ទេ តែជាមនុស្សស្រីពីរនាក់ ម្នាក់ខ្ទង់សាម ម្នាក់នៅ ក្មេង ស្រករនឹងបងសំនៀងដែរ។

- ហើយចុះគេមានទុកបណ្តាំអ្វីមកអោយខ្ញុំដែរឬទេ?

- ចាំសមាន! បងសំនៀងផ្ញើទុកឥវ៉ាន់មួយកញ្ចប់នេះទុកជូនលោកសុគុណ

CHANBOKEO.COM

វិញ តែមិនឮផ្តាំអ្វីទៀតទេ ។

- ហើយចុះនាងដឹងទេ ថាសំនៀងគេមានសុខភាពផ្លូវកាយយ៉ាងណាដែរ?

- តាមមើលទំនង ប្រហែលជាគេនាំបងសំនៀងទៅព្យាបាលកន្លែងណា ហើយ ព្រោះខ្ញុំឮគេជជែកគ្នាថាគាត់កំពុងត្រូវការជួបពេទ្យ ។

- តើនាងមានឮទេថាគេបំរុងយកនាងទៅមន្ទីរពេទ្យណាដែរទៅ?

- មិនបានឮទេ ចាស! ខ្ញុំឮតែប៉ុនហ្នឹងហើយពួកគេក៏នាំបងសំនៀងចេញ ទៅ ។

ភ្លាមនោះ ពិសិដ្ឋក៏លើកទូរសព្ទ័ទៅរកវរលក្ខណ៏ :

- បងលក្ខណ៏ ! ប្រហែលជាយើងត្រូវចេញតាមរកសំនៀងនៅតាមមន្ទីរ ពេទ្យហើយ ។ បងជួយខ្ញុំទេ? ក្រែងលោយើងរកនាងឃើញនៅមុនពេល នាយសុគុណគេចេញពីបន្ទប់ព្យាបាលអាសន្នមកវិញ ។ម្យ៉ាងទៀត ខ្ញុំក៏នឹកបារម្ភពីសំនៀងដែរ ។ ពេលនេះ សុខភាពរបស់នាងក៏ទ្រុឌទ្រោមមិនខុសពី សុគុណប៉ុន្មានឡើយ ។

- អឺ! បើដូច្នោះ ប្អូនមកទទួលបងឥលូវនេះមក យើងចេញតាមរកនាង ទាំងអស់គ្នា សង្ឃឹមថានាងមិនចាកចោលពួកយើងទៅណាដោយឥត ដំណឹងយ៉ាងនេះឡើយ ។

ឮហើយ ពិសិដ្ឋក៏ស្ទុះបររថយន្តរឹងទៅទទួលវរលក្ខណ៏ចេញតាមរក ធិតាយើងភ្លាមទាំងដួងចិត្តខ្វល់ខ្វាយ ។ តើហេតុអីទៅហ្ន៎ដែលធ្វើអោយគេ ទាំងពីរអំពល់តាមរកសំនៀងដល់ម្លឹង? នៅឯមន្ទីរពេទ្យ សុគុណនៅគេង ស្តូកស្តឹងសាជាថ្មី ក្រោមការពិនិត្យយ៉ាងល្អិតល្អន់របស់លោកវេជ្ជបណ្ឌិតសា ជាថ្មី ម្តងទៀត ។

CHANBOKEO.COM

## វិប្បដិសារី

ស្តាយដែលខឹងខុសខឹងខូចខឹងខាត          ចិត្តបងមិនស្អាតគិតអកុសល
ខឹងព្រោះប្រចណ្ឌ័ឆោមកែវនិមល          ខឹងត្បិតពិភាល់អូនភ្លេចរូបបង ។
ស្តាយបងភ្លេចខ្លួនលង់ក្តីពិរោធ          ចរិតក្រេវក្រោធក្លាយជាចំណង
បាបកម្មរួបរិតចងចិត្តប្រុសបង          លុះជួបសៅហ្មងទើបភ្ញាក់ស្មារតី ។
អភ័យបងផងនួនល្អងបងអើយ          ពេលនេះយល់ហើយថាបងអប្រិយ
គំនិតអគតិបង្កទុក្ខភ័យ          ដល់កល្យាណីស្លូតត្រង់ដូចអូន ។
បងសែនខឹងចិត្តចរិតផ្តេសផ្តាស          ឥលូវស្តាយណាស់ត្រូវព្រាត់រូបស្ងួន
អូនអើយ! បងឈឺត្បិតបាត់រូបអូន          ចិត្តបងស្រពោនលង់វិប្បដិសារី...

CHANBOKEO.COM

# វគ្គទី៧

## បាត់បេះដូង

នៅក្នុងមន្ទីរពេទ្យ...

សុគុណបានដឹងស្មារតីមកវិញម្តងទៀត តែម្តងនេះ នាយបានទទួល ការព្យាបាលនឹងការពិនិត្យឃ្លាំមើលរូបនាយ យ៉ាងតឹងរ៉ឹងជាងមុនឆ្ងាយ ណាស់ ត្បិតពេលនាយត្រលប់មកវិញនោះ វេជ្ជបណ្ឌិតបានពិនិត្យឃើញថា ឈាមរបស់នាយមានប្រតិកម្មប្រឆាំងនឹងការដាំក្រលៀនថ្មី ហើយប្រព័ន្ធ កោសិកាចិញ្ចឹមរូបកាយនៅតែមិនព្រមបណ្តុះឈាមក្រហមតាមចំនួនដែល រូបកាយត្រូវការ ម្ល៉ោះហើយនាយត្រូវការបញ្ចូលឈាមបន្ថែមរៀងរាល់ ថ្ងៃរហូតដល់ក្រលៀនរបស់នាយ ចាប់ផ្តើមធ្វើការជាប្រក្រតីមកវិញ ។ ពេលនោះ លោកវេជ្ជបណ្ឌិតបានបញ្ជាដាច់ណាត់អោយនាយថ្នមខ្លួនតាម បញ្ជារបស់ពេទ្យ ហើយអោយឈប់រវើរវាយនឹងពិភពក្រៅមួយរយៈ ។ ពាក្យបណ្តាំរបស់លោកគ្រូពេទ្យទាំងអំបាលម៉ាននេះ មិនខុសអ្វីពីការយក ច្រវាក់ មកចងកៀបសុគុណអោយនៅជាប់ក្នុងបន្ទប់រក្សាជំងឺនោះឡើយ ។ ថ្វីបើពេលនេះ នាយយើងនឹករលឹកខ្វាយខ្វល់ទៅដល់សំនៀងស្ទើរតែបែក ដើមទ្រូងម្តងៗទៅហើយក្តី ក៏នាយគ្មានមធ្យោបាយណាដែលត្រូវប្រឆាំង នឹងបញ្ជារបស់ពេទ្យដែរ មិនដូច្នោះទេ នាយច្បាស់មិនអាចមានជីវិតតាម ស្វែងរកសំនៀងតទៅទៀតមិនខាន ។ ពេលនេះ សុគុណនៅតែងបើកភ្នែក ម៉ក់ៗសំលឹ ពិដានបន្ទប់តែម្នាក់ឯង នឹកគិតសង្វេគក្នុងចិត្តតែម្យ៉ាងថា :

- សំនៀង... បងនឹកអូនណាស់! អោយបងសូមទោសអូនផងដែលបងបាន បញ្ចេញភាពគំរោះគំរើយដាក់អូនដោយមិនមានហេតុផល ។ តើពេលនេះ អូននៅទីណា? សំនៀង អភ័យទោសអោយបងផងណាអូន... កាលបើបង បំរុងនឹងមានជីវិតរស់នៅសាជាថ្មីដូចគេដូចឯង សូមអោយបងបានជួបនឹង អូនវិញកុំខាន ។ តើអោយបងរស់នៅមានជីវិតដើម្បីអ្វី បើសិនជាបងមាន ជីវិតមកវិញ តែបងត្រូវបាត់រូបអូនពីឱភាទៅ? ម្ចាស់ដួងចិត្តបងអើយ.. ថ្ងៃនេះ អូនកំពុងធ្វើអ្វី នៅទីណា សុខទុក្ខយ៉ាងណា? ដឹងទេថា បងកំពុង រែកវិប្បដិសារីនៅក្នុងដួងចិត្ត ដោយការដែលបងឆេវឆាវក្រេវក្រោធ ចំពោះអូនដោយមិនបានគិត? ឆាប់វិលមករកបងវិញណាអូនណា! ជីវិត

CHANBOKEO.COM

របស់បងពិតជាត្រូវការរូបអូនណាស់... !! សំនៀង... បងស្រលាញ់អូន ស្រលាញ់អូន... បងនឹកអូន... នឹកឥតឧបមារកអ្វីមកប្រៀបស្មើមិនបានទេ

សុគុណយកដៃគងថ្ងាស គេងគិតតែម្នាក់ឯងមិនអស់មិនហើយ ។ គេ នឹកមិនអស់ចិត្តឡើយ ថាតើហេតុអ្វីសំនៀងត្រូវមកគេងពេទ្យអស់ជាយូរ អាទិត្យនៅភ្នំពេញនេះ ប៉ុន្តែគ្មាននរណាមួយបង្ហើបប្រាប់នាយអ្វីបន្តិចសោះ សូម្បីតែពិសិដ្ឋដែលផ្តល់កន្លែងស្នាក់នៅដល់នាង មិនដឹងថា នាងមានគ្រោះ ថ្នាក់ចរាចរនៅក្នុងរថយន្តព្រមជាមួយនឹងវរលក្ខណ៏ឬក៏យ៉ាងណា ។ គេគេង នឹកដល់នាង នឹកដល់ការដែលនាងបានផ្តាប់ផ្តុនចិត្តនាយសព្វបែបសព្វយ៉ាង ដោយឥតលក្ខណ្ឌ សូម្បីបន្តិច ទោះបីជាគ្រានោះ នាងក៏ដឹងដែរថា នាយ យើងកំពុងតែមានដំណើរជីវិតខ្ចីទៅៗក៏ដោយ ។ នាងបានបូជារូបកាយ របស់នាងដោយការពេញចិត្តចំពោះនាយបំផុត ប៉ុន្តែហេតុអ្វី ខ្លួនបែរជានឹក យល់ច្រលំ មើលរំលងនូវភាពស្មោះត្រង់របស់នាងទៅវិញ ។ នឹកយូរៗទៅ សុគុណរិតតែបន្ទោសខ្លួនឯងខ្លាំងឡើងៗ មិនដាច់ ដែលជាហេតុធ្វើអោយ ជំងឺផ្លូវចិត្តរបស់នាយកាន់តែទ្រុឌទ្រោមទៅតាមនោះដែរ ។ ឥលូវ គេលែង ចង់និយាយស្តីរកនរណាទាំងអស់ សូម្បីតែលោកវរៈជាឪពុកដែលមកមើល ថែកូនជាញឹកញាប់ ឬក៏សូម្បីតែវរលក្ខណ៏ដែលជាបងស្រីសំណព្វចិត្តក៏នាយ លែងចង់ស្រដីរកដែរ ។ គេបានប្រែក្លាយទៅជាមនុស្សថ្នក់ថ្នុយ លែងវាចា លែងមាត់ក លែងមានភាពរាក់ទាក់ ដូចដែលគេធ្លាប់មានពីមុនៗមក ។ មានតែមនុស្សម្នាក់ទៅដែលនៅសុគុណនៅវាចាជាមួយ នោះគឺពិសិដ្ឋមិត្ត សំលាញ់របស់គេតែម្នាក់គត់ ។

ពីរអាទិត្យបានកន្លងទៅ...

តុក! តុក! តុក!

ពិសិដ្ឋគោះទ្វារហើយក៏ដើរចូលទៅ ឃើញសុគុណអង្គុយនៅលើគ្រែ អ្នកជំងឺក្នុងមន្ទីរពេទ្យយកដៃជ្រោងសក់ធ្វើមុខស្អុយប៉ែ ។ នាយក៏សួរទៅ សំលាញ់ថា :

- ឯងបានគ្រាន់បើខ្លះទេ សុគុណ?

សុគុណគ្រវីក្បាលហើយឆ្លើយវិញថា :

- ការពិត បើខ្ញុំស្លាប់ទៅកាលពីនៅបាត់ដំបង ប្រហែលជាខ្ញុំសប្បាយចិត្តជា ជាងពេលនេះ..

- ព្រោះហេតុអ្វីទៅ បានឯងនិយាយដូច្នេះ? ឯងកំពុងមានជីវិតសាជាថ្មី ហើយ មិនសប្បាយចិត្តទេហ៎?

- អោយសប្បាយយ៉ាងណាកើតទៅ កាលបើគ្នាមានជីវិត តែក៏បាត់បេះដូង ពីខ្លួនទៅយ៉ាងនេះ?

- ហ៊ឺ! គ្នាមិនដឹងជាត្រូវជួយឯងយ៉ាងណាទៀតទេសំលាញ់ ពេលនេះ គ្នា ដូចជាចាល់តម្រេះហើយ ។

- ឯងពិតជាគ្មានសង្ឃឹមមែនឬថា យើងអាចតាមរកសំនៀងឃើញ?

CHANBOKEO.COM

- គ្នាបានតាមទៅដល់ចំការឯវត្តគរបាត់ដំបងហើយ ប៉ុន្តែតាក្រូចយាយ ប្រាងមានប្រសាសន៍ថា សំនៀងមិនដែលត្រលប់ទៅទីនោះវិញទេ តាំងពី ថ្ងៃដែលនាងចាកចេញមកភ្នំពេញ ប៉ុន្មានអាទិត្យមុននោះម្ល៉េះ។ ឥលូវនេះ គ្នាមិនដឹងថាត្រូវជួយឯងតាមរកនាងនៅឯណា ទៀតទៅទើបឃើញ...

សុគុណអង្គុយឈ្ងឹថ្ងាសយ៉ាងយូរទើបស្រដីសួរបន្តថា :

- ហើយចុះឯងអាចប្រាប់យើងបានទេ ថាហេតុអ្វីកាលនោះ សំនៀងមាន ជំងឺត្រូវចូលព្យាបាលនៅមន្ទីរពេទ្យផង?

ពិសិដ្ឋព្ធដូច្នោះក៏លេបទឹកមាត់ក្អឹកផ្សើមបំពង់ក រួចហើយក៏ឆ្លើយថា :

- ចាំឯងមានសុខភាពគ្រប់គ្រាន់ គ្នានឹងនាំឯងទៅតាមរកចំលើយមិន ខាន។ ពេលនេះ អ្វីដែលឯងត្រូវគិតគឺរក្សាសុខភាពរហូតដល់បានជានាដូច ប្រក្រតីវិញសិនទៅ។ កាលបើឯងនៅតែជាអ្នកជំងឺអាមណាមដូច្នេះ តើ ឯងនឹងមានកំលាំងអីតាមរកសំនៀង និងអ្វីៗដែលទាក់ទងនឹងជីវិតរបស់ នាងបានទៅ? ឯងត្រូវតែរឹងប៉ឹងឡើងណា៎ ហើយឆាប់ជាសះស្បើយ នឹង អាលយើងនាំឯងតាមរកនាងសាជាថ្មី។

ឃើញពួកម៉ាកមិនបង្អើបរឿងអី សុគុណក៏ធ្លាក់ទឹកចិត្តស្រលេតហើយ ក៏ប្រះខ្លួនលើគ្រែ ស្រវាភួយដណ្តប់ រួចធ្មេចនេត្រាលែងនិយាយចចារអ្វីនឹង ពិសិដ្ឋតទៅទៀត។ លុះឃើញមិត្តរបស់ខ្លួនធ្មេចសំរាក ពិសិដ្ឋក៏មិនហ៊ាន នៅរំខានដែរ។ គេក៏គេចខ្លួនត្រលប់ចេញទៅធ្វើការវិញបាត់ទៅ។

ពេលពិសិដ្ឋដើរមកដល់មាត់ទ្វារ ស្រាប់តែនាយប្រទះនឹងដារិនី :

- សួស្តីពិសិដ្ឋ! សុខសប្បាយទេហ៎?

- អូហ៎ សុខជាទេណា៎! ដារិនីមកសួរសុខទុក្ខសុគុណមែនទេ?

- ចា៎ស! ខានមកលេងគាត់ពីរអាទិត្យហើយ មិនដឹងថាគាត់បានគ្រាន់បើ ជាងមុនហើយឬនៅ?

- ទាល់តែដារិនីទៅឃើញផ្ទាល់ជាជាងខ្ញុំនិយាយប្រាប់ហើយ បើអញ្ចឹង ខ្ញុំ លាសិនហើយណា៎។

- ចា៎ស! ថ្ងៃក្រោយជួបគ្នា។

ពិសិដ្ឋក៏ដើរចេញទៅ រីឯដារិនីក៏ម្ចីម្ចាដើរមករកសុគុណនៅក្នុងបន្ទប់។ ចៃដន្យ នាយលែងមានអារម្មណ៍ល្អទៅហើយ។ កាលបើបើកភ្នែកឡើង ឃើញដារិនីពេលនាយព្ធសំរឹបជើងដើរចូលមកដល់ សុគុណក៏ធ្មេចភ្នែកវិញ យ៉ាងរហ័សតែម្តង។ គេមិនចង់ឃើញ មិនចង់ជួបនាងតទៅទៀតទេ ថែម ទាំងគិតក្នុងចិត្តថា :

- ហេតុអ្វីទៅហ្ន៎ មនុស្សដែលយើងមិនចង់ជួប បែរជាមកអោយឃើញមុខ តែអ្នកដែលយើងចង់ឃើញមុខ បែរជាមិនមក? សុគុណអើយ.. ហេតុអ្វីក៏ រាសីរបស់អ្នកដើរបញ្ច្រាសទិសពីចិត្តនិងបំណងប្រាថ្នារបស់អ្នកដូច្នេះ?

CHANBOKEO.COM

ពេលនោះ សុគុណមានអារម្មណ៍ហាក់ដូចជាធុញថប់ឡើងៗរកថាមិន ត្រូវ។   បែរមកដារិនីវិញ នាងញញឹមយ៉ាងពព្រាយ
កាលបើបានមកជួប សុគុណនៅពេលនេះ :

- បងសុគុណ! ស្រួលបួលគ្រាន់បើហើយឬនៅបង? នេះ ដារិនីយកផ្លែឈើ និងបាច់ផ្កាដ៏ស្អាតមកផ្ញើបងណា៎ !
សង្ឃឹមថាក្លិនដ៏ក្រអូបនិងរូបសោភ័ណ របស់ផ្កានឹងធ្វើអោយបងមានអារម្មណ៍ធូរស្រាលមកវិញណា៎។

ថាហើយនាងក៏ដាក់កញ្ច្រែងផ្លែឈើនៅលើតុ រួចហើយក៏យកផ្កាដាក់ តំរៀបក្នុងថូយ៉ាងស្អាត
រួចហើយក៏បែរនិយាយបន្តទៀតទៅសុគុណថា :

- បងសំលាញ់! ហេតុអ្វីក៏នៅស្ងៀមឈឹងមិនស្រដីតបនឹងអូនយ៉ាងនេះ? នៅមិនទាន់ស្រួលខ្លួននៅឡើយ មែនទេបង?

ថាហើយនាងក៏ដាក់ខ្លួនអង្គុយចុះក្បែរសុគុណ ហើយយកដៃស្ទាបខ្លួន នាយថ្នមៗ :

- មើលទៅបងដូចជាមានសាច់ឈាមល្អជាងមុនច្រើនណាស់ ប្រហែលជា បងជិតជាស្រួលបួលវិញហើយ។ បើកភ្នែកមើល៍ បង!
យើងនិយាយគ្នា បន្តិចបានទេ?

តែសុគុណនៅតែធ្វើមិនដឹង ហើយក៏មិនព្រមឆ្លើយថាយ៉ាងណាដែរ។
ឃើញឫកពារបស់នាយយើងដូច្នោះ ដារិនីក៏ស្រដីទៀតថា :

- ណ្ហើយចុះ! បើសិនបងនៅខឹងនឹងដារិនី  ថ្ងៃនេះ   អូនមកសូមទោសបង
សាជាថ្មីម្តងទៀតណា៎! បងសុគុណ តើយើងអាចចាប់ផ្តើមសាជាថ្មីបានទេ?

រំពេចនោះ សុគុណក៏បើកភ្នែកឡើងព្រិមៗ តែមិនឮឆ្លើយអ្វីទៅដារិនី ទេ។ បន្តិចមកធិតាក៏និយាយបន្តថា :

- សូមបងឈប់ខឹងនឹងដារិនីទៀតទៅ! ថ្ងៃមុនអូនសុញគំនិតគិតមិនបានល្អ
ទើបបានជានិយាយជាមួយបងដោយខ្វះហេតុផល...តែពេលនេះ អូនដឹង កំហុសរបស់ខ្លួនហើយ ហើយក៏ទទូចសុំឱកាសថ្មី
មិនដឹងថា បងគិតយ៉ាង ណាដែរចំពោះរឿងនេះ?

សុគុណនៅស្ងៀមមួយស្របក់ក៏ឆ្លើយវិញថា :

- អរគុណណាស់ដារិនីដែលបានមកមើលសួរសុខទុក្ខរបស់បងពេលនេះ...

គ្រាន់តែសុគុណព្រមស្រដីតបវិញ ដារិនីសប្បាយចិត្តញញឹមពព្រាយ ភ្លាមមួយរំពេច :

- បងឈប់ខឹងនឹងអូនហើយមែនទេ?

សុគុណងក់ក្បាលហើយនិយាយខ្សិបៗថា :

- យើងចាប់ផ្តើមជាថ្មីក៏បានដែរណា៎ដារិនី តែបងសូមដូរទិវិញ... គឺយើង
មិនចាប់ផ្តើមពីចំណុចដែលដាច់គ្នាកាលពីលើកមុននោះទេ...

- បងចង់មានន័យថាម៉េចហ្នឹង?

- បងចង់មានន័យថា ចំណុចដែលបងចង់ចាប់ផ្តើមថ្មីជាមួយដារិនីនៅពេល
នេះ គឺសូមផ្តើមធ្វើជាមិត្តនឹងគ្នាធម្មតាៗ តែមិនមែនជាសង្សារឬជាអតិតគូ

CHANBOKEO.COM

ដណ្ដឹងឡើយ... បងសូមរក្សាសេរីភាពរបស់បងខ្លះ សំរាប់សំលឹងអនាគត របស់បងអោយបានមុតមាំជាងកាលមុនៗ...

ឮដូច្នោះ ដារិទីក៏ថ្លោះទឹកមុខភ្លាម :

- បងនៅមិនទាន់ទុកចិត្តដារិទី ឬក៏បងនៅខឹងនឹងអូននៅឡើយ?

- មិនមែនទេ ដារិទី! ការពិត.. ជីវិតរបស់បងកំពុងជាប់ចំណងថ្មីមួយទៀត ដែលបងមិនអាចស្រាយវិញបាន ម្ល៉ោះហើយ បងអាចទទួលអូនបានត្រឹម តែជាមិត្តរបស់បងប៉ុណ្ណោះ មិនអាចលើសពីនោះទៀតទេ។

ដារិទីសំលឹងមុខវិរិទ្ធសុគុណដោយទឹកមុខខកចិត្តយ៉ាងធំធេង :

- បងនិយាយនេះដើម្បីសងសឹករូបអូនដែលអូនបានធ្វើអោយដួងចិត្តរបស់ បងឈឺចាប់នាគ្រាមួយនោះ ឬក៏...

- គឺជាការពិតណាដារិទី! សូមអូនព្រមទទួលទៅ ថាបងមិនអាចវិលថយ ក្រោយបានទេ។ ពេលនេះ ជីវិតរបស់បង បេះដូងរបស់បង បានប្រគល់ជូន នារីដទៃមួយរូបទៅហើយ មិនមានអ្វីនៅសេសសល់នឹងមកលលេងសេចក្ដី ស្នេហារបស់អូនទៀតឡើយ។ គ្រានេះ បងមានផ្ដល់ត្រឹមតែមិត្តភាពដ៏ល្អ ចំពោះអូនតែម្យ៉ាងប៉ុណ្ណោះ... សូមអូនកុំសាងក្ដីសង្ឃឹមអ្វីដែលមានទំហំ លើសពីនេះអោយសោះណាអូន...

ដារិទីដាក់មុខជ្រប់អស់មួយស្របក់ ទើបងើបមុខឡើងស្រដីថា :

- ដារិទីមិនយល់សោះថា យើងបានស្គាល់គ្នា ស្រលាញ់គ្នាអស់ជាយូរឆ្នាំ ប៉ុន្តែមិនបានមួយប៉ប្រិចភ្នែក នារីចំលែកម្នាក់មកឆក់បេះដូងបងបានយ៉ាង រហ័សពីដៃអូនទៅយ៉ាងងាយដូច្នេះឡើយ... តើគេមានអ្វីពិសេសជាងដារិទី ទៅ ដែលអាចទិញបេះដូងរបស់បងបាន?

សុគុណសំលឹងមុខនារីយើងមួយស្របក់ ហើយគិតតែក្នុងចិត្តតែម្នាក់ ឯងយ៉ាងស្ងៀមស្ងាត់ថា :

- ដារិទី អូនជាបុត្រីអភិជន មានសេចក្ដីសុខ មានសុភមង្គល មានកត្តិយស និងអ្វីៗសព្វយ៉ាង ដែលសំនៀងមិនអាចប្រៀបស្មើនឹងអូនបាន ប៉ុន្តែអ្វីដែល ដារិទីត្រូវចាញ់សំនៀងទាំងស្រុងនោះ គឺទឹកចិត្ត... បងមិនបាច់រៀបរាប់ទេ ថាអ្នកទាំងពីរខុសគ្នាយ៉ាងណា... អ្វីដែលបងដឹងច្បាស់បំផុតនោះគឺសំនៀង គេមិនបោះបង់ចោលបងឡើយ នៅពេលដែលបងស្ថិតនៅភាពទាល់ច្រក ក្នុងជីវិត។ ផ្ទុយទៅវិញ នាងបែរជាផ្ដល់នូវអ្វីសព្វយ៉ាងចំពោះបង ដោយ ឥតមានលក្ខខណ្ឌ សូម្បីតែនាងដឹងហើយថា នាងកំពុងដើរនៅក្នុងចំណុច ខាត និងចំណុចចាញ់ក៏ដោយ ក៏នាងនៅតែផ្ដល់សេចក្ដីសុខដល់ជីវិតរបស់ បងជានិច្ចដែរ... រីឯដារិទីវិញ ហ៊ឹ... តើអូនធ្វើបានដូចសំនៀងដែរឬទេហ៎?

ឃើញសុគុណនៅស្ងៀមស្ងាត់មិនស្រដីតបមកវិញ ដារិទីក៏ពោលបន្ត:

- ណ្ហើយចុះ! ពេលនេះ បងកំពុងតែឈឺ... មិនទាន់មានអារម្មណ៍ល្អនៅ ឡើយ។ ចាំយើងនិយាយគ្នាពេលក្រោយក៏បានដែរ ប៉ុន្តែដារិទីមិនព្រមចុះ ចាញ់នារីថ្មីនោះទេ ព្រោះអូនចង់ដឹងណាស់ថាគេជានរណា? ហើយតើគេ មានគុណសម្បត្តិអ្វីខ្លះ ដែលអាចផ្លាស់ប្ដូរដួងចិត្តបងយ៉ាងឆាប់រហ័សបែប នេះ? ទោះជាយ៉ាងណា ដារិទីមិនអាចកាត់ចិត្តពីបងបានងាយៗឡើយ ដរាបណា ដារិទីមិនទាន់បានជួបគូប្រជែងប្រកួតគ្នា ដោយគុណសម្បត្តិឈ្នះ

CHANBOKEO.COM

ចាញ់ ដឹងទីដឹងកន្លែងនៅឡើយនោះ ។

ថាហើយនាងលាសុគុណចេញទៅវិញបាត់ស្រមោល ទុកអោយនាយ
នៅគេងគិតម្នាក់ឯងត្រមង់ត្រមោចខ្លោចផ្សាដួងចិត្ត...

ពីរអាទិត្យកន្លងទៅ...

សុគុណទ្រាំគេងនៅមន្ទីរពេទ្យទាំងលំបាកចិត្តបំផុត ត្បិតនាយត្រូវគេ យាមព្រឹកល្ងាចមិនអោយចេញទៅណាមកណា ។ ចំណែកឯដំណឹងរបស់ សំនៀងវិញក៏បាត់សូន្យទៅទៀត គ្មាននរណាម្នាក់ដឹងថា ពេលនេះ នាង នៅឯណា មានសុខទុក្ខយ៉ាងណា ។ ជាងមួយខែហើយដែលសុគុណមិនបាន ឮដំណឹងអ្វីពីនាងសោះ ជាងមួយខែហាក់ដូចជាជាងមួយរយឆ្នាំសំរាប់នាយ យើងដែលគេងទន្ទេញរង់ចាំជួបធិតាម្ចាស់ដួងចិត្ត អនិច្ចា ទេវតាមិនអាសូរ ប្រណីដល់ចិត្តបុរសយើងឡើយ ។ ថ្ងៃណាក៏ដូចថ្ងៃណាដែរ សុគុណគេងយក ដៃគងថ្ងាស រាប់ខែថ្ងៃ រង់ចាំការអនុញ្ញាត្តពីលោកគ្រូពេទ្យអោយចេញទៅ ផ្ទះ នឹងអាលមានឱកាសតាមរកសំនៀងមកវិញ ព្រមទាំងស្វែងរកចំលើយ
ទាំងឡាយសំរាប់ជំរះចំងល់ដែលនាយមាននៅក្នុងចិត្តទាំងអំបាលម៉ាន ។

បាត់ស្នេហ៍

បាត់អូនបាត់សូន្យគ្មានដំណឹង ឱ! កែវព្រលឹងសុខយ៉ាងណា?
បងនឹករូបស្រីពេញទ័យា នឹកតែពំងាពុំមានស្បើយ ។
បាត់ពៅបាត់ទៅលែងបានដឹង ថាស្រស់ព្រលឹងយ៉ាងណាហើយ
បងយំបងនឹកកែវត្រាណត្រើយ អូនអើយសូមវិល... បងអង្វរ ។
បាត់ស្រីបាត់ថ្លៃមិនឃើញសោះ បេះដូងស្វិតអស់នឹកកេសរ
អូននៅឯណាសូមវិលមក៍ បងសូមអង្វរលន់តួខ្លួន ។
បាត់ពៅបាត់ទៅស្ងាត់សូន្យឈឹង បងគេងរំពឹងរងចាំអូន
បន់ព្រះសូមអោយបងជួបស្ងួន សាងស្នេហ៍នឹមនួនត្រកាលអើយ...

ព្រឹកនេះ លោកវរៈនិងបងស្រីរបស់នាយក៏បានមកដល់ពេទ្យតាមការ ណាត់ជួបរបស់លោកវេជ្ជបណ្ឌិត ។ នៅពេលនោះ លោកគ្រូពេទ្យក៏បាន ហៅអោយបុរសយើងចូលរួមពិភាក្សា ពីការត្រូវថែជំងឺនៅពេលចេញទៅ ផ្ទះ ។ តាមរយៈអ្នកបកប្រែដ៏ប៉ិនប្រសព្វមួយរូប លោកគ្រូពេទ្យបានពន្យល់ ទៅអ្នកទាំងបីអំពីអាការរោគរបស់សុគុណ ។ ថ្វីបើពេលនេះមាណពហាក់ ដូចជាបានធូរស្រាលជាច្រើនក៏រិតហើយក៏ដោយ ប៉ុន្តែលោកវេជ្ជបណ្ឌិតបាន
ហាមមិនអោយនាយយើងបណ្តោយខ្លួនហួសជ្រុលពេកដែរ ថែមទាំងហាម មិនអោយបរិភោគស្រា មិនអោយដើរលេងអត់ងងុយ មិនអោយធ្វើការ ហួសកំលាំង ព្រមទាំងត្រូវរក្សាអាហារតាមក្បួនពេទ្យយ៉ាងត្រឹមត្រូវទៀត ផង ។ លុះចប់ពិគ្រោះកាលណា លោកវេជ្ជបណ្ឌិតក៏អនុញ្ញាត្តអោយលោក វរៈទទួលយកវិន្ទសុគុណទៅរក្សាជំងឺនៅផ្ទះវិញដោយមានលោកគ្រូពេទ្យ

CHANBOKEO.COM

ជំនាញមួយរូបទៅពិនិត្យរោគដល់ផ្ទះចំនួនពីរថ្ងៃម្តង រហូតដល់នាយបានធូរ ស្រាលមកវិញ ។
សុគុណឮដំណឹងនេះហើយត្រេកអរអនេក ក៏ស្ទុះរៀបខ្លួន ចេញទៅ ។ ថៃដន្យ ទទួលពិសិដ្ឋក៏មកដល់ល្មម ។ សុគុណក៏សុំខ្លួនជិះឡាន
ជាមួយពិសិដ្ឋទៅផ្ទះ ។ លោកវរៈមិនហ៊ានទំនាស់ចិត្តកូនក៏បណ្តោយអោយ
នាយចេញទៅជាមួយពិសិដ្ឋតែម្តង ។

មុននឹងឡើងរថយន្ត សុគុណស្រដីទៅពិសិដ្ឋថា :

- ពិសិដ្ឋ! ឯងសន្យាហើយថានឹងនាំខ្ញុំទៅរកចំលើយនិងអ្វីៗដែលទាក់ទង អំពីជីវិតរបស់សំនៀង... ពេលនេះ...

- ដឹងហើយណាំសំលាញ់! (ពិសិដ្ឋឆ្លើយកាត់) ព្រោះតែអញ្ចឹងហើយទើប គ្នាមកទទួលយកឯង ពីមន្ទីរពេទ្យថ្ងៃនេះនោះអី ។

ថាហើយពិសិដ្ឋក៏នាំសុគុណដើរចូលទៅក្នុងពេទ្យវិញ ដើម្បីទៅជួប បុគ្គលិកចំណាត់ការក្នុងមន្ទីរពេទ្យមួយរូប ។ បន្តិចមក
គេក៏នាំពិសិដ្ឋនិងវរិទ្ធ សុគុណមកដល់បណ្ណាល័យឯកសាររបស់ពេទ្យ ។ បុគ្គលិកនោះក៏ស្រវាទាញ
សំណៅបញ្ជីមួយក្បាលចេញមកហើយស្រដីថា :

- នេះជាសំណៅឯកសារអ្នកដែលធ្វើអំណោយក្រលៀនជូនលោកសុគុណ សូមពិនិត្យអញ្ជើញអានចុះ បើមានសំនួរអ្វី
សូមទៅជួបខ្ញុំចុះ ខ្ញុំរង់ចាំនៅ
ខាងក្រៅ ។

ថាហើយ លោកក៏ដើរចេញទៅ ។ សុគុណក៏ស្រវាទាញយកឯកសារ មកអានទាំងចិត្តកន្ទះរា ត្បិតចង់ដឹងថា
តើសប្បុរសជននោះជានរណា នឹង អាលអោយគេមានឱកាសទៅថ្លែងអំណរគុណដោយផ្ទាល់ ត្បិតនរជននោះ
បានផ្តល់នូវជីវិតថ្មីចំពោះនាយ ។ លុះនាយបើកអានទៅ ក៏មិនប្រទះអ្វីទាំង អស់
ព្រោះសប្បុរសជននោះមិនបានបំពេញឈ្មោះនិងអសយដ្ឋានទេ គ្រាន់ តែចុះហត្ថលេខាប្រគល់សិទ្ធ
ទៅអោយពេទ្យវះកាត់យកក្រលៀននោះតែ ប៉ុណ្ណោះ ។ សុគុណមិនអស់ចិត្តសោះ ក៏ចេះតែសើរើសំណៅពីរបីដងយ៉ាង វក់វី ។
ថៃដន្យ ស្រាប់តែមានកូនក្រដាសមួយសន្លឹកធ្លាក់ជ្រុះចេញមកពី ក្បាលបញ្ជីនោះ ។ សុគុណក៏ឈ្ងោករើសយកមកមើល
ក៏ប្រទះឃើញរូប គំនូរខ្មៅៗដោយដៃមួយជាគំនូរមនុស្សពីរនាក់ញញឹមយ៉ាងស្រស់ ម្នាក់ ជាបុរសសង្ហា
ម្នាក់ទៀតជានារីសោភាមួយរូបដែលមានកេសារំសាយ ។ គ្រាន់តែប្រទះឃើញរូបនោះភ្លាម សុគុណក៏ប្រែជាញ័រដៃទទ្រើកតែម្តង ។
ចំណែកឯបេះដូងរបស់នាយវិញក៏ញាប់ញ័រឱបខ្ទាក់យ៉ាងចំលែកបំផុតដែរ ។ ពិសិដ្ឋនៅអង្គុយស្ងៀមក្បែរនោះយូរហើយ
កាលបើសង្កេតឃើញ អាកប្ប កិរិយាប្រែប្រួលរបស់មិត្តដូច្នោះ គេក៏ឆក់យករូបពីដៃរបស់សុគុណយកទៅ មើល
ស្រាប់តែលាន់មាត់ថា :

- យី! រូបនេះ ដូចរូបឯងនិងសំនៀងអ្វីម្ល៉េះទេហ្ន៎?...

ឮដូច្នោះ សុគុណឈ្ងោកមុខចុះនៅស្ងៀម.. រំពេចនោះ ទឹកភ្នែកពីរ
ដំណក់ក៏ប្រជែងគ្នាហូរស្រក់ចុះមកពីកែវនេត្ររបស់បុរសយើងភ្លាម :

- សំនៀង... ការពិត សប្បុរសជននោះ គឺជារូបអូនទេតើហ៎... ហេតុអ្វីក៏

CHANBOKEO.COM

អូនមិនស្រដីប្រាប់បងអោយដឹងផង?... ហេតុអ្វីអូនហ៊ានប្រថុយដល់ថ្នាក់ ហ្នឹង? អូនដឹងទេថានេះជាការផ្សងព្រេងដ៏មានគ្រោះថ្នាក់ដល់ជីវិតបំផុត?

មាណពលួចគិតតែក្នុងចិត្តម្នាក់ឯងមិនហ៊ានស្រដីមកក្រៅទេ ត្បិតគេ កំពុងត្រូវវិប្បដិសារីជេរស្តីខ្លាំងណាស់ ។ បន្តិចមក សុគុណក៏បែរសួរពិសិដ្ឋ :

- ពិសិដ្ឋ! ហេតុអ្វីក៏ឯងមិនប្រាប់ដំណឹងនេះដល់យើងពេលសំនៀងមកកាន់ ទីនេះ? ហេតុអ្វីឯងទុកអោយយើងដេកបៀមទុក្ខនឹករូបនាងដល់ម្លឹង?

ពិសិដ្ឋឮហើយក៏ឆ្លើយវិញ :

- នោះគឺជាបំណងរបស់សំនៀងទេ... គ្នាមិនអាចឆ្លើយអ្វីជំនួសរូបនាងឱ្យ លើសពីនេះបានឡើយ ណាំសំលាញ់ ។

សុគុណស្រវាយកក្រដាស ដែលមានរូបគំនូរគូសខ្មៅកនោះឡើងយក មកមើលម្តងទៀត រួចហើយក៏ស្រដីខ្សិប១ក្នុងមាត់ថា :

- សំនៀង! ថ្វីបើអូនមិនបានបំពេញឈ្មោះអូននៅក្នុងបញ្ជីក៏ដោយ ក៏បង ដឹងច្បាស់ក្នុងចិត្តថា នេះជាស្នាដៃសំនៀងពិតប្រាកដណាស់... ព្រោះបង ធ្លាប់ឃើញ ធ្លាប់លួចស្ញើចស្នាដៃរបស់អូនជាយូរមកហើយ... សំនៀង... អោយបងសូមទោសអូនណាំ ដែលបងមានការយល់ច្រលំចំពោះអូនកន្លង មក... បងពិតជាចង់ជួបអូនណាស់ ចង់ជួបដើម្បីសុំទោសអូនហើយក៏ដើម្បី អរគុណចំពោះទឹកចិត្តដ៏ថ្លៃថ្លារបស់អូនដែរ... តើពេលណាទៅទើបបងមាន ឱកាសដូច្នេះ?...

CHANBOKEO.COM

សុគុណយកដៃផ្តិតទឹកភ្នែកដែលកំពុងរកស្រក់មកថែមទៀត រួចក៏ដក ដង្ហើមធំមួយយ៉ាងវែង ដើម្បីបន្ធូរការតានតឹងនៅក្នុងទ្រូង ។ បន្តិចមក គេ ក៏សួរទៅពិសិដ្ឋថា :

- សំលាញ់! គ្នាសូមពឹងឯងអោយជួយគ្នាតាមរកសំនៀងផងបានទេ?

- សុគុណ! យើងជាមិត្តសំលាញ់នឹងគ្នាយូរហើយ ម៉េចក៏ឯងនិយាយ ដូច្នេះ? យើងនឹងជួយឯងជានិច្ចណាំ មិនថាពេលណាទេ ។

ឮដូច្នោះសុគុណក៏ញញឹមឡើង ។ បន្តិចមក គេទាំងពីរក៏លាបុគ្គលិក ពេទ្យ ត្រលប់ទៅវិញ ។ លុះចូលមកដល់ក្នុងរថយន្តភ្លាម ពិសិដ្ឋបានហុច ឥវ៉ាន់មួយកញ្ចប់អោយទៅសុគុណព្រមទាំងវាចាថា :

- នេះជាបញ្ញើដែលសំនៀងទុកផ្ញើជូនមកសំលាញ់ឯងវិញ មុននឹងនាងចាក ចេញទៅ ។ កាលណោះ គ្នាឃើញឯងមានសុខភាពផ្លូវកាយផ្លូវចិត្តទុរន់ទុរា ពេក ទើបដំអក់មិនហ៊ានអោយទៅឯង ក្រែងធ្វើអោយឯងស្រកស្រុតទឹក ចិត្តរិតតែខ្លាំង ។ ប៉ុន្តែពេលនេះ គ្នាគិតថា ប្រហែលជាឯងរឹងប៉ឹងល្មមអាច ទទួលបណ្តាំនិងបញ្ញើរបស់សំនៀងនេះបានហើយ ។

សុគុណសំលឹងមុខពិសិដ្ឋធ្វើភាំងហើយក៏លូកដៃទទួលយកកញ្ចប់ឥវ៉ាន់ មកលាតមើលយ៉ាងរហ័ស ។ នៅក្នុងកញ្ចប់នោះ មាណពប្រទះឃើញមាន ប្រាក់ចំនួន១៩៥០ដុល្លារនិងប្រាក់ខ្មែរជាច្រើនម៉ឺនរៀលទៀតព្រមទាំងមាន កូនចំណារតូចមួយសរសេរថា :

- អោយសំនៀងសូមទោសផង ដែលត្រូវលក់ចិញ្ចៀនពេជ្រមួយនោះ ដើម្បីជាសោហ៊ុយធ្វើដំណើរមកតាមរកលោកនៅភ្នំពេញ។ ពេលនេះ ខ្ញុំក៏ បានដំណឹងហើយថាលោកសុខសប្បាយ ហើយនឹងជាសះស្បើយឆាប់ៗ។ ខ្ញុំ សូមជួយត្រេកអរលោកផងណា៎! រីឯប្រាក់ដែលនៅសល់ពីថ្លៃលក់ចិញ្ចៀន ទាំងប៉ុន្មាន ខ្ញុំសូមផ្ញើជូនលោកវិញចុះ ព្រោះឥលូវនេះខ្ញុំក៏លែងត្រូវការ ទៀតហើយ។ បើសិនជាមានឱកាស ខ្ញុំនឹងរកប្រាក់កាត់ថ្លៃសងចិញ្ចៀន របស់លោកវិញមិនខាន ព្រោះខ្ញុំបានយកវាទៅលក់ក្នុងតម្លៃថោកខុសធម្មតា។ សង្ឃឹមថាជោគជតារាសីដ៏អាប់អោនរបស់សំនៀង មិនបាននាំ ឧបទ្រពដល់ជីវិតលោកតទៅទៀតឡើយ... សូមលោករក្សាខ្លួនផងណា៎..! សំនៀង...

សុគុណអានបណ្តើរ រលីងរលោងទឹកភ្នែកបណ្តើរ រំជួលក្នុងចិត្តបណ្តើរ នឹកអាណិតសំនៀងខ្លោចចិត្តឥតឧបមា :

- សំនៀង... តើពេលនេះ អូននៅទីណា... សុខទុក្ខយ៉ាងណា? បងពិតជាស្តាយក្រោយណាស់ដែលបងបានប្រព្រឹត្តមិនគប្បីទៅលើរូបអូន... តើអូន នឹងរស់នៅយ៉ាងណាទៅ បើអូនគ្មានអ្វីនៅក្នុងដៃសូម្បីបន្តិចដូច្នេះ... ឱព្រះ ជាម្ចាស់អើយ.. សូមលោកមេត្តាតាមថែរក្សាសំនៀងផង.. សូមលោកជួយតម្រែតម្រង់ផ្លូវអោយរូបខ្ញុំបានជួបនឹងនាងឆាប់ៗនេះ កុំខាន....

បំណន់

| | |
|---|---|
| សូមអូនបានសុខណា៎អូនណា៎ | ចិត្តបងសច្ចាតាមរកអូន |
| ទោះនៅជើងមេឃឆ្ងាយដាច់សូន្យ | បងតាមរកស្ងួនមិនខ្លាចអ្វី។ |
| សូមអូនថែខ្លួនរង់ចាំបង | រៀមសូមបន់ផ្សងជួបរូបស្រី |
| មិនថាយូរឆ្នាំច្រើនខែថ្ងៃ | បងស្វែងរកថ្លៃមិនប្រែឡើយ។ |
| សូមអូនរក្សាខ្លួនអោយល្អ | រាល់ថ្ងៃបងចររកត្រាណត្រើយ |
| សង្ឃឹមតិចតួចក៏ដង្ហោយ | ស្វែងរកកែវហើយមិនរួញរា។ |
| សូមអូនអភ័យដល់បងផង | កំហុសខុសឆ្គងសូមវន្ទា |
| ទទួលកំហុសមិនតវ៉ា | អោយតែជីវ៉ានាងវិលវិញ... |

កាលបើឃើញមិត្តរបស់ខ្លួនយន់ចិត្តនៅក្នុងភាពសោកសៅ ពិសិដ្ឋក៏ប្រញិបប្រញាប់នាំរូបនាយត្រលប់ទៅគេហដ្ឋានយ៉ាងប្រញាប់រួសរាន់។

៩៩៩៩៩៩៩៩៩៩៩៩៩៩



CHANBOKEO.COM

# វគ្គទី៨
# វិប្បដិសារី

ពីរអាទិត្យកន្លងទៅ...

សុគុណបានស្រួលខ្លួនគ្រាន់បើហើយ ហើយក៏មានកំលាំងកំហែងវិញ ប្រហាក់ប្រហែលនឹងពីដើមដែរ ។ គេសប្បាយចិត្តណាស់ដែលសុខភាពដ៏ល្អ បានវិលមកវិញសាជាថ្មី ប៉ុន្តែទោះជាយ៉ាងណា ក៏នាយយើងនៅតែមិនអាចរីករាយពេញបេះដូងបានដែរដោយហេតុថាគេមិនទាន់ស្វែងរកឃើញម្ចាស់ ដួងចិត្តរបស់គេត្រលប់មកវិញនៅឡើយ ។ បីខែហើយដែលសំនៀងបាន បែកចេញពីជីវិតរបស់សុគុណទៅ បីខែប្រៀបបាក់ដូចបីសតវត្សដ៏យូរលង់ សំរាប់នាយយើង ដែលទន្ទឹងរង់ចាំការវិលត្រលប់របស់សំនៀង យ៉ាងសែន អន្ទះសា ។ ពេលនេះដារិនីបានវិលចូលខ្លួនមកក្នុងជីវិតរបស់នាយសាជាថ្មី ជាញឹកញាប់ ធ្វើឱ្យសុគុណរិតតែមានការធុញថប់ក្នុងដួងចិត្តរកថាមិនត្រូវ ។
គេក៏បានសុំលោកវរៈជាឪពុកទៅសំរាករក្សាខ្លួននៅឯចំការរបស់ពិសិដ្ឋឯវត្ត គរ បាត់ដំបងវិញ ។ ដោយមិនដឹងប្រកែកថាយ៉ាងណា លោកវរៈក៏សុខចិត្ត បណ្ដោយ ឱ្យកូនប្រុសធ្វើតាមតែចំណង់ ។

លុះគេមកដល់មណ្ឌលអនុស្សាវរីយ៍កាលណា... សុគុណមានអារម្មណ៍ ថាខ្លួនកំពុងតែលិចលង់ជំពាក់យ៉ាងជ្រៅ ទៅក្នុងគុណបំណាច់មួយដែល នាយគ្មានថ្ងៃនឹងរើបំរះរត់គេចបាន នោះគឺពលីកម្មរបស់សំនៀងដែលប្ដូរជីវិតប្រថុយអោយពេទ្យវះកាត់យកក្រលៀនរបស់នាង ទៅដាំឱ្យសុគុណ ដោយមិនទាំងដឹងថាតើនឹងជោគជ័យដែរឬយ៉ាងណា... ។ ពេលនេះ សុគុណ បានទទួលជីវិតថ្មីត្រលប់មកដល់ចំការឯវត្តគរវិញដោយសុខសប្បាយ ប៉ុន្តែ សំណាងមិនល្អម្ចាស់គុណបំណាច់បែរជា បាត់ស្រមោលទៅដោយឥត ដំណឹងអ្វីបន្តិចសោះ ។ តាក្រូចយាយប្រាងបានដឹង ដំណើររឿងពីសុគុណ ក៏នាំគ្នាយកដៃរីតដើមទ្រូងនឹកអាណិតអាសូរសំនៀង ដែលគាត់ធ្លាប់មានចិត្តស្រលាញ់ដូចជាកូនចៅសាច់ឈាមរបស់គាត់ដូច្នោះដែរ ។

ថ្ងៃខែចេះតែកន្លងទៅ...

សុគុណកាន់តែអស់សង្ឃឹមទៅៗរៀងរាល់ថ្ងៃ ព្រោះសំនៀងក៏នៅតែ បាត់ដំណឹងសូន្យដដែល ទោះបីជាពិសិដ្ឋឬបងស្រីរបស់គេព្យាយាមជួយ នាយតាមរកនាងគ្រប់ច្រកល្ហកយ៉ាងណាក៏ដោយ ។ ពេលនេះ សុខភាព

CHANBOKEO.COM

ផ្លូវកាយរបស់សុគុណបានប្រសើរឡើងមែន តែសុខភាពផ្លូវចិត្តវិញបែរជា ទ្រុឌទ្រោមទៅរៀងរាល់ថ្ងៃ មិនមានពេលស្បើយ ។ ក្តីសង្ឃឹមរបស់មាណព យើងក៏កាន់តែរលត់ពន្លឺទៅហើយ ត្បិតគេមិនដឹងជារកមធ្យោបាយយ៉ាងណាតាមរកសំនៀងអោយឃើញវិញឡើយ ។ រាល់ព្រឹក សុគុណតែងតែទៅ ថ្វាយបង្គំព្រះនៅវិហារវត្តគរ បន់ស្រន់សូមអោយសំនៀងឆាប់វិលត្រលប់ មកវិញយ៉ាងឆាប់រហ័សហើយសុខសប្បាយ ។

ដោយសារវិបត្តិដួងចិត្តរំខានជីវិតរបស់ខ្លួនពេក វិរិន្ទសុគុណក៏សំរេចចិត្តសូមអនុញ្ញាតពីឪពុកចូលផ្នួសរក្សាសីលជាសង្ឃ នៅវត្តគរបាត់ដំបង ដើម្បីលប់លាងនូវកំហុសដែលខ្លួនបានបំបាក់ទឹកចិត្តសំនៀងឱ្យធិតាខកចិត្ត យ៉ាងធំធេងចំពោះរូបនាយ រហូតដល់នាងត្រូវបោះជំហានចាកចេញទៅទាំងឈឺចាប់ក្នុងចិត្តលែងនឹកនាវិលត្រលប់មករកនាយវិញសាជាថ្មី ។ បុរស យើងសង្ឃឹមថាការសាងផ្នួសរក្សាសីលក្នុងម្លប់ព្រះធម៌ដ៏ត្រជាក់នោះ នឹង អាចជួយផ្សាផ្សះដំបៅដួងចិត្តរបស់នាយបានយ៉ាងសក្តិសិទ្ធិបំផុត ។

៦ខែកន្លងទៅ...

ភិក្ខុវិរិន្ទសុគុណកំពុងតែអង្គុយសំណាក់ធម៌សមាធិនៅក្នុងកុដិ តែមួយ ព្រះអង្គឯងស្រាប់តែព្រះអង្គបានឮសៀងមួយស្រួយស្រែសស្រែកមកពី នាយល្វើយៗហៅរកព្រះអង្គថា :

- ប៉ា! មកមើលម៉ាក់ផង! ប៉ា!....

ភិក្ខុបើកព្រះនេត្រឡើងបែរមើលជុំវិញព្រះអង្គ តែមិនប្រទះឃើញអ្វី សោះ ។ ព្រះអង្គក៏ធ្មេចសមាធិវិញដូចដើម ស្រាប់តែសំលេងនោះស្រែក ហៅសាជាថ្មី :

- ប៉ា! ឆាប់ទៅមើលម៉ាក់ផង... ម៉ាក់កំពុងត្រូវការរូបប៉ាណាំ...ឆាប់ឡើង!

ដោយក្តីពិភាល់ក្នុងចិត្តទ្រាំមិនបាន ភិក្ខុយើងក៏ស្ទុះចេញពីកុដិមកខាងក្រៅដើម្បីរកមើលម្ចាស់សំលេងសាជាថ្មី តែព្រះអង្គនៅតែមិនប្រទះអ្វីដដែល ។ លុះព្រះអង្គឈររេរាមួយស្របក់នៅខាងមុខព្រះវិហារ ស្រាប់តែប្រទះរថយន្តមួយបរចូលមក ។ ភិក្ខុសុគុណក៏លាន់ព្រះឱស្ឋឡើងថា :

- ពិសិដ្ឋ...?

ភ្លាមនោះ ពិសិដ្ឋក៏បើកទ្វាររថយន្តចុះចេញមកវន្ទាចំពោះភិក្ខុយើង ព្រមទាំងស្រដីថា :

- ថ្ងៃនេះមានភ្ញៀវពិសេសមកលេងព្រះអង្គ មិនដឹងថា ព្រះអង្គនៅចាំ លោកដែរឬក៏ទេ?

ភិក្ខុក្រលេកទៅខាងក្រោយខ្នងពិសិដ្ឋ ក៏ប្រទះឃើញបុរសចំណាស់ មួយរូបកំពុងដើរចូលមកទាំងភក្រ្តញញឹមពព្រាយ :

- លោកកូននៅចាំប៉ាបានទេ?

កាលបើក្រលេកឃើញវត្តមានរបស់លោកភ្លាម ភិក្ខុយើងក៏ឧទានម្តង ទៀតឡើងថា :

- ញោមសុខជ័យ?

CHANBOKEO.COM

មែនហើយ នោះគឺលោកសុខជ័យដែលត្រូវជាឪពុកធមិរបស់ពិសិដ្ឋនិង សុគុណ កាលពីគេនៅរៀននៅអាមេរិក។ លោកនិងភរិយាបានទទួលភារៈ ជាអ្នកអាណាព្យាបាលផ្តល់ការគ្រប់គ្រងនិងកន្លែងស្នាក់នៅដល់អ្នកទាំងពីរ រហូតដល់បានរៀនចប់បរិញ្ញាបត្រ័យ៉ាងជោគជ័យ។ កាលបើឃើញភិក្ខុ សំដែងការភ្ញាក់ផ្អើល លោកសុខជ័យក៏ញញឹមឡើង ៈ

- ពិសិដ្ឋបានប្រាប់ប៉ាថាកូនចូលផ្នួសរក្សាសីលនៅទីនេះ ទើបប៉ាមកសួរសុខទុក្ខតែម្តងទៅដោយមិនបានផ្តល់ដំណឹងជាមុន។

ភិក្ខុយើងក៏ញញឹមឡើង ហើយស្ទុះរត់មកទទួលលោកសុខជ័យយ៉ាង រាក់ទាក់សមរម្យបំផុត។ ក្រោយពីសំណេះសំណាលអស់ជាច្រើនម៉ោងជាមួយបុត្រធមិមក លោកសុខជ័យក៏ថ្វាយបង្គំលាត្រលប់ទៅសំរាកនៅចំការ របស់ពិសិដ្ឋ ដែលជាក្មួយខាងប្រពន្ធរបស់លោក និងត្រូវជាកូនធមិរបស់ លោកដែរ។

រាត្រីថ្ងៃដដែល...

ភិក្ខុវិន្ទសុគុណចូលសឹងតាមពេលវេលាដូចធម្មតា ប៉ុន្តែថ្ងៃនោះ ព្រះ អង្គហាក់ដូចចេះតែមានពិភាល់ក្នុងខ្លួនយ៉ាងចំលែក មិនអាចសឹងលក់សោះ មិនដឹងថាមកពីហេតុអ្វី។ ជាពិសេសទៅទៀត ពេលព្រះអង្គធ្មេចព្រះនេត្រ សឹង សំលេងកុមារមួយរូបចេះតែមកស្រែកដាក់ព្រះកាណ៌មិនព្រមឈប់ សោះ ចេះតែហៅព្រះអង្គអោយតើនឡើងជានិច្ច ហើយកុមារនោះស្រែក ហៅព្រះអង្គថា ប៉ាៗពេញមាត់...

នៅវេលាជិតភ្លឺប្រហែលម៉ោង៥ ភិក្ខុសុគុណក៏តើនឡើងតាមធម្មតា ស្រាប់តែព្រះអង្គឮសំលេងកុមារមករំខានស្មារតីនិងអារម្មណ៍របស់ព្រះអង្គ ទៀតហើយ ៈ

- ប៉ាអើយ!ឆាប់ទៅមើលម៉ាក់ផង... ម៉ាក់កំពុងត្រូវការលោកប៉ា... ឆាប់ ឡើង... ទៅជួយមើលថែរក្សាម៉ាក់ផង ប៉ាទ!

សំលេងនោះនៅតែស្រែករន្ថើនៗ ក្នុងព្រះកាណ៌របស់ព្រះអង្គ ចៃដន្យព្រះអង្គមិនបានប្រទះនឹងរូបកុមារណាមួយឡើយនៅក្នុងបរិវេណកុដិរបស់ព្រះអង្គ។ ទ្រាំមិនបាន ព្រះភិក្ខុក៏ស្ទុះរឹងសំដៅទៅកុដិព្រះចៅអធិការដើម្បីក្រាបបង្គំប្រគេនដំណឹងលោក។ ក្រោយពីរៀបរាប់ហេតុផលសព្វគ្រប់ដល់ព្រះគ្រូហើយ ព្រះចៅអធិការក៏មានសង្ឃដីការប្រាប់ថា ៈ

- នេះប្រហែលជាប្រផ្នូលកម្មកិលេស ដែលនៅមានសេសសល់នៅក្នុងចិត្ត របស់ភិក្ខុសុគុណហើយ។ ភិក្ខុមិនទាន់អស់កម្មអស់ពៀរជាមួយនឹងភព លោកីយ៍នៅឡើយទេ នេះប្រហែលជានរណាម្នាក់ក្នុងជីវិតរបស់ភិក្ខុកំពុងដង្ហោយហៅរកជំនួយផ្លូវចិត្តពីភិក្ខុហើយណ៎! ចូរសំរេចចិត្តទៅ ថាភិក្ខុនឹង ជ្រើសរើសផ្លូវជីវិតណាមួយ ជាសាមណេរឬក៏ជាគ្រហស្ថ។ បើសិនជាកាត់ ចិត្តពីកម្មកិលេសនោះមិនទាន់បានទេ ភិក្ខុនៅមានឱកាស វិលទៅបំពេញមុខនាទីនោះសាជាថ្មី អោយបានប្រសើរត្រឹមត្រូវមកវិញ ដើម្បីកុំឱ្យវិប្បដិសារីជេរស្តីមនសិការនិងសម្បជញ្ញៈរបស់ព្រះអង្គតទៅទៀត។

ឮព្រះចៅអធិការមានដីការដូច្នោះ ភិក្ខុសុគុណបានយកមកត្រិះរិះគិត ពិចារណាយ៉ាងយូរ ។ ប្រហែលពីរម៉ោងក្រោយមក ព្រះអង្គក៏សំរេចព្រះ ទ័យលាចាកសិក្ខាបទនៅថ្ងៃនោះតែម្តង ត្បិតយល់ឃើញថា កាលបើលោករក្សាផ្នួសដោយអារម្មណ៍ពោរពេញទៅដោយកម្មកិលេសមិនទាន់បាត់ នោះ សិក្ខាបទរបស់ព្រះអង្គនឹងមិនបានបរិសុទ្ធតាមផ្លូវព្រះពុទ្ធព្រះធម៌ដ៏ខ្ពង់ខ្ពស់ ឧត្តុង្គឧត្តមនោះឡើយ ។ ភិក្ខុមិនចង់អោយសិក្ខាបទរបស់ព្រះអង្គប្រលាក់ប្រលូសដោយស្នាមរបួសផ្លូវកិលេសលោកបន្តិចណាឡើយ ។ បន្តិចក្រោយ មក ព្រះគ្រូចៅអធិការក៏ចំរើនពរពិធីឧប្បាយ៍ជូនដំណើរភិក្ខុវិរិទ្ធសុគុណឱ្យ ត្រលប់មកជាគ្រហស្ថវិញ ដើម្បីទៅបំពេញតួនាទីដែលខ្លួនទុកសេសសល់ មិនទាន់ទទួលខុសត្រូវចប់ចុងចប់ដើមនៅឡើយ ។

នៅផ្ទះចំការរបស់ពិសិដ្ឋ...

ទាំងពិសិដ្ឋ ទាំងលោកសុខជ័យ ទាំងតាក្រូចយាយប្រាង ម្នាក់ៗសុទ្ធ តែសំដែងការភ្ញាក់ផ្អើលក្រៃលែង កាលបើយល់វត្តមានរបស់វិរិទ្ធសុគុណ នៅក្នុងសំលៀកជាគ្រហស្ថសាមញ្ញមកវិញដូច្នោះ ។ លោកសុខជ័យលាន់ មាត់មុនគេឡើងថា :

- ស្លាប់ហើយ សុគុណ! បើកូនលាផ្នួស ម៉េចមិនប្រាប់ប៉ាអោយដឹងកាលពីម្សិលនឹងអាលយើងបានចូលរួមពិធីលាចាកសិក្ខាបទរបស់កូនផង?

សុគុណឈ្ងោកមុខហើយឆ្លើយថា :

- ការដែលកូនរក្សាផ្នួសមិនបានបរិសុទ្ធទាំងកាយវាចាចិត្តនិងអារម្មណ៍ កូន មានការអាមាសខ្លួនណាស់ ម្លោះហើយក៏មិនគួរនឹងទទួលកត្តិយសធំដុំអ្វីទេ ទើបកូនមិនហ៊ានរំខានលោកប៉ានឹងពិសិដ្ឋ...

- មើលទៅកូនហាក់ដូចជាមានវិបត្តិដួងចិត្តធ្ងន់ធ្ងរណាស់ សុគុណ! កូនមាន រឿងអ្វីក្នុងជីវិតដោះស្រាយមិនចេញឬកូន?

សុគុណងើបសំលឹងមុខឪពុកធម៌ហើយក៏ឈ្ងោកមុខទៅវិញ រួចក៏នៅ ស្ងៀមមិនស្រដីអ្វីឡើយ ។ ពិសិដ្ឋឃើញដូច្នោះក៏ជំរាបសាច់រឿងត្រួសៗជូន លោកអោយបានយល់ហេតុការណ៍ ។ បន្ទាប់ពីបានដឹងច្បាស់នូវសតិវិបត្តិ របស់កូនប្រុស លោកសុខជ័យក៏មានប្រសាសន៍ថា :

- ណ្ហើយ កូនអើយ! កុំពិបាកចិត្តពេកអី ។ បើជាគូព្រេងពិតមែននោះ កូនច្បាស់ជានឹងជួបគ្នាវិញទេ...

- ប៉ុន្តែ កូនបានរង់ចាំអោយគេវិលត្រលប់មកវិញ៩ខែហើយ... គេនៅតែមិនឃើញវិលវិញដដែល ពេលនេះ កូនហាក់ដូចជាអស់សង្ឃឹមពន់ពេក ណាស់ លោកប៉ា!

- អឺ... នែ៎ គិតអញ្ចេះចុះ! បើនៅទីនេះ ល្អក់កករអារម្មណ៍ពេក កូនត្រលប់ទៅអាមេរិកជាមួយប៉ាវិញ ទៅសំរាកយកខ្យល់អាកាសមួយពេលសិនទៅ ទំរាំមានអារម្មណ៍ធូរស្រាលចាំត្រលប់មកផ្ទះកូនវិញយ៉ាងម៉េចដែរកូន?

CHANBOKEO.COM

សុគុណគ្រវីក្បាល ៖

- អត់ទេ លោកប៉ា! កូនមិនទៅណាំទាំងអស់ លុះត្រាតែកូនបានជួបនឹង គេសិន...

រំពេចនោះលោកវរៈនិងកូនស្រីរបស់លោកក៏បររថយន្តមកដល់ល្មម ៖

- យីសុខជ័យ សុខសប្បាយទេហ្នឹង? (លោកវរៈស្រែកឡើងកាលបើ ប្រទះឃើញវត្តមានលោកសុខជ័យនៅទីនោះ) ហើយចុះមកពីអាមេរិកពី អង្កាល់ ម៉េចមិនឮប្រាប់គ្នាសោះអញ្ចឹង?

លោកសុខជ័យក៏ញញឹមឡើង ៖

- ទើបតែមកដល់បានមួយអាទិត្យទេ មានកិច្ចការផ្ទាល់ខ្លួនរវល់បន្តិចទើប មិនទាន់បានចូលលេងវរៈឯង ហើយចុះឯងយ៉ាងម៉េចដែរសំលាញ់? សុខ ទុក្ខយ៉ាងណាហើយ?

- ហ៊ឺ! គ្នាមិនអីទេ.. យ៉ាប់តែកូនប្រុសគ្នាទេ ពិបាកយកភ្នែកមើលណាស់.. ហ្នក់ ដូចឯងកំពុងឃើញស្រាប់ហើយតើហ៎...

លោកសុខជ័យសំលឹងទៅវរលក្ខណ៍ដែលកំពុងអោនសំពះលោក រួច សំលឹងពិសិដ្ឋនិងសុគុណ ស្រាប់តែលោកលាន់មាត់ឡើងថា ៖

- អឺ...បានជុំគ្នាដូច្នេះល្អហើយ! ល្ងាចនេះ ខ្ញុំសូមអញ្ជើញអ្នករាល់គ្នាទៅ លេងផ្ទះរបស់ខ្ញុំ... អូហ៎មិនមែនផ្ទះខ្ញុំទេ តែជាផ្ទះសាច់ញាតិរបស់ខ្ញុំទេ ។ គេរស់នៅឯនរាងណោះហើយខ្ញុំស្នាក់នៅទីនោះតាំងពីមកដល់ម្ល៉េះ ។ ល្ងាច នេះ យើងបរិភោគអាហារជុំគ្នាអោយសប្បាយម្តង ព្រោះយើងបែកគ្នា យូរហើយ ហើយម្យ៉ាងទៀត ខ្ញុំក៏ចង់ណែនាំសមាជិកគ្រួសារយើងទាំងសង ខាងអោយស្គាល់រាប់អានគ្នាផង ជាពិសេសក្មេងៗ... ក្រែងលោដល់អស់ពីចាស់ៗយើងទៅ គេអាចនៅសល់មិត្តញាតិនឹងរាប់រកគ្នាតទៅទៀត ។

- ប្រសើរណាស់សំលាញ់ គ្នាក៏បំរុងបបួលឯងជប់លៀងជួបជុំគ្រួសារដែរ ។ កាលបើឯងគិតមុនទៅហើយ គ្នាសូមតោងកន្ទុយធ្វើជើងក្រោយចុះ ។

- អញ្ចឹង ល្ងាចនេះ យើងជួបគ្នាណាំ!

មានប្រសាសន៍ហើយ លោកសុខជ័យក៏លាអ្នកទាំងអស់ត្រលប់ទៅផ្ទះ របស់លោកវិញទាំងចិត្តសប្បាយរីករាយ ខុសតែសុគុណម្នាក់ទេដែលរក ទឹកញញឹមមិនចេញទាល់តែសោះ ។

៩៩៩៩៩៩៩៩៩៩៩៩៩៩៩៩៩

៩៩៩៩៩

៩

CHANBOKEO.COM

# វគ្គទី៩

# ជំពប់បំណន់

រសៀលថ្ងៃដដែល...

ម្នាក់ៗ ស្លៀកពាក់ត្រៀមខ្លួន បំរុងធ្វើដំណើរចេញទៅផ្ទះសាច់ញាតិ របស់លោកសុខជ័យដើម្បីទៅជួបជុំបរិភោគអាហារតាមការណាត់ ចំណែក តែសុគុណម្នាក់ដែលមិនរវីរវល់នឹងអ្វីទាំងអស់ ក្រៅតែរត់ទៅអង្គុយសំកុក នៅខ្ទមចាំចំការតែម្នាក់ឯង ដើម្បីរំលឹកនូវអនុស្សាវរីយដែលរូបនាយយើង និងសំនៀងធ្លាប់អង្គុយលេងសាសងគ្នានាគ្រាមួយកន្លងទៅ ហើយប្រកែក ដាច់អហង្ការ មិនព្រមទៅចូលរួមការណាត់បរិភោគបាយជុំគ្នាជាគ្រួសារ នោះឡើយដោយសំអាងថា មិនស្រួលខ្លួន។ ការពិត មាណពលេបបាយ មិនចូលទេ ព្រោះចិត្តរបស់គេកំពុងតែនឹកទៅដល់សំនៀង មិនដឹងថាជីវិត របស់នាងរសាត់អណ្តែតទៅដល់ណា... សុខទុក្ខយ៉ាងណាក៏គ្មាននរណាដឹង បន្តិចសោះ។

ដោយការទទូចរបស់លោកវរៈជាឪពុកខ្លាំងពេក  សុគុណក៏សុខចិត្តធ្វើ ដំណើរទៅជាមួយទាំងទឹកមុខហ្មូហ្មង។ លុះអ្នកទាំងបួនបានមកដល់មុខ គេហដ្ឋានមួយសង់ខ្ពស់ពីដី នៅមាត់កំពង់ចំលងភូមិនរា លោកវរៈក៏បាននាំ កូនប្រុសកូនស្រីព្រមទាំងពិសិដ្ឋចូលទៅជួបម្ចាស់ផ្ទះ។ ភ្លាមនោះ លោក សុខជ័យក៏នាំអ្នកស្រីចិន្តាជាភរិយាចេញមកទទួលយ៉ាងរាក់ទាក់។ កាលបើ ក្រលេកឃើញអ្នកស្រីចិន្តាភ្លាម ពិសិដ្ឋនិងសុគុណក៏ស្ទុះទៅជំរាបសួរភ្លាម :

- ជំរាបសួរម៉ាក់ (ពិសិដ្ឋនិងសុគុណពោលឡើងព្រមគ្នា)
- អឺ! ល្អហើយកូន! ម៉ាក់នឹកកូនណាស់ហើយក៏ត្រេកអរណាស់ដែរដែល កូនមកលេងម្តាយនៅពេលនេះ។

អ្នកស្រីចិន្តាយកដៃបបោសអង្អែលក្បាលកូនប្រុសទាំងពីរ ដែលកំពុង ឱនសំពះលោកដោយក្តីគោរព។ កាលបើលោកប្រទះឃើញវរលក្ខណ៏ដែល ឈរពីក្រោយអ្នកទាំងពីរ អ្នកស្រីក៏លាន់មាត់ថា :

- ហើយចុះវរលក្ខណ៏ សុខសប្បាយដែរទេកូន?

វរលក្ខណ៏លើកដៃផ្គុំគោរពយ៉ាងប្រពៃ :

CHANBOKEO.COM

- ចាំស! សុខទុក្ខធម្មតាទេអ្នកមីង!

- អឺ! បានក្មួយលក្ខណ៍ឯងមកល្អហើយត្បិតអីកូនស្រីរបស់មីងកំពុងតែត្រូវ ការមិត្តដដែកគ្នាលេងផង... ឥលូវគេនៅម្នាក់ឯងអផ្សុកណាស់...

ភ្លាមនោះ សុគុណនិងពិសិដ្ឋមើលមុខគ្នា ត្បិតពីមុន១មក អ្នកទាំងពីរ មិនដែលដឹងសោះថា អ្នកស្រីចិន្តាមានកូនស្រី។ ភ្លាមនោះ អ្នកស្រីចិន្តាក៏ ហៅអ្នកបំរើមួយរូបមកសួរ :

- ចូរនាងទៅហៅកូនស្រីខ្ញុំអោយមកជួបខ្ញុំបន្តិច..!

- ចាំស អ្នកស្រី! អ្នកនាងមិននៅទេ ឮថាឆ្លងទូកទៅវត្តស្លាកែតតាំងពីថ្ងៃ មិនទាន់មកវិញនៅឡើយទេ។

- អូហ៎ អញ្ចឹងដល់ពេលគេត្រលប់មកវិញ សូមនាងទៅប្រាប់គេផងថាឱ្យ មកជួបម៉ាក់កុំខាន។

- ចាំស!

បន្តិចមកចាស់ៗក៏ចាប់ផ្តើមសំណេះសំណាលគ្នាពីនេះពីនោះសើចក្អាក ក្អាយអឺងកង។ ប៉ុន្តែ សុគុណយើងមិនបានសប្បាយជាមួយឡើយ។ ផ្ទុយ ទៅវិញគេតប់ប្រមល់ក្នុងចិត្តណាស់ ធុញថប់រកនិយាយមិនត្រូវ។ មើលចុះ ច្រើនខែកន្លងទៅនេះ សុគុណមិនដែលញញឹមម្តងណាឡើយ ជាពិសេស តាំងពីសំនៀងបានឃ្លាតចាកពីរូបគេទៅ។ មួយស្របក់ក្រោយមក គេក៏ លួចសសៀវខ្លួនដកថយដើរចេញទៅក្រៅតែម្នាក់ឯង សំដៅមាត់កំពង់ ដែលមានចរាចរទូកដឹកអ្នកដំណើរទៅមកទៅមក។ គេនៅអង្គុយសំកុក នៅមាត់កំពង់ចំលងតែម្នាក់ឯង សំលឹងមើលទឹករលកដែលហូរទៅ រួច ហើយក៏បន់ស្រន់នៅក្នុងចិត្តថា :

- សូមអោយតេជបារមីសក្តិសិទ្ធិណែនាំផ្លូវអោយខ្ញុំបានជួបនឹងម្ចាស់ដួងចិត្ត របស់ខ្ញុំវិញឆាប់ៗនេះផង ហើយខ្ញុំនឹងថ្វាយផ្កាស្លាភ្លេងការតាមប្រពៃណី...

ទឹកគ្មានរសាយ...

| | |
|---|---|
| រលករលេញប្រជេញគ្នា | ហូតយកទ័យាពីទ្រូងទៅ |
| ប្រាប់ម្ចាស់ជីវិតស្រស់ឆ្អិនឆ្អៅ | ថាបងនឹកពៅគ្មានរសាយ។ |
| វាយោផាយផាត់កាត់បេះដូង | អណ្តែតអណ្តូងលង់ខ្វល់ខ្វាយ |
| បងនឹកមុំណាស់កែវនោមឆាយ | បន់រតនត្រ័យសូមជួបអូន។ |
| ពពកហោះគ្រឿនតឿនដួងចិត្ត | អោយនឹកវរមិត្រទ្វេផ្ទួន១ |
| ឱរាបងព្រួយក្រៀមស្រពោន | នឹកតែមាសស្ងួនទ្វេជាដប់។ |
| សុរិយាត្រចះបំភ្លឺលោក | ចិត្តបងវិយោគសោកអភព្វ |
| បន់ព្រះរមណីជួយបងឆាប់ | ជួបស្រីគូគាប់គ្រានេះផង។ |

CHANBOKEO.COM

រំពេចនោះស្រាប់តែមានទូកមួយអុំនាំអ្នកដំណើរពីត្រើយម្ខាងចូលមក ដល់ច្រាំង ។ អ្នកដំណើរក៏ដើរឡើងម្តងមួយៗតាមកាំជណ្តើរសំដៅឡើង ទៅផ្ទល់ធំ តែសុគុណមិនរវីរវល់ទេ គិតតែពីអង្គុយកេះដីមាត់ច្រាំងលុញបោះទៅក្នុងទឹកបំបាត់ក្តីតប់ប្រមល់នៅក្នុងចិត្ត ។ រំពេចនោះ ស្រាប់តែនាយ ឮសូរសំលេងស្ត្រីម្នាក់ស្រែកឧទានឡើងថា :

- អ៊ុយ!...

ឮសំលេងនោះភ្លាម សុគុណក៏ងាកមើល ឃើញស្ត្រីមួយរូបទទូរក្រមា បាំងកំដៅថ្ងៃ កំពុងដួលតគេះតគះ របូតកន្ត្រកផ្លែឈើពីដៃកំពប់ផ្លែឈើ រមូលចូលទឹកអស់ជាច្រើន ។ កុមារជំទង់ដែលជាអ្នកចំលងទូក ក៏ស្ទុះមករកជួយលើកស្ត្រីនោះឡើង ស្រាប់តែដួលទាំងពីរនាក់ទៅវិញព្រមគ្នាម្តង ទៀត ។ កាលបើឃើញដូច្នោះ នាយយើងក៏ងើបយ៉ាងរហ័សរត់មកជួយ លើកនាងឡើងអោយឈរសាជាថ្មី ។ ពេលនោះ មាណពសង្កេតឃើញថា ស្ត្រីនោះកំពុងមានផ្ទៃពោះជិតសំរាលបុត្រហើយ ។

- អរគុណ! ( ស្ត្រីនោះពោលឡើង ដោយងើបមុខសំលឹងមកសុគុណផង)

គ្រាន់តែដាក់ភ្នែកឃើញភក្រ្តរបស់នាងកាលណា សុគុណបើកភ្នែកធំៗ មូលក្រឡង់ហើយក៏ឧទានឡើងយ៉ាងរន្ធត់ក្នុងចិត្តថា :

- ពុទ្ធោ... សំនៀង? គឺជាអូនមែនតើហ៎... សំនៀង...!!

មែនហើយ នោះគឺជាសំនៀងពិតមែន ឥតក្លែងក្លាយឡើយ ។ លុះ ប្រទះនឹងវត្តមានបុរសយើង ធិតាក៏សំដែងទឹកមុខតក់ស្លុតហើយភ្ញាក់ផ្អើល ដូចគ្នាដែរ ។ ធិតាក៏ទាញក្រមាបាំងមុខហើយក៏សំរូតខ្លួនឈោងចាប់កន្ត្រកផ្លែឈើដែលកំពប់ផ្លែឈើអស់ពាក់កណ្តាលទៅដីហើយនោះ ដើរឡើងទៅ លើច្រាំងយ៉ាងរហ័ស ដោយមិនព្រមស្រដីរកសុគុណមួយម៉ាត់ណាទៀត ឡើយ ។ សុគុណឈរធ្វើភាំងមួយស្របក់ ដែលនាយឃើញសំនៀងកំពុង ពផ្ទៃ ហើយក៏ភ្ញាក់ផ្អើលក្នុងចិត្តជាខ្លាំង មិនដឹងថាត្រូវធ្វើបែបណា កាលបើ នាយមកប្រទះសំនៀងយ៉ាងចៃដន្យរបៀបនេះ ។ តែលុះឃើញនាងបោះ ជំហានចេញទៅ បេះដូងសុគុណក្លាយជារន្ធត់កាន់តែខ្លាំងឡើងៗ ស្ទើរតែ លោតធ្លាយទ្រូងមកក្រៅ ។ មែនហើយ... រូបគេពិតជាមិនអាចទ្រាំទ្រនឹង ការបាត់បង់រូបសំនៀងពីជីវិតបានឡើយ... ទោះជាយ៉ាងណាក៏គេត្រូវតែ ឃាត់រូបនាងមួយពេលសិនដែរ ដើម្បីបកស្រាយនូវអារម្មណ៍វិប្បដិសារី ទាំងឡាយដែលនាយបានលាក់ទុកក្នុងចិត្តច្រើនខែមកហើយ ។ សុគុណក៏ ស្ទុះរត់រឹងតាមពីក្រោយទៅរាំងឃាត់ដំណើរសំនៀងភ្លាម :

- សំនៀង... ឈប់សិនអូន!... បងមានរឿងត្រូវនិយាយជាមួយអូនណា់..

សំនៀងទុចង៉ក់ ឈ្ងោកមុខហើយខ្សិបតបតិចៗថា :

- តែរឿងយើងបានចប់យូរណាស់ទៅហើយ... គ្មានអ្វីត្រូវនិយាយគ្នាតទៅទៀតទេ...

CHANBOKEO.COM

- អត់ទេ... រឿងយើងមិនដែលចប់ទេ... ហើយបងក៏មិនដែលចង់អោយ រឿងយើងចប់ទៀតផង... យើងស្ថិតនៅក្នុងចំណុចចាប់ផ្តើមទេណាំអូន... សូមកុំទាន់អាលបញ្ចប់អីណាំ... បងនៅមានអ្វីៗច្រើនណាស់ក្នុងជីវិតដែលបងចង់ប្រគល់អោយអូន... ស្តាប់បងសិនបានទេ?...

សំនៀងនៅស្ងៀមមិនស្តីមិនតបអ្វីទេ គ្រាន់តែសំដែងទឹកមុខហាក់ដូច ជាកំពុងមានការឈឺចាប់នៅក្នុងខ្លួនដូច្នោះឯង។ កាលបើឃើញអាការៈ របស់នាងដូច្នោះ សុគុណគិតថា ប្រហែលជានាងកំពុងតែខ្ទក់ចិត្តចំពោះ នាយនៅឡើយ។ គេមានវាចាបន្តទៀតថា :

- សំនៀង... គឺបង.. បងចង់មកសូមទោសអូន... សូមទោសនូវអ្វីៗសព្វ យ៉ាង... សូមអូនអភ័យទោសអោយបងផង... សំនៀង... បងតាមរកអូន យូរខែហើយ... ដឹងទេថាបងត្រូវរងការលំបាកក្នុងចិត្តប៉ុណ្ណានៅពេលដែល បងបាត់រូបអូនពីរង្វង់ដៃរបស់បងទៅ...

សំនៀងឮដូច្នោះក៏ឆ្លើយខ្សិបៗតបវិញហាក់មិនចង់ឮសំលេង :

- មិនមែនតែលោកទេ ដែលចេះឈឺចាប់... សំនៀងក៏មិនដែលមានថ្ងៃណា ខ្លួនបានដែលស្វាងពីការឈឺចាប់បន្តិចឡើយ យូរខែកន្លងមកនេះ...

ភ្លាមនោះស្រាប់តែនាងយកដៃអោបពោះធ្វើមុខជូរ ហើយក៏ស្រែក ឧទានតិចៗថា :

- អ៊ូយ!....

រួចស្រាប់តែនាងទន់ខ្លួនរកកលនឹងដួលសាជាថ្មី។ សុគុណក៏ស្ទុះទៅ អោបចង្កេះនាងលើកបីត្រកងឡើងយ៉ាងរហ័ស។ ពេលនោះ សុគុណមាន អារម្មណ៍ថាទារកក្នុងផ្ទៃរបស់នាងកំពុងរើបំរះយ៉ាងខ្លាំង :

- សំនៀង! អូនយ៉ាងម៉េចហ្នឹង?....

- គឺ... ខ្ញុំឈឺពោះណាស់... អ៊ូយ...

- ប្រហែលជាអូនឈឺពោះសំរាលកូនហើយ...

សុគុណគិតអ្វីមិនឃើញទេ ក្រៅតែពីប្រឹងបីសំនៀងឡើងកាំជណ្តើរ មាត់កំពង់ សំដៅមកផ្ទះលោកសុខជ័យ។ វរលក្ខណ៍ដែលនៅឈរវេរាចាំ មើលផ្លូវប្អូនជាយូរមកហើយ លុះប្រទះឃើញសុគុណបីសំនៀងចូលមក នាងក៏ស្រែកនោឡោឡើងផ្អើលចាស់ៗរត់មកមើលគ្រប់គ្នា។ បន្តិចក្រោយ មក អ្នកស្រីចិន្តាក៏ហៅពេទ្យឆ្មបក្នុងភូមិមកដល់ ដើម្បីទទួលមើលការខុស ត្រូវសុខទុក្ខរបស់សំនៀងភ្លាម។

នៅខាងក្រៅបន្ទប់ សុគុណដើរទៅដើរមកទាំងកន្ទះរា មានចិត្តច្របូក ច្របល់រកថាមិនត្រូវ។ វរលក្ខណ៍ឃើញប្អូនប្រុសអន្ទះសាពេក ក៏ចូលទៅ លួងលោមអោយនាយអង្គុយចុះ :

- សុគុណ! បងគិតថា សំនៀងពិតជាមិនអីទេណាំអូន... អង្គុយចុះហើយ រំងាប់អារម្មណ៍កុំអន្ទះសាពេកមើល៍ អ្វីៗកំពុងតែមានដំណើរប្រសើរឡើង វិញហើយ...

- ប៉ុន្តែ... ខ្ញុំនៅមិនទាន់អស់ចិត្តទេណាំបង...

CHANBOKEO.COM

- មិនអស់ចិត្តរឿងអ្វីទៅ?

- គឺ... គេកំពុងមានកូន... មិនដឹងថា គេកំពុងមានជីវិតថ្មីជាមួយនរណា... ហើយតើខ្ញុំនេះនឹងក្លាយជាមនុស្សយ៉ាងណាចំពោះនាងទៅវិញ?...

- កុំទាន់អាលគិតអ្វីវែងឆ្ងាយដល់ម្លឹងណា៎សុគុណ! នាងកំពុងតែឆ្លងទន្លេ... យើងត្រូវតែផ្តល់កំលាំងចិត្តអោយនាងរហូតដល់នាងឆ្លងផុតការសំរាលកូន ដោយសុខសាន្ត។ ចាំដល់នាងមានសុខភាពប្រសើរហើយ ចាំយើងគិតគូរ រឿងអ្វីៗបន្តទៀត... បងគិតថា ព្រះមិនដាក់ទោសប្អូនរហូតនោះទេ។ ដរាបណាប្អូននៅថែរក្សាដួងចិត្ត អោយមានសទ្ធាល្អចំពោះស្នេហារបស់ប្អូន យ៉ាងបរិសុទ្ធប្ដូរផ្ដាច់ឥតក្លែងក្លាយមែននោះ ប្អូនប្រាកដជានឹងបានទទួល កុសលល្អជាការតបស្នងវិញមិនខានឡើយ ប្អូនជឿបងចុះ។

សុគុណញូហើយ យកដៃជ្រោងសក់ឡើង :

- ប្អូនក៏កំពុងបន់ស្រន់ដូច្នោះដែរណា៎បងលក្ខណ៍...

ពិសិដ្ឋដែលនៅក្បែរនោះយូរហើយក៏ពោលឡើងថា :

- ហើយចុះ សុគុណឯងមានដែលគិតខ្លះទេ ថាទារកតូចដែលកំពុងមាន កំណើតមកនោះជាសាច់ឈាមរបស់ឯង..?

ស្រាប់តែសុគុណភ្ញាក់ក្រញាង បើកភ្នែកធំៗ :

- ឯងចង់មានន័យថាម៉េចហ្នឹង ពិសិដ្ឋ?

- មានន័យថា ឯងមានទឹកចង់ទទួលខុសត្រូវនូវអំពើដែលឯងបានប្រព្រឹត្ត ទៅលើសំនៀងខ្លះដែរទេ?

សុគុណឈ្ងោកមុខនៅស្ងៀម។ ពិសិដ្ឋក៏ពោលបន្តថា :

- មុននឹងឯងលើកដាក់សំនៀងអោយទៅនរណា... សូមឯងនឹកទៅដល់ខ្លួន ឯងផង ថាតើឯងនឹងសំនៀងធ្លាប់មានចំណងអ្វីខ្លះចំពោះគ្នា ហើយជំរៅ ណាដែរ...? តើវាអាចទៅរួចទេ ដែលសំនៀងកំពុងពផ្ទៃទារកមួយដែលជា តំណក់ឈាមរបស់ឯងពិតៗ... ប្រយត្ន័ណា៎... គំនិតអគតិតែងនាំមកនូវ អពមង្គលសំរាប់ជីវិត.. ដូច្នេះ សូមរៀនបើកចិត្តអោយចំហហើយគិតអ្វីឱ្យ ល្អៗខ្លះទៅមើលសំលាញ់ ក្រែងលោជីវិតរបស់ឯងប្រទះនឹងពន្លឺសុភមង្គល មកវិញសាជាថ្មីម្តងទៀតណា៎... !

មែនហើយ... សុគុណមិនដែលនឹកគិតដល់រឿងនេះទេ។ សំដីរបស់ ពិសិដ្ឋប៉ុន្មានឃ្លានេះ ធ្វើអោយនាយយើងស្វាងសតិធេង ពីភាពសាំញ៉ាំក្នុង ចិត្តតែម្តង។ ភ្លាមនោះ គេក៏ញញឹមឡើងយ៉ាងបំព្រងជាលើកដំបូងដែលគេ មិនធ្លាប់ញញឹមបែបនេះយូរខែមកហើយ :

- អរគុណណាស់ពិសិដ្ឋ ចំពោះពាក្យដាស់តឿនដ៏មានតម្លៃរបស់ឯង

រួចហើយ គេក៏ស្ទុះទៅយ៉ាងលឿនសំដៅបន្ទប់របស់សំនៀង...

តុក! តុក! តុក!

អ្នកស្រីចិន្តាបើកទ្វារឡើងឧទានថា :

CHANBOKEO.COM

- មានការអ្វី សុគុណកូន?

- ខ្ញុំសូមចូលទៅខាងក្នុងមើលថៃសំនៀងបានដែរទេ ម៉ាក់?

- ហ្អាក! ខ្លួនជាប្រុស.. មកស្មគ្រ័ខ្លួនបំរើស្អីខុសវិន័យយ៉ាងហ្នឹង? នៅខាង ក្នុងមានតែពេទ្យឆ្មបនិងសាម៉ីខ្លួនគេ ហើយម៉ាក់នៅទីនេះដើម្បីជួយលើក កំលាំងចិត្តនាងតែប៉ុណ្ណោះ... ចុះកូនវិញ... មកប្រទីសប្រទើសស្អីហ្នឹង?

- ប៉ុន្តែ...នាងជាប្រពន្ធរបស់ខ្ញុំ... តើខ្ញុំអាចមានសិទ្ធចូលទៅមើលថៃនាង បានទេ បាទ?

- សុគុណនិយាយថាម៉េចហ្នឹងកូន?...

អ្នកស្រីឧទានទាំងភ្ញាក់ផ្អើល ចំហមាត់ បើកភ្នែកធំៗ ទំនងហាក់មិន ជឿពាក្យដែលសុគុណកំពុងស្រដីប្រាប់អ្នកស្រីពេលនេះ។ មាណពមិននៅ រង់ចាំអោយអ្នកស្រីឆ្លើយទាន់ទេ គេក៏ស្ទុះរឹងចូលទៅយ៉ាងរហ័សតែម្តង ទុកអោយអ្នកស្រីចិន្តាឈរធ្វើស្រលាំងកាំងតែម្នាក់ឯង។ នៅខាងក្រៅ បន្ទប់ ពិសិដ្ឋនិងវរលក្ខណ៍បែរសំលឹងមុខគ្នាទៅវិញទៅមកដោយចំលែក ចិត្តដែរ ដែលសុគុណផ្លាស់ប្តូរអាកប្បកិរិយាលឿនចាប់មិនទាន់ដូច្នោះ។

ឈានចូលដល់ក្នុងបន្ទប់កាលណា សុគុណប្រទះឃើញសំនៀងកំពុងខាំ មាត់ទ្រាំទ្រនឹងការឈឺចាប់ឡើងបែកញើសជោគខ្លួន ដោយមានពេទ្យឆ្មប វ័យកណ្តាលអាយុមួយរូបអង្គុយនៅក្បែរនោះផង។ បុរសយើងក៏ស្ទុះទៅ ជិតនាង ដាក់ខ្លួនចុះហើយស្រវាដៃនាងមកកាន់យ៉ាងណែន :

- សំនៀង! បងមកនៅក្បែរអូនហើយ... សូមអូនឆ្លងទន្លេអោយបានសុខ សាន្តណាអូនណា... ពេលនេះ បងសូមចូលខ្លួនមកដឹងឮកំណើតទារកដែល ជាកូនរបស់យើងទាំងពីរនាក់ហើយ...

ស្រាប់តែ សំនៀងបើកភ្នែកឡើងសំលឹងមកសុគុណ ទាំងចំលែកចិត្ត បំផុត។ ភ្លាមនោះ ស្រាប់តែឮសំលេងទារកយំរ៉ាឡើង....។ សុគុណយើង មានការភ្ញាក់ផ្អើលណាស់ចំពោះវត្តមានរបស់ទារកតូច រហូតដល់ទឹកភ្នែក រលីងរលោង។ ពេទ្យឆ្មបមួយរូបនោះបានរុំទារកនឹងភួយដ៏ស្អាតមួយហើយ ក៏លើកហុចទៅអោយសុគុណយ៉ាងថ្នមៗ។ មាណពត្រកងទទួលយកទាំង ដៃញ័រទទ្រើក ដោយក្តីអំណរនិងចិត្តរំភើបញ្ជាប់ញ័រក្រៃលែង។ បន្តិចមក គេក៏ស្រដីទៅរកសំនៀងថា :

- សំនៀង... មើលនែ៎... អូនប្រសូត្របានកូនប្រុសមួយរូបយ៉ាងស្រស់ស្អាត ណាស់... បងពិតជាមានមោទនភាពខ្ពង់ខ្ពស់ណាស់អូនដែលកូនរបស់យើង មានសុខភាពប្រក្រតី។ បងក៏សូមបន់ស្រន់អោយអូនឆាប់ជាសះស្បើយ ឡើងវិញដែរណា...

សំនៀងមិនមាត់មិនស្តីទេ មើលទៅនាងហាក់ដូចជាកំពុងអស់កំលាំង ល្ហិតល្ហៃណាស់។ បន្តិចក្រោយមក នាងក៏សំងំគេងលក់ទៅ ទុកអោយនាយ យើងនៅក្បែរអង្គុយរត់នេះធ្វើនោះបំរើនាងតាមការដែលនាយអាចធ្វើទៅ បាន។ កាលបើឃើញកិរិយារបស់សុគុណដូច្នោះ អ្នកស្រីចិន្តាក៏ដើរនាំពេទ្យ ឆ្មបត្រលប់ចេញទៅវិញដោយផ្តែផ្តាំទៅមាណពថា :

CHANBOKEO.COM

- សុគុណ! ម៉ាក់នៅខាងក្រៅ.. បើកូនមានការអ្វី រត់ទៅហៅម៉ាក់ចុះណា៎!

- បាទម៉ាក់!

សុគុណបីទារកតូចលើកសំលឹងមើល ហើយថៃថើបគេដោយសេចក្តី ស្រលាញ់ពេញបេះដូង មិនដឹងថាមកពីហេតុអ្វីទេដែលនាយមានអារម្មណ៍ ថាខ្លួនកំពុងមានចំណងពាក់ពន្ធ័នឹងទារកតូចនេះយ៉ាងជ្រាលជ្រៅបំផុត :

- ឱ! កូនប្រុសដ៏ស្រស់ស្អាតអើយ... ប៉ាត្រេកអរណាស់ដែលប៉ាបានមក ទាន់កំណើតរបស់កូន... សូមអោយប៉ាបានរស់នៅជួបជុំកូននឹងម៉ាក់របស់ កូនតរៀងទៅដោយសុភមង្គលផងណា៎កូនណា៎...

ពោលចប់សុគុណក៏ឈ្ងោកនាសាថើបថ្ពាសទារកថ្មម១ជាថ្មី ដោយក្តី រន្ធត់ញាប់ញ័រក្នុងបេះដូង ។ នៅលើគ្រែ សំនៀងធ្មេចភ្នែកសំងំយកកំលាំង យ៉ាងស្ងៀមស្ងាត់សុខសាន្ត ។

ពីរថ្ងៃកន្លងទៅ...

សុគុណមិនបានត្រលប់ទៅផ្ទះចំការឯវត្តគរវិញទេ ។ គេបានមកស្នាក់ នៅបំរើសំនៀង ឯផ្ទះរបស់សាច់ញាតិលោកសុខជ័យនិងអ្នកស្រីចិន្តា តាំងពី ថ្ងៃដែលសំនៀងសំរាលកូនមកម្លេះ ហើយក៏មិនដែលដើរឃ្លាតសំនៀងទៅ ណាចោលមួយជំហានឡើយ ។ គេហាក់បីដូចជានឹកខ្លាចនាងគេចខ្លួនបាត់ ទៅវិញទៀតសាជាថ្មីអញ្ចឹង ។ ទោះបីជាយ៉ាងណា សុគុណលែងនឹកខ្មាស់ នឹកខ្លាចចិត្តនរណាហើយ ។ គេបានបញ្ចេញមនោសញ្ចេតនាចំពោះក្តីស្នេហា របស់គេយ៉ាងត្រង់១ដោយឥតលាក់លៀម ធ្វើអោយចាស់ទុំទាំងអស់នឹក ស្រណោះអាណិតរូបនាយកាន់តែខ្លាំង តែលោកមិនហ៊ានមាត់កអ្វីទេ គ្រាន់ តែចង់ទុកឱកាសអោយអ្នកទាំងពីរសំរួលសាច់រឿងជីវិតជាមួយគ្នាប៉ុណ្ណោះ ចៃដន្យ ប៉ុន្មានថ្ងៃកន្លងមកនេះ គ្មាននរណាមួយបានឃើញសំនៀងស្រដីរក សុគុណយើងមួយម៉ាត់ឡើយ ថ្វីបើនាយយើងខិតខំយកចិត្តទុកដាក់ចំពោះ នាងយ៉ាងណាក៏ដោយ...

នៅព្រឹកមួយ សុគុណអស់កំលាំងពេកក៏ប្រាសខ្លួន ធ្មេចនៅលើអង្រឹង មួយដែលចងនៅក្រោមផ្ទះសំរាកមួយស្របក់ ។ លោកសុខជ័យនិងអ្នកស្រី ចិន្តាបានចេញតាមលោកវរៈទៅលេងមិត្តភក្តិឯបាត់ដំបងទៅ ។ ចំណែកឯ ពិសិដ្ឋក៏ត្រលប់ទៅភ្នំពេញវិញជាមួយវរលក្ខណ៍ ដើម្បីចូលទៅធ្វើការវិញ ។ ថ្ងៃនេះគ្មាននរណានៅផ្ទះទេ ក្រៅពីអ្នកស្រីសានីដែលជាប្អូនស្រីរបស់លោក សុខជ័យ ដែលស្ម័គ្រនៅចាំផ្ទះជួយមើលសំនៀងតែប៉ុណ្ណោះ ។

ភ្លាមនោះ សុគុណមានអារម្មណ៍ហាក់ដូចជាឮសូរជើងដើរចេញចុះពី លើផ្ទះមក ។ នាយយើងបើកភ្នែកឡើង ឃើញសំនៀងទទូរក្រមាបីទារក តូចចុះជណ្តើរមកដី ។ មាណពក៏ស្ទុះងើបហើយសួរទៅនាងថា :

- សំនៀង... អូនបំរុងចេញទៅណា៎ហ្នឹង?

រួចហើយក៏ហុចដៃសូមទទួលយកទារកតូចពីដៃនាង :

CHANBOKEO.COM

- សុខភាពអូនមិនទាន់រឹងប៉ឹងនៅឡើយទេ... ថែខ្លួនបន្តិចទៅណា៎ ។ ម៉ោះ! អោយបងជួយបីកូនវិញណា៎អូន...

ស្រាប់តែ សំនៀងគេចរឹង មិនព្រមហុចទារកអោយទៅនាយឡើយ ។

មាណពឃើញដូច្នោះភ្ញាក់ព្រើតក៏លាន់មាត់ឡើង :

- មានរឿងអ្វីហ្នឹង សំនៀង?

សំនៀងបីកូនអោបផ្អិបជាប់នឹងដើមទ្រូងរបស់នាង ហើយក៏ងើយមុខ ឡើងសម្លឹងទៅសុគុណដោយក្រសែភ្នែកយ៉ាងមុតបំផុត ។ មួយស្របក់មក នាងក៏ស្រដីតបទៅនាយវិញដោយសំដីខ្សិប១ត្រជាក់ស្រេប ហាក់ដូចជា កំពុងតែនៅបៀមកំហឹងនិងការឈឺចាប់ពេញខ្លួន :

- អ្នកដែលមានឈាមរាយមាយដូចយើងទាំងពីរនាក់ម្តាយកូននេះ... គ្មាន តម្លៃ គ្មានកត្តិយសអ្វីសក្តិសមនឹងមកទទួលចំណងសម្ពន្ធ័ពីមនុស្ស ដែល មានវណ្ណៈ មានកិត្តិយសខ្ពង់ខ្ពស់ឧត្តុង្គឧត្តមដូចរូបលោកទេ សូមបណ្តោយ អោយពួកយើងទៅរស់នៅតាមបែបឋានៈតូចទាបរបស់យើងទៅចុះ...

ធិតាស្រដីទាំងទឹកភ្នែករលីងរលោង ហើយក៏បីកូនបោះជំហានចេញ ទៅ ទុកអោយសុគុណនៅឈរភាំងស្រលាំងកាំង :

- អត់ទេ សំនៀង... អូនមិនអាចទៅណាបានទេ... (សុគុណស្រែកឃាត់)

ប៉ុន្តែសំនៀងមិនស្តាប់ទេគិតតែពីបោះជំហានចេញទៅទៀត ។ សុគុណ ក៏ស្ទុះរឹងទៅឈរពាំងផ្លូវនាងភ្លាម :

- អូនចង់ទៅណា..? អោយបងជូនទេ?... សំនៀង... ដឹងទេ ថាអូនសរសៃ ខ្ចីផង.. ថៃខ្លួនណា៎អូន.. ក្រែងលោឈឺទាស់ខូចសុខភាព...

- ជីវិតជនក្រីក្រគ្មានតម្លៃដូចសំនៀងនេះ ឈឺស្លាប់ទៅក៏ប្រសើរដែរ រស់ នៅធ្វើអ្វី នាំតែចង្អៀតផែនដីឥតប្រយោជន៍...(សំនៀងឈ្ងោកមុខស្រដី ខ្សិប១តបវិញ)

- ម៉េចក៏អូនវាចាយ៉ាងអញ្ចឹងសំនៀង...? អូនចាំទេ...នាគ្រាមួយនោះ អូន ធ្លាប់រើបំរះពីការយាយីរបស់គេដើម្បីរក្សាជីវិតខ្លួន រួចហើយនាគ្រាមួយថ្មី ទៀត បងក៏ធ្លាប់ស្រវេស្រវាសង្គ្រោះជីវិតរបស់អូនដោយដួងចិត្តសទ្ធា ថ្វី បីជាកាលនោះយើងមិនទាំងដែលស្គាល់គ្នាផង ។ ប៉ុន្តែហេតុអ្វីពេលនេះ អូន បែរជាប្រមាថជីវិតរបស់ខ្លួនឯងយ៉ាងធ្ងន់ធ្ងរទៅវិញ?...

- មែនហើយ កាលនោះ លោកបានសង្គ្រោះជីវិតរបស់សំនៀងមែន ប៉ុន្តែខ្ញុំ ក៏បានកាត់បន្ថយជីវិតរបស់ខ្លួនឯងសងជូនទៅលោកវិញហើយតើហ៎ ហើយ លោកក៏បានរស់រានមានជីវិតរស់នៅ ដូចប្រក្រតីវិញដែរ ដូច្នេះ យើងរួច បំណុលគ្នាហើយ មិនមានអ្វីជំពាក់គ្នាតទៅទៀតឡើយ...

ថាហើយ នាងក៏បោះជំហានដើរបន្តទៅទៀត ស្រាប់តែសុគុណស្រែក ឡើងពីក្រោយខ្នងរបស់នាងមកថា :

- អូនគិតខុសហើយ សំនៀង! តាមការពិតអូនបានសងជីវិតមកឱ្យបងវិញ ហើយបងក៏បានរស់រានឃើញរស្មីព្រះអាទិត្យសាជាថ្មីមែន ប៉ុន្តែ បើអូន បោះជំហានដើរចាកចេញពីរូបបងនៅពេលនេះ រូបអូនក៏នៅតែជំពាក់បង ដដែល គ្មានថ្ងៃនឹងដោះបំណុលនោះរួចវិញជាដាច់ខាត...

CHANBOKEO.COM

ឮដូច្នោះ សំនៀងទុចង៉ក់ ហើយសួរត្រលប់មកវិញដោយមិនងាក ក្រោយមើលមុខនាយយើងឡើយ :
- លោកបំរុងទារយកថ្លៃចិញ្ចៀនពេជ្រមួយវង់នោះពីសំនៀងវិញមែនទេ?
- មិនមែនទេ... អោយបងស្បថជូនអូនទៅចុះ បងមិនខ្វល់នឹងតម្លៃរបស់ ចិញ្ចៀននោះទេ ព្រោះពេលនេះ អ្វីដែលកំពុងបាត់ពីជីវិតរបស់បងទៅ វា មានតម្លៃលើសលប់លើសចិញ្ចៀននោះរាប់ម៉ឺនសែនដង  មិនអាចវាស់ថ្លឹម នឹងគ្នាបានឡើយ...
- ប៉ុន្តែ.. តើខ្ញុំមានជំពាក់អ្វីលោកទៀតដែរទៅ..? សំនៀងចាំមិនបានទេ...
- សំនៀង!.. អូនដឹងទេថា អូនបានផ្តល់ជីវិតអោយបងមែន តែអូនក៏បាន លួចយកបេះដូងរបស់បងទៅ មិនតែប៉ុណ្ណោះ អូនក៏ដកហូតយកព្រលឹង របស់បងទៅវិញជាមួយអូនដែរ... តើអោយបងរស់នៅយ៉ាងណា ខ្លឹមជីវិត របស់បងត្រូវអូនប្រមូលយកទៅវិញអស់រលីងយ៉ាងនេះ?
ឮសុគុណស្រដីយ៉ាងដូច្នោះ សំនៀងនៅឈរទ្រឹងមួយស្របក់ ទើប ឆ្លើយវិញថា :
- មនុស្សទន់ខ្សោយហើយក្រីក្រ គ្មានកិត្តិយស ដូចរូបសំនៀងនេះ តើនឹង មានសមត្ថភាពអី ទៅដកហូតព្រលឹងលោកបានទៅ?...
- ម៉េចក៏ថាមិនបាន? រូបអូនគឺជាបេះដូងរបស់បង  ហើយកូនដែលនៅក្នុង រង្វង់ដៃរបស់អូនគឺជាព្រលឹងរបស់បង... បើអូនពិតជាដាច់ចិត្តដើរចេញពី ជីវិតបងមែន បងមិនដឹងថា ជាតិនេះបងរស់ដើម្បីអ្វីតទៅទៀតឡើយ ។ តើអូនអោយជីវិតបងមកវិញធ្វើអី បើអូនកាត់យកបេះដូង ដកហូតព្រលឹង បង ទៅវិញដោយឥតស្រណោះអាល័យយ៉ាងនេះ? បងសុខចិត្តស្លាប់លា ចាកលោកទៅវិញចុះ មិនសុខចិត្តរស់នៅកណ្តោចកណ្តែងតែម្នាក់ឯង លង់ ក្នុងភពឯកាឥតន័យដូច្នេះតទៅទៀតឡើយ ។
សុគុណស្រដីអួល១នៅក្នុងបំពង់ក សំដែងការសោកសៅនៅក្នុងចិត្ត ចំពោះសំនៀង ។ នាយយើងលេបទឹកមាត់ផ្សើមបំពង់ក បំបាត់ក្តីរន្ធត់ញាប់ ញ័រនៅក្នុងចិត្តរួចហើយក៏ពោលបន្តទៀតថា :
- សំនៀង.. អោយបងសូមទោសណាំអូនណាំ ដែលបងធ្លាប់វាចាគំរោះ គំរើយថែមទាំងបញ្ចេញហឹង្សាទៅលើរូបអូន ប្រមាថទឹកចិត្តរបស់អូន ដែលមានសទ្ធាយ៉ាងបរិសុទ្ធចំពោះជីវិតរបស់បង.. គឺបងពិតជាខុសពិត មែន.. ការពិត បងមានវិប្បដិសារីធំធេងណាស់ ដែលបងបានក្លាយជា មនុស្សមានគំនិតអគតិចំពោះអូន ។ សំនៀង! សូមអូនអភ័យទោស អោយបងផងណាំ... បើកុំតែបានក្តីសប្បុរសរបស់អូន ម្លេះសមបងគ្មាន ឱកាសមកឃើញរូបអូនសាជាថ្មីនៅថ្ងៃនេះដែរ...
ឮប្រយោគនេះកាលណា សំនៀងនៅឈរទ្រឹង លែងនិយាយ លែង ស្តីតែម្តង ។ បន្តិចមក នាងឈ្ងោកមុខសំលឹងមុខទារកនៅក្នុងដៃ ទាំង បេះដូងញាប់ញ័ររំជើបរំជួលរកថាមិនត្រូវ ។ មែនហើយ! នាងបានបៀម ទុក្ខនិងក្តីឈឺចាប់នៅក្នុងដួងចិត្តអស់ជាច្រើនខែកន្លងមកហើយ... ឈឺចាប់ នឹងពាក្យប្រមាថរបស់សុគុណ ឈឺចាប់នឹងការគំហកកំហែងប្រើកំលាំង បាយទៅលើរូបនាងដែលកំពុងមានជំងឺ ប៉ុន្តែ...ហេតុអ្វីថ្ងៃនេះ គ្រាន់តែ ពាក្យសូមទោសមួយម៉ាត់របស់សុគុណ បែរជាធ្វើអោយនាងទន់ចិត្តយ៉ាង ងាយដូច្នេះទៅវិញ?
ទឹកភ្នែកពីរតំណក់បានលួចហូរចេញមកស្ងាត់១ ។ ដៃ របស់ធិតាក៏កាន់តែញ័រទទ្រើកឡើង ។ ឯហឫទ័យរបស់នាងវិញក៏កាន់តែ

CHANBOKEO.COM

ជ្រួលច្របល់ មិនដឹងថាតើនាងត្រូវសំរេចចិត្តយ៉ាងណាទេ ។ នាងពិចារណា មិនអស់មិនហើយថា តើសុគុណគេនិយាយពិតឬក៏គ្រាន់តែនិយាយ ដើម្បី លួងលោមនាងមួយគ្រាតែប៉ុណ្ណោះ ។ កាលបើឃើញសំនៀងនៅឈរស្ងៀមលែងស្រដីតប សុគុណក៏ពោលបន្តទៅទៀតថា :

- ឬក៏អូននៅមិនទាន់ជឿចិត្តបងថា បងពិតជាមានវិប្បដិសារីពិតមែន? អូនអោយបងលុតជង្គង់សូមទោសក៏បានដែរ បងអាចធ្វើបាន ត្បិតអូនគឺជា អ្នកមានគុណដែលផ្តល់ជីវិតថ្មីមកអោយបង... បងសូមលន់តួទទួលកំហុសឆ្គាំឆ្គងពីអតិតកាលទាំងអស់... សូមអោយតែអូនរំសាយចិត្តខឹង រំសាយ ចិត្តស្អប់ចំពោះបងទៅ! បងអាចធ្វើអ្វីសព្វយ៉ាងបាន ដើម្បីអូននិងកូនតូច របស់យើង... អភ័យទោសអោយបងផងណា៎...សំនៀងអូន! បងស្រឡាញ់ អូនណាស់... ស្រឡាញ់ជានិច្ច... ស្រឡាញ់គ្មានថ្ងៃផ្លាស់ប្តូរចិត្តវិញឡើយ! អភ័យទោសអោយបងណា៎អូនណា៎!!...

មិនទាន់ស្រដីចប់ផង សុគុណសំរុតខ្លួនចុះ លុតជង្គង់ទៅលើដីទាំង ទឹក ភ្នែករលីងរលោង ។ ពេលនោះ សំនៀងកាន់តែភ្ញាក់ផ្អើលខ្លាំងឡើងមែន ទែនហើយ ។ មាណវីយើងក៏ងាកបែរក្រោយមើលទៅសុគុណ ឃើញនាយកំពុងលុតជង្គង់ឈ្ងោកមុខ ហាក់កំពុងរង់ចាំការអភ័យទោសពីនាងពិតមែន នាងក៏ស្ទុះរឹងត្រលប់ក្រោយយ៉ាងរហ័សទាំងដួងចិត្តរន្ធត់ញាប់ញ័របំផុត រួច ស្រវាចាប់នាយឱ្យងើបឈរឡើងវិញ ទើបស្រដីខ្សិប១ទៅនាយថា :

- លោក!..មិនចាំបាច់ធ្វើដល់ថ្នាក់ហ្នឹងទេ... ខូចកិត្តិយសបុរសអស់ហើយ...ឆាប់ងើបឈរឡើងមក... កុំធ្វើអញ្ចឹងអីណា៎ ខ្មាស់គេជិតខាង...

តែសុគុណមិនព្រមក្រោកឈរទេ ថែមទាំងឆ្លើយទៅនាងវិញថា :

- បងមិនខ្មាសនរណាទេ... បងធ្វើដូច្នោះ ដើម្បីទាមទារការជួបជុំជាមួយ ប្រពន្ធកូន និងទាមទារសុភមង្គលក្នុងគ្រួសារអោយវិលត្រលប់មកជីវិត របស់ខ្លួនវិញ តើមានអីគួរអោយអាមាសទៅ? ហើយបងក៏មិនងើបឈរ ឡើងវិញដែរ កាលបើអូនមិនព្រមអភ័យទោសអោយបង...

សំនៀងសំលឹងមុខកូនដែលកំពុងគេងលក់ក្នុងរង្វង់ដៃរបស់នាងហើយ ក៏បែរទៅសុគុណរួចបន្លឺវាចាសួរថា :

- ចុះបើសិនជាទារកនេះ មិនមែនជាសាច់ឈាមរបស់លោក... តើលោក គិតយ៉ាងណាទៅវិញ?

សុគុណងើបមុខឡើង សំលឹងទៅសំនៀងវិញដោយក្រសែភ្នែកដែល ប្រកបដោយសេចក្តីស្រលាញ់ចំពោះនាងយ៉ាងជ្រាលជ្រៅមួយស្របក់ ទើប គេឆ្លើយតបទៅនាងដោយវាចាយ៉ាងស្រទន់ថា :

- បងមិនគិតទេ ថាទារកនេះជាសាច់ឈាមរបស់បង ឬក៏មិនមែន... តែគេ ក៏សាច់ឈាមរបស់អូន ហើយកន្លងមក អូនក៏បានបូជាជីវិតរបស់អូនដើម្បី បងដោយឥតលក្ខណ្ឌ... ដូច្នេះ បងក៏មិនខ្លាចនឹងផ្តល់សេចក្តីសុខឱ្យទារក តូចដែលជាសាច់ឈាមរបស់អូនដែរ ។ មើលចុះ! គេគួរអោយអាណិត ណាស់...

CHANBOKEO.COM

ឮដូច្នោះ សំនៀងនៅឈរទ្រឹងមួយស្របក់រកនឹកនិយាយតទៅទៀត ក៏លែងរួច ។ រីឯបេះដូងវិញក៏កក្រើកញាប់ញ័រគគ្រឹកដូចភ្លៀងផ្គរពេញដើម ទ្រូងរបស់នាង ។ នាងឈ្ងោកមុខសម្លឹងទារកក្រហមខ្ចីនៅក្នុងដៃ ក្នុងចិត្តក៏ នៅអាល័យសុគុណមិនអស់មិនហើយ ។ មែនហើយ! ថ្ងៃមុននាងនឹកខឹង នឹងគេខ្លាំងណាស់ នឹកថាមួយជីវិតនេះ មិនបាច់ជួបមុខគ្នាទៀតក៏បាន ។ នាងបានគេងយំខឹង ស្អប់ ហើយខកចិត្តចំពោះរូបមាណពដល់កំរិតហើយ ប៉ុន្តែពេលនេះ បេះដូងរបស់នាងប្រែជាទន់ជ្រាយអស់រលីង ។ ចិត្តដែលខឹង ស្អប់ទាំងអំបាលម៉ានបានរលាយខ្សុរ ចេញពីបេះដូងរបស់នាងអស់រលីងតែ ម្តង ។ បន្តិចមក ធិតាយើងក៏លើកកូនត្រកងហុចទៅអោយសុគុណ ថែមទាំងស្រដីខ្សិបៗទៅកាន់នាយថា :

- ពេលនេះ សំនៀងបីកូនចុកដៃហើយ សូមលោកក្រោកឈរឡើងជួយ បីគេម្តងបានដែរទេ?

សុគុណភ្ញាក់ក្រញាងកាលបើឮសំនៀងស្រដីដូច្នោះ ។ គេញញឹមឡើង ហើយងើបឈរយ៉ាងរហ័ស រួចលូកដៃស្រវាទទួលទារកមកបីក្នុងដៃភ្លាម ។ បន្ទាប់មក គេក៏លូកដៃម្ខាងទៀតស្រវាអោបខ្លួនសំនៀងផ្ទាប់នឹងដើមទ្រូង របស់នាយយ៉ាងណែនបំផុត ថែមទាំងវាចាទាំងរំភើបអួលអាក់ថា :

- អរគុណណាស់ អរគុណដែលអូនអភ័យទោសអោយបង...

មាណពស្រដីទាំងដួងចិត្តរន្ធត់ញាប់ញ័រ រហូតរលីងរលោងទឹកភ្នែកសាជាថ្មី ។ ពេលនោះ បុរសយើងនឹករកស្រដីតទៅទៀតលែងចេញហើយ ។ គេរំភើបចិត្តឥតឧបមា រកវាចានឹងថ្លែងអោយសមស្មើមិនបានឡើយ ។ ជា ច្រើនខែមកហើយដែលគេរង់ចាំ... រង់ចាំពេលវេលាដែលប្រកបដោយ សុភមង្គលដូចថ្ងៃនេះវេលានេះ កាលបើឱកាសនេះបានមកដល់ចំពោះមុខ ដូច្នេះ សុគុណក្លាយទៅរំភើបរហូតគ្មានវាចានឹងថ្លែង...

CHANBOKEO.COM

អរគុណ

អរគុណពាលពៅដែលវិលវៃ ជួបបងជាថ្មីដូចបំណន់
អរគុណម្ចាស់ស្នេហ៏ស្រស់តូចតន់ បងសូមអរគុណណាំពិសី ។
អរគុណដែលអូនលើកទោសបង កំហុសខុសឆ្គងយ៉ាងអប្រិយ
អរគុណដែលអូនស្មគ្រ័អភ័យ ផ្តល់ឱកាសថ្មីដល់រៀមបង ។
អរគុណដល់ព្រះពុទ្ធអង្គម្ចាស់ លោកឈ្វេងយល់ណាស់ជួយតម្រង់
អោយបងបានជួបស្រស់នួនល្អង ព្រមទាំងកូនផងមិនឃ្លាតឃ្លា ។
អរគុណអ្នកមានគុណទាំងឡាយ ញាតិមិត្តជិតឆ្ងាយរួមដៃគ្នា
ជួយបងជួបអូនសាងគ្រួសារ មង្គលសុខាតរៀងទៅ ។

រីឯមាណវីយើង ក៏ហាក់ដូចជាព្រមទទួលស្គាល់សុគុណវិញ ដោយមិន មានពួតវ៉ាអ្វីតទៅទៀតជាមួយនាយយើងទៀតដែរ ។ នាងងើបសម្លឹងកែវ ភ្នែករបស់សុគុណ ដែលកំពុងថ្លែងចចារនូវអារម្មណ៏សម្ងាត់ក្នុងជំរៅដួងចិត្ត របស់គេប្រាប់មកមាណវី ពេលនេះ

ធិតាយើងមានអារម្មណ៍ថា នាងកំពុង តែទទួលនូវភាពកក់ក្តៅមួយក្នុងចិត្តយ៉ាងជ្រាលជ្រៅធំធេង មិនអាចនឹង បរិយាយបាន។ ថ្វីបើថ្ងៃមុន នាងពិតជាមានអារិចិត្តនឹងគេពិតមែនតែពេល នេះ នាងប្រែចិត្តហើយ! វត្តមាននិងឥរិយាបថដែលគេកំពុងសម្តែងចំពោះ នាងនិងកូន គឺជារស្មីសុភមង្គលថ្មីមួយដែលនាងតែងគេងផ្សងចង់បានជា យូរមកហើយ។ ធិតាមិនដាច់ចិត្តនឹងប្រកែកតទៅទៀតទេ សុខចិត្តតែឈរ ស្ងាត់ស្ងៀមទទួលយកនូវសុភមង្គលនោះលាក់ទុកក្នុងចិត្តយ៉ាងអាថិកំបាំង វិញដែ។ អ្នកទាំងពីរនៅឈរហាលកំដៅព្រះអាទិត្យ សំលឹងមុខគ្នាទៅមក យ៉ាងភ្លេចស្មារតីអស់រយៈពេលដ៏យូរ រហូតទាល់តែមានសំលេងមួយមក ស្រដីឃាត់អ្នកទាំងពីរឡើងថា :

- យីអើ! កូនសំលាញ់អើយ! ហេតុអីបានជានាំគ្នាមកបីកូនឈរហាលថ្ងៃ បែបនេះឥចឹងកូន?

សុគុណនិងសំនៀងភ្ញាក់ក្រញាងបែរមើលម្ចាស់សំលេង ស្រាប់តែ ប្រទះឃើញអ្នកស្រីចិន្តា លោកសុខជ័យ និងលោកវរៈចុះពីរថយន្តដើរចូល មកដល់ក្បែររូបគេទាំងពីរតាំងពីអង្កាល់ណាមិនដឹង។ សំនៀងឈ្ងោកមុខ លូកដៃស្រវាកូនពីសុគុណហើយឆ្លើយថា :

- កូនសូមទោស ប៉ាម៉ាក់! កូនចូលទៅក្នុងផ្ទះវិញហើយ!

ថាហើយនាងក៏ប្រញាប់ដើរយ៉ាងលឿន បីកូនឡើងជណ្តើរផ្ទះបាត់ទៅ ទុកអោយសុគុណយើងនៅឈរភាំងមើលតាមពីក្រោយទាំងភ្ញាក់ផ្អើលក្នុង ចិត្ត ហើយនឹកគិតតែម្នាក់ឯងថា :

- សំនៀង! អូនហៅពីណាថា ប៉ាម៉ាក់...? លោកសុខជ័យអ្នកស្រីចិន្តាមែន ទេ? អូនជាកូនរបស់លោកទាំងពីរឬអ្វី? ហេតុដូចម្តេចក៏ក្លាយជាដូច្នោះ ទៅវិញឥចឹង?

ឃើញដូច្នោះ លោកសុខជ័យក៏ដើរមកជិត ហើយទះស្មាកូនធម៌របស់ លោក រួចមានប្រសាសន៍ថា :

- ឆ្ងល់អីមែនទេ? បើឆ្ងល់ សួរប៉ាមក ចាំជួយរកចំលើយបំបាត់ចម្ងល់របស់ កូនណាំ កូនសំលាញ់!

សុគុណនៅតែធ្វើមុខភាំងដដែល ត្បិតមិនដឹងថានឹងត្រូវសួរត្រង់ណា មុន ហើយនឹងសួរដូចម្តេចទៀតផង។ អ្នកស្រីចិន្តាក៏ញញឹមឡើងរួចមាន ប្រសាសន៍បន្ថែមថា :

- ម៉ោះ! ចូលផ្ទះសិនកូន! ចាំទំនេរបន្តិច ប៉ាម៉ាក់នឹងនិយាយរឿងខ្លះៗឱ្យ កូនស្តាប់ណាំ។

ថាហើយអ្នកស្រីក៏នាំមុខលោកសុខជ័យ សុគុណ និងលោកវរៈគេចពី កំដៅថ្ងៃ ចូលផ្ទះរកកន្លែងសមគួរសំរាកសំរួលកាយភ្លាមដែរ។

នៅក្នុងបន្ទប់...

CHANBOKEO.COM

សំនៀងអង្គុយបំពេកូនក្បែរមាត់បង្អួចយ៉ាងស្ងាត់ស្ងៀម តែពេលនេះ
នាងហាក់មានអារម្មណ៍ដូចជាត្រជាក់ក្នុងចិត្តជាងមុនបន្តិច មិនសូវជាចង ចិញ្ចើមក្រញូវដូចពេលមុនទៀតឡើយ ។
នាងបំពេកូនបណ្តើរ សំលឹងមុខ កូនបណ្តើរ នឹកទៅដល់អតិតកាលដ៏ជូរចត់របស់នាងដែលគួរអោយសង្វេគ បំផុត ។ ភ្លាមនោះ
សុគុណក៏ដើរចូលមកដល់ ដាក់ខ្លួនក្បែរនាង សួរថា :

- សំនៀង! បងមានអ្វីល្អៗខ្លះៗសំរាប់ចងដៃអូននិងកូន តើអូនព្រមទទួល យកពីបងទេ?

ឮប្រយោគនេះភ្លាម សំនៀងងើបមុខឡើងឆ្លើយថា :

- សំនៀងមិនត្រូវការអ្វីទេ ក្រៅពីចិត្តស្រលាញ់យ៉ាងស្មោះស្ម័គ្ររបស់បង តែម្យ៉ាងប៉ុណ្ណោះ...

- បងដឹងហើយ ថាអូនមិនទាមទារអ្វីច្រើនពីបងទេ.. តែបងពិតជាចង់ឱ្យ អូនមែន
ហើយក៏ជារបស់តែមួយគត់ដែលបងប្រគល់ចំពោះនារីតែម្នាក់ ក្នុងមួយជីវិតបងនេះ ។

សំដីនេះធ្វើអោយសំនៀងនឹកឆ្ងល់ណាស់ តែនាយយើងមិនអោយនាង សួរបន្តទៀតទេ ។ គេក៏និយាយថែមទៀតថា :

- ស្អែកនេះ បងនឹងនាំអូនទៅទទួលវត្ថុដ៏មានតម្លៃនោះហើយ អូនទៅជា
មួយបងណា៎...

- មានល្បិចអ្វីលេងនឹងសំនៀងទេដឹង? (សំនៀងសួរទាំងនឹកឆ្ងល់)

- មិនមានទេ... អ្វីៗ គឺកើតឡើងតែពីដួងចិត្តស្នេហាដ៏បរិសុទ្ធរបស់បង ចំពោះអូនតែប៉ុណ្ណោះ គ្មានក្នុងគ្មានក្រៅទេ ។ ពេលនេះ
យើងទាំងពីរក្លាយ ជាមនុស្សរួមដំណើរជីវិតជាមួយគ្នាហើយ តើអូននៅសង្ស័យអ្វីទៀត?

សំនៀងក៏ញញឹមឡើងយ៉ាងបំព្រង :

- បើពិតដូចសំដីរបស់បងមែន សំនៀងឈប់សង្ស័យហើយ ។

ភ្លាមនោះ សុគុណឈ្ងោកនាសាថើបថ្ពាល់កូនដែលកំពុងគេងលក់នៅ ក្នុងរង្វង់ដៃសំនៀង រួចហើយក៏បែរមករកធិតាយើងវិញ
សួរថា :

- អូនសំលាញ់! កាលដែលអូនបែកឃ្លាតពីបងទៅ... មិនដឹងជីវិតរបស់អូន ជួបទុក្ខលំបាកយ៉ាងណាខ្លះទេ
ឱ្យបងសូមទោសអូនផងដែលបងគ្មានស្មារតី
ទទួលខុសត្រូវចំពោះសុខទុក្ខរបស់អូន នាគ្រានោះ...

- តើអោយសំនៀងមានសេចក្តីសុខយ៉ាងណាទៅ.. បើ...

ស្រាប់តែមាណវីទុចង៉ក់វាចាលែងចេញតទៅទៀតហើយប្រែជារលីង រលោងទឹកភ្នែកជំនួសវិញ ។
បុរសហើយឃើញហើយក៏ស្ទុះយកដៃផ្តិតទឹក ភ្នែករបស់នាងយ៉ាងរហ័សមិនអោយស្រក់លើផ្ទៃមុខទាន់ទេ រួចក៏បន្លឺវាចា
យ៉ាងស្រទន់ទៅកាន់នាងថា :

- សូមអនុញ្ញាត្តអោយបងសូមទទួលដឹងនូវការឈឺចាប់របស់អូនផងណា៎..
គ្រាន់ជាគ្រឿងជួយរំលឹកដាស់ស្មារតីបងថាកុំអោយភ្លេចខ្លួនតទៅទៀត...

CHANBOKEO.COM

សំនៀងផ្តេកកេសាលើស្មាសុគុណសំដែងនូវភាពច្របូកច្របល់ក្នុងចិត្ត
មួយស្របក់មក ក៏ពោលថា :

- បើសំនៀងនិយាយជំរាបបង.. តើបងជឿសំដីរបស់អូនទេ?
- បងជឿ ជឿគ្រប់ម៉ាត់ទាំងអស់ដែលអូននិយាយប្រាប់... បងរង់ចាំស្តាប់ អូនហើយ.. អូននិយាយមកចុះ!

oooooooooooooooooo

CHANBOKEO .COM

# វគ្គទី១០

# ចកអណ្តែតទឹក

សំនៀងបានយកលក់ចិញ្ចៀនពេជ្រទៅលក់នៅផ្សារណាត់ បាត់ដំបង បានប្រាក់ពីរពាន់ដុល្លារ ។ លុះនាងដើរចេញពីហាងមាសមកភ្លាម ស្រាប់តែ មានបុរសពីរនាក់ជិះម៉ូតូប្រឆាបនាង ប្រផិតប្រផើយសក់ក្បាល ស្រវាឆក់យកសំពៀតពីលើស្មារបស់នាងទៅយ៉ាងរហ័ស បណ្តាលអោយរូបនាងដួល ច្រងាប់ច្រងិលតែម្នាក់ឯង ។ ថៃជន្ស ទេវតាមិនជួយ ពេលនោះមានគេរុញ រទេះដឹកបន្លែចេញមកពីម្ខាងរាំងផ្លូវម៉ូតូ ធ្វើអោយចោរពីរនាក់នោះភ្ញាក់ស្រលាំងកាំងកាច់ចង្កូតមិនទាន់ក៏ជ្រុលទៅបុករទេះនោះហើយក៏ត្រូវហោះផ្លោងខ្លួនចេញពីម៉ូតូទាំងពីរនាក់ដួលទៅលើថ្នល់ច្រងាប់ច្រងិល រហូតរបូត សំពៀតចេញពីដៃ ។ មានសប្បុរសជនម្នាក់បានឃើញហេតុការណ៍នៅទី នោះ ក៏ស្ទុះទៅរើសសំពៀតហុចអោយសំនៀងវិញរួចក៏ស្រដីថា :

- នាងអើយ... នេះសំពៀតរបស់ក្មួយ យកវិញទៅ ហើយត្រលប់ទៅផ្ទះវិញដោយសុខសប្បាយចុះ ។ មនុស្សសម័យឥលូវ អនាធិបតេយ្យណាស់! គេមិនសូវចង់រកស៊ីផ្លូវសុចរិតទេ..  ថ្ងៃក្រោយ ចូលផ្សារចូរនាងប្រយត្ន័ខ្លួន បន្តិចណា៎... ក្រែងមនុស្សពាលវាតាមសងសឹក ។

សំនៀងលើកដៃសំពះអរគុណលោកហើយក៏លូកដៃទទួលសំពៀតមក វិញ ក្នុងឱកាសដែលមនុស្សម្នានៅក្នុងទីផ្សាររត់ចោមវាយចោរក្បាលខូច ពីររូបនេះ ថែមទាំងមានអ្នកស្រុកខ្លះស្រដីថា :

- វាយវាទៅ! វាយទៅ! ប្រដៅពួកវាដោយដៃរបស់យើង កុំចាប់វាអោយ ប៉ូលីសអី... ប៉ូលីសសព្វថ្ងៃស៊ីសំណូកចោរ ចាប់ដាក់គុកតែអ្នកក្រ និងអ្នក ស្លូតត្រង់ទេ ។ បើចាប់ចោរបានអោយប៉ូលីស គឺដូចជាទុកផ្លូវអោយវាវិលត្រលប់មកធ្វើបាបពួកយើងសាជាថ្មីអញ្ចឹង... ដាក់ទៅ! ដាក់អោយងាប់ តែម្តងទៅ! កុំថ្នមដៃអោយសោះ ។

ពេលនោះ សំនៀងមិនបានដឹងថា តើចោរទាំងពីររូបនោះត្រូវអ្នក ស្រុកវាយដាក់ទោសប៉ុនណាទេ ត្បិតនាងបានរត់មកដល់ចំណតរថយន្ត ក្រុងនៅផ្សារណាត់ទៅហើយ ។

នៅលើរថយន្តក្រុងដែលមានអ្នកដំណើរណែនណាន់ខ្ពាន់ខ្ពាប់ សំនៀង អង្គុយស្ងៀមស្ងាត់តែម្នាក់ឯង ។ នៅក្នុងចិត្ត នាងមានការខ្វល់ខ្វាយហើយ នឹកធុញថប់កន្ទុះរាយ៉ាងណាមិនដឹង ណាមួយមិនស្គាល់ក្រុងភ្នំពេញ ណា មួយទៀត នាងមិនដឹង

CHANBOKEO.COM

ថាអាចទាក់ទងរកពិសិដ្ឋនៅភ្នំពេញឃើញឬក៏យ៉ាង ណាទេវិញ ណាមួយនាងបារម្ភអំពីសុខទុក្ខសុគុណស្ទើរតែប្រេះទ្រូងស្លាប់ម្ដងៗទៅហើយ ។ ថ្វីបើនាងអង្គុយនៅខាងមុខក្បែរតៃកុងឡានជិតម៉ាស៊ីន ត្រជាក់ហើយថែមទាំងមានទូរទស្សន៍ចាក់ផ្សាយកុនខ្មែរអោយអ្នកដំណើរ ទស្សនាយ៉ាងហូរហែក៏ដោយ ក៏សំនៀងមិនបានចាប់ភ្លឹកឡើយថាកុននោះ ល្អមើលឬយ៉ាងណា ម៉ាស៊ីនត្រជាក់នោះដើរដែរទេ ឬក៏សូម្បីតែមានអ្នកដំណើរឡើងចុះៗនៅគ្រប់ដំណាក់តាមផ្លូវរហូតមក ក៏នាងមិនបានចាប់ភ្លឹក ឡើយ ក្រៅតែពីអង្គុយបែបទន់អោយរថយន្តឆាប់ទៅដល់ភ្នំពេញតែម្យ៉ាង ប៉ុណ្ណោះ ។

ច្រើនម៉ោងក្រោយមករថយន្តបានដឹកអ្នកដំណើរចូលមកដល់ដីទីក្រុង ភ្នំពេញ ។ សំនៀងចុះពីរថយន្តក្រុងភ្លាម ក៏បែរមើលជុំវិញខ្លួនទាំងក្ដីភ្ញាក់ ផ្អើល ត្បិតនាងមិនដែលដឹងសោះថានៅភ្នំពេញមានមនុស្សកុះករធ្វើដំណើរ រចល់ទៅមក ថ្ងៃបុណ្យក៏ដូចថ្ងៃមិនមានបុណ្យ ថ្ងៃណាក៏មនុស្សណែនណាន់ តាន់តាប់ជាទំលាប់ធម្មតារបស់ទីក្រុងនេះទៅហើយ ។ ដោយទើបប្រទះនឹង ចោរឆក់សំពៀតថ្មីៗនៅផ្សារណាត់បាត់ដំបង មិនទាន់បាត់ភ័យនៅឡើយ សំនៀងហាក់ដូចជាមានការប្រយ័ត្នខ្លួនជាងមុនបន្តិច ។ នាងដើរទៅដើរ មកពេញទីក្រុងមិនដឹងថាចង់ទៅណាទេ ។ ទីបំផុតមាណវីក៏បានមកដល់ តូបទូរសព្ទ័មួយ ។ នាងក៏សាកល្បងទូរសព្ទ៍ទៅពិសិដ្ឋជាច្រើនសា តែមិន បានជោគជ័យទាល់តែសោះ ។ ថៃដន្យ នាងក៏គ្មានលេខទូរសព្ទ័របស់ វីរលក្ខណ៍បងស្រីរបស់សុគុណដែរ ធិតាយើងក៏បាក់កំលាំងចិត្តរលីងអស់ ពីខ្លួនតែម្ដង ។

រសៀលថ្ងៃលិចទៅហើយ...

ពេលនេះ នារីទុគតយើងមិនដឹងថា ចង់ធ្វើដំណើរទៅខាងណា សំរាកនៅឯណាទេ បើនាងគ្មានស្គាល់នរណាម្នាក់នៅភ្នំពេញមួយគ្រាប់សោះ ។ លុះដើរទៅដើរមកវង្វេងពេញទីក្រុង មាណវីក៏នឹកភ្នកទៅដល់មេរៀនភូមិ សាស្ត្រដែលនាងធ្លាប់រៀនស្ដីពីក្រុងភ្នំពេញ ស្រាប់តែនឹកឃើញដល់ព្រះរាជវាំងដែលនៅមាត់ទន្លេបែរមុខទៅខាងកើត ។ សំនៀងក៏ដើររឹងសំដៅទិស ខាងកើត ។ មិនយូរប៉ុន្មាន នាងក៏បានមកដល់មុខបរមរាជវាំងពិតមែន ។ ពេលនោះយប់ងងិតបន្តិចហើយ ។ នៅទីនោះ នាងប្រទះឃើញមនុស្សធ្វើដំណើរទៅមក មានអ្នកលក់ចំណើរកេតរកូត មានអ្នកសូមទាន ចាស់ក៏មាន ក្មេងក៏មាន ដើរទៅដើរមក ខ្លះដេករុំមុងក្រោមគល់ឈើ ខ្លះដេកលើស៊ីក្លូ លក់ចំហមាត់ទំនងដូចជាប្រឹងរកស៊ីពីថ្ងៃអស់កំលាំងពន់ពេក ។ មកដល់មុខព្រះអង្គដង្កើដែលមានទិដ្ឋភាពស្ងាត់ជ្រងំហើយទ្រង់ងងិតបន្តិច ធិតាយើង ឃើញក្មេងៗស្មូមទាន កំពុងលាស្លឹកឈូកចាប់បាយចែកគ្នាឆីរញ៉ីមើលទៅ គួរអោយអណោចអធម្មណាស់ ។ នាងមិនយល់ទេថាហេតុអ្វីទីក្រុងភ្នំពេញ ដែលនាងធ្លាប់ល្បីថាស្រស់សង្ហាហើយទំនើបស៊ីវិល័យ សំបូណ៌ទៅដោយ អភិជន បញ្ញវ័ន និងអ្នកខ្ពង់ខ្ពស់ តែថៃដន្យទីក្រុងដែលនាងឃើញ បែរ ជាពោរពេញទៅដោយអ្នកស្មូមទាន ដេករកេតរកូតរណ្ដូករណែលតាមដងផ្លូវយ៉ាងនេះទៅវិញ?

បន្តិចមក នាងក៏លុតជង្គង់នៅចំពោះមុខព្រះអង្គដង្កើ លើកដៃផ្គុំ ប្រណម្យបែបទន់ថា :

- សូមបារមីសក្ដិសិទ្ធិនៃព្រះអង្គដង្កើជួយបំបែរនាំផ្លូវនាងខ្ញុំម្ចាស់ឱ្យបានទៅ ជួបនឹងបងសុគុណឆាប់ៗនេះផង!

CHANBOKEO.COM

រាត្រីនោះ សំនៀងមិនដឹងថា ខ្លួននាងនឹងទៅសំរាកឯណាឡើយ ។ លុះ ដើរមកដល់កាច់ជ្រុងវិថីមួយ នាងក៏ប្រទះយាយចាស់យាចកពីររូបកំពុងតែ លាតកន្ទេលក្រាលរកទំរេតខ្នង នាងក៏សសៀរទៅជិតដាក់ខ្លួនផ្អែកគល់ឈើក្បែរៗយាយទាំងពីរហើយក៏ស្រដីថា :

- យាយ! ខ្ញុំសូមគេងនៅគល់ឈើនេះក្បែរយាយផងបានទេ?

ស្រាប់តែយាយចាស់ម្នាក់ឆ្លើយឡើងថា :

- ចៅអើយ! រស់យ៉ាងណាបាន ក៏ធ្វើទៅ យើងជាអ្នកក្រ គ្មានសំបុកជ្រក កោនទេ ស្រឡះត្រង់ណាដេកត្រង់ហ្នឹងទៅ មិនបាច់សុំយាយទេណា៎...

ថាហើយ យាយចាស់នោះក៏ផ្តេកខ្លួនកើយដៃលើកន្ទេលកញ្ចាស់ក្បែរ យាយចាស់ម្នាក់ទៀត ដែលមើលទៅជរាទ្រុឌទ្រោមគួរអោយអាណិត បំផុត ។ យប់នោះ ធិតាយើងស្ទើរតែមិនហ៊ានធ្មេចភ្នែកមួយស្របលេតសោះ ឡើយ ត្បិតនាងហាក់ដូចជានឹកភ័យខ្លាចយ៉ាងណាមិនដឹង ដែលត្រូវមក ទទួលទានដំណេកហេងហោងឯកាកណ្តាលពិភពមួយយ៉ាងចំលែក ។ មួយ រាត្រីដ៏សែនយូរលង់.. សំនៀងភិតភ័យញាប់ញ័រក្នុងខ្លួនរហូតទើសភ្លឺ...

ពពកបាំងចន្ទ័...

យប់នេះព្រះចន្ទ័បាំងពពក　　កន្សែងវិយោគតែឯកា
កណ្តោចកណ្តែងឯវេហាស៏　　ធំធេងអស្ចារ្យរងាប្រាណ ។
យប់នេះពពកសែនអួរអាប់　　ហាក់ចាប់ក្រសោបស្រស់កល្យាណ
អោយលង់ក្នុងទុក្ខសោករំខាន　　មិនមានពេលស្រាន្តស្រាកវិបរិត ។
យប់នេះមេឃខ្មៅមើលមិនយល់　　ឱរាខ្វាយខ្វល់ឥតបើគិត
សុញ្ញអស់ស្មារតីចិត្តគំនិត　　តើស្រស់វរមិត្រគិតយ៉ាងណា?
យប់អើយឆ្លងទៅកុំនៅយូរ　　អាលថ្ងៃមកប្តូរមានសុរិយា
បំភ្លឺលោកិយ៏អោយភ្លឺថ្លា　　ឱ្យខ្ញុំយាត្រារកស្នេហាម្តងទៀត...

ថ្ងៃរះម្តងទៀតហើយ...

ធិតាយើងម្ចីម្នាដើររកកន្លែងទូរសព្ទ័សាជាថ្មី ។ ដោយហេតុថានាងមិន ស្គាល់ភូមិសាស្រ្តក្រុងភ្នំពេញ ទំរាំតែនាងដើររកឃើញ ថ្ងៃត្រង់បាត់ទៅ ហើយ ។ សំណាងនាងមិនល្អ ធិតាយើងនៅតែហៅរកពិសិដ្ឋមិនជួបដដែល មិនថានាងខិតខំទៅទូរសព្ទ័ច្រើនដងយ៉ាងណាក៏ដោយ ។ ពីរបីថ្ងៃបន្តបន្ទាប់ មកនាងក៏ក្លាយខ្លួនជាមនុស្សគេងតាមចិញ្ចើមផ្លូវដូចស្មូមទានទាំងឡាយ ។ កាលបើធិតាយើងស្ថិតនៅក្នុងភពសតិវិបត្តិធ្ងន់ធ្ងរ នាងមិនអាចគិតឃើញ មធ្យោបាយអ្វីល្អសំរាប់ជួយខ្លួននាងឡើយ ក្រៅតែពីអង្គុយសំរក់ទឹកភ្នែកពី

CHANBOKEO.COM

មួយថ្ងៃទៅមួយថ្ងៃរង់ចាំតែអង្គុយទូរសព្ទ័តាមរកពិសិដ្ឋតែម្យ៉ាងប៉ុណ្ណោះ ។

វាសនាល្អក៏វិលត្រលប់មកនាងវិញ នៅថ្ងៃទីប្រាំមួយបន្ទាប់ពីនាងមក ដល់ភ្នំពេញ មាណវីបានទូរសព្ទ័រកពិសិដ្ឋឃើញដូចបំណង ហើយពិសិដ្ឋក៏ ភ្ញាក់ផ្អើលណាស់ដែរដែលនាងធ្វើដំណើរតែម្នាក់ឯងមកដល់រាជធានី ។ ថ្វី បើ ពិសិដ្ឋមិនហ៊ានស្រដីសួរសំនៀងច្រើនក៏ដោយ ក៏សភាពរូបកាយរបស់ សំនៀងបានឆ្លើយប្រាប់ពិសិដ្ឋយ៉ាងជាក់ច្បាស់ថា ជីវិតនាងពិតជាដុនដាប ណាស់ ប៉ុន្មានថ្ងៃកន្លងមកនេះ ។

លុះគេនាំនាងមកដល់ផ្ទះភ្លាម ពិសិដ្ឋក៏ទូរសព្ទ័ទៅលោកវរៈភ្លាម ស្រាប់តែនាយបានដឹងថា វរលក្ខណ៏កំពុងមានគ្រោះថ្នាក់ចរាចរត្រូវដឹកចូល មន្ទីរពេទ្យពីម្សិលមិញ ចំណែកឯសុគុណស្ថិតនៅក្នុងពេទ្យព្យាបាលអាសន្ន មិនទាន់ដឹងខ្លួននៅឡើយ ។ លោកវរៈក៏តឿនសុំអោយពិសិដ្ឋទៅមើលកូន ស្រីជំនួសលោកផងត្បិតលោកកំពុងនៅចាំមើលថែសុគុណ ។ គ្រាន់តែបាន ដំណឹងដូច្នោះភ្លាម ពិសិដ្ឋក៏បររថយន្តនាំសំនៀងរឹងទៅមើលវរលក្ខណ៏ភ្លាម ដែរ ។ សំណាងល្អ វរលក្ខណ៏មានគ្រោះថ្នាក់ត្រឹមតែបាក់ឆ្អឹងស្មាម្ខាង តែមិន មានគ្រោះថ្នាក់ដល់ជីវិត ។ រីឯអ្នកបំរើដែលទៅជាមួយវរលក្ខណ៏នោះ រង របួសស្រាលជាង ក៏ត្រូវពេទ្យអនុញ្ញាត្តអោយចេញទៅផ្ទះវិញទៅ ។

នៅក្នុងមន្ទីរពេទ្យ...

វរលក្ខណ៏ចាប់ដៃសំនៀងមកកាន់ហើយស្រដីថា :

- អរគុណអូនណាស់សំនៀង ដែលអូនមានទឹកចិត្តតាមមករកពួកយើងឯភ្នំ ពេញដោយខ្លួនឯង ។ បងកំពុងតែបារម្ភពីសុគុណណាស់ មិនដឹងថាគេយ៉ាង ណាហើយទេ...

សំនៀងនៅស្ងៀមមួយស្របក់ក៏ឆ្លើយថា :

- កុំព្រួយច្រើនអីណាបង! ប្រហែលជាយើងមិនអស់សង្ឃឹមពេកទេ... ខ្ញុំ ជឿថាបងសុគុណនៅមានឱកាសនៅឡើយទេ...

- ម៉េចក៏ប្អូននិយាយបែបនេះសំនៀង?.. អូនមានរឿងអ្វីដែលបងមិនដឹង នៅឡើយ មែនទេហ៏?

សំនៀងងាកមើលពិសិដ្ឋ ហើយក៏បែរមកវរលក្ខណ៏វិញ រួចក៏តបថា :

- គឺកាលពីខែមុន ខ្ញុំបានសុំអោយបងពិសិដ្ឋនាំខ្ញុំទៅពិនិត្យឈាមនៅឯបាត់ ដំបង ។ ពេទ្យពិនិត្យឃើញថា ឈាមខ្ញុំល្អណាស់មិនមានជំងឺឆ្លងទេហើយ បងពិសិដ្ឋ គាត់បានប្រាប់ខ្ញុំថា បងសុគុណក៏មានឈាមជំពូកដូចខ្ញុំដែរ ដូច្នេះ បើខ្ញុំចង់បរិចាគក្រលៀនខ្ញុំម្ខាងដល់បងពិសិដ្ឋ គឺគាត់ច្បាស់ជាមានឱកាស រស់នៅដូចប្រក្រតីវិញមិនខាន ។

វរលក្ខណ៏ឮហើយញញឹមតែម្តង :

- បងអរគុណណាស់សំនៀង ដែលអូនមានសទ្ធាយ៉ាងខ្ពង់ខ្ពស់ទៅលើប្អូន ប្រុសរបស់បង ។ ការពិត គួរតែបងទេ ជាអ្នកបរិច្ចាគព្រោះជាបងស្រីរបស់ គេ ថៃដន្យ បងគ្រាន់តែជាកូនចិញ្ចឹមរបស់ប៉ាហើយក៏មានឈាមជំពូកខុស គ្នាពីសុគុណទៀត ទើបមិនអាចធ្វើទៅបាន ។ ការពិត សុគុណពិតជាមាន សំណាងខ្ពស់ណាស់ដែលបានមកជួបរូបអូន... កុំអី...

- មិនអីទេ បង! សំនៀងអាចធ្វើអ្វីសព្វយ៉ាងជូនបងសុគុណបាន អោយតែ គាត់បានសុខសប្បាយមកវិញ ។

CHANBOKEO.COM

បន្ទាប់មក ពិសិដ្ឋក៏នាំសំនៀងទៅមើលសុគុណឯមន្ទីរពេទ្យ ។ ថៃ្ងដន្យ ទាំងពីរលើកដែលគេនាំសំនៀងទៅសុគុណបែរជាឈឺខ្លាំងមមើមមាយ មើលមិនយល់ ហើយតែងត្រូវការការពិនិត្យយ៉ាងអាសន្នពីលោកវេជ្ជ បណ្ឌិតជានិច្ច ម្ល៉ោះហើយសំនៀងមិនហ៊ានអែអង់យូរក៏ស្ម័គ្រចិត្តចូលខ្លួន ធ្វើពលី បរិចាគក្រលៀនអោយទៅបុរសជាទីស្រលាញ់របស់នាងដោយមិនបានគិតអ្វីវែងឆ្ងាយតទៅទៀតឡើយ ។ គេទាំងពីរក៏មិនមានឱកាសនឹង និយាយគ្នាដែរ ត្បិតសំនៀងត្រូវចូលមន្ទីរពិនិត្យសុខភាពនិងដំណើរឈាម
ចំនួនពីរថ្ងៃ មុននឹងពេទ្យចាប់ផ្តើមធ្វើការវះកាត់ ។

ជាងពីរអាទិត្យកន្លងទៅ...

ការវះកាត់ដាំក្រលៀនថ្មីអោយទៅសុគុណ ក៏បានទទួលជោគជ័យជា បណ្តើរៗហើយ ។ ឯសុខភាពរបស់សំនៀងក៏បានគ្រាន់បើមកវិញដែរ ។ តែ ដោយហេតុថានាងមិនមានជំងឺរ៉ាំរ៉ៃដូចសុគុណ នាងក៏ឆាប់ជាស្រួលបួលរហ័សជាងនាយយើងច្រើនណាស់ ។ រសៀលនេះ ពេទ្យក៏អនុញ្ញាតអោយ ធិតាយើងចេញទៅរក្សាខ្លួនឯផ្ទះវិញ ។ ពេលនោះវរលក្ខណ៏និងពិសិដ្ឋក៏មក ទទួលនាងពីមន្ទីរពេទ្យ ។ ថៃ្ងដន្យ នាងត្រូវរង់ចាំទទួលបញ្ជាថ្នាំពីលោកគ្រូ ពេទ្យ ទើបវរលក្ខណ៏ចេញទៅរកសុគុណមុនទៅ ហើយទុកអោយពិសិដ្ឋនាំ ធិតាទៅតាមក្រោយ ។ បួនដប់នាទីបន្ទាប់មក ពិសិដ្ឋក៏នាំសំនៀងដើរទៅ តាមក្រោយតម្រង់ទៅបន្ទប់របស់សុគុណ ។ លុះមកដល់មាត់ទ្វារបន្ទប់ របស់បុរសយើង ស្រាប់តែសំនៀងប្រទះឃើញនារីស្រស់សោភាមួយរូប កំពុងសាសងម្ទិកម្ទក់ជាមួយសុគុណយ៉ាងស្និទ្ធស្នាលបំផុត ។ នាងក៏បែរសួរ ពិសិដ្ឋភ្លាមថា :

- បងពិសិដ្ឋ! តើនារីមួយរូបនោះជានរណាដែរ? តើយើងគួរចូលទៅទេ?
- នោះ.. គឺជាដារិនី.. គូដណ្តឹងរបស់សុគុណណាំសំនៀង...!

គ្រាន់តែឮចំលើយដូច្នោះ សំនៀងថ្លោះទឹកមុខ ធ្វើមុខស្លេកស្វាយល្អក មួយរំពេច ។ ព្រមគ្នានោះដែរ នាងក៏ឃើញដារិនីឈ្ងោកមុខយកដៃអង្អែល ថ្ពាល់សុគុណថ្នមហើយស្រដីខ្សិបដាក់ត្រចៀកមាណពមិនដឹងថាគេនិយាយអ្វីដាក់គ្នាទេ ។ ធិតាតក់ស្លុតក្នុងចិត្តពេក ក៏បែរក្រោយដើររឹងត្រលប់ចេញ ទៅក្រៅអង្គុយយំតែម្នាក់ឯង ។ លុះពិសិដ្ឋរត់មកតាមក្រោយរកនាងឃើញ អង្វរអោយត្រលប់ទៅរកសុគុណយ៉ាងណា ក៏នាងប្រកែកមិនព្រមទៅវិល ឡើយ ត្បិតនាងកំពុងតែរលាកបេះដូងបាក់កំលាំងចិត្តអស់រលីង ។ ឃើញ ដូច្នោះ
ពិសិដ្ឋក៏នាំធិតាត្រលប់ទៅផ្ទះដើម្បីសំរាកយកកំលាំងវិញទៅ ។

រាត្រីនោះ សំនៀងតប់ប្រមល់ទាល់ភ្លឺ អន្ទះសាក្នុងចិត្តមិនដឹងថាជាគិត ពីអ្វីទៅអ្វីទេ ។ ភ្លឺឡើងសុខភាពរបស់នាងក៏ធ្លាក់ចុះដុនដាបដើរយោងខ្លួន លែងរួច ។ ដោយឃើញនាងទ្រុឌទ្រោមខុសប្រក្រតី ពិសិដ្ឋក៏សំរេចចិត្តនាំនាងត្រលប់ចូលពេទ្យវិញសាជាថ្មី ទទួលសុគុណជិះម៉ូតូឌុបមករកនាងដល់ មុខផ្ទះរបស់នាយល្ហម ។ គ្រានោះអាកប្បកិរិយានិងពាក្យពេចន៏គំរោះ គំរើយរបស់សុគុណ បានធ្វើអោយសំនៀងយើងកើតអារិចិត្តចំពោះមាណពជាខ្លាំងរហូតដល់មាណវីយើងអស់ទឹកចិត្តនឹងទ្រាំតស៊ូតទៅមុខទៀត ដើម្បី រូបនាយ ។ នាងក៏ដាច់ចិត្តបោះជំហាន រត់ចាកចេញ

CHANBOKEO.COM

ពីបរិវេណគេហដ្ឋាន របស់ពិសិដ្ឋទៅដោយដៃទទេ... ទុកអោយពិសិដ្ឋនិងសុគុណនៅឈ្លោះ ប្រកែកគ្នាងក្រោយខ្នង.. មិនដឹងថាគេនឹងដោះស្រាយគ្នាយ៉ាងណាឡើយ ។ តាមផ្លូវចេញទៅ សំនៀងមានអារម្មណ៍ថា បេះដូងរបស់នាងហាក់ដូចជា កំពុងត្រូវមុខកាំបិតយ៉ាងស្រួចកំពុងចាក់ឆ្កៀល ឱ្យឈឺផ្សាក្ដៅក្រហាយ ស្ទើរទ្រាំលែងបាន ព្រោះហេតុថា ការដែលនាងកំពុងទុរន់ទុរាផ្លូវកាយ ហើយស្រាប់តែត្រូវគេមកប្រច្រានអុកគូថទៅដី ហើយប្រើពាក្យអសុរស ទ្រគោះគំហកដាក់នាងដោយខ្វះសតិត្តយ៉ាងដូចដែលសុគុណធ្វើមកលើនាង តើនារីណាមួយ អាចទ្រាំទ្របានទៅ? ជាពិសេសជាងហ្នឹងទៅទៀត សំនៀងគិតថា សុគុណកំពុងតែសម្រុះសម្រួលជាមួយ នឹងគូដណ្ដឹងរបស់គេ ដ៏សោភា ទើបគេធ្វើដូច្នោះ ដើម្បីរកលេសបណ្ដេញរូបនាងចេញពីជីវិត របស់គេ ។ ម្យ៉ាងទៀត ដោយសារប្រវត្តិអតិតកាលមិនល្អរបស់នាង ធិតាក៏ ទទួលការវិនិច្ឆ័យយ៉ាងអគតិពីសុគុណថា នាងជាស្រីដែលមានចិត្តរាយ មាយ ធ្វើអោយនាងរិតតែមានការឈឺចាប់ក្នុងចិត្តថែមទ្វេឡើង ឈឺចិត្ត រហូតចង់តែរត់ទៅសម្លាប់ខ្លួនម្ដងៗទៅហើយ.. ប៉ុន្តែ ទោះជាយ៉ាងណា ក៏នាងមិនដាច់នឹងធ្វើដូច្នោះសោះឡើយ ។

មិនធ្វើអត្តឃាតដាច់ខាត...

មិនធ្វើអត្តឃាតដើម្បីស្នេហ៍ ខកចិត្តពិតតែមិនចុះចាញ់
ស៊ូរក្សាយសរស់ស្ថិតស្ថាញ ដើម្បីបង្ហាញចិត្តបរិសុទ្ធ ។
មិនធ្វើអត្តឃាតជីវិតខ្លួន ខុសនឹងច្បាប់ក្បួនធម៌ព្រះពុទ្ធ
ស៊ូរស់សាងល្អដ៏ប្រាកដ ថ្ងៃមួយគង់ផុតឈ្នះពាក្យដៀល ។
មិនឡើយធ្វើបាបកាយខ្លួនឯង ឱ្យឈឺចំបែងព្រោះដំនៀល
ស៊ូរស់ស្វែងសុខចៀសចិត្តពាល សាងឈ្មោះរន្ទាលល្អជាថ្មី ។
សង្ឃឹមថ្ងៃមួយបានបំភ្លឺ ចិត្តមនុស្សសើរើប្រមាថស្ដី
អោយគេស្លាក់កព្រោះសំដី វិភាគរូបស្រីខុសការពិត ។
ច្នេះទុកអោយកម្មតាមអន្ទោល ទោសប្រដេញថ្កោលជនឧក្រិដ្ឋ
ដែលមានអគតិអារិចិត្ត កម្មតាមជីវិតឱ្យសមអំពើរបស់គេ ។

នៅលើវិថីមួយដែលមានចរាចររចល់... សំនៀងមិនដឹងថានាងត្រូវ ត្រលប់ទៅទីណាទេ កាលបើនាងគ្មានអ្វីជាប់ខ្លួនមកផង ។ ទទួលពេលនោះ នាងប្រទះឃើញគេដាក់កាសែតលក់នៅតូបមួយតាមដងវិថី ។ នាងក៏ឈរ អានដោយចៃដន្យ ឃើញគេផ្សាយពតិមានអំពីក្រសួងមនុស្សធម៌ដែលបាន ជួយសង្គ្រោះនារីនិងកុមារីរងគ្រោះជាច្រើន មកពីបណ្ដាញជួញដូរមនុស្ស ។ នាងក៏សួរទៅអ្នកលក់ថា :

- មីង... បើសិនខ្ញុំចង់ទាក់ទងទៅកន្លែងមួយនេះ តើខ្ញុំត្រូវធ្វើយ៉ាងណា?

មីងម្ចាស់តូបសំលឹងមុខនាងមួយស្របក់ក៏សួរថា :

CHANBOKEO.COM

- នាងចង់ទៅកន្លែងហ្នឹងធ្វើអ្វី? កន្លែងនោះគេទទួលតែស្រីរងគ្រោះដោយ ពេស្យាចារទេ...

- តែខ្ញុំចង់ទៅរកបងប្អូន...

យើញទឹកមុខធិតាប្រកបដោយទោម្នេញ មីងអ្នកលក់ក៏សួរឡើង :

- មុខហ្នឹងច្បាស់ជាអ្នករងគ្រោះម្នាក់ដែរហើយទេដឹង? អឺ១ ចាំមីងជួយ សួរគេឯងសិន ព្រោះមីងមិនដឹងថាទីតាំងរបស់គេនៅឯណាដែរទេ។

ទទួលពេលនោះមានបុរសមួយរូបជិះម៉ូតូមកដល់ ស្រាប់តែមីងម្ចាស់ តូបលាន់មាត់ឡើងថា :

- អូហ៎ មែនហើយ! ក្មួយស្រីសួរគេខាងនេះទៅ ច្បាស់ជាគេស្គាល់មិនខាន ព្រោះគេជាកាសែតស្រាប់។

ភ្លាមនោះ មីងយើងក៏ពឹងអោយបុរសម្នាក់នោះជួយទទួលយកនាង ទៅដាក់នៅក្រសួងសង្គ្រោះនារីនិងកុមារភ្លាម។ បុរសនោះក៏មិនមានចិត្ត កំណាញ់ដែរ។ កាលបើឃើញសភាពផ្លូវកាយរបស់នារីយើងមិនសូវស្រួល គេក៏បញ្ឆេះម៉ូតូឌុបនាង រហូតទៅដល់មណ្ឌលទទួលនារីនិងកុមាររងគ្រោះ ភ្លាម។ ឃើញសភាពមិនប្រក្រតីរបស់នាង បុគ្គលិកម្នាក់ក៏សួរហេតុផលតែសំនៀងស្រដីបានត្រួស១ប៉ុណ្ណោះ ដោយសុខភាពរបស់នាងកាន់តែចុះទ្រុឌ ទ្រោមពេក ម្ល៉ោះហើយបុគ្គលិកពីររូបក៏ទៅជួយយកឥវ៉ាន់ផ្ទាល់ខ្លួនរបស់ នាងពីផ្ទះពិសិដ្ឋមកវិញ។

ក្រោយពីបានទទួលការព្យាបាលថែទាំយ៉ាងល្អរបស់ក្រសួង មាណវី យើងក៏មានអាការៈរឹងប៉ឹងយ៉ាងច្រើន តែសភាពផ្លូវចិត្តនៅតែទ្រុឌទ្រោម ដដែល ដែលជាហេតុធ្វើអោយបុគ្គលិកពិសេសខាងអប់រំចិត្តសាស្ត្រណាត់ ជួបនាងរាល់ថ្ងៃដែរ។ គេមិនដែលមើលបំណាំនាងម្ដងណាទេ គឺគេតែងតែ យកចិត្តទុកដាក់ចំពោះសភាពផ្លូវចិត្តផ្លូវកាយរបស់នាងយ៉ាងកក់ក្ដៅ។ នៅទីនោះ នាងមានអារម្មណ៍ថា ខ្លួនមានសន្តិសុខគ្រប់គ្រាន់ណាស់ ហើយក៏ រីករាយក្នុងចិត្តខ្លាំងណាស់ដែរដែលសង្គមខ្មែរសព្វថ្ងៃមានទីកន្លែងដូច្នោះ សំរាប់នារីរងគ្រោះទាល់ច្រកដូចរូបនាង កុំអីជីវិតរបស់នាងច្បាស់ជារសាត់ ដូចចកកណ្តាលទន្លេមិនខានឡើយ។

ពីរអាទិត្យកន្លងទៅ...

សំនៀងកំពុងតែអង្គុយពិគ្រោះជាមួយបុគ្គលិកការងារមួយរូប របស់ ក្រសួង ស្រាប់តែមានស្ត្រីមួយរូបចូលមកដល់ឈ្មោះអ្នកស្រីសានីដែលជា បុគ្គលិកមកពីខេត្តបាត់ដំបង។ កាលបើអ្នកស្រីក្រលេកឃើញសំនៀងកាល ណាក៏ធ្វើមុខភាំងទំនងភ្ញាក់ផ្អើល ហើយបែរសួរនាងថា :

- ក្មួយស្រី ជាកូនរបស់បងស៊ីនួននៅបាត់ដំបងមែនទេ?

សំនៀងភ្ញាក់ព្រើតដែលស្ត្រីរូបនោះស្គាល់ឈ្មោះម្ដាយរបស់នាង។ នារី យើងក៏ឆ្លើយវិញថា :

- ចាំស! អ្នកមីងមានប្រសាសន៍ត្រូវហើយ។ តើអ្នកមីងត្រូវជាអ្វីនឹងម្ដាយ របស់ខ្ញុំដែរ ទើបបានជាស្គាល់គាត់?

- គឺ.. មកពីក្មួយមានមុខមាត់ដូចម្ដាយនាងពេកនោះអី ទើបមីងសួរ លេងទៅ... ការពិត មីងមិនមែនជាសាច់ញាតិខាងម្ដាយក្មួយទេ តែត្រូវជា សាច់ញាតិខាងឪពុករបស់ឯងណា៎...

CHANBOKEO.COM

សំនៀងបើកភ្នែកធំៗ ត្បិតតាំងពីតូចក្រូចឆ្មារមក ម្ដាយនាងមិនដែល បង្ហើបអ្វីប្រាប់នាងពីឪពុករបស់នាងឬក៏សាច់ញាតិខាងឪពុកទេ។ ពេលនេះ នាងចង់ដឹងណាស់ថាតើនរណាទៅជាឪពុករបស់នាង។ ភ្លាមនោះ អ្នកស្រី សាលីក៏សុំខ្លួន :

- ក្មួយស្រីនៅអង្គុយលេងត្រង់នេះមួយភ្លែតសិនចុះ មីងមានការជាមួយ ក្រសួងមួយភ្លែត បន្តិចមីងត្រលប់មកវិញ។

សំនៀងសំលឹងមើលតាមគាត់ឥតពព្រិច។ ភ្លាមនោះ នាងគិតក្នុងចិត្ត តែម្នាក់ឯងថា :

- ប្រាកដជាទេវតាបញ្ជូនអ្នកស្រីនេះឱ្យមកអោយមកសង្គ្រោះរូបខ្ញុំហើយ!

មួយសន្ទុះធំក្រោយមក អ្នកស្រីសានីក៏ត្រលប់មកដល់វិញព្រមជា មួយបុគ្គលិកពីររូបទៀតរបស់ក្រសួង។ លុះក្រលេកឃើញសំនៀងភ្លាម អ្នកស្រីក៏មានប្រសាសន៍ទៅកាន់បុគ្គលិកទាំងពីរថា :

- គឺខ្ញុំសូមធានាយកនារីមួយរូបនេះទៅចិញ្ចឹមផ្ទាល់ទៅចុះ ហើយសូមថ្លែង អំណរគុណដល់ក្រសួងដែលបានទទួលថែរក្សានាងយ៉ាងល្អប្រសើរបំផុត។

សំនៀងអង្គុយធ្វើភាំងមិនយល់ហេតុការណ៍។ ឃើញដូច្នោះអ្នកស្រី សានីក៏ពន្យល់ទៅនាងថា :

- មីងបានសុំយកក្មួយទៅបាត់ដំបងជាមួយមីងវិញហើយ។ ម៉ោះ! ទៅ យកឥវ៉ាន់របស់ក្មួយមក ចាំមីងដំណាលរឿងប្រាប់នាងតាមផ្លូវ ដើម្បីឱ្យ បានដឹងអំពីប្រវត្តិសាច់សាលោហិតរបស់ក្មួយណា។

រសៀលថ្ងៃដដែល អ្នកស្រីសានីនាំសំនៀងឡើងរថយន្តផ្ទាល់ខ្លួនមួយ ដែលមានសូហ្វ័រចំណាស់ម្នាក់ជាអ្នកបើកបរជូនដំណើរ។ តាមផ្លូវ សំនៀង សួរទៅអ្នកស្រីសានីថា :

- អ្នកមីង.. អោយសំនៀងសុំស្គាល់ផងបានទេ ថាខ្ញុំនិងអ្នកមីងត្រូវជាប់ សាច់ឈាមនឹងគ្នាយ៉ាងណាដែរ?

- អឺ.. មីងកំពុងចង់ប្រាប់ឯងហើយ។ ការពិត បងស៊ីនួនជាប្រពន្ធដើម របស់បងប្រុសមីង ឈ្មោះសុខជ័យ។ គាត់រៀបការនឹងគ្នាតាំងពីឆ្នាំ១៩៨៣ តែមិនមានកូនសោះ ម្ល៉ោះហើយបងសុខជ័យក៏បែកចិត្តទៅរៀបការប្រពន្ធ ថ្មីម្នាក់ទៀត ស្រាប់តែបងស៊ីនួនចាប់មានផ្ទៃពោះព្រមពេលជាមួយគ្នានោះ ដែរ។ ដោយខឹងនឹងបងសុខជ័យ ដែលលួចទៅរៀបការប្រពន្ធថ្មីចោលគាត់ បងស៊ីនួនក៏គេចខ្លួនបាត់ដំណឹងទៅតាំងពីឆ្នាំ១៩៨៨ម្ល៉េះ។ កាលនោះ គាត់ កំពុងតែពផ្ទៃផង.. មើលទៅ ទារកនោះគឺច្បាស់ជារូបក្មួយហើយ ហើយចុះ ឥលូវនេះ នាងអាយុប៉ុន្មានដែរហើយ?

- ចាស ចូល១៩ឆ្នាំហើយ។

- ពុទ្ធោអើយ... គឺជានាងប្រាកដណាស់! គួរអោយអាណិតម្ល៉េះទេដែលខ្លួន ទើបតែមានវ័យប៉ុនហ្នឹង តែបែរជាមកឆ្លងកាត់ជីវិតយ៉ាងលំបាកៗយ៉ាង អណោចអធម្មទៅវិញ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏មីងសន្យាថាមិន អោយក្មួយបោះជំហានថយក្រោយ ទៅរកជីវិតដ៏អភព្វ ដូចអតិតកាល របស់នាងសាជាថ្មីទៀតឡើយ។

មានប្រសាសន៍ចប់ អ្នកស្រីក៏យកដៃអង្អែលក្បាលក្មួយស្រីដោយក្ដី អាណិតស្រលាញ់ ថែមទាំងពោលបន្ថែមថា :

CHANBOKEO.COM

- នឹកៗទៅ គួរអរគុណដល់អង្គការសង្គ្រោះនារីណាស់ ដែលផ្តល់ការងារឱ្យ មីងធ្វើ ហើយក៏បានជួយសង្គ្រោះរូបក្មួយមកទៀត បើកុំតែយ៉ាងហ្នឹង កុំអី យើងមិនបានជួបគ្នាឡើយ ។

សំនៀងញញឹមឡើងហើយក៏វាចាថា :

- ខ្ញុំក៏មានអារម្មណ៍ដូច្នោះដែរណ៎អ្នកមីង...! ថ្ងៃណាដែលជីវភាពរបស់ខ្ញុំ បានប្រសើរមកវិញ ខ្ញុំនឹងវិលមកសំដែងកតញ្ញូដល់ក្រសួងវិញមិនខាន ។

បន្តិចក្រោយមក សំនៀងនឹកពិភាល់រឿងមួយក៏សួរទៅអ្នកស្រីសានី ភ្លាមថា :

- អ្នកមីង! ចុះឪពុករបស់ខ្ញុំនោះ សព្វថ្ងៃលោករស់នៅទីណាដែរ?

- អូហ៎ គាត់រស់នៅឆ្ងាយណាស់ ដល់ទៅអាមេរិកឯណោះ ។ គាត់បានទៅ រស់នៅទីនោះតាំងពីឆ្នាំ១៩៩០ម្ល៉េះ ។ តែគាត់មិនដែលភ្លេចស្រុកយើងទេ ។ នៅរៀងរាល់ឆ្នាំគាត់តែងនាំប្រពន្ធមកលេងស្រុកជានិច្ច ។ ចៃដន្យ បង សុខជ័យគាត់មានបាបកម្មដែលបានធ្វើបាបចិត្តបងស៊ីនួន ទើបទេវតាដាក់ ទោសគាត់មិនអោយមានកូនមួយគ្រាប់ តាំងពីបានរៀបការនឹងបងចិន្តា កាលណោមក ។ អាស្រ័យហេតុនោះហើយទើបគាត់តែងតែដុកដាន់មីងឱ្យ ជួយតាមរកបងស៊ីនួននិងកូនរបស់គាត់ដែលគាត់មិនបានដឹងថា ជាប្រុសឬ ជាស្រីទេ ។ មីងក៏ខំតាមជួយតាមរកបងស៊ីនួនអស់ជាយូរឆ្នាំហើយតែមិន ដែលបានប្រទះគ្នាសោះឡើយ ។

- ការពិត ម៉ែរស់នៅឯផ្សារលើបាត់ដំបងនោះតើហ៎ គ្រាន់តែគាត់រកស៊ីលក់ បាយសម្លមិនដែលទៅណាមកណាសោះ ។ ឯប្តីក្រោយរបស់គាត់ជាមនុស្ស មិនសូវមានប្រិយភាពសោះ ទើបយើងគ្មានញាតិទៅមករាប់អានប៉ុន្មាន ។

- ហើយចុះក្រុមគ្រួសាររបស់ឯងយ៉ាងណាហើយ..

សំនៀងឈ្ងោកមុខនៅស្ងៀម កាត់ចិត្តយ៉ាងយូរទើបឆ្លើយថា :

- ពួកគេបានលាចាកលោកទៅអស់ហើយ... នៅសល់តែខ្ញុំម្នាក់ឯងទេ...

ថាតែប៉ុននេះ មាណវីក៏ស្រក់ទឹកភ្នែកច្រោក និយាយតទៅទៀតលែង រួចតែម្តង ។ អ្នកស្រីឃើញដូច្នោះក៏ពោលឃាត់ :

- ល្ហើយចុះ! ចាំយើងទៅដល់ផ្ទះ គេងសំរាកមានអារម្មណ៍ មានកំលាំងល្អ ចាំក្មួយនិយាយរៀបរាប់រឿងក្មួយប្រាប់មីងក៏បានដែរណ៎...

ថាហើយគាត់ក៏យកដៃបបោសក្បាលមាណវីបង្ហាញនូវទឹកចិត្តអាណិត អាសូរយ៉ាងធំធេងក្រៃលែង ។

ថ្ងៃមួយ...

- សំនៀង..!

- ចាំស អ្នកមីង!

- នេះ លោកប៉ាទូរសព្ទ័មកពីអាមេរិក កូននិយាយជាមួយគាត់បន្តិចទៅ..

CHANBOKEO.COM

ភ្លាមនោះ សំនៀងរន្ធត់ចិត្តណាស់មិនដឹងថាត្រូវនិយាយជាមួយលោក យ៉ាងណា កាលបើនាងមិនដែលស្គាល់ឪពុកនាងបន្តិចណាសោះ ។ ទោះបីជា យ៉ាងណា... នាងក៏បាននិយាយទូរសព្ទ័ជាមួយលោករាល់អាទិត្យតាំងពីថ្ងៃ ដែលនាងមកដល់ផ្ទះអ្នកស្រីសានី ។ លោកសុខជ័យថែមទាំងសន្យាថានឹង ត្រលប់មកស្រុកខ្មែរជួបនាងឆាប់ៗនេះផង ។ ចាប់តាំងពីថ្ងៃនោះមក ធិតា ក៏បានមករស់នៅយ៉ាងសុខសាន្ត ជាមួយនឹងអ្នកស្រីសានីដែលរស់នៅតែ ម្នាក់ឯងនៅឯភូមិនរា ។ ប៉ុន្តែ ដោយសារគាត់ជាមនុស្សមានសន្តានចិត្តល្អ អ្នកជិតខាងភូមិផងរបងជាមួយបាន ក្លាយខ្លួនជាញាតិរបស់អ្នកស្រីសានី យ៉ាងជុំជិត ។ ពេលសំនៀងធ្វើដំណើរទៅណាមកណាជាមួយអ្នកស្រី នាង តែងតែឮអ្នកស្រុកកូកហៅឆ្លើយឆ្លងនឹងគាត់ រហូតចប់តាមផ្លូវមិនលោះ ពេលឡើយ ។

ច្រើនខែកន្លងទៅ...

- សំនៀង! មីងសង្កេតឃើញឯងមានសុខភាពនិងរាងកាយផ្លាស់ប្តូរ ចំលែកណាស់ ។ ឯងកំពុងតែមានផ្ទៃពោះមែនទេ?

ឮម្តាយមីងហៅមកសួរដូច្នោះ សំនៀងឈ្ងោកមុខនៅស្ងៀម ។ អ្នក ស្រីក៏មានប្រសាសន៍តទៅទៀតថា :

- ក្មួយកុំខ្លាចចិត្តមីងអី... មានការអីយើងនិយាយគ្នាណា៎...ក្រែងលោអាច ជួយគ្នាដោះស្រាយបញ្ហាបានងាយជាងមុន ។

ឮអ្នកស្រីសានីមានប្រសាសន៍ដូច្នោះ សំនៀងក៏តបវិញថា :

- ខ្ញុំពិតជាមានផ្ទៃពោះមែន តែខ្ញុំមិនចង់រំលឹកអតិតកាលនោះមកវិញទេ ត្បិតវាបានធ្វើអោយបេះដូងរបស់ខ្ញុំឈឺចុកចាប់ណាស់...

- អឺ! បើមិនចង់រំលឹកទេក៏បើចុះ តែមីងសូមចិត្តទៅចុះ ថាកុំអោយឯងគិត អ្វីខ្លីៗអោយសោះ ។ បើមានរឿងអ្វីមិនសុខស្រណុកក្នុងចិត្ត ប្រាប់មីងណា៎ កុំលាក់អី ទោះជាយ៉ាងណាក៏មីងបារម្ភពីសុខទុក្ខរបស់ឯងជានិច្ច ។

- ចាំស! អរគុណអ្នកមីងណាស់ ។ សព្វថ្ងៃ សំនៀងមានសេចក្តីសុខណាស់ មិនមានអ្វីដែលក្មួយត្រូវពិបាកចិត្តទៀតទេ... គ្រាន់តែដំបៅចាស់ក្នុងដួង ចិត្តមិនទាន់បានជាសះស្រលះពីក្នុងខ្លួនតែប៉ុណ្ណោះ ។

- មីងសង្ឃឹមថា មិនយូរមិនឆាប់ ក្មួយនឹងបានជាសះស្បើយមិនខាន!

ច្រើនខែកន្លងទៅ...

សំនៀងអង្គុយអ៊ុតខោអាវជូនមីងសានីដែលបានចេញទៅធ្វើការតាំង ពីព្រហាមស្រាប់តែនាងឮសូរសំលេងរថយន្តមួយមកឈប់ចតនៅមុខផ្ទះ ។ នាងក៏ស្ទុះងើបឡើងទៅរកមើលក៏ប្រទះ អ្នកស្រីសានីកំពុងនាំបុរសស្ត្រីពីរ រូបក្នុងវ័យពាក់កណ្តាលអាយុ ចុះពីលើរថយន្តដើរសំដៅមករកនាង ថែម ទាំងមានប្រសាសន៍ថា :

- សំនៀង! ឆាប់មកនេះ ជំរាបសួរអ្នកមានគុណទៅក្មួយ...

- អ្នកមានគុណ?... (សំនៀងឧទានខ្សិបៗ)

ធិតាសំលឹងទៅបុរសចំណាស់នោះមិនដាក់ភ្នែក ។ មែនហើយ! នាង មនដែលស្គាល់លោកពីមុនមកទេ ប៉ុន្តែមើលទៅភិនភាគរបស់លោក គ្មាន

CHANBOKEO.COM

អ្វីជាសញ្ញាថា លោកជាមនុស្សមានពិសពុលដែរ ។ ធិតាក៏ប្រញាប់ដើរទៅ ជិតលោកហើយ ក៏លំទោនកាយលើកដៃផ្គុំប្រណម្យសំពះលោកដោយក្ដី គោរពអស់ពីដួងចិត្ត ។ លោកសុខជ័យលើកដៃអង្អែលក្បាលកូនស្រីដោយបេះដូងរន្ធត់ញាប់ញ័រ :

- កូនស្រីប៉ា...! ប៉ាសប្បាយចិត្តអ្វីម្ល៉េះទេ កាលបើប៉ាបានជួបសាច់ឈាម របស់ប៉ានៅពេលនេះ... កូនមានមុខមាត់ដូចម៉ាក់របស់កូនក្រៃលែង ។

មានប្រសាសន៍ចប់ លោកក៏ស្រវាអោបកូនស្រីយ៉ាងណែនពេញរង្វង់ ដៃ ទាំងទឹកភ្នែករលីងរលោង ។ មួយស្របក់ក្រោយមក លោកក៏មាន ប្រសាសន៍បន្តថា:

- គឺជាកំហុសរបស់ប៉ាទាំងអស់ ដែលបានធ្វើអោយជីវិតរបស់កូននិងម្ដាយ របស់កូនក្លាយទៅជាអពមង្គល... សូមកូនអភ័យទោសអោយប៉ាផង...

ពូវាចារបស់ឪពុកដូច្នោះកាលណា សំនៀងក៏ស្រក់ទឹកភ្នែកច្រោកតែ ម្ដង ។ បន្តិចមក នាងក៏ឆ្លើយតបទៅលោកវិញថា :

- អ្វីៗទាំងអស់ គឺជាបំណែកកម្មរបស់យើង... មិនអាចបន្ទោសនរណាបាន ទេ ។ ទោះបីជាយ៉ាងណាក៏ដោយ កូនស្រីរបស់លោកប៉ាពិតជាសប្បាយរីក រាយណាស់ កាលដែលកូនបានជួបលោកប៉ាវិញ នៅពេលនេះ...

នៅគ្រានោះ បរិយាកាសគ្រួសារក៏ប្រែធូរស្រាលមកវិញដោយសារតែ ការជួបជុំថ្មីរបស់ឪពុកនិងកូនរបស់យើង ។ លោកសុខជ័យក៏បានណែនាំអ្នក ស្រីចិន្ដាដែលជាភរិយាទីពីររបស់គាត់អោយសំនៀងទទួលស្គាល់ ។ ដោយហេតុថាអ្នកស្រីជាមនុស្សមានសទ្ធាតាំងពីណាពីណើមក ហើយមួយជីវិត រៀបការរបស់អ្នកស្រីជាមួយលោកសុខជ័យ អ្នកស្រីក៏មិនដែលមានបុត្រ មួយគ្រាប់នឹងគេ អ្នកស្រីក៏មានចិត្តស្រលាញ់សំនៀងហាក់បីដូចជាកូនស្រី បង្កើតមួយរូបដែរ ។ ម្យ៉ាង អ្នកស្រីហាក់ដូចជាមាននិស្ស័យនឹងសំនៀង ណាស់ ត្បិតធិតាជាមនុស្សមានទំលាប់ល្អហើយទន់ភ្លន់ទៀតផង ធ្វើអោយអ្នកស្រីពេញចិត្តពេញថ្លើមនឹងកូនស្រីមួយរូបនេះ រកប្រកែកមិនបាន ។ ពីរ បីថ្ងៃក្រោយមក លោកសុខជ័យនិងអ្នកស្រីចិន្ដាក៏មានការចេញទៅជួបមិត្ត ភក្ដិចាស់របស់គាត់បាត់ទៅ ។ រីឯអ្នកស្រីសានីវិញ ក៏មានការជាប់រវល់នៅឯការិយាល័យដែរ ។ ទទួលចៃដន្យ នៅថ្ងៃដដែលនោះ ធិតាយើងមាន អារម្មណ៍ល្ហេះល្ហុះមិនស្រួលក្នុងខ្លួនយ៉ាងណាមិនដឹង ក៏រកទូកឆ្លងទៅរក ពេទ្យនៅត្រើយម្ខាងស្ទឹងដើម្បីពិនិត្យផ្ទៃពោះ ។ លុះរសៀលបន្តិច នាងក៏រកទិញផ្លែឈើបីបួនមុខហើយក៏ឆ្លងទូកត្រលប់មកផ្ទះវិញល្មមចំពេលដែល សុគុណបានមកដល់មាត់កំពង់ ហើយក៏បានពើបមុខគ្នាតែម្ដង...

៩៩៩៩៩៩៩៩៩៩៩៩៩៩

៩៩៩៩៩

៩

CHANBOKEO.COM

# វគ្គទី១១

# ជើងមេឃថ្មី

នៅក្នុងបន្ទប់គេង...

សុគុណលើកកូនប្រុសផ្តេកអោយគេងប្របនឹងម្តាយរបស់គេ ហើយក៏ ដាក់ខ្លួនអង្គុយក្បែរនោះ សម្លឹងអ្នកទាំងពីរដោយភក្ត្រញញឹម ប្រកប ដោយសេចក្តីសុខក្នុងចិត្តយ៉ាងជ្រាលជ្រៅធំធេង។ យូរខែហើយ ដែលគេ ភ្លេចញញឹម តែពេលនេះបុរសយើងមានអារម្មណ៍ថា ទេវតាកំពុងតែប្រស់ ព្រំទឹកអម្រឹតដល់បេះដូងដ៏ស្ងួតក្រៀមរបស់នាយហើយ។ រីឯសំនៀងវិញក៏ ហាក់ដូចជាមានហឫទ័យស្ងប់សុខជាងមុខខុសធម្មតាដែរ ថ្វីបើនាងមិនទាន់ ដឹងថា តើសុគុណពិតជាធ្វើបានដូចពាក្យដែលគេសន្យាចំពោះនាងបានដែរ ឬយ៉ាងណា។ នាងចេះតែនឹកគិតបារម្ភថាគេមិនទាន់អាចរំលត់ភាពឆេវឆាវ ពីក្នុងខ្លួនរបស់គេបាននៅឡើយ ហើយនាងក៏នៅបារម្ភដែរថា រូបនាងអាច ក្លាយជាបុគ្គលរងគ្រោះសាជាថ្មី  បើសិនជាភាពឆេវឆាវត្រលប់មករកជីវិត របស់សុគុណវិញ។ កាលបើឃើញនាងគេងធ្វើមុខស្មើ ទំនងគិតវែងឆ្ងាយ សុគុណក៏យកដៃទៅអង្អែលកេសាសំនៀងបន្ថើរៗ :

- កំពុងគិតអីហ្នឹងកំពូលដួងចិត្តបង? នៅសង្ស័យពីចិត្តគំនិតរបស់បងទៀត មែនទេ? បើនៅគិតដូច្នោះពិតមែន បងសូមប្រាប់អូនចុះណា៎ ថាឈប់ព្រួយ ទៅ។ នៅថ្ងៃស្អែក អូននឹងបានឃើញចម្លើយទាំងឡាយនោះនៅច្បាស់នឹងភ្នែកអូនមិនខាន។ ធ្មេចគេងទៅណា៎ គេងអោយបានលក់សុខសាន្តបំផុត ដើម្បីជីវិតថ្មីរបស់យើងទាំងពីរនៅព្រឹកស្អែកនេះ...

សុគុណក៏បន្លឺសៀងបំពេរមួយយ៉ាងពិរោះ ដល់គូគាប់បណ្តូលចិត្តរបស់ គេព្រមទាំងទារកតូចដែលកំពុងគេងលក់ក្បែរនោះយ៉ាងក្សេមក្សាន្ត។

ព្រហាមថ្ងៃបន្ទាប់...

សំនៀងភ្ញាក់ពីនិទ្រាឃើញសុគុណកំពុងរៀបចំឥវ៉ាន់ :

- យើងធ្វើដំណើរទៅណាហ្នឹង បងសុគុណ?

សុគុណឮហើយ ក៏បែរញញឹមមករកនាងហើយឆ្លើយថា :

- ទៅជិតៗនេះទេអូន... ម៉ោះ! ងើបឡើងរៀបចំខ្លួនទៅណា៎ នឹងអាលទៅ ទាំងអស់គ្នា។

CHANBOKEO.COM

ក្រោយពីរៀបចំខ្លួនហើយ សំនៀងក៏ដើរតាមពីក្រោយសុគុណដែល កំពុងបីកូនសំដៅរថយន្តមួយដែលចតចោលនៅទីធ្លាមុខផ្ទះ។ សំនៀងបែរ មើលជុំវិញខ្លួនហើយក៏លាន់មាត់សួរឡើងថា :

- ចុះឯណាមិនឃើញប៉ាម៉ាក់អញ្ចឹង?

- អូហ៍ លោកអញ្ជើញទៅមុនតាំងពីយប់មិញម្ល៉េះ ពេលនេះមានតែអូននិង បងទេដែលធ្វើដំណើរទៅដល់ក្រោយគេ។

សំនៀងដើរចូលទៅក្នុងរថយន្តទាំងទឹកមុខឆ្ងើងឆ្ងល់បំផុត តែក៏មិន ហ៊ានសួរអ្វីទៀតដែរ គ្រាន់តែរង់ចាំមើលស្ថានការណ៍តទៅទៀតប៉ុណ្ណោះ។ បន្តិចមក រថយន្តក៏បានមកដល់មុខវត្តគរ រួចហើយក៏បន្តដំណើររហូតដល់ ដីចំការរបស់ពិសិដ្ឋ។ សុគុណក៏នាំសំនៀងចុះពីរថយន្តដើរសំដៅទៅផ្ទះនៅ កណ្ដាលចំការដែលអ្នកទាំងពីរធ្លាប់រស់នៅជាមួយគ្នាកាលពីឆ្នាំទៅ។ ភ្លាម នោះ សំនៀងបើកភ្នែកធំៗដោយការភ្ញាក់ផ្អើល ត្បិតនាងបានឃើញគេសង់ រោងផ្កាស្លាមួយយ៉ាងធំនៅពីមុខផ្ទះថែមទាំងមានភ្ញៀវមកជួបជុំយ៉ាងអ៊ូអរ កុះករទៀតផង។ នាងក៏សួរទៅសុគុណថា :

- នេះជាពិធីមង្គលការរបស់ពិសិដ្ឋមែនទេ?...

សុគុណញញឹមឡើង ហើយឆ្លើយថា :

- តោះអូន! ប្រញាប់ចូលទៅក្នុងផ្ទះណា៎ ចាស់ៗកំពុងរង់ចាំអូនហើយ។

រំពេចនោះ ស្រាប់តែអ្នកទាំងពីរឮសំលេងស្រួយស្រែសមួយស្រែកពី ចម្ងាយមកថា :

- បងសុគុណ!...

សំនៀងងាកទៅឃើញនារីសោភាមួយរូប ក្នុងសម្លៀកខ្មែរបុរាណ របៀបជាកូនក្រមុំឬក៏ជាកូនកំដរកូនក្រមុំដើរចូលមកដល់។ រីសុគុណវិញ កាលបើក្រលេកឃើញនាងភ្លាម ក៏លាន់មាត់ឡើង :

- ដារិនី?... អូនក៏មកដល់ទីនេះដែរ?

គ្រាន់តែយល់វត្តមានរបស់ដារិនីភ្លាម ស្រាប់តែសំនៀងថ្លោះទឹកមុខ ភ្លាមមួយរំពេច។ នាងជ្រួញចិញ្ចើមសំលឹងទៅសុគុណហើយស្រដីថា :

- បងកំពុងធ្វើអី គិតអីហ្នឹង? សំនៀងមិនចូលចិត្តធ្វើជាតួតុក្កតាអោយបង យកមកលេងសើចទេ...

ថាហើយ នាងក៏បីកូនរឹងដើរថយក្រោយសំដៅទៅមាត់ផ្លូវវិញយ៉ាង រហ័សបំផុត ធ្វើអោយសុគុណភ្ញាក់ព្រើត កាលបើឃើញកិរិយារបស់ សំនៀងដូច្នោះ។ គេក៏ស្ទុះរឹងទៅឃាត់នាងភ្លាម :

- សំនៀង..! ទៅណាហ្នឹងអូន! កុំទាន់មានចិត្តហួហួងអីណា៎។ យើងចូល ទៅក្នុងជួបចាស់ទុំសិនទៅ.. បានទេ?

សំនៀងសំលឹងមុខសុគុណ ហើយតបថា :

- ជួបដើម្បីអ្វី? ដើម្បីអោយសំនៀងទទួលការអាមាសដែលបងកំពុងរៀប ការគូថ្មីនោះមែនទេ?

CHANBOKEO.COM

- អត់ទេ! ខុសហើយអូន... ដារិទីធ្លាប់ជាគូដណ្ដឹងរបស់បងនាគ្រាមួយនោះ ពិតមែន ប៉ុន្តែពេលនេះ អ្វីៗរវាងបងនិងគេ ក៏បានក្លាយជាអតិតកាលទៅ ហើយ ។ គឺសំនៀងនិងកូនទេតើហ៎ដែលជាបច្ចុប្បន្នរបស់បង...ស្ដាប់បងណា៎ អូន.. យើងឡើងទៅលើផ្ទះសិនទៅណា៎...

គ្រាន់តែឮវាចានេះពេលណា ដារិទីដែលកំពុងឈរនៅខាងក្រោយខ្នង សុគុណនោះស្រក់ទឹកភ្នែកច្រោកតែម្ដង រួចហើយក៏លួចលើកដៃផ្ដិតទឹក ភ្នែកស្ងាត់ៗ ។ រីសំនៀងវិញក៏ឈរញញោកមុខមិនស្រដី ។ បន្តិចមក ដារិទីក៏ ដើរមកជិតសំនៀងដែលកំពុងបីកូននៅក្នុងដៃ ហើយក៏វាចាទៅធិតាយើង យ៉ាងសុភាពថា :

- អោយខ្ញុំសូមជួយត្រេកអរផង ដែលនាងបានក្លាយជាបុគ្គលសំខាន់ក្នុង ជីវិតរបស់បងសុគុណ ។ ការពិត នាងគឺជាមនុស្សល្អបំផុត ព្រោះនាងហ៊ាន ពលីជីវិតខ្លួនដើម្បីស្នេហា ដែលដារិទីមិនអាចប្រៀបធៀបបាន.. ពេលនេះ សូមនាងឈប់មានអារិចិត្តនឹងបងសុគុណទៀតទៅ ព្រោះគាត់បានលប់រូប របស់ដារិទីចោលពីបេះដូងរបស់គាត់តាំងពីយូរមកហើយ គឺតាំងពីគាត់បាន មកជួបនាងដំបូងនៅទីនេះម្ល៉េះ ។ ពេលនេះ នាងគួរតែមានមោទនភាពវិញ ហើយដែលនាងបានក្លាយជាតួឯកនៅក្នុងដួងចិត្តរបស់បងសុគុណតែម្នាក់...ម្យ៉ាងទៀត មើលទៅនាងក៏បីទារកតូចនេះយូរហើយ ប្រហែលជាគាំងដៃ ហើយទេដឹង...លួមទុកវេនអោយបងសុគុណបីម្ដងទៅ ដើម្បីឱ្យគាត់ចែក រំលែកកិច្ចការគ្រួសារពីនាងខ្លះៗ ។ នាងគិតមើលថាខ្ញុំនិយាយត្រូវទេហ៎?

ថាហើយ ដារិទីក៏លូកដៃត្រកងទារកតូចពីដៃសំនៀង ហើយក៏ហុច ទៅអោយសុគុណភ្លាមថែមទាំងស្រដីថា :

- សូមបងធ្វើជាស្វាមីដ៏ល្អនិងជាឪពុកដ៏ល្អផងណា៎ យ៉ាងណាកុំអោយក្រុម គ្រួសារយើងបាក់មុខមាត់ដោយសាររូបបងអោយសោះ ។

ទាំងសុគុណ ទាំងសំនៀង ធ្វើមុខភាំងទាំងពីរនាក់ ត្បិតនឹកចំលែកចិត្ត នឹងកិរិយារបស់ដារិទីជាខ្លាំង ។ ភ្លាមនោះ សុគុណក៏លាតដៃត្រកងយក ទារកតូចពីដៃដារិទីមកវិញ ហើយក៏ស្រដីថា :

- អរគុណណាស់ដារិទី! បងប្រាកដជាមិនអោយនរណាម្នាក់ក្នុងគ្រួសារ ត្រូវខ្មាក់ចិត្តដោយសារបងតទៅទៀតឡើយ ។

សុគុណស្រដីផង លួចសំលឹងមុខសំនៀងផង ហាក់បីដូចជាមានបំណង អោយនាងយល់ចិត្តនាយជាងមុន ។ ព្រមពេលជាមួយគ្នានោះ ចាស់ទុំ និងសាច់ញាតិរបស់សុគុណនិងដារិទី ក៏មានវត្តមានឡើងនៅជុំវិញគេទាំង ពីរយ៉ាងកុះករ ប្រកបដោយទឹកមុខរីករាយបំព្រង ។

បន្តិចក្រោយមក សុគុណបានឈរនៅមុខកាំជណ្ដើរផ្ទះដោយមានកាន់ ផ្កាស្លានិងការហែហមពីចាស់ទុំនិងញាតិសន្តានមិត្តភក្តិជាច្រើនទៀត ។ រីឯ សំនៀងរបស់យើងក៏បានចុះកាំជណ្ដើរមកដល់ទីនោះដែរ ។ កាលបើឃើញ ធិតាយើងក្នុងសម្លៀកមង្គលការយ៉ាងស្រស់ស្អាត សុគុណសំលឹងនាងសឹង តែភ្លឹកស្មារតី រួចហើយក៏ឧទានឡើងថា :

- ម្សិលមិញ បងបានសន្យានឹងអូនថានឹងប្រគល់របស់អនុស្សាវរីយ៍ដ៏មាន តម្លៃបំផុតក្នុងជីវិតរបស់បងជូនចំពោះអូន ។ ថ្ងៃនេះ បងយករបស់នេះមក ប្រគល់ជូនអូនដោយផ្ទាល់ដៃហើយ ដោយមានលោកចាស់ទុំមេបាហែហម ជាកសិណសាក្សីចំពោះការបំពេញពាក្យសន្យារបស់បង... នោះគឺជាផ្កាស្លា មង្គល

ដែលបងបានត្រៀមជូនអូនដោយដួងចិត្តស្នេហាយ៉ាងស្មោះស្ម័គ្រ ភក្តីនិងបរិសុទ្ធបំផុត... សូមអូនទទួលយកផងណា កំពូលដួងចិត្តរបស់បង..

សំនៀងរលីងរលោងទឹកភ្នែកមួយរំពេចកាលបើឃើញសុគុណប្រព្រឹត្ត តាមពាក្យសន្យារបស់គេមែន ។ មាណវីលេបទឹកមាត់ផ្អើមបំពង់កបន្តិច រួចក៏វាចាតបទៅបុរសយើងវិញដោយបេះដូងរំភើបញាប់ញ័រថា :

- នេះជាកត្តិយសដ៏ធំធេងបំផុតដែលសំនៀងបានទទួលផ្កាស្លាពីបង ។ អូន សូមទទួលយកដោយក្តីពេញចិត្តបំផុត! អរគុណណាស់ បងសុគុណ!

ថាហើយនាងក៏លូកដៃទទួលយកផ្កាស្លាពីបុរសកំពូលដួងចិត្តរបស់នាង ទាំងហប្ញទ័យរំជើបរំជួលក្រៃលែង ។ សូរសៀងឃ្មោះការក៏បន្លឺឡើងរន្ទើន អមដោយសំលេងបាយខុនចងដៃដ៏រំពងថែមទៀត បានធ្វើឱ្យផ្អើលអស់អ្នក ស្រុកជិតខាងទាំងឡាយអោយមកចោមរោមអបអរសាទរ យ៉ាងកកកុញ ក្រៃលែង ។ នោះជាលើកទីមួយក្នុងជីវិតហើយ ដែលសំនៀងមានអារម្មណ៍ ថានាងមានសេចក្តីសុខយ៉ាងពេញលេញបំផុតដែលនាងមិនដែលប្រទះតាំង ពីក្មេងវ័យមក ។ ចំពោះសុគុណវិញ វេលានោះគឺជាការអបអរសាទរចំពោះ ជីវិតថ្មីរបស់នាយ ដែលប្រកបដោយសុភមង្គល និងការកក់ក្តៅក្នុងចិត្តឥត ឧបមា ត្បិតនាយមានទាំងកូននិងប្រពន្ធអមខ្លួនទាំងសងខាងព្រមទាំង ឪពុកម្តាយបងប្អូននិងញាតិសន្តានជុំជិត ។ នេះហើយជាជីវិតដែលសុគុណ បានគេងផ្សងយូរមកហើយ ។ ថ្ងៃនេះ ក្តីស្រម័យរបស់បុរសយើងក៏បាន ក្លាយជាការពិតជាស្ថាពរដែរ ។ ទាំងលោកសុខជ័យនិងភរិយា លោកវរៈ និងវរលក្ខណ៍កូនស្រី ពិសិដ្ឋ ដារិទី តាក្រូច យាយប្រាង អ្នកស្រីសានី ព្រមទាំងញាតិមិត្តជាច្រើនទៀត ក៏មានសេចក្តីសោមនស្សរីករាយបំផុត ដែរ កាលបើគេទាំងអស់មានឱកាសបានចូលខ្លួនមកធ្វើជាសាក្សីនៃចំណង មេត្រីរបស់គូស្នេហ៍មួយគូ ដែលមានចិត្តស្រលាញ់គ្នាយ៉ាងស្ម័គ្រស្មោះប្តូរ ផ្តាច់បំផុត ។

នៅចំពោះមុខព្រះពុទ្ធបដិមារក្នុងព្រះវិហារនៅវត្តគរ...

សុគុណនិងសំនៀងឱនប្រណម្យក្រាបថ្វាយបង្គំ ក្បាលដល់កម្រាល ។ បន្តិចមក គេក៏បីកូនដើរសំដៅទៅពោធិព្រឹក្សមួយដើមដ៏ត្រឈឹងត្រឈៃ ។ នៅទីនោះ សុគុណក៏បានបង្ហាញជើងដាក់ជើងធូបមួយនៅគល់ពោធិព្រឹក្ស ដល់ភរិយា ហើយក៏ស្រដីថា :

- អូនសង្កេតជើងមួយនេះមើល៍ ថាមានអ្វីចំលែកខុសធម្មតាទេ?

សំនៀងឈ្ងោកមើលទៅជិតជើង ដែលមានកណ្តាប់ជើងធូបស្រោក់គ្នា យ៉ាងក្រាស់ក្រែល ស្រាប់តែមាណវីប្រទះឃើញចំណារជាអក្សរល្អិត២ នៅ លើជើងធើងដាក់ថា "ដើម្បីសំនៀងតែម្នាក់..." ។ ធិតាអានចប់ក៏បើកភ្នែកធំ២ឡើង រួចឧទានសួរសុគុណថា :

- មានន័យថាយ៉ាងម៉េចទៅហ្នឹង បងសុគុណ?

CHANBOKEO.COM

- គឺនៅគ្រាដែលបងបានធ្វើអោយរូបអូនបែកឃ្លាតទៅ ដោយសារគំនិត និងកិរិយាដ៏អគតិរបស់បង... បងមានវិប្បដិសារីណាស់ ។ ពេលនោះបង ក៏សំរេចចិត្តមករក្សាផ្នួសនៅទីនេះចំនួន៦ខែ ហើយបងតែងតែមកអុជធូប បួងសួងដល់គុណព្រះរតនត្រ័យរាក់ព្រឹកល្ងាច ដើម្បីសូមអោយអូនបានសុខ សប្បាយចាកផុតនូវគ្រោះភ័យនិងការយាយីទាំងឡាយ ។ ដូចអូនឃើញ ស្រាប់ហើយ ចំនួនជើងធូបទាំងឡាយ ដែលដោតនៅក្នុងផើងសក្ការៈនេះ នឹងឆ្លើយប្រាប់អូនសព្វគ្រប់ទាំងអស់ ថាបងបានមកបែបទំបួងសួងដល់ គុណព្រះពុទ្ធអង្គញឹកញាប់ប៉ុណ្ណា ដើម្បីឱ្យលោកតាមថែរក្សារូបអូន...

សំនៀងបែរសំលឹងមើលមុខស្វាមីហើយក៏ញញឹមឡើង :

- ពេលនេះ អូនយល់ចិត្តបងហើយ ថាបងពិតជាបារម្ភចំពោះសំនៀងពិត មែន... អរគុណបងណាស់ ដែលបងរង់ចាំអូន... រហូតដល់គ្រាដែលយើង ទាំងពីរបានវិលមកជួបគ្នាវិញសាថ្មី...

ភ្លាមនោះ សុគុណក៏ដូរប្រយោគថា :

- សំនៀង! អូនដឹងទេ... ថាយើងឥលូវនេះ មានជីវិតតែមួយ?

ឮដូច្នោះ សំនៀងក៏ញញឹមឡើង ហើយឆ្លើយតបទៅវិញថា :

- រឿងហ្នឹង សំនៀងដឹងតាំងតែពីឆ្នាំទៅម្ល៉េះណាំបង!

- មែនហ្អែស? ម៉េចក៏ដឹងកើតថា យើងនឹងវិលមកជួបគ្នាសាងផ្លូវជីវិតតែ មួយនោះ?

សំនៀងសើចខឹក១យ៉ាងរីករាយ :

- គឺអូនបានបូជាជីវិតពាក់កណ្តាលជូនបងនោះអី ហើយពាក់កណ្តាលទៀត អូនរក្សាទុកខ្លួនឯងណា ។ ឥលូវ ពាក់កណ្តាលទាំងពីរភាគនោះបានវិលមក ជួបគ្នាវិញហើយ នោះមិនក្លាយជាជីវិតមួយវិញហើយទេហ៎?

កាលបើស្តាប់ប្រយោគនេះចប់ សុគុណក៏ពោលឡើងភ្លាមដែរ :

- បងស្មានតែអូនភ្លេចរឿងហ្នឹងហើយតើហ៎...

- មិនភ្លេចទេ.. មួយជីវិត សំនៀងនឹងចងចាំរហូត...

- ចាំដល់ជាតិក្រោយទេអូន?

- ឱ្យតែព្រះប្រទាននូវបំណន់នោះ សំនៀងស្ម័គ្រចាំបងជានិច្ចរហូតទៅ!

- អរគុណអូនណាស់ សំនៀងមាសបង... បងពិតជាមិនខកចិត្តទេដែលបង ជ្រើសរើសរូបអូនជាគូជីវិត...

រំពេចនោះ ទារកតូចក៏យំង៉ាឡើង ។ សំនៀងលើកកូនឡើងថ្នាក់ថ្នម បបោសមិនអោយគេយំតទៅទៀត ។ បន្តិចមក ទារកតូចក៏ឈប់យំទៅ ។ មាណេវីក៏លើកកូនឡើងហុចទៅអោយសុគុណបី ព្រមទាំងស្រដីថា :

- គេនេះជាសាច់ឈាមរបស់បងពិត១ហើយ មិនមែនជាកូនអ្នកដទៃណា ទៀតទេ សូមបងទទួលយកគេដោយសេចក្តីស្រលាញ់ផងណាំ!

សុគុណឮហើយ ក៏លើកដៃទទួលយកកូនប្រុសទាំងទឹកមុខញញឹម យ៉ាងស្រស់បំព្រងតែម្តង :

CHANBOKEO.COM

- បងដឹងជាយូរមកហើយ... ថាគេជាសាច់ឈាមរបស់បង!!

- ហេតុដូចម្តេចក៏បងដឹងកើត បើ...

ស្រាប់តែសុគុណយកដៃខ្ទប់មាត់ធិតាមិនអោយស្រដីតទៅទៀត រួច ហើយក៏អោនខ្សិបដាក់ត្រចៀកនាងតិចៗថា :

- គឺបងលួចគុណលេខ រាប់ខែរាប់ថ្ងៃនោះអី...

សំនៀងសំលឹងមុខសុគុណធ្វើខ្នក់ខ្នាញ់ ហើយឧទានថា :

- ពុទ្ធោ! បងដឹងមុនអញ្ចឹង សំនៀងលលេងបាត់សប្បាយអស់...

សុគុណក៏សើចខឹកៗឡើង ដាក់កិរិយារបស់ខ្លួនយ៉ាងរីករាយ សំដែង នូវសេចក្តីស្រលាញ់និងដួងចិត្តត្រេកត្រអាល ចំពោះសុភមង្គលថ្មីរបស់គេ។ ភ្លាមនោះ ទាំងពីរនាក់ក៏ស្រវាកាន់ដៃគ្នាឡើង បែរសម្លឹងទៅកំពូលព្រះ វិហារ រួចហើយបែរញញឹមដាក់គ្នាសាជាថ្មី ដើម្បីទទួលនូវពរជ័យប្រសព្រំ យ៉ាងសុខដុមរមនាពីបារមីសក្តិសិទ្ធិនៃព្រះអង្គវត្តគរដែលលោកបានប្រទាន ពរមកគេទាំងពីរព្រមទាំងទារកតូចនៅក្នុងរង្វង់ដៃរបស់សំនៀងផងនូវខ្លឹម រសជាតិសុភមង្គលយ៉ាងត្រកាលបំផុត...

**ចប់**

CHANBOKEO . COM

# វាចាចុងក្រោយ

- ការស្រលាញ់ខ្លាំងតែងតែនាំអោយយើងខ្វះសតិ រួចកើតក្តីសង្ស័យ ដោយមិនដឹងខ្លួន។ នោះក៏អាចជាប្រភពនៃការប្រេះឆាក្នុងគ្រួសារបានដែរ កាលបើគូស្រករមានចិត្តសង្ស័យ ចំពោះគ្នាដោយឥតហេតុផលជាក់លាក់ ហើយមិនព្រមពិគ្រោះគ្នាដោយសមរម្យ។
- នៅនាទីចុងក្រោយនៃជីវិត.. អ្នកជំងឺតែងតែដង្ហោយរកកំលាំងចិត្តជានិច្ច ហើយ កំលាំងចិត្ត នោះឯងច្រើនតែក្លាយជាឱសថដ៏មានប្រសិទ្ធិភាពជានិច្ច លើសពីថ្នាំសង្កូវទាំងឡាយ ដែល លោកគ្រូពេទ្យផ្តល់អោយ។
- ជីវិតរបស់នារី មិនមែនដូចផ្កាដែលរោយទៅហើយមិនអាចរីកវិញនោះទេ។ ជីវិតមនុស្ស តែងតែមានឱកាសរីកស្រស់ត្រកាលមានរស្មីសាជាថ្មីមកវិញជានិច្ច បើសិនជាយើងប្រឹង ព្យាយាមផ្តល់ឱកាសថ្មីដល់ខ្លួនឯង។ ចូរកុំបំបិទផ្លូវដង្ហើមជីវិតរបស់ខ្លួនយើងអោយសោះ។
- មានជីវិត ត្រូវតែមានសង្ឃឹម! សេចក្តីសង្ឃឹមនឹងជួយអោយយើងប្រឹងតស៊ូរហូតដល់យើង បានប្រទះរស្មីជោគជ័យនៅថ្ងៃណាមួយ។ ចូរកុំលះបង់ក្តីសង្ឃឹមសំរាប់ខ្លួនយើង ជីវិតយើង សោះឡើយ។ ចូរសាងសេចក្តីសង្ឃឹមឡើង ទោះបីជាតិចតួចក៏ដោយ!
- ការធ្វើអត្តឃាតមិនមែនជាការដោះស្រាយបញ្ហាទេ។ វាគ្រាន់តែជាមធ្យោបាយទាល់ច្រក ប៉ុណ្ណោះ។ សូមគិតអំពីអារម្មណ៍នៃសមាជិកគ្រួសារទាំងឡាយជុំវិញខ្លួន ដែលតែងតែ ស្រលាញ់ហើយបារម្ភចំពោះរូបអ្នកជានិច្ច។ បើអ្នកស្លាប់ទៅ អ្នកដែលរស់នៅទេ ដែលត្រូវរង ទុក្ខវេទនាដោយសារតែទង្វើរបស់យើង។
- រីឯអ្នកដែលគេចខ្លួនទៅស្លាប់ គឺជាអ្នកដែលខ្វះទឹកចិត្តរឹងប៉ឹង សំរាប់ទទួលខុសត្រូវជីវិត របស់ខ្លួននិងក្រុមគ្រួសារ។ ចូរកុំទន់ខ្សោយរហូតហ៊ានធ្វើអត្តឃាតអោយសោះ។ ជីវិតមាន តម្លៃណាស់ សូមថែរក្សាអោយបានល្អហើយរស់នៅអោយ បានយូរអង្វែងដោយសុខសប្បាយ

អ្នកស្រីកែវចន្ទ័បូរណ៍

អ្នកនិពន្ធ

តារាយរាយឈ្មោះកំណាព្យ កំរងកែវ និង ទំនុកចំរៀង

ដែលនិពន្ធឡើងដោយអ្នកស្រីកែវចន្ទ័បូរណ៍


| | | |
|---|---|---|
| ១. | ចិញ្ចៀនបញ្ចាំចិត្ត | ទំព័រ ៩ |
| ២. | ស្ថានស្នេហ៍មនោរម្យ | ទំព័រ ១៥ |
| ៣. | លាហើយស្នេហ៍ | ទំព័រ ២៥ |
| ៤. | ទេវីកំពូលដួងចិត្ត | ទំព័រ ៣៨ |
| ៥. | ជំនោរមេសា | ទំព័រ ៤៤ |
| ៦. | បំពេរក្សេមក្សាន្ត | ទំព័រ ៤៧ |
| ៧. | សំនៀងដួងចិត្ត | ទំព័រ ៥៧ |
| ៨. | សុភមង្គល | ទំព័រ ៦៤ |
| ៩. | ក្លិនស្នេហ៍ | ទំព័រ ៨០ |
| ១០. | ស្តាយ | ទំព័រ ៨៨ |
| ១១. | ទំហំស្នេហ៍ | ទំព័រ ៩០ |
| ១២. | បើសិនជាមានថ្ងៃស្អែក | ទំព័រ ៩៦ |
| ១៣ | ឱរាព្រាត់បេះដូង | ទំព័រ ១០០ |
| ១៤. | នឹក | ទំព័រ ១០៥ |


CHANBOKEO . COM

១៥ វិលវិញណាអូន ទំព័រ ១១៣
១៦. វិប្បដិសារី ទំព័រ ១២២
១៧. បាត់ស្នេហ៍ ទំព័រ ១៣២
១៨. បំណន់ ទំព័រ ១៣៨
១៩. នឹកគ្មានរសាយ ទំព័រ ១៥០
២០. អរគុណ ទំព័រ ១៦៦
២១. ពពកបាំងចន្ទ័ ទំព័រ ១៧៥
២២. មិនធ្វើអត្តឃាតដាច់ខាត ទំព័រ ១៨១


CHANBOKEO . COM